# មីក្រូហិរញ្ញវត្ថុ ក្នុងសម័យកូវីដ ១៩

## កិច្ចគាំពារអតិថិជន និងដំណើរការរៀបចំឥណទានឡើងវិញ នៅក្នុងប្រទេសកម្ពុជា





Australian Aid

PONLOK CHOMNES

The Asia Foundation


រេះ ផាស៊ី


យន្តការគាំពារ
បំណុល
អនាគត
ស្ពានភាពសេដ្ឋកិច្ចគ្រួសារ

# មីក្រូហិរញ្ញវត្ថុ ក្នុងសម័យកូវីដ ១៩

## កិច្ចគាំពារអតិថិជន និងដំណើរការរៀបចំឥណទានឡើងវិញ នៅក្នុងប្រទេសកម្ពុជា

**រេះ ផាស៊ី**

មិថុនា ២០២១

មីក្រូហិរញ្ញវត្ថុ ក្នុងពេលមានជម្ងឺរាតត្បាតកូវីដ-១៩

© រក្សាសិទ្ធិ របស់អ្នកនិពន្ធ (បើកឲ្យប្រើជាសាធារណៈ) ខែមិថុនា ឆ្នាំ២០២១

គំនូរនៅលើក្រប និង រចនាអត្ថបទ ដោយ៖ ជីគ្រីអេតទីវ (Gcreatives)

សារអេឡិចត្រូនិច៖ gcreatives.solution@gmail.com

**សេចក្តីប្រកាសអំពីការទទួលខុសត្រូវលើខ្លឹមសារ៖** ក្នុងរបាយការណ៍នេះ ទស្សនៈទាំងអស់ដែលបានលើកឡើង គឺជារបស់ប្រធានក្រុមស្រាវជ្រាវតែម្នាក់ ហើយមិនមែនជាទស្សនៈរបស់ រដ្ឋាភិបាលអូស្ត្រាលី អង្គការមូលនិធិអាស៊ី មជ្ឈមណ្ឌលខេមរសិក្សា ឬ បុគ្គលផ្សេងទៀតដែលបានចូលរួមក្នុងការស្រាវជ្រាវនេះទេ។

# មាតិកា


បុព្វកថា 9

សេចក្តីថ្លែងអំណរគុណ 17

អ្នកចូលរួមក្នុងការស្រាវជ្រាវ 18

បញ្ជីពាក្យកាត់ 19

សេចក្តីសង្ខេប 20

I. សេចក្តីផ្តើម 26

II. សាវតារ 28

III. វិធីសាស្ត្រ 33

១. វិធីសាស្ត្រស្រាវជ្រាវ 33

២. ទីតាំងស្រាវជ្រាវ 34

៣. ការប្រមូល និងការវិភាគទិន្នន័យ 35

IV. របកគំហើញ 38

ផ្នែកទី ១. ផលប៉ះពាល់សេដ្ឋកិច្ច និងសង្គមនៃកូវីដ ១៩ មកលើកូនបំណុល 38

១.១. ការផលិតសម្លៀកបំពាក់ 38

១.២. ទេសចរណ៍ 41

១.៣. កម្មករចំណាកស្រុកក្រៅប្រទេស 44

១.៤. កសិករដាំស្រូវ/ពោត/ដំឡូងមី 48

១.៥. ភាពងាយរងគ្រោះក្នុងជីវភាពរស់នៅពាក់ព័ន្ធនឹងវិស័យនីមួយៗ មុនកូវីដ ១៩ 54

ផ្នែកទី ២. ការកែប្រែមុខរបរទប់ទល់ទៅនឹងការធ្លាក់ចុះប្រាក់ចំណូល 54

២.១. ការកែប្រែជីវភាព : វិធីប្រើដោយគ្រួសារដែលមានមុខរបរច្រើនមុខ 55

២.២. មុខរបរថ្មី ៖ ការឆ្លើយតបដោយគ្រួសារដែលមានប្រាក់ចំណូលតែមួយមុខ 56

ផ្នែកទី ៣. វិធីសងបំណុលរបស់គ្រួសារដែលរងសម្ពាធបំណុល 59

៣.១. ការកាត់បន្ថយម្ហូបអាហារនៅក្នុងគ្រួសារ និងការចាយវាយប្រាក់សន្សំ 61

៣.២. ការបង្វិលលុយ 62

៣.៣. វិធីចុងក្រោយ 63

ផ្នែកទី ៤. ការឆ្លើយតបរបស់គ្រឹះស្ថានហិរញ្ញវត្ថុចំពោះវិបត្តិកូវីដ ១៩ 65

៤.១. យន្តការនានាមុនកូវីដ ១៩ 65

៤.២. យន្តការនានាក្នុងអំឡុង កូវីដ ១៩ 66

៤.៣. ដំណើរការរៀបចំតំណទានឡើងវិញ 68
៤.៤. ការរៀបចំតំណទានឡើងវិញក្នុងចំណោមអ្នកផ្តល់កិច្ចសម្ភាសរបស់យើង 71
ផ្នែកទី ៥. កាលានុវត្តភាព ការអនុវត្តនៅមានកម្រិត និងបញ្ហាប្រឈមក្នុងការរៀបចំតំណទានឡើងវិញ 73
៥.១. ទស្សនៈរបស់កូនបំណុលចំពោះការទទួលបាននូវការរៀបចំតំណទានឡើងវិញ 73
៥.២. ការចុះផ្សព្វផ្សាយនៅមានកម្រិត 75
៥.៣. គ្រួសារទាំងឡាយដែលបានប៉ះពាល់ ហើយមិនទទួលបានការរៀបចំតំណទានឡើងវិញ 76
៥.៤. ភាពមិនច្បាស់លាស់នៃផលវិបាករបស់ការរៀបចំតំណទានឡើងវិញទៅលើប្រវត្តិតំណទាន 81
**V. វិធីសាស្ត្រឆ្លើយតបដែលភាគីផ្សេងៗអាចយកទៅអនុវត្តបាន** 82
ឧបសម្ព័ន្ធ១. បញ្ជីអ្នកផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ 87
ឧបសម្ព័ន្ធ២. គន្ថនិទ្ទេស 89

# បញ្ជីគំនូសតាង រូបថត និងតារាង

## គំនូសតាង


គំនូសតាង ១: កំណើន និងការព្យាករ ផ.ស.ស 25

គំនូសតាង ២: ខ្សែកោងប្រាក់កម្ចីមធ្យមនៃគ្រួសារ 31

គំនូសតាង ៣: ផែនទីទីតាំងស្រាវជ្រាវ 35

គំនូសតាង ៤: ការបាត់បង់ប្រាក់ចំណូលក្នុងវិស័យផលិតសម្លៀកបំពាក់ និងកាត់ដេរ 40

គំនូសតាង ៥: វដ្តឥណទានរបស់ បុប្ផា ក្នុងគ្រឹះស្ថានហិរញ្ញវត្ថុតែមួយ 50

គំនូសតាង ៦: ប្រតិទិនដាំស្រូវ/ពោត/ដំឡូងមី នៅកម្ពុជា 51


## រូបថត


រូបថត ១: កំពុងសម្អាសនៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឆ្នាំ២០២០ 37

រូបថត ២: កំពុងចម្លង សាទ្បាង ខេត្តកំពង់ឆ្នាំង ឆ្នាំ២០២០ 37

រូបថត ៣: ផ្លូវដាប់ស្ទើត (ខាងលើ) ផ្លូវក្នុងផ្សារ (ខាងក្រោម) ក្រុងសៀមរាប ខេត្តសៀមរាប ឆ្នាំ២០២០ 42

រូបថត ៤. ឯកសារចំណាកស្រុកប្រចាំរដូវ - ប័ណ្ណព្រំដែនពណ៌ខៀវ និងប័ណ្ណចេញចូលព្រំដែនប្រចាំថ្ងៃ - ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឆ្នាំ២០២០ 46

រូបថត ៥: យុវជនមួយក្រុមកំពុងរកចាប់ត្រីនាពេលទឹកជំនន់ក្នុងស្រុកបវេល ខេត្តបាត់ដំបង ឆ្នាំ២០២០ 49

រូបថត ៦: កំពុងកាប់ដំឡូងមី ដែលប្រមូលមុនរដូវ នៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឆ្នាំ២០២០ 52

រូបថត ៧: ដំណាំស្រូវ ដំឡូងមី ពោត សណ្តែកបាយ ខេត្ត កំពង់ឆ្នាំង និង បាត់ដំបង ឆ្នាំ២០២០ 53

រូបថត ៨: ខ្យងដែលគ្រួសារចំណាកស្រុករើសមកពីព្រៃ នៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឆ្នាំ២០២០ 57

រូបថត ៩: អក្សរខ្មែរសរសេរថា "អ្វីទៅជាការរៀបចំឥណទានឡើងវិញ?" យកមកពីហ្វេសប៊ុក ខែមិថុនា ឆ្នាំ២០២០ 66


## តារាង


តារាង ១: ការបាត់បង់ប្រាក់ចំណូលក្នុងវិស័យទេសចរណ៍ 43

តារាង ២: វិធីសងបំណុលទូទៅ ចំពោះគ្រួសាររងសម្ពាធបំណុល 60

តារាង ៣: យន្តការនានាសម្រាប់គ្រួសាររងសម្ពាធបំណុល 65

តារាង ៤: ការរៀបចំឥណទានឡើងវិញក្នុងតំណាងគ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗ 70

# បុព្វកថា

**ដោយ លោក ង៉ោ ណត្ថារុន**

នៅកម្ពុជានាបច្ចុប្បន្នការធ្លាក់ចុះសេដ្ឋកិច្ចដោយសារជំងឺរាតត្បាតកូវីដ ១៩ ដែលមានទូទាំងពិភពលោកដែរនោះ បានផ្តល់ឱកាសឲ្យអ្នកនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុកែប្រែវិធីអនុវត្តធុរកិច្ចរបស់ខ្លួន ហើយផ្តោតលើបេសកកម្មសង្គម ដែលជាស្នូលនៃវិស័យនេះតាំងពីដំបូងមក។

ក្នុងដំណាក់កាលដំបូងនៃការប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងវិសមភាពសេដ្ឋកិច្ច អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានា (NGOs) បានរួមគ្នាផ្តល់មូលនិធិដល់កម្មវិធីទាំងឡាយ ដែលមានទិសដៅបង្កើនបរិយាបណ្ណហិរញ្ញវត្ថុនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ ក្រោយមកកម្មវិធីទាំងនេះបានក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (គ.ម.ហ) ជាលើកដំបូង។ ខណៈដែលឥណទានឥតសំណង និងការឧបត្ថម្ភធនដំបូងៗពីម្ចាស់ជំនួយ បានកាត់បន្ថយ គ.ម.ហ ក៏ចាប់ផ្តើមក្លាយខ្លួនទៅជាទម្រង់ថ្មីមួយ ដែលដឹកនាំដោយវិស័យឯកជន។ ទោះជាយ៉ាងណាក៏ដោយ ការពឹងផ្អែកដំបូងៗទៅលើទុនឯកជន មិនបានលុបបំបាត់ភ្លាមៗនូវបេសកកម្មសង្គមរបស់ គ.ម.ហ ឡើយ ដែលអាចចាត់ទុកថា គ្រឹះស្ថានទាំងនោះគឺជាសហគ្រាសគាំពារសង្គមកម្ពុជាជំនាន់ទីមួយ។ ក្នុងដំណាក់កាលដែលកម្ពុជាមានស្ថិរភាពនយោបាយ និងអភិវឌ្ឍន៍សេដ្ឋកិច្ច - ដូចជាបានកាត់បន្ថយភាពក្រីក្រ បង្កើនអត្រាផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ក្នុងម្នាក់ៗ និងបានធ្វើឲ្យមានការកើនឡើងនៃគ្រួសារដែលមានជីវភាពមធ្យម - គ.ម.ហ ដែលសកម្មនៅក្នុងប្រទេសបានមើលឃើញឱកាសក្នុងការពង្រីកទីផ្សារ ដោយការបើកទទួលយកទុន និងរបៀបសម្រេចចិត្តពីមូលនិធិវិនិយោគអន្តរជាតិ និងក្រុមហ៊ុនបណ្តាក់ទុននានា។

វិនិយោគិនអន្តរជាតិដែលខាតបង់ដោយសារវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨ ហើយបន្តបារម្ភពីការធ្លាក់ចុះប្រាក់ចំណេញនៅក្នុងបណ្តាប្រទេសជឿនលឿន បានមើលឃើញកម្ពុជា (និងជាទូទៅតំបន់អាស៊ីអាគ្នេយ៍) ជាឱកាសទីផ្សារថ្មីមួយក្នុងការវិនិយោគ។ ដោយសារកំណើនសេដ្ឋកិច្ចខ្លាំងក្លាជាប់លាប់នៅកម្ពុជា វិនិយោគិនទាំងនោះបានជឿជាក់ថា ការវិនិយោគនៅកម្ពុជាមានសក្តានុពលដែលអាចទទួលបានប្រាក់ចំណេញខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ការដែលពួកគេឈានជើងចូលក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា បានធ្វើឲ្យប្រែប្រួលអាទិភាពទាំងឡាយរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅមូលដ្ឋាន។ ខណៈដែលមានតម្រូវការកាន់តែខ្ពស់ក្នុងការសម្រេចគោលដៅហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ក្រុមហ៊ុនទាំងនេះហាក់ដូចជាចាត់ទុកគោលដៅសង្គមមិនមែនជាអាទិភាពទៅវិញ។ ចុងក្រោយមកចំណុចនេះគឺជាសក្ខីភាពបង្ហាញច្បាស់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាមួយចំនួនបានក្លាយជាធនាគារពាណិជ្ជកម្មធម្មតា។

បន្ទាប់ពី គ.ម.ហ បានដំណើរការជាង២០ឆ្នាំនៅកម្ពុជា យើងយល់ថា វិស័យនេះមានលក្ខណៈចម្រុះ ពោលគឺ យើងមិនអាចដាក់ គ.ម.ហ កម្ពុជាទាំងអស់ទៅក្នុងចង្កោមពាក្យតែមួយបានទេ។ បេសកកម្មសង្គមជាស្នូលនៅតែជំរុញដល់បុគ្គលិក និងថ្នាក់ដឹកនាំនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាតិមួយចំនួន។ បន្ថែមទៅលើការអនុវត្ត និងគោរពតាមបទដ្ឋាន និងក្របខណ្ឌអន្តរជាតិ គ្រឹះស្ថានទាំងនេះក៏បានបញ្ចូលកត្តាសង្គមទៅក្នុងផែនការយុទ្ធសាស្ត្រ និងបានកំណត់ធនធានសម្រាប់ធ្វើការវាយតម្លៃការប៉ះពាល់នៃសកម្មភាពរបស់ពួកគេដល់សង្គម។ ទោះជាយ៉ាងណាក៏ដោយ អាទិភាពចម្បងនៃក្រុមហ៊ុនទាំងនេះ តែងតែបានកំណត់ដោយសមាជិកក្រុមប្រឹក្សាភិបាលជាន់ខ្ពស់ និងវិនិយោគិនអន្តរជាតិដែលផ្តោតសំខាន់ទៅលើសូចនាករស្តីពីការអនុវត្តធុរកិច្ចតាមទម្លាប់ចាស់ ហើយដែលពេលខ្លះគ្របដណ្តប់ទៅលើវិស័យពាណិជ្ជកម្ម និងបណ្តាប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍។ បទពិសោធន៍វិជ្ជាជីវៈ និងចិត្តគំនិតខាងហិរញ្ញវត្ថុរបស់ពួកគេ ទំនងជាមានអាទិភាពសំខាន់ជាងគោលដៅ

អភិវឌ្ឍន៍សង្គម។ កាលណាយើងយល់ពីរបៀបដែលលទ្ធផលខាងហិរញ្ញវត្ថុធ្វើឲ្យថ្នាក់ដឹកនាំ និងវិនិយោគិន គ.ម.ហ សម្រេចដូចម្ដេចនោះ យើងនឹងមិនត្រឹមតែអាចយល់បានពីអនាគតនៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចយល់បានពីរបៀបដែលយើងនឹងអាចជះឥទ្ធិពលទៅលើវិស័យនោះនាអនាគតថែមទៀតផង។

អាស្រ័យហេតុនេះ យើងឃើញថា គ.ម.ហ កម្ពុជាបានងាកខ្លួនចេញពីទស្សនវិស័យមីក្រូហិរញ្ញវត្ថុរបស់ស្ថាបនិកឈ្មោះ **បណ្ឌិត មូហាំមេត យូណូស** ម្ចាស់ពានរង្វាន់ណូបែលសន្តិភាព។ ដោយយល់ថា ធនាគារពាណិជ្ជកម្មទាំងឡាយបានផ្ដោតធនធាន និងចាប់យកឥណទានទ្រង់ទ្រាយធំ មានទ្រព្យធានា ការប្រាក់ខ្ពស់ ភាគច្រើនមកពីអ្នកមានប្រាក់ចំណូលខ្ពស់ និងធម្យមជាចម្បង **បណ្ឌិត យូណូស** បានបង្កើតវិធីសាស្ត្រហិរញ្ញវត្ថុមួយ ដែលមានលក្ខណៈមនុស្សធម៌ និងបរិយាបណ្ណជាងមុន។ ការប្រឹងប្រែងដំបូងរបស់គាត់ខាងវិស័យមីក្រូហិរញ្ញវត្ថុពឹងផ្អែកទៅលើ “ឥណទានខ្នាតតូច” ដែលមិនមានដាក់ទ្រព្យធានា ដែលផ្ដល់ដល់ស្ត្រីដែលមានប្រាក់ចំណូលទាប និងអ្នករស់នៅជនបទដាច់ស្រយាល ដើម្បីកាត់បន្ថយភាពក្រីក្រ និងចូលរួមអភិវឌ្ឍន៍សង្គម។ រយៈពេល២០ឆ្នាំកន្លងទៅហើយ តើ គ.ម.ហ កម្ពុជាសម្រេចបានអ្វីខ្លះទៅតាមទស្សនវិស័យដំបូងនៃការបង្កើតវិស័យនេះ?

## *ការពិនិត្យឡើងវិញនូវការកាត់បន្ថយភាពក្រីក្រ និងបេសកកម្មសង្គមរបស់ គ.ម.ហ*

នាពេលបច្ចុប្បន្នផលិតផលមីក្រូឥណទាន គឺជាសេវាចម្បងដែល គ.ម.ហ កម្ពុជា ផ្ដល់ដល់គ្រួសារមានប្រាក់ចំណូលទាប។ នៅក្នុងទម្រង់បច្ចុប្បន្នមីក្រូឥណទាន បានចុះដល់ប្រជាជនកម្ពុជាជាច្រើន ដែលធ្វើការនៅក្នុងវិស័យក្រៅប្រព័ន្ធ។ ប៉ុន្តែ ប្រសិទ្ធភាពនៃទម្រង់នេះក្នុងការកាត់បន្ថយភាពក្រីក្រគួរត្រូវពិនិត្យឡើងវិញ។ នាពេលបច្ចុប្បន្ន លទ្ធភាពនៃទម្រង់នេះថាអាចកាត់បន្ថយភាពក្រីក្រជាទ្រង់ទ្រាយធំមិនទាន់បង្ហាញបាននៅឡើយទេ។ ការនិយាយបែបនេះ ហាក់ដូចជាមានភាពចម្រូងចម្រាស បើគិតពីវិស័យនេះបានចុះទៅដល់អ្នកដែលត្រូវការជាងគេ ហើយជាពិសេសបើគិតទៅដល់ការរីកលូតលាស់នៃវិស័យមីក្រូហិរញ្ញវត្ថុយ៉ាងឆាប់រហ័សនាពេលកន្លងទៅ។ នៅតែមានសំណួរសំខាន់ៗមួយចំនួន ឧទាហរណ៍ តើផលប័ត្រឥណទានរបស់ក្រុមហ៊ុនទាំងនេះ បានបង្កើតឡើង និងវិវឌ្ឍន៍កន្លងមកដូចម្ដេចខ្លះ? តើកូនបំណុលមានចំណូលទាប នៅតែជាផ្នែកធំនៃផលប័ត្រអតិថិជនរបស់ គ.ម.ហ ឬ? បើដូច្នោះ តើយើងមានលទ្ធភាពវាស់វែងបានត្រឹមត្រូវ ថាតើឥណទានទាំងនេះមានផលជាវិជ្ជមានទៅលើជីវភាពរបស់កូនបំណុលឬទេ? សរុបទៅ ការខ្ចីប្រាក់បាន និងការសងប្រាក់ទាន់ពេល មិនប្រាកដមានន័យថា បានកាត់បន្ថយភាពក្រីក្រ និងពង្រីកឱកាសសម្រាប់បុគ្គល និងគ្រួសារដែលមានប្រាក់ចំណូលទាបនោះទេ។ ប្រសិនបើវិធីសាស្ត្រសេដ្ឋកិច្ចថ្មីមួយសម្រាប់ប្រជាជនកម្ពុជាមានប្រាក់ចំណូលទាប ត្រូវផ្ដល់ឱកាសក្នុងការខ្ចីប្រាក់ ហើយនោះគឺជាគោលដៅចម្បងរបស់ គ.ម.ហ នៃកម្ពុជា ដូច្នេះការស្វែងយល់ថាគោលដៅនេះជាក់ស្ដែងសម្រេចបានកម្រិតណា មានសារៈសំខាន់ក្នុងការព្យាករអនាគតនៃវិស័យនេះ។

បច្ចុប្បន្ននេះមិនមានការស្រាវជ្រាវធំណាមួយ មានភស្តុតាងគ្រប់គ្រាន់ថា ការដែលសេវាហិរញ្ញវត្ថុរបស់ គ.ម.ហ ចុះដល់ប្រជាជនកម្ពុជាមានប្រាក់ចំណូលទាបពិតជាបានបង្កើនប្រាក់ចំណូល ឬបង្កើនសេដ្ឋកិច្ចប្រកបបរិយាបណ្ណកាន់តែប្រសើរនោះទេ។ ការវាយតម្លៃលទ្ធផលជាទ្រង់ទ្រាយធំដោយប្រើវិធីសិក្សាក្រុមសំណាកជ្រើសរើសដោយឥតព្រាងទុក ជាការចាំបាច់ក្នុងការវាស់វែងត្រឹមត្រូវ អំពីផលប្រយោជន៍ខាងសេដ្ឋកិច្ច និងសង្គម ចំពោះការដែលមីក្រូឥណទានបានផ្ដល់ដល់កូនបំណុល។ ការត្រួតពិនិត្យតាមដាន និងការវាស់វែងផលប៉ះពាល់នេះជាពិសេសផលប៉ះពាល់ដល់ផ្នែកសង្គម មិនត្រូវទុកចោលឡើយ។

## *តើទម្រង់មួយថ្មីអាចទៅរួចឬទេ ?*

ទម្រង់ផ្តល់ឥណទានរបស់ គ.ម.ហ ដែលមានស្រាប់ ត្រូវការនវានុវត្តន៍។ បញ្ហាសំខាន់គឺកម្រិតដែល គ.ម.ហ អាចកាត់បន្ថយការចំណាយសម្រាប់ការផ្តល់ហិរញ្ញវត្ថុដល់ជនក្រីក្រជាងគេ (តាមទ្រឹស្តីគឺជាកូនបំណុល ដែលធនាគារត្រូវចំណាយច្រើនដើម្បីឲ្យខ្ចីបាន) បើប្រៀបធៀបទៅនឹងអតិថិជនដែលមានប្រាក់បំណុលខ្ពស់។ តើអាចកាត់បន្ថយកម្លាំងពលកម្មក្នុងការផ្តល់សេវាមីក្រូឥណទានឬទេ ? តើ គ.ម.ហ ធានាប្រាក់ចំណូលយកទប់នឹងចំណាយប្រតិបត្តិការដោយរបៀបណា ក្នុងលក្ខណៈថា ទម្រង់នៃបរិយាបណ្ណហិរញ្ញវត្ថុសម្រាប់ជនក្រីក្រ របស់វិស័យឯកជន នៅតែអាចប្រកួតប្រជែងជាមួយនឹងទម្រង់របស់អង្គការមិនមែនរដ្ឋាភិបាលមិនរកប្រាក់ចំណូល ? តើក្រុមហ៊ុនទាំងនេះអាចធានាដោយរបៀបណាថានឹងបានប្រាក់ចំណេញបានច្រើនឆ្នាំ តាមផែនការរបស់ផ្នែកវិនិយោគមីក្រូហិរញ្ញវត្ថុ ហើយរក្សាបាននូវស្ថិរភាពប្រាក់ចំណូលដល់វិនិយោគិនរបស់ខ្លួនទាំងអស់គ្នាឬទេ ? ការឆ្លើយនឹងសំណួរទាំងនេះនឹងត្រូវពាក់ព័ន្ធដល់ការបង្កើនទុន និងការចំណាយខាងហិរញ្ញវត្ថុដោយសារតួនាទី និងការអនុវត្តធុរកិច្ចនឹងត្រូវបង្កើតឡើងជាថ្មី និងត្រូវបញ្ជ្រាបចូលទៅក្នុងរចនាសម្ព័ន្ធប្រតិបត្តិការដែលក្រុមហ៊ុនមានស្រាប់។ ទង្វើបែបនេះក៏អាចនឹងត្រូវបដិសេធដោយវិនិយោគិន ដែលមិនមើលឃើញពីតម្លៃនៃការកែប្រែនេះ ដោយសារពួកគេប្រហែលនឹងមិនបើកឱកាសចំពោះវិធីរកចំណូលថ្មីនៃធុរកិច្ចដែលពួកគេបានវិនិយោគរួចហើយនោះទេ។ តើនេះមានន័យថា អង្គការក្រៅរដ្ឋាភិបាល ចៀសមិនផុតនឹងត្រូវលូកដៃចូល ក្នុងការផ្តល់នូវសេវាមិនមែនហិរញ្ញវត្ថុមួយចំនួន ដែលចាំបាច់សម្រាប់សម្រេចនូវបេសកកម្មសង្គមរបស់ គ.ម.ហ មែនទេ ?

យើងត្រូវងាកចេញពីផ្នត់គំនិតដែលថា ក្រុមហ៊ុនទាំងនេះ កើតឡើងគឺដើម្បីតែផ្តល់ផលិតផល និងសេវាកម្មផ្សេងៗខាងហិរញ្ញវត្ថុ។ យើងត្រូវយល់ថា ការផ្តល់សេវាមីក្រូឥណទានមានជាប់មកជាមួយនូវការទទួលខុសត្រូវ ខុសពីការលក់ឥណទានសេវាទូរសព្ទដៃ ឬសាប៊ូកក់សក់ទៅឲ្យប្រជាជនដែលងាយរងគ្រោះ។ និយាយសាមញ្ញទៅ ការផ្តល់សេវាមីក្រូហិរញ្ញវត្ថុមាន ទំនួលខុសត្រូវខ្ពស់ជាង។ ពីព្រោះវាមានសក្តានុពលក្នុងការពន្លឿនលទ្ធផលនៃការអភិវឌ្ឍសង្គម ដែលយើងចង់បាន ប៉ុន្តែសេវាមីក្រូហិរញ្ញវត្ថុក៏អាចឲ្យកូនបំណុលមានប្រាក់ចំណូលទាបធ្លាក់ទៅក្នុងអន្ទាក់បំណុលតូចៗ (ដែលកាលណាចំនួនបណុលកើនឡើង នឹងអាចបណ្តាលឲ្យមានវិបត្តសេដ្ឋកិច្ច និងសង្គម)។

វិស័យឯកជននៅកម្ពុជាអាចមើលឃើញតួនាទីរបស់ខ្លួនថាត្រឹមតែជាអ្នកផ្គត់ផ្គង់សេវាមីក្រូហិរញ្ញវត្ថុស្របច្បាប់ ក្នុងទីផ្សារដែលអនុវត្តតាមច្បាប់ ក៏គិតថាខ្លួនឯងមានតួនាទីត្រឹមតែផ្តល់ព័ត៌ឲ្យបានគ្រប់គ្រាន់ដល់ អតិថិជន តាមរយៈបុគ្គលិកឥណទាន អ្នកគ្រប់គ្រង និងបុគ្គលិកផ្នែកលក់ ដោយទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ ក្នុងលក្ខណខ័ណ្ឌនេះ អតិថិជនបានក្លាយជាកូនបំណុលដោយរីករាយ និងដោយស្ម័គ្រចិត្ត។ ពួកគេអាចយល់ថា ខ្លួនឯងក្នុងនាមជាអ្នកលក់ មិនអាចត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះ "ការប្រើប្រាស់កម្ចីខុសទិសដៅ" ដែលបណ្តាលមកពីខ្វះការប្រុងប្រយ័ត្នរបស់អតិថិជននោះឡើយ។ ដូច្នេះ ដំណោះស្រាយចំពោះកូនបំណុលមីក្រូឥណទានកម្ពុជា ដែលបានធ្លាក់ក្នុងវិបត្តិហិរញ្ញវត្ថុនោះ គឺជាបញ្ហាមួយដែលមិនមានចម្លើយងាយស្រួលនោះឡើយ ដោយសារម្នាក់ៗ ទាំងខាងរដ្ឋាភិបាល វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល រួមទាំងកូនបំណុលមិនអាចដោះស្រាយបញ្ហានេះដោយតែម្នាក់ឯងបានឡើយ។

ក្រៅពីការរកប្រាក់ចំណូលឲ្យបានគ្រប់គ្រាន់ជូនម្ចាស់ភាគហ៊ុន និងវិនិយោគិន គ.ម.ហ កម្ពុជាត្រូវសួរខ្លួនឯងថា តើទម្រង់បច្ចុប្បន្នរបស់ខ្លួនពិតជាសម្រេចបានតាមការសន្យាផ្នែកមីក្រូហិរញ្ញវត្ថុឬទេ ថានឹងផ្តល់កាលានុវត្តភាពអភិវឌ្ឍន៍សេដ្ឋកិច្ច និងជួយកូនបំណុលឲ្យផុតពីអន្ទាក់បំណុលដែលធ្វើឲ្យកាន់តែក្រ ? តើទម្រង់បច្ចុប្បន្នរបស់ខ្លួនអាចបញ្ឈប់ ហើយនាំកូនបំណុលកម្ពុជាដើរបញ្ច្រាសទិសបានទេ គឺឲ្យផុតពីទិសដែល

ភាគច្រើននៃជនងាយរងគ្រោះ គឺការបាត់បង់ទ្រព្យធានា ជាពិសេសដីរបស់ពួកគេ ពីព្រោះទិសដៅនេះអាចធ្វើឲ្យជនដែលងាយរងគ្រោះកាន់តែរងគ្រោះជាងពេលណាៗទាំងអស់?

តើ គ.ម.ហ កម្ពុជាអាចបង្កើតធុរកិច្ចមួយ គឺទម្រង់ដែលបំពេញតម្រូវការរបស់ប្រជាជនដែលងាយរងគ្រោះ ហើយមិនបង្កើនហានិភ័យដល់ពួកគាត់? លើសពីបរិយាបណ្ណហិរញ្ញវត្ថុ និងលទ្ធភាពទទួលបានមីក្រូឥណទាននោះ តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគួរមានសេវាដោយផ្ទាល់បានទេ ដូចជាការថែទាំងសុខភាព ការអប់រំ ផ្ទះសមរម្យ និង ទុនសកម្ម? ថ្នាក់ដឹកនាំ គ.ម.ហ កម្ពុជា និងអន្តរជាតិមួយចំនួនតូចជឿជាក់ និងព្យាយាមលើកកម្ពស់បេសកកម្មសង្គមនៃក្រុមហ៊ុនរបស់គេ។ ទោះបីជាពួកគេមិនតំណាងឲ្យភាគច្រើននៃអ្នកនៅក្នុងវិស័យនេះក៏ដោយ ក៏ពួកគេបានយល់ពីការលំបាកក្នុងការផ្តល់សេវាក្នុងទីផ្សារដល់ជនក្រីក្រ ហើយនៅតែប្រកាន់យកនូវតម្លៃនៃការបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដំបូងច្រើនជាងគូប្រកួតប្រជែងរបស់ខ្លួន។ ពួកគេយកចិត្តទុកដាក់ចំពោះសូចនាករពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ដែលសំខាន់ចំពោះការកើនឡើងនៃឥណទានខូច និងផលប័ត្រអតិថិជន ប៉ុន្តែពួកគេក៏ ចុះទៅមូលដ្ឋានជាទៀងទាត់ ជួបជាមួយអតិថិជនដែលក្រីក្រ ហើយព្យាយាមយល់ឲ្យកាន់តែច្បាស់ពីបញ្ហាទាំងឡាយ ដែលអតិថិជនទាំងនោះបានជួប ព្រមទាំងយល់ពីវិធីដែលត្រូវបម្រើអតិថិជនទាំងនោះ។ ពួកគេបានបង្ហាញថា គ.ម.ហ អាចជះឥទ្ធិពលដោយផ្ទាល់ចំពោះអត្រាសង និងសមត្ថភាពក្នុងការកែតម្រូវតារាងសងត្រឡប់ឲ្យត្រូវនឹងលទ្ធិភាពនៃការសងប្រឡប់របស់ជនងាយរងគ្រោះ។ ប្រសិនបើមានសេចក្តីសង្ឃឹមណាមួយថា វិស័យនេះអាចកែលម្អទម្រង់របស់ខ្លួន ហើយស្តារឡើងវិញនូវគោលដៅគាំពារសង្គមក្រោយពេលចប់ជំងឺរាតត្បាតកូវីដ ១៩ សេចក្តីសង្ឃឹមនោះគឺបានមកពីក្រុមហ៊ុនទាំងនេះឯង។

## *ការស្រាវជ្រាវមានតិចតួច និងលទ្ធភាពកើតមានវិបត្តិ*

ការស្រាវជ្រាវនេះមិនបានពិនិត្យទៅលើផ្នែកឥណទានទាំងមូលនៃវិស័យ គ.ម.ហ កម្ពុជាទេ ប៉ុន្តែផ្ទុយមកវិញផ្តោតទៅលើកូនបំណុលទាំងឡាយណាដែលប៉ះពាល់ខ្លាំងជាងគេដោយសារជំងឺរាតត្បាតកូវីដ ១៩។ ការស្រាវជ្រាវនេះមិនបង្ហាញថា ផលប៉ះពាល់នៃជំងឺនោះ កើតមានដូចៗគ្នានៅបណ្តាខេត្តនៃប្រទេសកម្ពុជានោះទេ ហើយក៏មិនអះអាងថា វិស័យមីក្រូហិរញ្ញវត្ថុ ជាភាគីតែមួយដែលទទួលខុសត្រូវក្នុងការកាត់បន្ថយបញ្ហាទាំងឡាយ ដែលជំងឺនេះបានប៉ះពាល់នោះឡើយ។ ផ្ទុយមកវិញ ការស្រាវជ្រាវនេះមានបំណងជំរុញឲ្យមានការវិភាគបន្ថែមទៀតចំពោះបញ្ហាទាំងនេះ ហើយក៏ឲ្យផ្តោតការយកចិត្តទុកដាក់ជាបន្ទាន់ទៅលើការកើនឡើងនៃភាពងាយរងគ្រោះ និងអស្ថិរភាពមុខរបរ ចំពោះជនដែលងាយរងគ្រោះបំផុតនៅប្រទេសកម្ពុជា។ ការសិក្សានេះ ចោទថាតើលទ្ធផលដែលរកឃើញ អាចយកប្រើពន្យល់បានដូចៗគ្នាទេ ចំពោះជនងាយរងគ្រោះទាំងអស់ទូទាំងប្រទេសកម្ពុជា ឬយ៉ាងណា។ ដោយសារជំងឺរាតត្បាតកូវីដ ១៩ នៅមានបន្ត យើងមិនអាចមានពេលគ្រប់គ្រាន់ដើម្បីវាយតម្លៃឲ្យបានច្បាស់លាស់ចំពោះភាពក្រីក្រដែលបានប៉ះពាល់ (ហើយ និងបន្តប៉ះពាល់) ដែលជាផលវិបាកទាំងមូលនៃជំងឺនេះ។ ទោះជាយ៉ាងណាក៏ដោយ ការស្វែងយល់ពីល្បឿនការកើនឡើងនៃភាពក្រីក្រដែលចៀសមិនផុត និងដែលជាអកុសល ក្នុងរយៈពេលខ្លីនិងមធ្យម ជាការចាំបាច់ដើម្បីកំណត់ទំហំនៃផលប៉ះពាល់ដែលជំងឺរាតត្បាតនេះ បានប៉ះពាល់ដល់កិច្ចប្រឹងប្រែងរបស់ប្រទេសកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រកន្លងមក និងដើម្បីព្យាករណ៍រកប្រភេទវិធានការណា ដែលចាំបាច់ក្នុងការធានាកុំឲ្យបាត់បង់នូវវឌ្ឍនភាពពីរទសវត្សរ៍កន្លងមកក្នុងវិស័យនេះ។

ក្នុងការស្រាវជ្រាវនេះយើងឃើញករណីមួយចំនួនតូចដែលជាទីសង្ឃឹម ប៉ុន្តែយើងក៏បានរកឃើញគ្រួសារច្រើនដែលកំពុងត្រដាបត្រដួសក្នុងការសងប្រាក់ឥណទាន។ បញ្ហានេះធ្លាប់បានលើកឡើងរួចហើយក្នុងការស្រាវជ្រាវមួយចំនួនតាំងតែមុនពេលកើតជំងឺរាតត្បាតកូវីដ ១៩ ហើយ

បញ្ហានេះធ្ងន់ធ្ងរឡើងក្នុងប៉ុន្មានខែកន្លងទៅនេះ។ ភាគីទាំងឡាយនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅតែអះអាងថា នឹងមិនមានហានិភ័យនៃវិបត្តិនេះកើនមានឡើងនាពេលឆាប់ៗនេះទេ ប៉ុន្តែអ្នកវិភាគផ្សេងៗបានព្រមានអំពីកំណើនដោយគំហុកនៃសន្ទនិយភាព ស្របពេលជាមួយនឹងកំណើននៃការជាប់បំណុល ដែលបង្ខំឲ្យប្រជាជនកម្ពុជាដែលមានប្រាក់ចំណូលទាបស្រាប់រួចទៅហើយ ត្រូវលក់ទ្រព្យសកម្ម (ពោលគឺដីរបស់ពួកគាត់)។ ប្រការនេះនាំឲ្យយើងមានសំណួរថា៖ តើ គ.ម.ហ បានមើលរំលងឬទេទៅលើសូចនាករសំខាន់ៗ នៅពេលដែលគេវិភាគបញ្ហា? តើខ្លឹមសារដែលគេបកស្រាយសូចនាករមានស្រាប់នោះ (ដូចជាអត្រាផលប័ត្រដែលមានហានិភ័យ) អាចបង្ហាញបានគ្រប់ជ្រុងជ្រោយឬទេ? តើគ្រឹះស្ថាននានាអាចវាយតម្លៃតាមបច្ចេកទេសវិទ្យាសាស្ត្រដោយរបៀបណាចំពោះភាពរឹងមាំឬលទ្ធភាពបរាជ័យក្នុងប្រព័ន្ធមីក្រូហិរញ្ញវត្ថុនៃប្រទេសមួយ? ចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែម ដើម្បីកំណត់ថាតើមានទិន្នន័យអ្វីខ្លះពាក់ព័ន្ធនឹងឥណទានខូច ព្រមទាំងដើម្បីកំណត់ថាតើសំណើរៀបចំឥណទានឡើងវិញ ពិតជាគ្រប់គ្រាន់ក្នុងការបញ្ចៀសវិបត្តិមីក្រូហិរញ្ញវត្ថុ និងគ្រប់គ្រាន់ក្នុងការការពារកុំឲ្យកូនបំណុលធ្លាក់ក្នុងអន្លង់នៃបំណុលវ័ណ្ឌក។

វាជាការពិតមិនអាចប្រកែកបានទេថា ការប្រើប្រាស់ឥណទាននៅប្រទេសកម្ពុជាមានលក្ខណៈទូលំទូលាយជាងមុន សម្រាប់ប្រជាជនកម្ពុជាដែលមានជីវភាពប្រហាក់ប្រហែល ឬនៅគៀកបន្ទាត់ក្រីក្រ ក្នុងនោះមានទាំងស្ត្រីរស់នៅតាមជនបទផងដែរ។ នៅក្នុងពីរទសវត្សរ៍កន្លងទៅការស្រាវជ្រាវមួយចំនួនអំពី គ.ម.ហ កម្ពុជាបានបង្ហាញច្បាស់អំពីការខ្វះខាត និងផលអវិជ្ជមាននៃវិស័យមីក្រូហិរញ្ញវត្ថុ៖ ធ្វើឲ្យប្រជាជនក្រីក្រនៅកម្ពុជាកាន់តែលំបាក បង្កើនជាជាងកាត់បន្ថយភាពក្រីក្រ ព្រមទាំងមិនបានបង្ហាញឲ្យបានជាក់លាក់ថា ការប្រើប្រាស់មីក្រូឥណទានអាចជួយលើកកម្ពស់ការអប់រំ ឬសុខាភិបាលនោះទេ។ ដូចមុនដែរ សំណួរសំខាន់ៗជាច្រើនបានចោទសួរអំពីសមិទ្ធផលនៃវិស័យនេះ តែនៅតែមិនទាន់ឆ្លើយបាន។ តើជំងឺរាតត្បាតកូវីដ ១៩ កំពុងបង្កើតបញ្ហាចំពោះផលប័ត្រអតិថិជនទាំងអស់នៃ គ.ម.ហ ឬក៏វាប៉ះពាល់តែជនងាយរងគ្រោះបំផុត? តើយើងគួរឲ្យនិយមន័យភាពងាយរងគ្រោះ និងរាប់ចំនួនជនងាយរងគ្រោះបំផុតនោះដោយរបៀបណា? តើយើង អាចវាស់វែងដូចម្ដេច ដើម្បីគណនាភាគរយជនងាយរងគ្រោះបំផុតនៅក្នុងចំណោមផលប័ត្រអតិថិជនរបស់ គ.ម.ហ? តើមានចំនួនប៉ុន្មាននាក់ក្នុងចំណោមកូនបំណុលទាំងនេះនឹងអាចធ្លាក់ខ្លួនក្រដុនដាបដោយសារជំងឺរាតត្បាតនេះ? ហើយតើមានលទ្ធភាពកើតឡើងប្រាកដប៉ុនណា ករណីបញ្ហាធ្លាក់ខ្លួននេះនឹងរីករាលដាលដល់កំរិតណា ហើយអាចចាក់ឫសជាបញ្ហាប្រព័ន្ធ ជាពិសេសនៅពេលដែលមានភាគី ទាំងផ្លូវការ ទាំងក្រៅផ្លូវការបានពាក់ព័ន្ធ?

ដោយសារមានសំណួរច្រើនមិនទាន់បានឆ្លើយដូចខាងលើ ដូច្នេះរបកគំហើញនៃការស្រាវជ្រាវជាក់ស្ដែងថ្មីៗនេះ គួរចាត់ទុកថា ជាការដាស់តឿនឲ្យមានការប្រុងប្រយ័ត្ន ជំរុញឲ្យមានការស្រាវជ្រាវបន្ថែម ព្រមទាំងវិភាគកាន់តែស៊ីជម្រៅថែមទៀត។ កាលណាមានទិន្នន័យកាន់តែច្រើន ទើបយើងអាចយល់បាននូវភាពធ្ងន់ធ្ងរ និងវិសាលភាពនៃបញ្ហាទាំងនេះ។ ការព្យាករអំពីហានិភ័យជាប្រព័ន្ធត្រូវតែមើលឲ្យបានលើសពីអត្រាផលប័ត្រហានិភ័យ (PAR) ភាគចំណូលនៃផលប័ត្រ ទុនបម្រុង អត្រាកំណើនទ្រព្យសកម្ម និងសូចនាករធុរកិច្ចដែលធ្លាប់ប្រើ បង្ហាញបានតែសមិទ្ធផលផ្ទៃក្នុងខ្លះរបស់ គ.ម.ហ ប៉ុន្តែមិនបានបង្ហាញគ្រប់គ្រាន់ពីហានិភ័យជាប្រព័ន្ធនៃកត្តាខាងក្រៅ ដោយសារហានិភ័យនេះពាក់ព័ន្ធទៅនឹងភាពងាយរងគ្រោះរបស់កូនបំណុលក្នុងការបាត់បង់លទ្ធិភាពសង (អសាធនីយភាព)។

ការសិក្សាពីការវិវឌ្ឍសំណាកតាមពេលវេលា ដោយវិភាគលើផលប៉ះពាល់សេដ្ឋកិច្ច និងសង្គម បណ្ដាលមកពីវិស័យមីក្រូហិរញ្ញវត្ថុនៅប្រទេសកម្ពុជា មានសារៈសំខាន់ក្នុងការយកមកគាំទ្របាន ឬមិនបាន ចំពោះលទ្ធផលសិក្សាក្រុមសំណាកជ្រើសរើសដោយឥតព្រាងទុកស្ដីអំពីការកាត់បន្ថយភាពក្រីក្រ។

## *ការដោះស្រាយហានិភ័យដែលកំពុងកើតឡើង*

ក្រោយពីវិបត្តិកូវីដ ១៩ មានលទ្ធភាពអាចកើតមាននូវប្រភេទសេដ្ឋកិច្ចថ្មីមួយៈ សេដ្ឋកិច្ចដែលនៅតែជាសេដ្ឋកិច្ចទីផ្សារ ប៉ុន្តែដែលនឹងផ្តោតសំខាន់ ហើយប្រើធនធានច្រើនជាងមុនទៅលើប្រជាជនធម្មតា ជាពិសេសជនងាយរងគ្រោះ ហើយដែលគ្រប់គ្រងបាន នូវបញ្ហាវិសមភាពសេដ្ឋកិច្ច និងសង្គម។ ការប្រែប្រួលបែបនេះមានសង្ឃឹមថានឹងទៅរួចនៅកម្ពុជា ដូចមាននៅជុំវិញពិភពលោកដែរ ប៉ុន្តែនៅសល់កិច្ចការយ៉ាងច្រើនដែលត្រូវសម្រេចឲ្យបាន។ វិស័យមីក្រូហិរញ្ញវត្ថុឈរក្នុងទីតាំងល្អបំផុតក្នុងការជំរុញឲ្យមានការប្រែប្រួលទាំងនេះនៅក្នុងបរិបទកម្ពុជា។

អ្វីដែលសំខាន់បំផុតនៅបច្ចុប្បន្ននេះ គឺថា ស្ថិរភាពនៃវិស័យនេះត្រូវធានាឲ្យបានជាចម្បងតាមរយៈ ការធានាថា កូនបំណុល គ.ម.ហ នឹងបានទទួលផលពីឥណទានដែលបានចែងក្នុងកិច្ចសន្យា ហើយថា ជនងាយរងគ្រោះខាងសង្គម និងសេដ្ឋកិច្ចក្នុងចំណោមកូនបំណុលទាំងនោះ នឹងទទួលបានការគាំពារសមរម្យ។ មីក្រូឥណទានដែលជនងាយរងគ្រោះទទួលបាន ជាញឹកញាប់ពេក បង្កឲ្យមានការជំពាក់បំណុលខ្ពស់ហួសមិនអាចទទួលយកបាន បណ្តាលឲ្យមានភាពមិននឹងនរនៅក្នុងគ្រួសារក្នុងកម្រិតមួយដែលមិនទាន់យល់បានច្បាស់លាស់។ តើរបៀបនៃការវាយតម្លៃលទ្ធផលហិរញ្ញវត្ថុ ដែលវិនិយោគិនអន្តរជាតិតម្រូវឲ្យ គ.ម.ហ សម្រេចបាន ហើយដែលជាកត្តាជំរុញឲ្យ គ.ម.ហ បង្កើនចំនួនអតិថិជនបានឆាប់រហ័ស ព្រមទាំងអនុមត្តិផ្តល់ឥណទានឲ្យបានចំនួនកាន់តែច្រើននោះ គឺជាមូលហេតុចម្បងដែលនាំឲ្យមានបញ្ហានេះឬយ៉ាងណា?

ការបន្ធូរថ្លៃនៃប្រាក់កម្ចីជូនប្រជាជនកម្ពុជាដែលមានចំណូលទាប គឺជាកត្តាចាំបាច់របស់ដំណើរការទីផ្សារ និងសីលធម៌។ បេសកកម្មរកប្រាក់ចំណូល និងបេសកកម្មសង្គម អាចដើរទន្ទឹមគ្នាបានចំពោះវិធីវិនិយោគណាដែលបានជ្រើសរើសត្រឹមត្រូវ។ វិនិយោគិនដែលចង់ឲ្យមានការរីកចម្រើន ត្រូវតែថ្លឹងថ្លែងរកតុល្យភាពរវាងសូចនាករធុរកិច្ច និងសង្គម។ បើទុនដែលបានដាក់ចូលក្នុងការវិនិយោគ គ.ម.ហ ចង់បានតែចំណូលជាទ្រព្យផ្ទាល់ ប្រាក់វិនិយោគ និងទ្រព្យសកម្ម នោះវិស័យមីក្រូហិរញ្ញវត្ថុដែលមានតួនាទីធំលើសពីនេះ ហើយមានវិនិយោគិនចង់ឲ្យរីកចម្រើនដល់សេដ្ឋកិច្ចផង និងសង្គមផង ត្រូវតែកែទម្រង់របៀបធ្វើការ។ ទោះជាយ៉ាងណាក៏ដោយ វិនិយោគិនដែលចង់បានការរីកចម្រើនតែងតែពណ៌នាថា ខ្លួនឯងចង់បានជាខ្លាំងនូវការទទួលខុសត្រូវសង្គម ប៉ុន្តែ វិនិយោគិនទាំងនោះមិនបានគោរពពាក្យសន្យារបស់ខ្លួនជាទៀងទាត់នោះទេ។ ទោះជាវិនិយោគិនទាំងនេះតែងតែប្តេជ្ញាក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយបរិយាបណ្ណមាននៅលើក្រដាសក៏ដោយ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ពួកគេតែងតែឃ្លាតឆ្ងាយចេញពីគោលដៅដែលប្រកាសថា ចង់ពង្រឹងគ្រួសារដែលមានប្រាក់ចំណូលទាប និងនាំគ្រួសារទាំងនោះចេញផុតពីភាពក្រីក្រ។ ការទាញយកអ្នកមិនដែលប្រើធនាគារឲ្យមកប្រើធនាគារ និងការបញ្ចៀសកូនបំណុលដែលងាយរងគ្រោះឲ្យផុតពីម្ចាស់ឥណទានដែលមានទម្លាប់លេបកូនបំណុល ហើយនាំទៅជួបម្ចាស់បំណុលដែលជាគ្រឹះស្ថានហើយដើរតាមទីផ្សារសេរីកន្លងមក ជាប្រការវិជ្ជមានដែលបានកើតមាននៅក្នុងវិស័យនេះគឺជា ស្ថិតនៅជំហានដំបូងប៉ុនណ្ណោះ។ ភាពក្រីក្រកាត់បន្ថយប្រកបដោយចិរភាព គឺមិនមែនដោយសារតែកម្ចីដល់ជនងាយរងគ្រោះនោះទេ គឺដោយសារឧស្សាហកម្មផ្សេងៗបានរីកលូតលាស់ ហើយវិស័យសេដ្ឋកិច្ចបង្កើតការងារដល់ប្រជាពលរដ្ឋ។ ប្រជាជនដែលងាយរងគ្រោះផ្នែកសេដ្ឋកិច្ចត្រូវចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្តប្រសិនបើចង់ឲ្យពួកគាត់មានចំណែកក្នុងកំណើនសេដ្ឋកិច្ច និងគុណតម្លៃទាំងឡាយដែលមាននៅក្នុងសេដ្ឋកិច្ចជាតិ។

ការដាក់លក្ខខណ្ឌខ្ចីប្រាក់ និងលទ្ធភាពរបស់កូនបំណុលក្នុងការចែកឲ្យដាច់ រវាងឥណទានដែលប្រើសម្រាប់ផលិត និងមិនផលិតបានកែប្រែដោយសារជំងឺរាតត្បាតកូវីដ ១៩។ ដើមទុនដំបូងនិងទ្រព្យសកម្មគឺជាតម្រូវការសម្រាប់ការបើកធុរកិច្ច ហើយពេលវេលាទុកឲ្យធុរកិច្ចរក

ចំណូលមកវិញបាន គឺបានកើនឡើង កត្តានេះ (អាច) ធ្វើឲ្យកូនបំណុលមានហានិភ័យកាន់តែខ្ពស់ ធ្លាក់ក្នុងស្ថានភាពអសាធនីយ (បាត់បង់សមត្ថភាពក្នុងការសងត្រឡប់)។

ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ជាច្រើននៅថ្នាក់ក្រោមជាតិ បាននិយាយពីដំណើរការដែលឥណទានសម្រាប់បើកធុរកិច្ចអាចក្លាយជាបំណុលវ័ណ្ឌក។ ការសន្និដ្ឋានថា គ្រប់ជនក្រីក្រទាំងអស់សុទ្ធតែអាចបើក និងរក្សាដំណើរការសហគ្រាសណាមួយបាន ត្រូវតែចោទសួរជាសំណួរឡើងវិញ។ ឧទាហរណ៍ តើជាក់លាក់ដែរឬទេ ដែលយើងសន្និដ្ឋានថា បុគ្គលម្នាក់ ឬគ្រួសារមួយរស់នៅដោយចំណាយពីរបទៅប្រាំដុល្លារក្នុងមួយថ្ងៃអាចប្រើប្រាស់ប្រាក់កម្ចី ដើម្បីបង្កើនប្រាក់ចំណូល ខណៈដែលការចំណាយរស់នៅរបស់ពួកគាត់ត្រូវ បានកើនឡើងយ៉ាងឆាប់រហ័ស? តើយើងមានលទ្ធភាពឬទេក្នុងការវាស់វែងផលប៉ះពាល់នៃការប្រើប្រាស់ប្រាក់កម្ចីសម្រាប់ប្រកបអាជីវកម្មរបស់អ្នកក្រ? តើយើងអាចរកឃើញទេថាការប្រើប្រាស់ប្រាក់កម្ចីដែលមិនត្រូវទិសដៅ ទាំងនោះជាការសម្រេចចិត្តរបស់កូនបំណុល ក្នុងការវិនិយោគនៅលើអាជីវកម្មដែលបរាជ័យ ឬក៏បណ្តាលមកពីកង្វះសមត្ថភាពក្នុងការពង្រីកអាជីវកម្ម? យើងគួរតែផ្តោតការយកចិត្តទុកដាក់ស្វែងយល់អំពីកត្តាផ្សេងៗ ដែលនៅពីក្រោយការសងឥណទាន និងអសាធនីយភាព (បាត់បង់សមត្ថភាពក្នុងការសងត្រឡប់) ជាជាងទៅលើកត្តាទាំងពីរនេះសុទ្ធសាធ និងតួលេខតែមួយមុខនោះផងដែរ។

យោងតាមទស្សនៈរបស់ម្ចាស់បំណុល និងអាជ្ញាធរមានសមត្ថកិច្ច អត្រាសងប្រាក់ដែលមានកម្រិតខ្ពស់ បង្ហាញពីស្ថិរភាពនៃវិស័យ។ យោងតាមទស្សនៈរបស់កូនបំណុល បើឥណទានបានសងទៅវិញដោយប្រើចំណូលពីធុរកិច្ចដែលរីកចម្រើន នោះមានន័យថា បានបង្កើតវដ្តដ៏ល្អមួយ។ ប៉ុន្តែការស្រាវជ្រាវភាគច្រើនចង្អុលបង្ហាញថា កូនបំណុលបានប្រើប្រាស់ប្រាក់កម្ចីសម្រាប់ការចំណាយប្រចាំថ្ងៃទៅវិញ ហើយក៏បង្ហាញថា កូនបំណុលជាច្រើននាក់ចុងបញ្ចប់ត្រូវបាត់បង់ដីធ្លី។ អាស្រ័យហេតុនេះ តើថវិកាដែលបង់សងឥណទានទាំងនេះបានមកពីណា? ហើយតើការផ្ទុះឡើងហើយបរាជ័យទៅវិញនៃបំណុលតូចៗ ដែលភាគច្រើនមិនសូវមានអ្នកណាដឹងនោះ មានហានិភ័យ និងប៉ះពាល់ដល់ម៉ាក្រូសេដ្ឋកិច្ចឬទេ? ឥរិយាវិទ្យាសាស្ត្រមានតួនាទីក្នុងការឆ្លើយសំណួរទាំងនេះ ក្នុងការបង្កើតទម្រង់ និងយន្តការហិរញ្ញវត្ថុ ឲ្យបានប្រសើរឡើងដោយសម្របតាមតម្រូវការរបស់ប្រជាជនដែលមានប្រាក់ចំណូលទាប។

## *ដើម្បីកែលម្អគោលនយោបាយ តើការយកគុណសម្បត្តិខាងពាណិជ្ជកម្មតិចតួច ហើយផ្តល់គុណសម្បត្តិសង្គមឲ្យបានច្រើន អាចធ្វើបានតាមរបៀបណា?*

ឧទាហរណ៍ថាកូនបំណុលដែលមានប្រាក់ចំណូលទាប និងងាយរងគ្រោះ នៅតែជាអតិថិជនភាគច្រើនរបស់ គ.ម.ហ កម្ពុជា នោះការបែងចែកអតិថិជនទាំងនេះឲ្យស្របទៅតាមភាពងាយរងគ្រោះ និងលទ្ធភាពបរាជ័យទៅតាមស្ថានភាពសេដ្ឋកិច្ចធ្លាក់ចុះក្នុងពេលមានជំងឺរាតត្បាតកូវីដ ១៩ គឺជាកត្តាចាំបាច់បំផុតក្នុងការកែលម្អគោលនយោបាយនានា ដែលជួយបុគ្គលទាំងនេះក្នុងគ្រាសេដ្ឋកិច្ចធ្លាក់ចុះ និងរក្សាស្ថិរភាពនៃវិស័យមីក្រូហិរញ្ញវត្ថុទាំងមូលផង។

ការទទួលបានប្រាក់ចំណូលមិនទៀងទាត់របស់ប្រជាជនងាយរងគ្រោះនៅប្រទេសកម្ពុជា (លំហូរសាច់ប្រាក់ប្រចាំថ្ងៃរបស់អតិថិជន គ.ម.ហ បានប្រែប្រួលស្ទើររាល់ថ្ងៃ ពេលខ្លះបានទម្លាក់ពួកគាត់ជិតដល់បន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ នៅពេលខ្លះទៀតបានធ្លាក់ចុះក្នុងកម្រិតពីរដងធ្ងន់ជាងនេះទៀត ហើយពេលខ្លះទៀតធ្លាក់ចុះជិតទៅដល់កម្រិតសូន្យ) និងភាពមិនទៀងទាត់នៃការចំណាយ បានធ្វើឲ្យមានការ

លំបាកក្នុងការវិភាគ និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចរបស់ពួកគាត់។ នៅពេលដែលភាពងាយរងគ្រោះកើនឡើងបានបន្ថែមទៅលើភាពមិនទៀងទាត់ និងមិនអាចព្យាករបាននោះ លទ្ធផលចុងក្រោយគឺមានអស្ថិរភាពកាន់តែធ្ងន់ធ្ងរចំពោះប្រព័ន្ធមីក្រូឥណទានទាំងមូល។ អ្វីដែលជាហានិភ័យនោះគឺត្រង់ថា បញ្ហាដែលកើតមានរបៀបនេះ អាចមានមូលហេតុដោយឡែក ដូច្នេះ បណ្តាលឲ្យមានបំណុលវ័ណ្ឌក ដែលជាចុងក្រោយនាំឲ្យប្រព័ន្ធទាំងមូលបរាជ័យ។ យើងបានសង្កេតឃើញលំនាំបែបនេះបានកើតមានឡើងរួចហើយនៅក្នុងវិបត្តិហិរញ្ញវត្ថុធំៗកន្លងមក ហើយយើងត្រូវតែបង្កើនការប្រុងប្រយ័ត្ន ដើម្បីធានាឲ្យបានថា វិបត្តិដូចគ្នានេះនឹងមិនកើតឡើងក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជានាបច្ចុប្បន្ន។

ការស្រាវជ្រាវនេះពិនិត្យមើលទំនាក់ទំនងនៃភាពងាយរងគ្រោះក្នុងកត្តាសេដ្ឋកិច្ច និងសង្គម ចំពោះគ្រួសារងាយរងគ្រោះនៅកម្ពុជាក្នុងបំណងស្វែងយល់ពីផលប៉ះពាល់ ក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ ១៩។ ការសិក្សានេះជាការចាប់ផ្តើមដំបូង ដែលត្រូវតែបន្តសិក្សា វិភាគ និងស្វែងយល់បន្ថែម។ សេចក្តីសន្និដ្ឋានសំខាន់មួយរបស់ប្រធានក្រុមស្រាវជ្រាវ ត្រូវនឹងស្ថានភាពបច្ចុប្បន្នរបស់យើងតែម្តង៖ មានការចាំបាច់បន្ទាន់ត្រូវផ្តល់ឲ្យកូនបំណុលងាយរងគ្រោះនូវការការពារដែលរឹងមាំ ឆាប់រហ័ស និងមានគុណភាពខ្ពស់ជាងមុន ដើម្បីបញ្ចៀសអ្នកទាំងនោះកុំឲ្យធ្លាក់ក្នុងស្ថានភាពអសាធនីយផង និងដើម្បីការពារអ្នកទាំងនោះពីសម្ពាធអវិជ្ជមានផ្សេងៗ បើពួកគាត់បានស្ថិតនៅក្នុងស្ថានភាពអសាធនីយរួចហើយនោះផង។ ជាអនុសាសន៍គឺថា ការការពារនេះត្រូវតែអនុវត្តទប់ទល់នឹង ហានិភ័យ ស្ថានភាពសេដ្ឋកិច្ចធ្លាក់ចុះ និងសម្ពាធពីតតីយភាគីទៅលើកូនបំណុល ដែលបណ្តាលឲ្យធ្លាក់ខ្លួនជាប់បំណុល ដែលជារឿយៗហាក់ដូចជាមិនអាចនឹងគេចផុតបាន។ ការបង្កើតក្របខណ្ឌមួយសមស្របមកដោះស្រាយបញ្ហាទាំងនេះ មិនមែនជាការងាយស្រួលទេ ជាពិសេសដោយសារនៅកម្ពុជាមិនមាន "ផ្នត់គំនិតនៃកិច្ចគាំពារអតិថិជន" នៅឡើយ។ ទោះជាយ៉ាងណាក៏ដោយវិស័យមីក្រូហិរញ្ញវត្ថុមិនអាចរង់ចាំអ្នកខាងក្រៅមកដាក់បទដ្ឋានឲ្យខ្លួននោះឡើយ ពោលគឺវិស័យនេះត្រូវតែបង្កើតដោយខ្លួនឯងនូវយុទ្ធសាស្ត្រទប់ទល់ហានិភ័យ ដែលបានរៀបរាប់ខាងលើ។ មានមូលដ្ឋានរឹងមាំរួចស្រេចហើយដើម្បីចាត់វិធានការថ្មី និងមានប្រសិទ្ធភាពខ្ពស់ជាងមុនក្នុងការការពារជនក្រីក្រ៖ វិធីកំណត់គោលដៅល្អដែលបានធ្វើតាមរយៈប្រព័ន្ធ បណ្ណក្រីក្រ (IDPoor) នៅកម្ពុជា ទិន្នន័យថ្មីៗមាននៅក្នុងជំរឿនសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ២០១៩ - ២០ ក្របខណ្ឌកិច្ចគាំពារសង្គម និងរបបសន្តិសុខសង្គម។ល។ ហានិភ័យមានខ្ពស់ហើយបញ្ហាក៏ធំពេកក្នុងលក្ខណៈថា គ្រប់ភាគីក្នុងវិស័យ គ.ម.ហ មិនអាចមិនចាត់វិធានការនាពេលនេះឆាប់ៗបានឡើយ។

*ពន្លកចំណេះ គឺជាកម្មវិធីបែបនវានុវត្តន៍មួយ ជួយដល់ស្ថាប័នស្រាវជ្រាវមួយចំនួន តាមរយៈជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី ហើយដែលចាត់ចែងដោយមូលនិធិអាស៊ី ក្នុងគោលបំណងលើកកម្ពស់ និងពង្រឹងវិស័យចំណេះដឹងនៅប្រទេសកម្ពុជា ជាពិសេសផ្តោតទៅលើការវិភាគព័ត៌មានដើម្បីជូនដំណឹងដល់អ្នកបង្កើតគោលនយោបាយ។* ពន្លកចំណេះបានបើកឱកាសថ្មីមួយឲ្យអ្នកស្រាវជ្រាវកម្ពុជា ដើរតួនាទីសំខាន់ក្នុងការដឹកនាំការស្រាវជ្រាវដោយឯករាជ្យ ទៅលើប្រធានបទដែលបង្កផលប៉ះពាល់ដល់ប្រទេសកម្ពុជា។ ការស្រាវជ្រាវដែលមិនលម្អៀង ឈរលើទិន្នន័យលើពហុវិស័យ អ្នកស្រាវជ្រាវមានសេរីភាពក្នុងការប្រើវិធីសាស្ត្រ គឺជាមូលដ្ឋានគ្រឹះ ក្នុងការស្វែងយល់ឲ្យបានកាន់តែជ្រៅនូវបញ្ហានាពេលបច្ចុប្បន្ន។ សូមអរគុណដល់កម្មវិធីពន្លកចំណេះ ដែលផ្តល់ឱកាសឲ្យមជ្ឈមណ្ឌលខេមរសិក្សា បានធ្វើការជាមួយអ្នកស្រាវជ្រាវកម្ពុជា កញ្ញា **រេះ ផាសុី** ដែលមានចំណេះដឹងខ្ពស់ ភាពឈ្លៀសវៃ និងភាពអំណត់ខ្ពស់ក្នុងការបង្កើតវិធីសាស្ត្រស្រាវជ្រាវដោយឯករាជ្យដោយខ្លួនឯងព្រមទាំងក្នុងការប្រមូល និងវិភាគទិន្នន័យ។ នៅក្នុងការសិក្សានេះ កញ្ញា **រេះ ផាសុី** បានដើរតួនាទីជាអ្នកដឹកនាំស្រាវជ្រាវជាលើកដំបូង ហើយការស្រាវជ្រាវនេះក៏មានសារៈសំខាន់ចំពោះការអភិវឌ្ឍប្រកបដោយចិរភាពនៅកម្ពុជា។

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងយើងសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីពន្លកចំណេះដែលបានឧបត្ថមគម្រោងស្រាវជ្រាវនេះ។ ជាបន្ទាប់ យើងសូមអរគុណចំពោះលោកស្រី **ហៀង សោភា** និងលោក **ប្រាក់ រត្តិធីរា** មកពីអង្គការមូលនិធិអាស៊ី ព្រមទាំង កញ្ញា **ស៊្វីង សាម៉ីឌី** និង កញ្ញា **ស៊ា ផិចលីម** មកពីមជ្ឈមណ្ឌលខេមរសិក្សា ចំពោះការជួយផ្តល់យោបល់ល្អៗ និងគាំទ្រដល់ការស្រាវជ្រាវនេះ។ យើងក៏សូមអរគុណផងដែរដល់ លោក **យ៉ានិក មីឡេរ** និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងអ្នកត្រួតពិនិត្យសំណេរដែលមិនបានបញ្ចេញឈ្មោះនានា ចំពោះការផ្តល់យោបល់កែលម្អ នៅគ្រប់ដំណាក់កាលនៃការស្រាវជ្រាវនេះ។ កិច្ចសម្ភាសដែលបានរៀបចំជាមួយតំណាងគ្រឹះស្ថានហិរញ្ញវត្ថុមួយចំនួនមិនអាចបានជោគជ័យនោះទេ ប្រសិនបើគ្មានការជួយគាំទ្រពីសមាគមមីក្រូហិរញ្ញវត្ថុ និងលោក **យ៉ានិក មីឡេរ**។ ជាចុងក្រោយ យើងសូមអរគុណដល់ ក្រុមស្រាវជ្រាវរបស់យើងដែលបានប្រឹងប្រែងសម្ភាស ដល់អ្នកផ្តល់កិច្ចសម្ភាស ដែលបានចំណាយពេលវេលារបស់ខ្លួន ដល់ក្រុមរដ្ឋបាល និងហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលខេមរសិក្សា និងអង្គការមូលនិធិអាស៊ី ដល់ក្រុមប្រតិចារឹក ដល់ក្រុមរចនារូបភាព ដល់ក្រុមកែសម្រួលអត្ថបទស្រាវជ្រាវ ព្រមទាំងដល់ក្រុមអ្នកបកប្រែ។ បើគ្មានការប្តេជ្ញាចិត្តគាំទ្ររបស់អ្នកទាំងអស់គ្នានេះទេ គម្រោងស្រាវជ្រាវនេះ *ផលប៉ះពាល់ខាងសេដ្ឋកិច្ច និងសង្គម នៃជំងឺរាតត្បាតកូវីដ ១៩ មកលើកូនបំណុល* ប្រាកដជាមិនអាចសម្រេចបានដោយជោគជ័យនោះឡើយ។

# អ្នកចូលរួមក្នុងការស្រាវជ្រាវ

កញ្ញា **រេះ ផាសុី** គឺជាអ្នកដឹកនាំស្រាវជ្រាវក្នុងគម្រោងនេះ ព្រមទាំងបានពិនិត្យ និងវិភាគឯកសារដែលមានស្រាប់ បង្កើតវិធីសាស្ត្រស្រាវជ្រាវ ប្រមូលទិន្នន័យ ធ្វើប្រតិចារឹកទិន្នន័យ ដាក់កូដទិន្នន័យ វិភាគទិន្នន័យ និងពន្យល់របកគំហើញ។ កញ្ញាបានព្រាងសំណេររបាយការណ៍ ពិនិត្យឡើងវិញ កែសម្រួល និងបញ្ចូលយោបល់របស់បណ្ឌិត **ម៉ារីយ៉ាន់ បាយឡេនឌឺ** សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា លោក **ង៉ោ ណត្ថារុន** និងអង្គការមូលនិធិអាស៊ី។ សមាជិកក្រុមស្រាវជ្រាវផ្សេងទៀត រួមមាន **អេង ស្រីមុំ**, **ខ្លង គឹមអាន** និង **ណូ អាស៊ីម** ដែលបានចូលរួមប្រមូលទិន្នន័យសម្រាប់គម្រោងនេះ។ បណ្ឌិត **ម៉ារីយ៉ាន បាយឡេនឌឺ** គឺជាអ្នកផ្តល់យោបល់ណែនាំការស្រាវជ្រាវ និងបានជួយដល់ក្រុមស្រាវជ្រាវផ្នែកវិធីសាស្ត្រ ក្រមសីលធម៌ស្រាវជ្រាវ និងយុទ្ធសាស្ត្រក្នុងការវិភាគទិន្នន័យ។ បណ្ឌិត **បាយឡេនឌឺ** និងលោក **ង៉ោ ណត្ថារុន** បានពិនិត្យ និងផ្តល់យោបល់សំខាន់ៗ ជួយសម្រួលដល់ការសរសេរសំណើគម្រោង ការវិភាគ ខ្លឹមសារនៃសេចក្តីព្រាង និងរបាយការណ៍បញ្ចប់។

# ពាក្យកាត់

| | | |
|---|---|---|
| **ស.ធ.ក** | - | សមាគមធនាគារកម្ពុជា |
| **អេស៊ីលីដា** | - | សមាគមភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានកម្ពុជា |
| **កូវីដ ១៩** | - | ជំងឺរាតត្បាតកូវីដ ២០១៩ |
| **ក.ឥ.ក** | - | ការិយាល័យឥណទានកម្ពុជា |
| **ម.ប.ហ** | - | មជ្ឈមណ្ឌលបរិយាបណ្ណហិរញ្ញវត្ថុ |
| **ស.ម.ហ.ក** | - | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា |
| **ក.គ.អ** | - | កិច្ចគាំពារអតិថិជន |
| **គ.ក.អ** | - | គោលការណ៍ស្តីពីកិច្ចគាំពារអតិថិជន |
| **ស៊ីជីអេភី/CGAP** | - | ក្រុមប្រឹក្សាយោបល់សម្រាប់ជួយជនក្រីក្រ |
| **អ៊ីប៊ីអេ/EBA** | - | អ្វីៗទាំងអស់តែមិនមែនអាវុធ |
| **ផ.ស.ស/GDP** | - | ផលិតផលក្នុងស្រុកសរុប |
| **អេហ្វអេសភី/FSPs** | - | អ្នកផ្តល់សេវាហិរញ្ញវត្ថុ |
| **គ.ហ/FI** | - | គ្រឹះស្ថានហិរញ្ញវត្ថុ |
| **អាយអឹមអេហ្វ/IMF** | - | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| **ក.ឥ.ឡ/LR** | - | ការរៀបចំឥណទានឡើងវិញ |
| **ក.ប** | - | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **អឹមអេហ្វស៊ី/MFC** | - | មជ្ឈមណ្ឌលមីក្រូហិរញ្ញវត្ថុ |
| **អិនជីអូអេស/NGOs** | - | អង្គការមិនមែនរដ្ឋាភិបាល |
| **ធ.ជ.ក** | - | ធនាគារជាតិកម្ពុជា |
| **បាត/THB** | - | ប្រាក់បាតថៃ |
| **ដុល្លារសហរដ្ឋអាមេរិក/USD** | | |
| **យូអិនឌីភី/UNDP** | - | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| **អ.ស.ព/WHO** | - | អង្គការសុខភាពពិភពលោក |

# សេចក្តីសង្ខេប

## សាវតារ

វិបត្តិជំងឺរាតត្បាតកូវីដ ១៩ បានបង្កភាពរើករវរខាងសេដ្ឋកិច្ចមិនធ្លាប់មានពីមុនមកនៅទូទាំងកម្ពុជា រួមមានការបាត់បង់ការងារជាច្រើនក្នុងវិស័យសំខាន់ៗនៃសេដ្ឋកិច្ច និងការព្រួយបារម្ភពីការកើតមានភាពក្រីក្រ និងការកើនឡើងភាពងាយរងគ្រោះ។ នៅក្នុងបរិបទកម្ពុជា ការព្រួយបារម្ភសំខាន់មួយ គឺចំពោះភាពធ្ងន់ធ្ងរនៃការប៉ះពាល់របស់ជំងឺរាតត្បាតកូវីដ ១៩ បន្ថែមទៅលើបញ្ហាសេដ្ឋកិច្ចផ្សេងៗទៀត ដោយសារនៅមុនកើតជំងឺរាតត្បាតនេះ មានគ្រួសារនានាជំពាក់បំណុលក្នុងកម្រិតខ្ពស់រួចទៅហើយ យោងតាមរបាយការណ៍របស់ភាគីផ្សេងៗ។ នៅក្នុងបរិបទនេះ ការស្រាវជ្រាវនេះមានបំណងចាប់ផ្តើមស្វែងយល់ពីបញ្ហាពីរដែលទាក់ទងគ្នា៖ តើជំងឺរាតត្បាតកូវីដ ១៩ បានប៉ះពាល់ដូចម្តេចខ្លះទៅលើកូនបំណុល / ការរងសម្ពាធបំណុល ព្រមទាំងថាតើភាគីហិរញ្ញវត្ថុបានឆ្លើយតបនឹងវិបត្តិនេះដោយរបៀបណា។ តាមរយៈការឆ្លើយសំណួរទាំងនេះ គោលដៅធំរបស់យើងគឺដើម្បីផ្តល់សំណូមពរមួយចំនួនដែលផ្អែកលើភស្តុតាង ដល់អ្នកបង្កើតគោលនយោបាយ គ្រឹះស្ថានហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ ដើម្បីការពារដល់គ្រួសារងាយរងគ្រោះខាងផ្នែកសេដ្ឋកិច្ច ឲ្យបានកាន់តែប្រសើរ នៅក្នុងពេល និងនៅក្រោយវិបត្តិជំងឺរាតត្បាតកូវីដ ១៩។

## វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឆ្លើយនឹងសំណួរ និងសម្រេចគោលដៅនៃការស្រាវជ្រាវខាងលើ យើងបានជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវគឺការសម្ភាសបែបស៊ីជម្រៅ ដែលមានសំណួរខ្លះៗត្រូវបានរៀបចំទុកជាមុន។ វិធីសាស្ត្រនេះផ្តល់ឱកាសឲ្យយើងយល់ពីបញ្ហា និងផលប៉ះពាល់ដែលអាចកើតឡើងចំពោះគ្រួសារជាប់បំណុល។ វិធីនេះក៏ឲ្យយើងមានជម្រើសច្រើនក្នុងការកំណត់បញ្ហាដែលកើតឡើង និងឱកាសក្នុងការជួយដល់គ្រួសារជាប់បំណុល។ ហេតុដូច្នេះការស្រាវជ្រាវនេះបានប្រើប្រាស់សំណាកក្នុងចំនួនតិចជាងបើប្រៀបធៀបនឹងការធ្វើជំរឿនគ្រួសារ និងការស្ទង់មតិផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ វិធីសាស្ត្រនេះមានលក្ខណៈសមស្របសម្រាប់គោលដៅស្រាវជ្រាវរបស់យើង ដោយសារយើងចង់បង្ហាញពីលក្ខណៈស្មុគស្មាញនៃបញ្ហា ដែលកូនបំណុលមីក្រូហិរញ្ញវត្ថុកំពុងជួបប្រទះ និងដើម្បីស្វែងយល់ពីបញ្ហាប្រឈមផ្សេងៗ។ ការស្រាវជ្រាវតាមគុណវិស័យមានលក្ខណៈសមស្របសម្រាប់ការស្រាវជ្រាវបែបនេះ។

ដើម្បីធានាថាយើងប្រាកដជាអាចបង្ហាញបញ្ហាទាំងនេះ និងអាចបញ្ជ្រាបសមភាពយេនឌ័ និងក្របខណ្ឌបរិយាបណ្ណសង្គម យើងបានរើសយកគ្រួសារដែលមានលក្ខណៈផ្សេងៗគ្នាដូចជា ៖ គ្រួសារចំណាកស្រុកក្នុងប្រទេស និងក្រៅប្រទេស កម្មកររោងចក្រ កសិករដាំស្រូវ/ពោត/ដំឡូងមី ដែលជាម្ចាស់ដី កសិករដែលជាម្ចាស់ដីផង និងធ្វើការយកប្រាក់ឈ្នួលផង[1] កសិករដែលធ្វើការយកប្រាក់ឈ្នួល អ្នកលក់វត្ថុអនុស្សាវរីយ៍ អ្នកបើកបរទុកទុក មគ្គុទ្ទេសទេសចរណ៍ ព្រមទាំងបុគ្គលិកសណ្ឋាគារ និងភោជនីយដ្ឋាន។

កិច្ចសម្ភាសផ្អែកលើសំណួរដែលបានរៀបចំខ្លះ បានធ្វើឡើងជាមួយកូនបំណុលមីក្រូហិរញ្ញវត្ថុ កូនបំណុលមិនមែនមីក្រូហិរញ្ញវត្ថុ និងបុគ្គលិកនៃគ្រឹះស្ថានហិរញ្ញវត្ថុ។ កិច្ចសម្ភាសនេះបានធ្វើជាមួយបុគ្គលិក ៣៤នាក់ មកពីគ្រឹះស្ថានហិរញ្ញវត្ថុចំនួន៥។

[1] កសិករដែលជាម្ចាស់ដីផង និងធ្វើការយកប្រាក់ឈ្នួលផង មានន័យថាជាកសិករដែលមានកម្មសិទ្ធិដីខ្លួនឯងផង ហើយក៏ធ្វើការឲ្យកសិករផ្សេងទៀតដើម្បីរកប្រាក់ឈ្នួលប្រចាំថ្ងៃផងដែរ។

ភាគច្រើននៃកិច្ចសម្ភាសនេះ បានធ្វើជាមួយមន្ត្រីឥណទាន (N=18) និងប្រធានសាខា (N=15) ប៉ុន្តែយើងក៏បានពិភាក្សាជាមួយនាយកប្រតិបត្តិម្នាក់ដែរ។ ដោយសារមានបុរសភាគច្រើនធ្វើការនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដូច្នេះបុគ្គលិក គ.ម.ហ ទាំងអស់ដែលបានសម្ភាសក្នុងគម្រោងនេះសុទ្ធតែជាបុរស មានតែម្នាក់ជាស្ត្រី។ លើសពីនេះទៀត ក្រុមស្រាវជ្រាវបានសម្ភាសជាមួយកូនបំណុលមីក្រូហិរញ្ញវត្ថុបច្ចុប្បន្នបានចំនួន១១៩នាក់ ព្រមទាំងកូនបំណុលមិនមែនមីក្រូហិរញ្ញវត្ថុចំនួន១៧នាក់។ កិច្ចសម្ភាសជាមួយកូនបំណុលមិនមែនមីក្រូហិរញ្ញវត្ថុបានបំភ្លឺអំពីភាពខុសគ្នា និងមិនខុសគ្នា រវាងយុទ្ធសាស្ត្រទប់ទល់ ដែលបានប្រើដោយគ្រួសារកូនបំណុលមីក្រូហិរញ្ញវត្ថុ និងគ្រួសារកូនបំណុលមិនមែនមីក្រូហិរញ្ញវត្ថុ ដែលបានធ្លាក់ចុះប្រាក់ចំណូលដោយសារជំងឺរាតត្បាតកូវីដ ១៩។ ភាគច្រើននៃអ្នកផ្តល់សម្ភាសគឺជាស្ត្រី (សូមមើលឧបសម្ព័ន្ធ ១ បន្ថែម)។ កិច្ចសម្ភាសជាមួយគ្រួសារទាំងនេះមានរយៈពេល ៤ខែ ចាប់ពីខែកក្កដា ដល់ខែតុលា ឆ្នាំ២០២០ នៅខេត្តបាត់ដំបង សៀមរាប កំពង់ឆ្នាំង និងភ្នំពេញ។

## របកគំហើញ

- វិធានការជាទូទៅសម្រាប់ទប់ទល់នៅក្នុងពេលធម្មតា ដូចជាការកាត់បន្ថយការចំណាយប្រចាំថ្ងៃ ការចាយប្រាក់សន្សំផ្ទាល់ខ្លួនជាដើម មិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឲ្យគ្រួសារងាយរងគ្រោះ អាចទប់ទល់បានជាមួយផលប៉ះពាល់នៃវិបត្តិជំងឺរាតត្បាតកូវីដ ១៩ ឡើយ។ អាស្រ័យហេតុនេះ គ្រួសារនានាត្រូវទៅរកការងារបណ្តោះអាសន្នក្នុងវិស័យសំណង់ ឬកសិកម្ម រៀបចំឡើងវិញនូវវិធីរកប្រាក់ចំណូល ឬកែសម្រួលតម្រូវការក្នុងគ្រួសារ ឬត្រូវប្រើវិធីលើសពីមួយក្នុងចំណោមវិធីទាំងនេះ។

- ការប្រើវិធីបង្វិលលុយ ជាទម្លាប់ដែលធ្លាប់ធ្វើក្នុងការដោះស្រាយជីវភាព ដែលអាចយកមកគួបផ្សំជាមួយវិធីសាស្ត្រផ្សេងៗ ឬក៏អាចនឹងប្រើដោយឡែក។ ការបង្វិលលុយក្នុងចំណោមសាច់ញាតិ ដើរតួនាទីជាការគាំពារសង្គមក្រៅផ្លូវការសម្រាប់គ្រួសារដែលរងសម្ពាធបំណុល។ ទំហំទឹកប្រាក់ ទ្រព្យ និងទឹកចិត្តក្នុងការជួយដល់គ្រួសារសាច់ញាតិ ជាកត្តាកំណត់នូវសមត្ថភាពដើម្បីងើបឡើងពីការធ្លាក់ចុះខាងសេដ្ឋកិច្ច។ ប៉ុន្តែ ក្នុងករណីភាគច្រើន គ្រួសារដែលមានចំណូលទាប មិនស្ថិតនៅក្នុងចំណោមសាច់ញាតិដែលធូរធារនោះទេ។

- ជំងឺរាតត្បាតកូវីដ ១៩ បានកាត់បន្ថយសមត្ថភាពគ្រួសារដែលមានចំណូលទាបក្នុងការរកចំណូលឲ្យបានពីច្រើនប្រភព។ ឧទាហរណ៍ ជំងឺរាតត្បាតនេះបានធ្វើឲ្យគ្រួសារនានាមិនអាចធ្វើចំណាកស្រុកជាទម្លាប់ទៅប្រទេសថៃបាន។ ការមិនអាចធ្វើចំណាកស្រុកនេះ និងការបាត់បង់ការងារក្នុងវិស័យទេសចរណ៍ បានធ្វើឲ្យមានអតិរេកក្នុងការផ្គត់ផ្គង់ទីផ្សារកម្លាំងពលកម្មក្នុងស្រុក។ វិស័យសំណង់ និងកសិកម្មអាចស្រូបយកកម្លាំងពលកម្មមួយចំនួនពីទីផ្សារ ប៉ុន្តែនៅក្នុងកម្រិតបច្ចុប្បន្ននេះ វិស័យទាំងពីរនេះមិនអាចស្រូបយកបានការងារទាំងអស់ ដែលបានបាត់បង់ដោយសារជំងឺរាតត្បាតកូវីដ ១៩ នោះទេ។

- ឥណទានអាចជួយឲ្យគ្រួសារខ្លះរៀបចំសកម្មភាពរកចំណូលជាថ្មីឡើងវិញ។ ដើម្បីកាត់បន្ថយហានិភ័យជីវភាព គ្រួសារនានានិយមផ្លាស់ទៅធ្វើសកម្មភាពណាដែលប្រើជំនាញស្រដៀងនឹងជំនាញចាស់ ឬដែលមិនត្រូវការជំនាញថ្មី។ ឧទាហរណ៍ ដោយបានឥណទានមីក្រូហិរញ្ញវត្ថុជួយ កម្មករផលិតសម្លៀកបំពាក់ដែលត្រូវបានបញ្ឈប់ពីការងារ មានលទ្ធភាពបើកហាងកាត់ដេរនៅ

ស្រុកកំណើតរបស់គាត់។ ទោះជាយ៉ាងណាក៏ដោយ ដោយសារជំងឺរាតត្បាតកូវីដ ១៩ ធ្វើឲ្យសភាពការណ៍មិនទៀងទាត់ មុខរបរថ្មីនេះមិនទាន់ប្រាកដថានឹងទទួលបានជោគជ័យនោះទេ។

- មានបញ្ហាប្រឈមខ្លះៗទាក់ទងនឹងការផ្ទេរប្រាក់ឧបត្ថម្ភដល់គ្រួសារក្រីក្រនៅតាមមូលដ្ឋាន ប៉ុន្តែការឧបត្ថម្ភសាច់ប្រាក់ ដែលរដ្ឋាភិបាលផ្តល់ដល់គ្រួសារដែលមានប្រាក់ចំណូលទាប ដែលមានបណ្ណក្រីក្រ បានស្តែងឲ្យឃើញថា មានប្រសិទ្ធភាពក្នុងការសម្រាលដល់ការបាត់បង់ចំណូលនៅតាមគ្រួសារទាំងនោះ។

- នៅពេលមានបញ្ហាការដោះបំណុល កូនបំណុលមានការស្ទាក់ស្ទើរក្នុងការទៅចរចាជាមួយនឹងគ្រឹះស្ថានឥណទានរបស់ខ្លួន។ មូលហេតុដែលកូនបំណុលស្ទាក់ស្ទើរនោះ គឺម៉្យាងដោយសារកូនបំណុលទាំងនោះមិនបានដឹងអំពីគោលការណ៍ផ្សេងៗ របស់គ្រឹះស្ថាន ឬពួកគាត់មិនហ៊ានទៅជួបគ្រឹះស្ថានហិរញ្ញវត្ថុ ដោយសារខ្លាចថា បើទៅជួបនឹងអាចជះផលអវិជ្ជមានដល់ប្រវត្តិឥណទានរបស់គាត់ ដែលអាចនឹងលែងបានទទួលឥណទានម្តងទៀតនាពេលអនាគត។ ការភ័យខ្លាចនេះមិនមែនអត់ហេតុផលនោះទេ ពីព្រោះអ្នកចូលរួមផ្តល់ព័ត៌មានរបស់យើងមួយចំនួន បានត្រូវមន្ត្រីឥណទានរបស់ពួកគាត់ប្រាប់ថា ការសងមិនទៀងទាត់នឹងរារាំងគាត់នៅពេលអនាគតក្នុងការទទួលប្រាក់កម្ចីសាជាថ្មី។ ករណីទាំងពីរនេះ អាចបង្កឲ្យមានបំណុលវ័ណ្ឌក ដោយសារករណីមិនទទួលបានគោលការណ៍ទ្រទ្រង់ផ្សេងៗ អាចនាំឲ្យគ្រួសារដែលរងសម្ពាធបំណុលអាចនឹងទៅចាប់យកវិធីដោះស្រាយដែលពួកគាត់មិនចង់បាន។

- ក្នុងពេលវិបត្តិជំងឺរាតត្បាតកូវីដ ១៩ បណ្តាគ្រឹះស្ថានឥណទានបានអនុវត្តគោលការណ៍រៀបចំឥណទានឡើងវិញ ដើម្បីគាំទ្រដល់អតិថិជនដែលប្រាក់ចំណូលរបស់ពួកគាត់ប៉ះពាល់ដោយសារជំងឺរាតត្បាតកូវីដ ១៩។ ការស្រាវជ្រាវរបស់យើងបានរកឃើញបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តគោលការណ៍នេះ។ ទី១ ការរៀបចំឥណទានឡើងវិញមិន បានដាក់ឲ្យ មានសម្រាប់គ្រប់គ្រួសារដែលបានប៉ះពាល់នោះទេ។ ទី២ មិនមានការចុះផ្សព្វផ្សាយឲ្យបានគ្រប់គ្រាន់ទៅដល់គ្រួសារងាយរងគ្រោះ និងប៉ះពាល់ដោយជំងឺរាតត្បាតកូវីដ ១៩។ ទី៣ ការរៀបចំឥណទានឡើងវិញជាបញ្ហាប្រឈមសម្រាប់ករណីខ្ចីជំនួស ដែលក្នុងនោះអ្នកដែលមកខ្ចីប្រាក់ជាមនុស្សខុសពីអ្នកដែលទទួលខុសត្រូវចម្បងចំពោះការបង់សងត្រឡប់។ ក្នុងករណីខ្លះកូនបំណុលមិនអាចទទួលបានការរៀបចំឥណទានឡើងវិញ ពីព្រោះមុខរបររបស់ពួកគាត់មិនត្រូវបានចាត់ទុកថាប៉ះពាល់ដោយផ្ទាល់ដោយសារកូវីដ ១៩ ទោះបីជាអ្នកដែលជួយកូនបំណុលបង់សងបំណុលនោះ បានប៉ះពាល់ដោយផ្ទាល់ក៏ដោយ។

- ដំណើរការរៀបចំឥណទានឡើងវិញ ត្រូវបានកំណត់ដោយមន្ត្រីឥណទាន មិនមែនដោយកូនបំណុលនោះទេ។ ឈរលើទិន្នន័យដែលបានមកពីប្រធានសាខា និងមន្ត្រីឥណទានបង្ហាញថា មន្ត្រីឥណទានជាអ្នកដើរតួចម្បងក្នុងការកំណត់ថា កូនបំណុលណាមានលក្ខខណ្ឌគ្រប់គ្រាន់ ក្នុងការ ទទួលបានការរៀបចំឥណទានឡើងវិញ។ ការសងយឺតយ៉ាវ ជាលក្ខខណ្ឌចម្បងក្នុងការសម្គាល់ថាគ្រួសារណាបានបាត់បង់លទ្ធភាពសង ហើយដូច្នេះបានបំពេញលក្ខខណ្ឌសម្រាប់ការទទួលការរៀបចំឥណទានឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ យោងតាមវិធីផ្សេងៗដែលគ្រួសាររងសម្ពាធបំណុលបានប្រើក្នុងការសងប្រាក់ កូនបំណុលអាចនឹងធ្លាក់ខ្លួនយ៉ាប់យ៉ឺនមុននឹងលេចចេញជាបញ្ហាសងប្រាក់យឺតយ៉ាវ។ ដូច្នេះ បញ្ហាមួយដែលត្រូវព្រួយបារម្ភជាចម្បងនោះគឺថាការយកការសងយឺត ក្នុងការសម្គាល់ថាគ្រួសារណាបានបាត់បង់លទ្ធភាពសង មានន័យថា បានបិទផ្លូវអស់រួចទៅហើយក្នុងការការ

ពារអតិថិជន។ បើប្រៀបធៀបទៅហាក់ដូចជារង់ចាំឲ្យជំងឺមហារីកវិភាគឃើញដល់ដំណាក់កាលទីពីរ ឬទីបីអញ្ចឹង។ លើសពីនេះទៀតការដាក់បន្ទុកលើមន្ត្រីឥណទានទទួលខុសត្រូវបែងចែកថាកូនបំណុលណាត្រូវការឬសមនឹងទទួលបានការរៀបចំឥណទានឡើងវិញ ហើយដោយគ្មានឧបករណ៍ ការបណ្តុះបណ្តាល និងវិធីវាយតម្លៃដ៏ត្រឹមត្រូវនៅនឹងកន្លែង ទំនងជាធ្វើឲ្យការវាយតម្លៃមានភាពលម្អៀង និងមិនអាចគ្រប់គ្រងជ្រោយ។ ការដាក់បន្ទុកឲ្យមន្ត្រីឥណទានជាអ្នកទទួលខុសត្រូវ ក៏ជាប្រការមួយមិនលើកទឹកចិត្តឲ្យកូនបំណុលបានចូលរួមដោយសកម្មក្នុងដំណើរការឥណទាន និងតស៊ូមតិដើម្បីបំពេញតម្រូវការរបស់ខ្លួនឡើយ។ ធ្វើដូច្នេះអាចនឹងនាំឲ្យមានការយល់ច្រឡំក្នុងការស្វែងយល់ពីស្ថានភាពផលប័ត្រឥណទានរបស់ពួកគាត់។

- គោលនយោបាយរៀបចំឥណទានឡើងវិញបានជួយវិស័យមីក្រូហិរញ្ញវត្ថុឲ្យចៀសផុតពីវិបត្តិ ដោយសារធ្វើឲ្យកូនបំណុលមានពេលវេលាសម្រាប់រកការងារបណ្តោះអាសន្ន ឬរៀបចំមុខរបរឡើងវិញ (ឬក៏បានធ្វើទាំងពីរតែម្តង)។ ទោះជាយ៉ាងណាក៏ដោយការអនុញ្ញាតឲ្យកូនបំណុលរើសយកវិធីរៀបចំឥណទានឡើងវិញដោយសងតែប្រាក់ការ (ទុកប្រាក់ដើម) ចុងក្រោយមកបណ្តាលឲ្យកើនឡើងនូវចំនួនប្រាក់ដែលកូនបំណុលត្រូវបង់សរុបចំពោះឥណទាន។

- សរុបទៅគ្រួសារដែលត្រូវបានប៉ះពាល់ ហើយដែលជាប់បំណុលឥណទាន អាចដោះស្រាយវិបត្តិនេះបាន តាមរយៈការទទួលបានគោលការណ៍រៀបចំឥណទានឡើងវិញ ការឧបត្ថម្ភជាសាច់ប្រាក់ក្នុងលក្ខណៈមិនអចិន្ត្រៃយ៍របស់រដ្ឋាភិបាល និងការបង្វិលលុយក្នុងរង្វង់សាច់ញាតិ។ គ្រួសារនានាអាចងើបឡើងពីការធ្លាក់ចុះខាងសេដ្ឋកិច្ច ក្នុងករណីដែលគ្រួសារទាំងនោះអាចទទួលបាននូវយន្តការជួយឧបត្ថម្ភទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ គ្រួសារងាយរងគ្រោះដែលយើងបានសម្ភាសមិនអាចទទួលបានយន្តការទាំងនេះក្នុងពេលតែមួយនោះទេ នេះបង្កឲ្យមានការព្រួយបារម្ភខ្លាំងថា គ្រួសារទាំងនេះនឹងអាច កាន់តែធ្លាក់ជ្រៅទៅៗក្នុងអន្លង់បំណុល។

## វិធីសាស្ត្រឆ្លើយតបផ្សេងៗសម្រាប់ភាគីពាក់ព័ន្ធ

- ក្នុងបច្ចុប្បន្ននេះគោលការណ៍ស្តីពីកិច្ចគាំពារអតិថិជន (គ.ក.អ) ដែលបានផ្តួចផ្តើមដោយយុទ្ធនាការសកល ស្មាត (SMART Campaign) មិនចងកាតព្វកិច្ចតាមផ្លូវច្បាប់ទេ ហើយ ការអនុវត្តត្រូវគ្រប់គ្រងដោយខ្លួនឯង។ ភាគីរដ្ឋាភិបាលអាចពិចារណាចេញវិធានការមួយដែលដាក់ (គ.ក.អ) បច្ចុប្បន្ននេះឲ្យក្លាយទៅជាច្បាប់ ព្រមទាំងបើកឲ្យមានការពិន័យចំពោះគ្រឹះស្ថានណាដែលមិនអនុវត្តតាម (គ.ក.អ) នេះ។

- ធ.ជ.ក (NBC) អាចពិចារណាបង្កើតនូវមណ្ឌលទិន្នន័យនៃឥណទានមូលដ្ឋាន ដែលសាធារណជនអាចចូលមើលបាន ដើម្បីឲ្យកូនបំណុលជ្រើសរើសយកមួយណាក្នុងចំណោមគ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុ។ នេះជាគោលការណ៍មួយនៃ គ.ក.អ ពោលគឺតម្លាភាព អាចនឹងយកមកអនុវត្ត។ ឧទាហរណ៍ ធ.ជ.ក អាចជួយផ្តល់ឲ្យមានប្រព័ន្ធទិន្នន័យអនឡាញ ជាភាសាខ្មែរផង និងជាភាសាអង់គ្លេសផង ដោយដាក់ឈ្មោះគ្រប់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ដែលបានចុះឈ្មោះជាមួយ ធ.ជ.ក។ មណ្ឌលទិន្នន័យនេះ នឹងត្រូវតម្រូវឲ្យមានរបាយការណ៍ដាក់មកជាកាតព្វកិច្ច ហើយព័ត៌មានក្នុងរបាយការណ៍នោះ មានដូចជាអត្រាការប្រាក់

ជាមធ្យម ឬក៏កម្រិតការប្រាក់ ប្រាក់បង់ថ្លៃសេវាជាមធ្យម ឬកម្រិតបង់ថ្លៃសេវា យន្តការតវ៉ាចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងលក្ខខណ្ឌទាំងឡាយនៃឥណទាន ព្រមទាំងគោលការណ៍ដែលមានចែងក្នុង គ.ក.អ ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះបេជ្ញាគោរពតាម។ ព័ត៌មាននេះគួរតែដាក់នៅមណ្ឌលកណ្ដាលមួយ ហើយដាក់ឲ្យសាធារណជនអាចប្រើប្រាស់បាន។

- គ្រប់ជម្រើសដែលអាចធ្វើបាននៅក្នុងគោលការណ៍រៀបចំឥណទានឡើងវិញ គួរតែដាក់ឲ្យប្រើប្រាស់បានចំពោះគ្រប់គ្រួសារទាំងអស់ដែលបានរងការប៉ះពាល់។ ខណៈដែលនាបច្ចុប្បន្ន គោលការណ៍នេះមានចែងនៅលើក្រដាស ការអនុវត្តមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ។ វាជាកត្តាសំខាន់ខ្លាំងណាស់ ដែលអ្នកចាត់ការគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាន់ខ្ពស់ ត្រូវធានាឲ្យបានថា បុគ្គលិកដែលចុះផ្ទាល់ជាមួយគ្រួសារ ផ្ដល់គ្រប់ជម្រើសដែលមានឲ្យអតិថិជនបានដឹង ជាពិសេសគឺគ្រួសារដែលបានប៉ះពាល់ដោយវិបត្តិជំងឺរាតត្បាតកូវីដ ១៩ ហើយក៏ត្រូវធានាថា ប្រាកដជាមានការអនុវត្តគោលការណ៍ទាំងនេះដោយល្អិតល្អន់ ដោយរលូន និងដោយយុត្តិធម៌។ កាលណាមិនមានជម្រើសរៀបចំឥណទានឡើងវិញសមរម្យ ផ្ដល់ឲ្យចំពោះគ្រួសារដែលបានប៉ះពាល់ ហើយត្រូវការវានោះទេ នោះករណីនេះនឹងនាំឲ្យឈានដល់ដំណាក់កាលប្រើប្រាស់វិធីដោះស្រាយដូចជា ចំណាកស្រុកដែលមានហានិភ័យខ្ពស់ ការកាត់បន្ថយការចំណាយប្រចាំថ្ងៃ ដកកូនចៅចេញពីសាលា (ឬ កូនៗសម្រេចឈប់រៀនដោយខ្លួនឯង) ព្រមទាំងការលក់ទ្រព្យសកម្ម ដូចជាដីធ្លីជាដើម។ វិធីដោះស្រាយទាំងនេះអាចធ្វើឲ្យគ្រួសារទទួលប្រាក់ចំណូលទាបមានភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចកាន់តែខ្លាំង។

- ការរៀបចំឥណទានឡើងវិញនៅពេលអនាគតគួរតែផ្ដល់ឱកាសឲ្យទាំងមន្ត្រីឥណទាន ទាំងកូនបំណុលចូលរួមសម្រេចក្នុងដំណើរការនោះ។ ករណីនេះនឹងត្រូវការឲ្យបុគ្គលិកដែលចុះជួបកូនបំណុលពន្យល់ផ្ទាល់មាត់ជាភាសាសាមញ្ញដល់កូនបំណុលអំពីយន្តការដែលមានស្រាប់ ព្រមទាំង ជម្រើសនៃវិធីទាំងឡាយដែលអាចមាន ឲ្យកូនបំណុលយកមកដោះស្រាយបញ្ហាបំណុល។ ព័ត៌មាននេះគួរតែផ្ដល់ឲ្យបានឆាប់នៅដំណាក់កាលដំបូង គឺនៅពេលដាក់ពាក្យសុំឥណទាន និង/ឬ ផ្សាយឲ្យបានកាន់តែទូលាយដោយគ្រឹះស្ថានហិរញ្ញវត្ថុ រដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងៗ។

- គ្រឹះស្ថានហិរញ្ញវត្ថុ និង ធ.ជ.ក គួរតែផ្សព្វផ្សាយឲ្យបានច្បាស់ថា ការរៀបចំឥណទានឡើងវិញមិនប៉ះពាល់ដល់ប្រវត្តិឥណទាន (ទូទាត់សង) និងឱកាសនៅពេលអនាគតក្នុងការទទួលបានឥណទានសារជាថ្មីនោះទេ។ ព័ត៌មាននេះគួរតែបញ្ជូនឲ្យដល់បុគ្គលិកមូលដ្ឋាន និងកូនបំណុលក្នុងលក្ខណៈជាគោលនយោបាយឯកភាពមួយដែល ធ.ជ.ក បានគាំទ្រ។

- រដ្ឋាភិបាលគួរពិចារណាចេញច្បាប់ស្ដីពីក្ស័យធនជាបុគ្គល ដែលតម្រូវឲ្យមានការសង្គ្រោះអ្នកជាប់បំណុលធ្ងន់ធ្ងរ ជាពិសេសដូចជាគ្រួសារដែលមានប្រាក់ចំណូលទាប។ ផ្អែកទៅលើច្បាប់ស្ដីអំពី*ក្ស័យធន* ឆ្នាំ២០០៧ លេខ នស/រកម/១០២៧/០៣១ ទីមួយ រដ្ឋាភិបាលអាចចេញសេចក្ដីណែនាំឲ្យមានការបែងចែកច្បាស់លាស់រវាងការអនុវត្តច្បាប់ក្ស័យធនចំពោះធុរកិច្ច និងច្បាប់ក្ស័យធនជាបុគ្គល ចំពោះពលរដ្ឋម្នាក់ៗ។ ទីពីរ ត្រូវមានការសម្រួលដំណើរការធ្វើយ៉ាងណាឲ្យច្បាប់បានដឹងឮច្រើន និងជ្រាបទៅដល់សាធារណជន ជាពិសេសទៅដល់គ្រួសារដែលងាយរងគ្រោះ។ នាបច្ចុប្បន្ន ច្បាប់ក្ស័យធនដែលមានស្រាប់មិនសូវបានដឹង

ដល់សាធារណជននោះទេ ដោយសារច្បាប់នោះមាននីតិវិធីស្មុគស្មាញ មានចំណុចខ្វះខាត និងមិនច្បាស់លាស់។[2] លើសពីនេះប្រសិនបើសាធារណជនដឹងពីច្បាប់ក្ស័យធនសម្រាប់បុគ្គល ថាអាចប្រើប្រាស់បាន ចំណេះដឹងជាសាធារណនេះក៏រួមចំណែកផងដែរក្នុងកិច្ចគាំពារបានល្អប្រសើរ ដោយសារធ្វើដូច្នេះអាចកាត់បន្ថយការអនុវត្តឲ្យប្រាក់កម្ចីដែលមានហានិភ័យខ្ពស់។

- ការលុតលាស់ដល់ផ្នែកវិស័យហិរញ្ញវត្ថុ និងវិធានការការពារអតិថិជន គួរតែមានអាទិភាពស្មើរគ្នា ដូច្នេះហើយ ដៃគូអភិវឌ្ឍន៍គួរផ្តល់មូលនិធិសម្រាប់កម្មវិធីការអប់រំផ្នែកហិរញ្ញវត្ថុ ទៅដល់គ្រួសារដែលមានចំណូលទាប ដោយផ្តោតសំខាន់ទៅលើសិទ្ធិស្តីពីកិច្ចគាំពារអតិថិជន និងសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ឥណទាន។

- ជាជំនួយបន្ថែមដល់មណ្ឌលទិន្នន័យ ភាគីអភិវឌ្ឍន៍អាចបង្កើតយន្តការវេទិកាសាធារណៈដោយឯករាជ្យដែលអ្នកប្រើប្រាស់ ឥណទាន អាចចែករំលែកបទពិសោធន៍អំពីគ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុ។ ឧទាហរណ៍ វេទិកាសាធារណៈនេះអាចជាលក្ខណអនឡាញតាមបច្ចេកវិទ្យាព័ត៌មានដែលមានប្រើភាសាខ្មែរ។ ចំពោះការចែករំលែកបទពិសោធន៍ និងមតិរិះគន់ត្រូវធ្វើឲ្យបាននូវភាពមាន គុណភាពខ្ពស់ និងភាពដែលអាចទុកចិត្តបាន ដោយដាក់ឲ្យមានប្រព័ន្ធត្រួតពិនិត្យយ៉ាងម៉ត់ចត់។ អ្នកបង្កើត វេទិកាសាធារណៈអនឡាញនេះ ត្រូវគិតផងដែរថាតើត្រូវទាក់ទាញអ្នកប្រើប្រាស់យ៉ាងម៉េចដោយដឹងថា មានអ្នកប្រើប្រាស់ជាច្រើនប្រហែល ជាមិនទាន់បានភ្ជាប់ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់ជ្រុងជ្រោយនោះទេ។

[2] Ly 2020.

# I. សេចក្តីផ្តើម

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ប្រទេសកម្ពុជាបានរកឃើញ និងប្រកាសថាមានជំងឺរាតត្បាតកូវីដ ១៩ ជាលើកដំបូង។ យោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក (WHO) បោះពុម្ពផ្សាយនៅខែ ឧសភា ឆ្នាំ២០២០ បានសង្កេតឃើញថា កម្ពុជាឆ្លើយតបដោយមានប្រសិទ្ធភាពដោយជោគជ័យ និងដោយឆាប់រហ័សទៅនឹងជំងឺរាតត្បាតនេះ តែការសន្និដ្ឋាននេះនូវមិនមានការប្រាកដប្រជានៅឡើយដោយសារជំងឺរាតត្បាតកូវីដ ១៩ នៅតែបន្ត។ ប៉ុន្តែទោះជា ក្នុងខណៈពេលនោះ កម្ពុជាទទួលបានជោគជ័យក្នុងការទប់ទល់ជំងឺនេះក៏ដោយ ក៏ផលប៉ះពាល់សេដ្ឋកិច្ចនៅតែមាន។ ដោយសារកម្ពុជាបានក្លាយទៅជាផ្នែកមួយនៃសកលភាវូបនីយកម្ម កម្ពុជាមិនអាចចៀសផុតពីការធ្លាក់ចុះសេដ្ឋកិច្ចដោយសារជំងឺរាតត្បាតកូវីដ ១៩ នេះបានឡើយ។ តាមពិតបណ្តារដ្ឋនៅទូទាំងអាស៊ីប៉ាស៊ីហ្វិកទំនងជា នឹងទទួលផលប៉ះពាល់សេដ្ឋកិច្ចធ្ងន់ធ្ងរ ដោយធនាគារអភិវឌ្ឍន៍អាស៊ីព្យាករថានឹងមានសេដ្ឋកិច្ចធ្លាក់ចុះក្នុងរង្វង់ពី ១,៧ ទៅដល់ ២,៥ ពាន់លានដុល្លារសហរដ្ឋអាមេរិក។[៤]

### គំនូសតាង ១. កំណើន និងការព្យាករ ផ.ស.ស




*ប្រភព៖ មូលនិធិហិរញ្ញវត្ថុអន្តរជាតិ ឆ្នាំ២០១២ ខែតុលា ឆ្នាំ២០២០*

ការធ្លាក់ចុះសេដ្ឋកិច្ចនេះកើតឡើងក្រោយពីប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចរឹងមាំ និងស្ថិតស្ថេរអស់រយៈពេលមួយទសវត្សរ៍។ បន្ទាប់ពីមានកំណើនជាមធ្យមអត្រា ៧% ចាប់តាំងពីឆ្នាំ២០១១ មកដល់ឆ្នាំ២០២០ ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាបានព្យាករថានឹងធ្លាក់ចុះដល់ ២,៨% (សូមមើលគំនូសតាង ១)។ មូលហេតុសំខាន់គឺបណ្តាលមកពីផលប៉ះពាល់ធ្ងន់ធ្ងរនៃជំងឺរាតត្បាតកូវីដ ១៩ មកលើវិស័យសំខាន់ៗដែលជំរុញកំណើនសេដ្ឋកិច្ច៖ ដូចជា ទេសចរណ៍ សំណង់ និងការផលិតសម្លៀកបំពាក់។

---

[3] World Health Organization 2020.
[4] Asian Development Bank 2020.
[5] International Monetary Fund October 2020.

ជំងឺរាតត្បាតកូវីដ ១៩ បានរាំងស្ទះដល់សង្វាក់ផ្គត់ផ្គង់ បង្ខំឲ្យរឹតបន្តឹងចរាចរណ៍នៅបណ្តាប្រទេសនានា ព្រមទាំងបណ្តាលឲ្យបាត់បង់ការងារនៅក្នុងវិស័យជាច្រើន។ អាស្រ័យហេតុនេះហើយបានជាប្រទេសកម្ពុជាបានព្យាករថា អាចនឹងបាត់បង់ការងារចំនួន ១,៧៦ លាន។ គ្រួសារងាយរងគ្រោះ និងមានចំណូលទាប ទំនងនឹងទទួលផលប៉ះពាល់សេដ្ឋកិច្ចធ្លាក់ចុះនេះធ្ងន់ធ្ងរជាងគេ។ បញ្ហាទាំងនេះបណ្តាលឲ្យធនាគារពិភពលោក (២០២០:៣) ចេញសេចក្តីថ្លែងការណ៍ថា "វិបត្តិសេដ្ឋកិច្ច និងជំងឺរាតត្បាតជាសកលបណ្តាលមកពីជំងឺកូវីដ ១៩ គឺជាការគំរាមកំហែងធ្ងន់ធ្ងរបំផុតចំពោះការអភិវឌ្ឍនៃប្រទេសកម្ពុជាក្នុងរយៈពេល ៣០ ឆ្នាំចុងក្រោយនេះ ... ភាពក្រីក្រអាចនឹងកើនឡើងពី ៣ ទៅដល់ ១១% ដោយបាត់បង់ចំណូលចាប់ពី ៥០% ឡើងក្នុងរយៈពេល ៦ ខែ ចំពោះគ្រួសារដែលប្រកបរបរក្នុងវិស័យទេសចរណ៍ លក់ដូរដុំ និងរាយ ការផលិតសម្លៀកបំពាក់ សំណង់ ឬកម្មន្តសាល។"

ការធ្លាក់ចុះសេដ្ឋកិច្ចដោយសារជំងឺរាតត្បាតកូវីដ ១៩ បណ្តាលឲ្យមានការព្រួយបារម្ភខ្លាំងនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក៏ដូចជានៅក្នុងចំណោមអតិថិជននៃវិស័យនេះ។ មុនពេលកើតមានជំងឺរាតត្បាតនេះ ដៃគូមួយចំនួនបានសម្តែងការព្រួយបារម្ភរួចហើយ អំពីកម្រិតកើនឡើងខ្ពស់នៃគ្រួសារជំពាក់បំណុលវ័ណ្ឌក ព្រមទាំងអំពីទំនាក់ទំនងនៃប្រាក់បំណុលទៅនឹងភាពងាយរងគ្រោះនៃគ្រួសារនីមួយៗ។ ឧទាហរណ៍ ជំរឿន (N=802) បានធ្វើឡើងនៅឆ្នាំ២០១៧ ដោយភាគីក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាមួយនឹងគ្រួសារកូនបំណុលនៅក្នុងខេត្តចំនួន ១២ និងនៅរាជធានីភ្នំពេញបានបង្ហាញថា ២៨% នៃគ្រួសារកូនបំណុលមីក្រូហិរញ្ញវត្ថុធ្លាក់ក្នុងស្ថានភាពអសាធនីយ ហើយ ២២% ទៀត ជួបបញ្ហាធ្ងន់ធ្ងរ ឬមានហានិភ័យខ្ពស់។ ការស្រាវជ្រាវជាន់ខ្ពស់នៅក្នុងតំបន់បានចង្អុលបង្ហាញថា មានបញ្ហាជាក់លាក់មួយចំនួនបានកើតឡើងដោយសារការជំពាក់បំណុលវ័ណ្ឌកជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចជាការបាត់បង់ដីធ្លី ការធ្វើចំណាកស្រុកបណ្តាលមកពីការរងសម្ពាធ ការធ្លាក់ចុះកម្រិតអាហារូបត្ថម្ភនៅក្នុងគ្រួសារដោយបានកាត់ចំណាយលើម្ហូបអាហារ ព្រមទាំងការជាប់អន្ទាក់បំណុល។ ដោយសារមានវិបត្តិជំងឺរាតត្បាតកូវីដ ១៩ គ្រួសារងាយរងគ្រោះកាន់តែមានជីវភាពមិននឹងនរ ក្នុងនោះគ្រួសារជាច្រើនបានបាត់បង់ ឬថយចុះដោយគំហុកនូវប្រភពចំណូលសំខាន់ បណ្តាលមកពីការរាំងស្ទះជាទូទៅនៃមុខរបរ។ ការបាត់បង់ទាំងនេះធ្វើឲ្យគ្រួសារទាំងឡាយកាន់តែលំបាកក្នុងការសងបំណុល។

នៅក្នុងបរិបទដែលមានផលប៉ះពាល់សេដ្ឋកិច្ចនៃជំងឺរាតត្បាតកូវីដ ១៩ និងការព្រួយបារម្ភកាន់តែខ្លាំងឡើងអំពីគ្រួសារជាប់បំណុល របាយការណ៍នេះព្យាយាមបង្ហាញឲ្យឃើញនូវផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ ១៩ មកលើកូនបំណុលមីក្រូហិរញ្ញវត្ថុ ដែលបានបាត់ប្រាក់ចំណូលដោយសារជំងឺនេះ។ ជាពិសេសរបាយការណ៍នេះផ្តោតទៅលើគ្រួសារដែលជាអតិថិជនរបស់មីក្រូហិរញ្ញវត្ថុ ដែលប្រកបរបរជាកម្មកររោងចក្រ ក្នុងវិស័យទេសចរណ៍ កសិកម្ម ឬកម្មករចំណាកស្រុកមុនពេលកើតកូវីដ ១៩។ ទីមួយ របាយការណ៍នេះចងក្រងលក្ខណៈដែលជំងឺរាតត្បាតកូវីដ ១៩ បានប៉ះពាល់ដល់សន្តិសុខខាងសេដ្ឋកិច្ច ក្នុងចំណោមគ្រួសារកូនបំណុល ព្រមទាំងចងក្រងវិធីដោះស្រាយទាំងឡាយដែលបានប្រើដោះស្រាយការបាត់បង់ទាំងនេះ។ បន្ទាប់មក របាយការណ៍នេះស្វែងយល់ពីវិធីដែលគ្រឹះស្ថានហិរញ្ញវត្ថុ (ធនាគារ និង គ.ម.ហ) ប្រើក្នុងការជួយដល់កូនបំណុលក្នុងពេលកើតមានវិបត្តិនេះ និងស្វែងយល់ពីរបៀបរៀបចំតណទានឡើងវិញ ដែលបើកឲ្យកូនបំណុលប្រើប្រាស់ ដោយសារពួកគាត់ទទួលការប៉ះពាល់ពីជំងឺកូវីដ ១៩។ ដើម្បីធ្វើការស្វែងយល់នេះ របាយការណ៍ក៏ចង្អុលបង្ហាញនូវកាលានុវត្តភាព និងកិច្ចគាំពារអតិថិជនដែលនៅមានកម្រិត ក្នុងវិស័យហិរញ្ញវត្ថុ។ ចុងបញ្ចប់ របាយការណ៍នេះអំពាវនាវដល់ដៃគូផ្សេងៗឲ្យទទួលខុសត្រូវ ទប់ទល់ការធ្លាក់ចុះសេដ្ឋកិច្ចបណ្តាលមកពីវិបត្តិនេះ ព្រមទាំងឲ្យបង្កើនការការពារដល់គ្រួសារមានប្រាក់ចំណូលទាប ជាពិសេសដល់គ្រួសារដែលត្រដាបត្រដួសក្នុងការសងបំណុល។ មុននឹងឈានចូលដល់ផ្នែកទាំងនេះ នៅក្នុងផ្នែកបន្ទាប់ របាយការណ៍នេះនឹងរៀបរាប់សង្ខេបពីសភាពការណ៍នៅប្រទេសកម្ពុជាមុនជំងឺរាតត្បាតកូវីដ ១៩ ដោយផ្តោតសំខាន់លើបញ្ហាជាប់បំណុល និងយន្តការគាំពារអតិថិជនក្នុងវិស័យហិរញ្ញវត្ថុ។

6 World Bank 2020.
7 World Bank 2020:3.
8 Ovesen and Trankell 2014; Bylander et al 2017; MFC and Good Return 2017; Bateman 2019; LICADHO 2019.
9 MFC and Good Return 2017.
10 Green 2018; Green & Bylander forthcoming.
11 Bylander 2014; Ovesen and Trankell 2014; Green and Estes 2018.
12 Seng 2018.
13 Natarajan et al 2020.

# II. សាវតារ

គិតមកត្រឹមចុងឆ្នាំ២០២០ គ.ម.ហ បានផ្តល់ឥណទានក្នុងអត្រាការប្រាក់ទាប (បើប្រៀបធៀបទៅនឹងអត្រាការប្រាក់របស់ម្ចាស់បំណុលឯកជនក្រៅប្រព័ន្ធ) ដល់កូនបំណុលប្រហែល ២,២ លាននាក់នៅប្រទេសកម្ពុជា។ គ.ម.ហ ក៏បានផ្តល់ឥណទានគិតជាសាច់ប្រាក់ហើយដែលមិនទាន់បានសងមកវិញចំនួន ៨,១ ពាន់លានដុល្លារសហរដ្ឋអាមេរិក។[14] គិតត្រឹមឆ្នាំ២០១៩ វិស័យនេះបានប្រើកម្លាំងពលកម្មកម្ពុជាចំនួនសរុប ៣៥.១៦៩នាក់ ជាពិសេសគឺយុវជន[15] ហើយបានផ្តល់ដល់កម្លាំងពលកម្មទាំងនោះនូវរបបធានារ៉ាប់រងសុខភាពផ្លូវការបែបឯកជន និង ឬ ចាត់ចែងដោយរដ្ឋាភិបាល ក៏ដូចជាមានផលប្រយោជន៍ផ្សេងៗផងដែរ។ វិស័យនេះក៏បានជួយផងដែរដល់ប្អូនៗនិស្សិតបរិញ្ញាបត្រក្នុងការបង់ថ្លៃការសិក្សា តាមរយៈឱកាសធ្វើការងារទាំងនេះ។ លើសពីនេះទៀត មីក្រូហិរញ្ញវត្ថុ បានជួយដល់ប្រជាជនជនបទមួយចំនួនឲ្យបានប្រើទឹកស្អាត និងមានអនាម័យប្រសើរឡើងតាមរយៈការផ្តល់ឥណទានឲ្យទិញឧបករណ៍ចម្រោះទឹក និងបង្គន់។

វាច្បាស់ណាស់ថា មីក្រូហិរញ្ញវត្ថុបានជួយដល់ប្រជាជនមួយចំនួនប៉ុន្តែតាមទិសដៅបច្ចុប្បន្នដែលវិស័យនេះកំពុងតែឈានទៅរកនោះ គឺមានលក្ខណៈគួរឲ្យព្រួយបារម្ភ។ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាបានប្រែប្រួលកន្លងមកយ៉ាងឆាប់រហ័សក្នុងពេលបីទសវត្សរ៍។ ប្រទេសកម្ពុជាបានបើករបបសេដ្ឋកិច្ចទីផ្សារសេរីនៅក្នុងដើមទសវត្សរ៍ ១៩៩០ ហើយ នៅពេលនោះ មីក្រូឥណទានបានផ្តល់ទៅឲ្យគ្រួសារជនបទក្រីក្រក្រោមកម្មវិធីអភិវឌ្ឍន៍ផ្សេងៗដឹកនាំដោយអង្គការអន្តរជាតិ ដែលដាក់គោលដៅបេសកកម្មសង្គមរបស់ខ្លួនទៅលើការកាត់បន្ថយភាពក្រីក្រ។ គ.ម.ហ ដែលកើតដំបូង និងល្បីល្បាញជាងគេនោះគឺ សមាគមភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានកម្ពុជា (អេស៊ីលីដា) ដែលជា គ.ម.ហ មួយកើតចេញពីគម្រោងអភិវឌ្ឍន៍ពីដំបូងរបស់ យូអិនឌីភី។ ដូចគ្នាផងដែរ គ.ម.ហ ធំៗភាគច្រើននៅកម្ពុជាមានប្រភពចេញមកពីវិស័យអភិវឌ្ឍន៍។ ពីរបីឆ្នាំក្រោយពីអេស៊ីលីដាត្រូវបានបង្កើត អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិផ្សេងៗខាងវិស័យអភិវឌ្ឍន៍ក៏បានចូលរួមក្នុងវិស័យនេះដូចគ្នា។ ឧទាហរណ៍ នៅឆ្នាំ១៩៩៤ អង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យមនុស្សធម៌ឈ្មោះ សេវាជំនួយសង្គ្រោះកាតូលិក បានបង្កើតធនាគារភូមិ ហើយក្រោយមកត្រូវក្រុមហ៊ុនសាជីវកម្មអន្តរជាតិទិញយក ហើយដូរឈ្មោះដាក់ជា អិលអូអិលស៊ី (ខេមបូឌា)។ នៅឆ្នាំ១៩៩៥ អង្គការប្រាសាក់ បានចាប់ផ្តើមចេញពីគម្រោងអភិវឌ្ឍន៍ដោយបានការឧបត្ថម្ភថវិកាពីសហភាពអឺរ៉ុប ដោយមានគោលដៅស្តារ និងទ្រទ្រង់ដល់វិស័យកសិកម្ម។ អម្រឹត កើតចេញមកពីអង្គការហ្គ្រេត (GRET) ជាអង្គការមិនមែនរដ្ឋាភិបាលរបស់បារាំង ដំណើរការគម្រោងផ្តល់មីក្រូឥណទានដល់ប្រជាជនរស់នៅជនបទក្នុងប្រទេសកម្ពុជា ហើយក្នុងពេលប្រហាក់ប្រហែលគ្នានេះ អង្គការ ខន់ស៊ីន (Concern) ក៏បានបង្កើត អេអឹមខេ អូស៊ីអេសឌី/អក់ស្វាមកេបេក (OCSD/OXFARM Quebec) បង្កើតហត្ថាកសិករ ហើយ វើលរីលីវ យូអេស (World Relief US) បានបង្កើតក្រេឌីត។[16]

មកដល់ដើមទសវត្សរ៍២០០០ ភាគច្រើននៃអង្គការទាំងនេះ បានកែប្រែ ហើយបានទទួលអាជ្ញាបណ្ណប្រតិបត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមកពីធនាគារជាតិនៃកម្ពុជា។[17] មួយទសវត្សរ៍ក្រោយពីវិស័យនេះបានកែប្រែ អ្នកសិក្សាជាន់ខ្ពស់មួយចំនួនក៏ចាប់ផ្តើមសម្តែងការព្រួយបារម្ភថា កម្ពុជាជាប្រទេសមួយនៅលើពិភពលោកដែលមានវិស័យមីក្រូហិរញ្ញវត្ថុច្រើនជោគជាំ។[18] នៅចុងឆ្នាំ ២០០៩

---

[14] ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយ សមហាក នៅក្នុងខែធ្នូ ឆ្នាំ២០២០។

[15] ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយ សមហាក នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១។

[16] ព័ត៌មានយកមកពីរបាយការណ៍ប្រចាំឆ្នាំរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងគេហទំព័រ។

[17] ដូចខាងលើ។

[18] Gonzalez 2010; Gonzalez & Javoy 2011; Krauss et al 2012.

ប្រព័ន្ធមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមាន គ.ម.ហ ដែលបានអាជ្ញាបណ្ណចំនួន ២០ ប្រតិបត្តករឥណទានជនបទដែលបានចុះបញ្ជីចំនួន ២៦ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលចំនួនប្រហែល ៦០ ទាំងអស់នេះ សុទ្ធតែជាអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅប្រព័ន្ធនៅតំបន់ជាច្រើនទូទាំងកម្ពុជា។[19] គិតមកត្រឹមឆ្នាំ២០១៨ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣៥៣ ក្នុងនោះមានគ្រឹះស្ថានទទួលប្រាក់បញ្ញើមីក្រូហិរញ្ញវត្ថុចំនួន ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៧៣ និងប្រតិបត្តិករឥណទានជនបទចំនួន ២៧៣។[20]

តើការប្រែប្រួលទាំងនេះបានប៉ះពាល់ដោយរបៀបណាដល់គោលការណ៍ គ.ម.ហ ក្នុងការលើកស្ទួយគ្រួសារដែលមានប្រាក់ចំណូលទាបឲ្យរួចផុតពីភាពក្រីក្រ? មានគ្រឹះស្ថានមួយចំនួនតូចរក្សាបាននូវបេសកកម្មសង្គម ប៉ុន្តែមួយចំនួនធំបានបោះបង់ចោលបេសកកម្មទាំងនោះទៅហើយ។ ចំពោះគ្រឹះស្ថានដែលនៅរក្សាបាននូវបេសកកម្មសង្គម របាយការណ៍នេះសួរថាតើពួកគេនឹងបន្តបេសកកម្មសង្គមបានដល់ពេលណា? មានឯកសារបានចងក្រងរួចមកហើយដែរ អំពីមីក្រូហិរញ្ញវត្ថុ នៅបង់ក្លាដេស[21] និងនៅឥណ្ឌា[22] បង្ហាញពីការប្រែប្រួលប្រហាក់ប្រហែលគ្នា ពោលគឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុងាកចេញពីបេសកកម្មសង្គម ទៅចាប់យកប្រាក់ចំណេញខ្ពស់ជាគោលបំណងចម្បង។

ការបើកឲ្យទូលំទូលាយនៃទីផ្សារហិរញ្ញវត្ថុនៅប្រទេសកម្ពុជាបានទាក់ទាញក្រុមហ៊ុន និងទុនអន្តរជាតិជាច្រើនឲ្យចូលមកវិនិយោគក្នុងប្រទេសន នេះក៏ជាការព្រួយបារម្ភផងដែរ។ នៅក្នុងឆ្នាំ២០១៨ យោងតាមជំរឿនមួយទៅលើវិនិយោគិនអន្តរជាតិ ប្រទេសកម្ពុជាទទួលបាន ៨,៤% នៃវិនិយោគផ្នែកមីក្រូហិរញ្ញវត្ថុសរុបទូទាំងពិភពលោក។ ផ្នែកឥណទាននៃវិស័យនេះបានឈរលំដាប់ទីពីរ នៅលើពិភពលោកបន្ទាប់ពីឥណ្ឌា ដែលជាប្រទេសមួយមានប្រជាជនទៅដល់ជិត៨៥ដងច្រើនជាងកម្ពុជា។[23] យោងតាមការសិក្សារបស់ មីម៉ូសា (MIMOSA) ដែលចេញនៅខែមីនា ឆ្នាំ២០២០ បានរកឃើញដូច្នេះថា អត្រានៃការប្រើប្រាស់ឥណទាននៅប្រទេសកម្ពុជា (មីក្រូហិរញ្ញវត្ថុ និងធនាគារ) គឺមានកម្រិតចន្លោះពី ២១,៨ ដល់ ៣៤,៩ ជាកូនបំណុលក្នុងចំណោមមនុស្សពេញវ័យ ១00នាក់។ ដោយទទួលបានពិន្ទុអប្បបរិមាចំនួន ៦ ដែលជាកម្រិតខ្ពស់ជាងគេ ដែលមាននៅក្នុងក្របខណ្ឌ មីម៉ូសា ហើយក៏ជាពិន្ទុខ្ពស់បំផុតក្នុងចំណោមបណ្តាប្រទេសទាំង ១១ ដែលបានយកទៅសិក្សា។[24] ការផ្តល់ហិរញ្ញវត្ថុរបៀបនេះ អាចនឹងរំលោភលើគោលការណ៍ស្តីពីកិច្ចគាំពារអតិថិជន និងជំរុញឲ្យមានការផ្តល់ឥណទានដោយប្រថុយប្រថាន (ឧទាហរណ៍របៀបនេះឃើញមានច្រើននៅទូទាំងពិភពលោក ដូចដែលកើតមានជាវិបត្តិដាក់ផ្ទះធានា ដែលមានចំណាត់ថ្នាក់ហានិភ័យខ្ពស់ នៅសហរដ្ឋអាមេរិកកាលពីចុងទសវត្សរ៍២000) ហើយវាអាចបង្កើនហានិភ័យដល់អ្នកជាប់ជំពាក់បំណុលវ័ណ្ឌក។ ជាការពិត ទីផ្សារឥណទានមានភាពផុយអាចស្រួយនឹងកើតមាននូវវដ្តនៃការកើនឡើង និងធ្លាក់ចុះជាញឹកញាប់ ហើយអាចនាំឲ្យជួបវិបត្តិក្នុងករណីគ្មានការអនុវត្តច្បាប់ដោយប្រសិទ្ធភាព។[25]

ក្នុងទសវត្សរ៍កន្លងទៅទាំងភាគីហិរញ្ញវត្ថុ ទាំងអ្នកសិក្សាជាន់ខ្ពស់បានសម្តែងការព្រួយបារម្ភចំពោះការកើនឡើងដោយឆាប់រហ័ស និងដល់កម្រិតតិត្ថិភាពនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងផលវិបាករបស់វា ដែលនាំឲ្យកើនឡើងបំណុលវ័ណ្ឌក និងសម្ពាធបំណុលក្នុងចំណោមគ្រួសារកូនបំណុល។[26] ការព្រួយបារម្ភនេះ មានការទទួលស្គាល់ផងដែរក្នុងចំណោមសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (ស.ម.ហ.ក) ដែលបានកត់សម្គាល់តាំងពីឆ្នាំ២០១៤ ថា បញ្ហាជាប់បំណុលវ័ណ្ឌកនេះ គឺជាបញ្ហាមួយក្នុងចំណោមការព្រួយបារម្ភធំៗទាំងបី ដែលធ្វើឲ្យខូចដល់ការលូតលាស់ប្រកបដោយចិរភាពនៃវិស័យនោះ។[27] នៅក្នុងឆ្នាំ២០១២ វិនិយោគិនមីក្រូហិរញ្ញវត្ថុបានចាត់ចែងឲ្យមានសិក្សាជាលើកដំបូងមួយ ស្តីអំពីបញ្ហាបំណុលវ័ណ្ឌកនៅកម្ពុជា ដោយសារព្រួយបារម្ភថា “បញ្ហាបំណុលវ័ណ្ឌកអាចនឹងក្លាយជាបញ្ហាធ្ងន់ធ្ងរក្នុងចំណោមហានិភ័យទាំងឡាយនៃវិស័យមីក្រូហិរញ្ញវត្ថុនាបច្ចុប្បន្ន។”[28] របកគំហើញនៃ

---

[19] NBC. 2009.

[20] NBC.2018:38.

[21] សូមមើល Karim 2011.

[22] សូមមើល Bateman 2010; Mader 2015.

[23] Symbiotics 2018 ដែលមានយោងនៅក្នុង Green 2020.

[24] MIMOSA 2020:7.

[25] Davel 2013.

[26] Gonzalez 2010; Gonzalez & Javoy 2011; Krauss et al 2012; Bylander et al 2017.

[27] CMA 2014.

[28] Liv 2013.

ការសិក្សានេះ បានលើកទឹកចិត្តឲ្យមានការសិក្សាធំមួយថ្នាក់ជាតិទៅលើបញ្ហាដដែល ដែលបានបញ្ចប់តែមិនបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៧។ របកគំហើញទាំងនោះចង្អុលបង្ហាញថា មានបញ្ហាបំណុលកម្រិតខ្ពស់នៅក្នុងចំណោមកូនបំណុលមីក្រូហិរញ្ញវត្ថុ។ ជំរឿននោះ (N=802) បានធ្វើជាមួយគ្រួសារកូនបំណុលនៅក្នុងខេត្តចំនួន ១២ និងនៅភ្នំពេញ ហើយបានបង្ហាញថា ២៨% នៃគ្រួសារកូនបំណុលមីក្រូហិរញ្ញវត្ថុធ្លាក់ក្នុងស្ថានភាពអសាធនីយ ហើយ ២២% ផ្សេងទៀតជួបបញ្ហាធ្ងន់ធ្ងរ ឬក៏មានហានិភ័យខ្ពស់។[29] ទោះជាអត្រាបង់សងបំណុលនៅពេលនេះនៅតែខ្ពស់ (២៨% នៃអតិថិជនបានបង់សងបំណុលទាន់ពេល ឬក្នុងរង្វង់ ៣០ថ្ងៃ) ក៏ដោយក៏កូនបំណុលមួយចំនួនធំបានសម្តែងនូវអារម្មណ៍តានតឹងផ្ទាល់ខ្លួនដោយសារសម្ពាធបំណុល។ របាយការណ៍ដដែលនេះកត់សម្គាល់ថាមានមូលហេតុមួយចំនួនដែលនាំឲ្យមានការលំបាកដោយសារសម្ពាធបំណុល (រួមមានទាំងកត្តាផ្គត់ផ្គង់ ដូចជាការលូតលាស់នៃគ្រឹះស្ថាន ការផ្តល់ឥណទាន ការប្រកួតប្រជែងរវាងគ្រឹះស្ថាន) កត្តាអតិថិជន (ដូចជាខ្ចីច្រើនមុខ ការលម្អៀងលក្ខណៈចិត្តសាស្ត្រ និងលក្ខណៈប្រជាសាស្ត្រ ដូចជាការអប់រំ) ព្រមទាំងកត្តាខាងក្រៅ (ដូចជាអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបរិស្ថាន)។

ការអនុវត្តច្បាប់ដែលនៅមានកម្រិតក៏រួមចំណែកមួយនៅក្នុងបញ្ហានេះដែរ។ អ្នកដែលធ្វើការនៅក្នុងវិស័យហិរញ្ញវត្ថុបានកត់សម្គាល់អំពីសារៈសំខាន់នៃការអនុវត្តច្បាប់ ដូចជាត្រូវ ហាមឃាត់នូវការផ្តល់ឥណទានដែលមិនបានបើកចំហ ដាក់កម្រិតទៅលើការបង្កើនប្រាក់ឥណទានជាស្វ័យប្រវត្តិ (ឬការឲ្យខ្ចីបន្ថែម) ដាក់កំណត់លើប្រាក់ជើងសារឥណទានចំពោះបុគ្គលិកឥណទាន ដាក់កាតព្វកិច្ចតម្រូវធ្វើការវាយតម្លៃលើលទ្ធភាពសងវិញបាន និងកម្មវិធីប្រឹក្សាឃ្លាំមើលវិស័យ (ក្នុងចំណោមកម្មវិធីផ្សេងៗ) យកមកធ្វើជាវិធីសំខាន់ដើម្បីត្រួតពិនិត្យភាពហួសហេតុរបស់ទីផ្សារ។[30] នាបច្ចុប្បន្ននេះ រដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវបញ្ញត្តិមួយចំនួនទៅលើវិស័យមីក្រូហិរញ្ញវត្ថុ តែនៅមានកម្រិតនៅឡើយ។ មជ្ឈមណ្ឌលសម្រាប់បរិយាបណ្ណហិរញ្ញវត្ថុ (CFI) បានកត់សម្គាល់ថា នៅកម្ពុជាបច្ចុប្បន្នលិខិតបទដ្ឋានគតិយុត្តស្តីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ នៅមានការខ្វះខាត។[31] លើសពីនេះទៀត យោងទៅតាមរបាយការណ៍ "មីក្រូទស្សន៍ (Microscope)" របស់អង្គភាពព័ត៌មានអ្នកសេដ្ឋកិច្ច បង្ហាញថា ប្រទេសកម្ពុជាឈរនៅស្ទើរតែក្រោមគេបំផុតក្នុងវិស័យកិច្ចគាំពារអតិថិជនឥណទាន។ ប្រទេសកម្ពុជាឈរនៅលំដាប់ ៥៣ បានពិន្ទុ ១៤ ខណៈដែលប្រទេសឥណ្ឌូនេស៊ីឈរនៅលំដាប់ ១៣ បានពិន្ទុ ៧៧ ក្នុងវិស័យគាំពារអ្នកប្រើប្រាស់ឥណទាន។[32]

ក្នុងរយៈពេល ៥ឆ្នាំ កន្លងទៅបញ្ហាបំណុលវ័ណ្ឌកកាន់តែព្រួយបារម្ភឡើង ហើយបញ្ហានេះបានធ្វើឲ្យមានការចាប់អារម្មណ៍ដល់អ្នកសិក្សាជាន់ខ្ពស់ អង្គការមិនមែនរដ្ឋាភិបាល វិនិយោគសង្គម ម្ចាស់ជំនួយ និងប្រតិបត្តិករក្នុងវិស័យហិរញ្ញវត្ថុ។ ប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ បញ្ហាទាំងនេះក៏បានទាញការចាប់អារម្មណ៍ពីបណ្តាញព័ត៌មានជាតិ និងអន្តរជាតិផងដែរ។ ការព្រួយបារម្ភជាចម្បងរបស់ភាគីទាំងនេះ គឺថាទំហំនៃប្រាក់ចំណូលជាមធ្យមមិនបានកើនឡើងក្នុងល្បឿន និងទំហំប្រហាក់ប្រហែលគ្នានឹងទំហំនៃការកើនឡើងរបស់ឥណទាន។ ឧទាហរណ៍ ដូចដែលបានយោងនៅក្នុងមជ្ឈមណ្ឌលសម្រាប់បរិយាបណ្ណហិរញ្ញវត្ថុ (ម.ប.ហ) ការិយាល័យឥណទានកម្ពុជាអះអាងថា ចន្លោះពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១៤ ទំហំឥណទានមធ្យមបានកើនឡើងចំនួន ៤ដង លឿនជាងទំហំប្រាក់ចំណូលជាមធ្យមរបស់កូនបំណុលនាំឲ្យ ម.ប.ហ សន្និដ្ឋានថា កំណើននេះនឹងមិនមានចិរភាពឡើយ។[33] លើសពីនេះយោង

[29] MFC and Good Return 2017.

[30] សូមមើល Davel 2013 ចំពោះការពិភាក្សាបន្ថែមអំពីបញ្ញត្តិនានាក្នុងការទប់ស្កាត់ការរងសម្ពាធបំណុល។

[31] Center for Financial Inclusion 2019.

[32] Economist Intelligence Unit 2019.

[33] Center for Financial Inclusion 2019; Evers 2019.

តាមធនាគារពិភពលោក (២០១៩) ក្នុងរយៈពេល ៥ឆ្នាំកន្លងទៅ ទំហំឥណទានជាមធ្យមក្នុងគ្រួសារបានកើនឡើងចំនួន ១០ដង[34] (សូមមើលផងដែរ គំនូសតាង ២)។ ការស្រាវជ្រាវកន្លងមកបានសរសេរថា គ្រួសារកម្ពុជាដែលរងសម្ពាធបំណុលបានប្រើប្រាស់វិធីដោះស្រាយជាច្រើន ហើយភាគច្រើននៃវិធីទាំងនោះបង្កើនឲ្យមានភាពងាយរងគ្រោះកាន់តែខ្ពស់។ ឧទាហរណ៍ របាយការណ៍នៃវិស័យបានបង្ហាញថា កូនបំណុលមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ជាទៀងទាត់បានប្រើវិធីដោះស្រាយដែលកូនបំណុលទាំងនោះយល់ថាមិនអាចទទួលយកបាន ដើម្បីសងបំណុល។ វិធីដោះស្រាយជាទូទៅដែលច្រើនតែបានពណ៌នាថា “មិនអាចទទួលយកបាន” នោះរួមមានកាត់បន្ថយចំណាយខាងថៃទាំសុខភាព ការយកឥណទានបន្ថែម ការលក់ទ្រព្យ ការបញ្ជូនកូនៗឲ្យទៅធ្វើការ និងការដកកូនៗចេញពីសាលា។ ការងាកទៅដោះស្រាយតាមវិធីទាំងនេះអាចធ្វើឲ្យគ្រួសារជាប់បំណុលកាន់តែងាយរងគ្រោះថែមទៀត។ យន្តការគាំពារត្រូវមានជាចាំបាច់ ដើម្បីកុំឲ្យគ្រួសាររងសម្ពាធបំណុលប្រើវិធីដែលបង្កើនភាពងាយរងគ្រោះ ឬអស្ថិរភាពសេដ្ឋកិច្ច។ មកដល់បច្ចុប្បន្ននេះ ក្របខណ្ឌបទដ្ឋានគតិយុត្ត និងយន្តការគាំពារចំពោះគ្រួសាររងសម្ពាធបំណុលនៅមានកម្រិត។

### គំនូសតាង ២: ខ្សែកោងប្រាក់កម្ចីមធ្យមនៃគ្រួសារ




***ប្រភព: សមាគមហិរញ្ញវត្ថុកម្ពុជា (ឆ្នាំ២០២០)***

** ស្ថិតិនេះរួមមាន អេអន ហ្វីលីព លីហ្សូ និង ហត្ថា ដែលបានក្លាយខ្លួនមកជាធនាគារក្នុងឆ្នាំ២០២០*

** មិនបានគិតចូល : អេស៊ីលីដា និង ស្ថាបនា*

[34] Pimhidzai et al 2019.

ដោយបានទទួលស្គាល់ការព្រួយបារម្ភនេះ ភាគីខាងរដ្ឋាភិបាលនិងគ្រឹះស្ថានហិរញ្ញវត្ថុបានចាត់វិធានការមួយចំនួនដើម្បីបញ្ជ្រាបគំរូអនុវត្តន៍ល្អៗ ទៅក្នុងកិច្ចការពារអ្នកប្រើប្រាស់ក្នុងវិស័យហិរញ្ញវត្ថុ។ ឧទាហរណ៍ តាំងពីឆ្នាំ២០១៦មក សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (ស.ម.ហ.ក) បានពង្រឹងកិច្ចគាំពារអតិថិជនដោយចេញសេចក្ដីណែនាំស្ដីពីការផ្ដល់ឥណទាន ហើយ នៅឆ្នាំ២០១៥ សមាគមធនាគារនៅកម្ពុជា (ស.ធ.ក) ក៏បានចេញ*កម្រងណែនាំ និងបទប្បញ្ញត្តិអនុវត្តន៍ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងសេចក្ដីណែនាំអនុវត្តន៍គោលការណ៍ហិរញ្ញវត្ថុដែលមានចិរភាពកម្ពុជា*។ យន្តការទាំងពីរនេះបានប្រើដោយសមាគមទាំងពីរក្នុងការណែនាំគ្រឹះស្ថានដែលជាសមាជិករបស់ខ្លួន ក្នុងការផ្ដល់សេវាហិរញ្ញវត្ថុ។ លើសពីនេះទៀត ធនាគារជាតិកម្ពុជា (ធ.ជ.ក) ក៏បានកត់សម្គាល់សារៈសំខាន់នៃកិច្ចគាំពារអតិថិជននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ ដែលបានចេញនាពេលថ្មីៗនេះ។ នៅក្នុងផែនការយុទ្ធសាស្ត្រនេះ ធ.ជ.ក បានសម្ដែងនូវការប្ដេជ្ញាចិត្តដាក់កិច្ចគាំពារអ្នកប្រើប្រាស់ទៅក្នុងក្របខណ្ឌបទប្បញ្ញត្តិរបស់ខ្លួន។ នៅចុងឆ្នាំ២០១៩ រដ្ឋាភិបាលកម្ពុជាបានអនុម័ត និងដាក់ចេញនូវច្បាប់ស្ដីពីកិច្ចគាំពារអតិថិជន (លេខ នស/រកម/១១១៩/០១៦)។ ទោះជាយ៉ាងណាក៏ដោយច្បាប់នេះមិនបានគ្របដណ្ដប់លើសេវាហិរញ្ញវត្ថុរបស់ភាគីផ្ដល់សេវាដែលមិនមែនជាធនាគារ។ ចំណុច ១៤ នៃមាត្រា ៤ ចែងថា "សេវា សំដៅដល់សិទ្ធិ អត្ថប្រយោជន៍ អាទិភាព ឬរាល់ការសម្រួលទាំងឡាយដែលត្រូវបានផ្ដល់ ឬបានឲ្យតាមប្រភេទកិច្ចសន្យាមានជាអាទិ៍ដូចខាងក្រោម លើកលែងសេវាហិរញ្ញវត្ថុមិនមែនធនាគារ" សេចក្ដីសម្រេចទុកឲ្យច្បាប់នេះ មិនអនុវត្តចំពោះសេវាហិរញ្ញវត្ថុរបស់ភាគីមិនមែនធនាគារ ធ្វើឲ្យមានការបារម្ភ ចំពោះសុខមាលភាព និងសិទ្ធិរបស់គ្រួសារកូនបំណុល ដែលបានទទួលសេវាពីគ្រឹះស្ថានមិនមែនធនាគារ។

ចំពោះគោលការណ៍ស្ដីអំពីកិច្ចគាំពារអតិថិជនវិញ យុទ្ធនាការ ស្មាត (តទៅនេះហៅថា ស្មាត SMART) គឺជាយុទ្ធនាការជាសកល ដើម្បីបញ្ជ្រាបការអនុវត្តល្អៗស្ដីអំពីកិច្ចការពារអតិថិជន ទៅក្នុងវប្បធម៌និងការប្រតិបត្តិការរបស់គ្រឹះស្ថានដែលធ្វើការលើផ្នែកបរិយាបណ្ណហិរញ្ញវត្ថុ។ ស.ម.ហ.ក គាំទ្រដល់ ស្មាត ហើយកំពុងធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញ គ.ម.ហ ឲ្យទទួលបានការទទួលស្គាល់ពី ស្មាត។ ដើម្បីទទួលបានការទទួលស្គាល់ពី ស្មាត គ.ម.ហ នានាត្រូវតែប្ដេជ្ញាចិត្តអនុម័តឲ្យបាននូវគោលការណ៍ស្ដីពីកិច្ចគាំពារអតិថិជន (គ.ក.អ) ជំនួន ៧ ចំណុច រួមមាន: ១) ផែនការ និងលទ្ធផលនៃសេវាមានលក្ខណៈសមរម្យ ២) ការចៀសវាងបំណុលវ័ណ្ឌក ៣) តម្លាភាព ៤) ការកំណត់តម្លៃដោយទទួលខុសត្រូវ ៥) ទំនាក់ទំនងជាមួយអតិថិជន ដោយយុត្តិធម៌ និងដោយគោរព ៦) រក្សាការសម្ងាត់ឯកជននៃទិន្នន័យរបស់អ្នកប្រើប្រាស់ ៧) យន្តការដោះស្រាយបណ្ដឹងតវ៉ា (SMART ២០១១)។ គោលដៅរបស់យុទ្ធនាការនេះគឺដើម្បីធានាថា សេវាហិរញ្ញវត្ថុមិនធ្វើឲ្យអន្តរាយដល់អ្នកប្រើប្រាស់។ មកដល់សព្វថ្ងៃនេះ ស.ម.ហ.ក និង ធ.ជ.ក បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត និងត្រួតពិនិត្យ គ.ក.អ។ ទោះជាយ៉ាងណាក៏ដោយ គ.ក.អ បច្ចុប្បន្នមិនចងកាតព្វកិច្ចផ្លូវច្បាប់ទេ ហើយការគោរពគោលការណ៍នៃយុទ្ធនាការ ស្មាត[35] ត្រូវវិស័យនោះជាអ្នកពិនិត្យការអនុវត្តដោយខ្លួនឯង។ ដូចដែលអ្នកធ្វើការនៅក្នុងវិស័យនោះបានលើកឡើង គឺថា ការត្រួតពិនិត្យមើលការអនុវត្តដោយខ្លួនឯងបែបនេះបានស្ដែងចេញមកនូវអប្រសិទ្ធភាពក្នុងការគាំពារកូនបំណុល[36] និងអាចនាំឲ្យមានវិបត្តិឥណទាន។[37] ប្រការនេះបង្ហាញឲ្យឃើញភាពនៅមានកម្រិតនៃសេចក្ដីណែនាំស្ដីអំពីការផ្ដល់ឥណទានដែលត្រួតពិនិត្យខ្លួនឯង ក៏ដូចជាគោលការណ៍ស្ដីពីកិច្ចគាំពារអតិថិជន ដែលបានធ្វើក្នុងទម្រង់របៀបនោះ។

[35] នាបច្ចុប្បន្នភារកិច្ចនេះបានផ្ទេរទៅឲ្យ Social Performance Task Force (SPTF).

[36] Rozas 2020.

[37] សូមមើល Afonso, Forcella, and Guérin 2016.

# III. វិធីសាស្ត្រស្រាវជ្រាវ

## ១. គោលដៅនៃការស្រាវជ្រាវ

ចាប់តាំងពីមានវិបត្តិជំងឺរាតត្បាតកូវីដ ១៩ ជីវភាពគ្រួសារជាច្រើនដែលងាយរងគ្រោះ កាន់តែមិននឹងនរឡើងថែមទៀត ដោយសារគ្រួសារជាច្រើនបានបាត់បង់ប្រភពចំណូលសំខាន់ៗ ឬក៏ចំណូលធ្លាក់ចុះយ៉ាងគំហុក។[38] ប្រការនេះបានធ្វើឲ្យសម្ពាធបំណុលកាន់តែធ្ងន់ធ្ងរឡើង និងឲ្យកូនបំណុលកាន់តែលំបាកបំពេញកាតព្វកិច្ចសងបំណុល។ នៅក្នុងបរិបទនេះ ការស្រាវជ្រាវនេះចាប់ផ្តើមឡើងដោយចង់ស្វែងយល់អំពីបញ្ហាព្រួយបារម្ភពីរ ដែលពាក់ព័ន្ធគ្នា៖ របៀបដែលជំងឺរាតត្បាតកូវីដ ១៩ បានប៉ះពាល់ដល់កូនបំណុល និងរបៀបដែលគ្រឹះស្ថានហិរញ្ញវត្ថុបានឆ្លើយតបចំពោះវិបត្តិកូវីដ ១៩ នេះ។ ជាពិសេស យើងចាប់អារម្មណ៍ចំពោះយន្តការថ្មី នៃការរៀបចំឥណទានឡើងវិញ ដែលគ្រឹះស្ថានហិរញ្ញវត្ថុបានដាក់ចេញដើម្បីឆ្លើយតបទៅនឹងជំងឺរាតត្បាតកូវីដ ១៩។ គោលដៅនៃការស្រាវជ្រាវនេះគឺ ទី១ ស្វែងយល់ពីការឆ្លើយតបរបស់គ្រួសារនានា ទៅនឹងការបាត់បង់ចំណូល ហើយ ទី២ ស្វែងយល់ពីវិធីផ្សេងៗក្នុងការសងបំណុលរបស់គ្រួសាររងសម្ពាធបំណុលមីក្រូហិរញ្ញវត្ថុ ក៏ដូចជាផលវិបាកដែលអាចមានចេញពីវិធីសាស្ត្រផ្សេងៗក្នុងការសងបំណុល។ ការស្រាវជ្រាវនេះមានបំណងចង់បង្ហាញពីបញ្ហាដែលកើតឡើងជាថ្មីហើយកាន់តែធ្ងន់ធ្ងរក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ ១៩។ ចុងបញ្ចប់ ការស្រាវជ្រាវនេះមានបំណងដាក់ជាអនុសាសន៍ស្តីពីវិធីឆ្លើយតបដែលអាចធ្វើទៅបាន ជូនចំពោះអ្នកបង្កើតគោលនយោបាយ គ្រឹះស្ថានហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹងកិច្ចគាំពារគ្រួសារងាយរងគ្រោះនៅកម្ពុជា ធ្វើយ៉ាងណាឲ្យគ្រួសារទាំងនោះអាចទប់ទល់បានផលប៉ះពាល់សេដ្ឋកិច្ច សង្គម នៃវិបត្តិជំងឺរាតត្បាតកូវីដ ១៩។ ដោយសារអ្វីដែលយើងព្យាយាមស្វែងយល់ គឺផលវិបាកកើតចេញពីបញ្ហាទាំងនេះ ដូច្នេះ យើងអនុវត្តវិធីសាស្ត្រស្រាវជ្រាវ ដោយធ្វើការសម្ភាសបែបស៊ីជម្រៅ និងមានសំណួរដែលបានរៀបចំខ្លះ។ ទីមួយ វិធីសាស្ត្រនេះធ្វើឲ្យយើងចាប់យកបានបញ្ហាច្រើនស្រទាប់ ហើយនិងផលវិបាកដែលអាចមានចេញពីបញ្ហានោះ។ វាក៏ធ្វើឲ្យយើងអាចបត់បែនបានរកឃើញបញ្ហាដែលកើតឡើង ព្រមទាំងរកឃើញឱកាសផ្សេងៗ ដើម្បីកែលម្អជីវភាពនៃគ្រួសាររងសម្ពាធបំណុល។ អាស្រ័យហេតុនេះ បានជាការស្រាវជ្រាវនេះកំណត់យកសំណាកក្នុងចំនួនតិចជាង បើប្រៀបធៀបនឹងការជំរឿនគ្រួសារផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ វិធីនេះមានលក្ខណៈសមស្របចំពោះគោលដៅរបស់យើង ដោយសារយើងចង់បង្ហាញលក្ខណៈសាំញ៉ាំនៃបញ្ហាដែលកូនបំណុលមីក្រូហិរញ្ញវត្ថុជួបប្រទះ ហើយក៏ចង់ស្វែងយល់ពីបញ្ហាប្រឈមណាដែលសំខាន់ចំពោះកូនបំណុល។ ការស្រាវជ្រាវតាមគុណវិស័យមានលក្ខណៈសមស្របសម្រាប់ការស្រាវជ្រាវជាមូលដ្ឋានដំបូងបែបនេះ។

ក្នុងការកំណត់វិសាលភាពនៃការស្រាវជ្រាវនេះ យើងបានរៀនសូត្រពីសារាចររបស់ធនាគារជាតិកម្ពុជាលេខ TP 7.020.001 ដែលចេញនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ហើយណែនាំឲ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជាអនុវត្តទូលាយចំពោះការសងបំណុលតាមរបៀបរៀបចំឥណទានឡើងវិញឲ្យកូនបំណុលនៅក្នុងវិស័យអាទិភាពចំនួន ៤ ៖ ១) ទេសចរណ៍ ២) ការផលិតសម្លៀកបំពាក់ ៣) សំណង់ និង ៤) ការដឹកជញ្ជូន និងភស្តុភា។ ទោះជាយ៉ាងណាក៏ដោយ យើងក៏ចង់ស្វែងយល់អំពីគ្រួសារទាំងឡាយនៅក្នុងវិស័យផ្សេងៗ ដែលអាចនឹងត្រូវប៉ះពាល់ដោយសារជំងឺរាតត្បាតកូវីដ ១៩ ដែរ ប៉ុន្តែមិនបានចាត់ទុកជាអាទិភាព និងមិនបាន

[38] សូមមើល World Bank 2020 សម្រាប់តួលេខស្ថិតិ។

ចែងជាក់លាក់នៅក្នុងសារាចររបស់ ធ.ជ.ក។ ដូច្នេះ យើងស្វែងយល់បទពិសោធន៍កូនបំណុលនៅក្នុងវិស័យចំនួន ២ ដែល ធ.ជ.ក បានចាត់ទុកជាអាទិភាព (ទេសចរណ៍ និងការផលិតសម្លៀកបំពាក់) ក៏ដូចជាក្រុមពីរបន្ថែមទៀត គឺកូនបំណុលដែលមិនស្ថិតក្នុង "វិស័យអាទិភាព" (គ្រួសារចំណាកស្រុកឆ្លងដែនដែលពឹងលើប្រាក់ផ្ញើមកផ្ទះ និងគ្រួសារធ្វើកសិកម្មដែលបម្រើឲ្យការនាំចេញ)។ ការស្រាវជ្រាវមុនៗបានសរសេរថា ក្រុមទាំងនេះក៏រងសម្ពាធបំណុលខ្ពស់ដែរ[39] ហើយក៏ត្រូវប៉ះពាល់ដោយជំងឺរាតត្បាតកូវីដ ១៩ ដែរ។ ឧទាហរណ៍ ធនាគារពិភពលោក (២០២០ : ២១) ថ្មីៗនេះកត់សម្គាល់ថា "កម្មករចំណាកស្រុកដែលត្រឡប់មកពីប្រទេសថៃ និងគ្រួសារពួកគេដែលពឹងលើប្រាក់ផ្ញើមកផ្ទះ ក៏ទំនងនឹងបាត់បង់ចំណូលធ្ងន់ធ្ងរដែរ ហើយក៏មានហានិភ័យកាន់តែខ្ពស់ធ្លាក់ទៅក្នុងភាពក្រីក្រ។" ជាញឹកញាប់នៅក្នុងករណីបែបនេះ កម្មករចំណាកស្រុក និងសមាជិកគ្រួសាររបស់ពួកគេងាយរងគ្រោះខ្លាំងជាងគេ ហើយអាចជួបបញ្ហាដាក់ឲ្យនៅក្រៅសង្គម ដូចជា ការលំបាកទទួលបានឯកសារផ្នែកច្បាប់ផ្សេងៗ និងសេវាពិនិត្យសុខភាព ទាំងនៅក្នុងប្រទេសទិសដៅ និងប្រទេសកំណើត។ លើសពីនេះទៀតគ្រួសារកសិករដែលបម្រើឲ្យការនាំចេញ បានដាក់ចូលជាពិសេសនៅក្នុងការស្រាវជ្រាវនេះ ពីព្រោះពួកគាត់ទំនងជានឹងបានយកឥណទានមីក្រូហិរញ្ញវត្ថុមកវិនិយោគនៅក្នុងសកម្មភាពកសិកម្មរបស់ខ្លួន ហើយពួកគាត់តំណាងឲ្យគ្រួសារភាគច្រើនដែលធ្វើកសិកម្ម។ ផ្អែកលើបទពិសោធន៍ការចុះស្រាវជ្រាវរបស់យើងមុនៗ យើងបានសង្កេតឃើញថា បើប្រៀបធៀបទៅនឹងគ្រួសារដែលធ្វើកសិកម្មជាទូទៅ គ្រួសារដែលធ្វើកសិកម្មសម្រាប់បម្រើការនាំចេញ មានលទ្ធភាពច្រើនជាងគេក្នុងការជាប់បំណុល។ កត្តានេះធ្វើឲ្យគ្រួសារទាំងនោះងាយនឹងរងគ្រោះជាងគេចំពោះវិបត្តិជំងឺរាតត្បាតកូវីដ ១៩ ពីព្រោះយើងរំពឹងថាជំងឺរាតត្បាតកូវីដ ១៩ នឹងត្រូវកាត់បន្ថយសមត្ថភាពរបស់គ្រួសារកសិករក្នុងការរកចំណូលបន្ថែម ដោយសារការងារដែលបានប្រាក់ឈ្នួលប្រចាំថ្ងៃ ដែលធ្លាប់តែធ្វើក្រៅពីរដូវដាំដុះនោះ អាចលែងមានទៀតហើយ។ ដោយសារ ធ.ជ.ក មិនបានចែងជាក់លាក់អំពីក្រុមទាំងនេះនៅក្នុងគោលនយោបាយរបស់ខ្លួន ដូច្នេះវាមិនច្បាស់ទេ ថាតើ គ.ម.ហ ចាត់ទុកថាគ្រួសារទាំងនេះមានលក្ខណៈស្របច្បាប់ឬយ៉ាងណា ក្នុងការទទួលបានការរៀបចំឥណទានឡើងវិញ បើទោះបីជាគ្រួសារទាំងនោះបានប៉ះពាល់យ៉ាងច្បាស់ទៅហើយដោយសារជំងឺរាតត្បាតកូវីដ ១៩។ ដូច្នេះ គោលបំណងមួយនៃការស្រាវជ្រាវនេះ គឺស្វែងយល់ថាតើគោលនយោបាយរៀបចំឥណទានឡើងវិញមានសម្រាប់គ្រួសារទាំងនោះឬទេ។

## ២. ទីតាំងស្រាវជ្រាវ

ការសម្ភាសជាមួយគ្រួសារផ្សេងៗបានធ្វើនៅខេត្តបាត់ដំបង សៀមរាប កំពង់ឆ្នាំង និងនៅរាជធានីភ្នំពេញ (សូមមើលគំនូសតាង ៣)។ ទីតាំងនេះបានជ្រើសរើសដោយសារមានវិស័យដែលយើងចង់សិក្សាច្រើននៅតំបន់នោះ។ ឧទាហរណ៍រោងចក្រសម្លៀកបំពាក់ភាគច្រើនស្ថិតនៅភ្នំពេញ និងស្ថិតនៅកំពង់ឆ្នាំងមួយចំនួន។ សៀមរាប ពឹងផ្អែកច្រើនទៅលើវិស័យទេសចរណ៍អន្តរជាតិ។ បាត់ដំបង ជាតំបន់កំណើតមួយក្នុងចំណោមតំបន់កំណើតផ្សេងៗទៀតរបស់ពលករទេសន្តប្រវេសន៍ ហើយក៏ល្បីខាងការដាំដំណាំសម្រាប់លក់ដូចជាដំណាំស្រូវ ពោត និងដំឡូងមី។ លើសពីនេះ ទីតាំងទាំងនេះក៏បានជ្រើសរើសដោយផ្អែកទៅលើបទពិសោធន៍ស្រាវជ្រាវមុនៗ (កំពង់ឆ្នាំង) របស់ក្រុមស្រាវជ្រាវ ព្រមទាំងទំនាក់ទំនងដែលក្រុមស្រាវជ្រាវធ្លាប់មានជាមួយសហគមន៍ទាំងនេះ។ ទំនាក់ទំនងដែលមានពីមុននេះដើរតួសំខាន់ក្នុងការធ្វើឲ្យការចុះសម្ភាសមានភាពរលូនទៅបាននៅក្នុងកាលៈទេសៈដែលមានការភ័យខ្លាចខ្លាំងចំពោះអ្នកមកពីក្រៅមូលដ្ឋាន។

---

[39] Bylander 2014; Bylander 2015; IOM 2019; Green 2018; Green 2020.

**គំនូសតាង ៣: ផែនទីទីតាំងស្រាវជ្រាវ**




*ប្រភព: គំនិតរបស់អ្នកនិពន្ធ។ រចនារូបភាពដោយ Gcreatives*

## ៣. ទីតាំងស្រាវជ្រាវ

ការប្រមូលទិន្នន័យបានប្រើអស់រយៈពេល ៤ខែ ចាប់ពីខែកក្កដា ដល់ខែតុលា ឆ្នាំ២០២០ ហើយ បានយកព័ត៌មានពីកូនបំណុលមីក្រូហិរញ្ញវត្ថុ កូនបំណុលមិនមែនមីក្រូហិរញ្ញវត្ថុ និងបុគ្គលិកគ្រឹះស្ថានហិរញ្ញវត្ថុ។ ដោយមានការជួយទំនុកបម្រុងពីសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា លិខិតសុំការអនុញ្ញាតចំនួន ៧ច្បាប់បានដាក់ទៅសមាជិកដែលបានទទួលស្គាល់ដោយ ស្មាត ហើយដែលជាគ្រឹះស្ថានហិរញ្ញវត្ថុ មីក្រូហិរញ្ញវត្ថុធំៗ ហើយ លិខិតពីរច្បាប់បានផ្ញើដោយឡែកទៅខាងធនាគារនាំមុខ ហើយដែលបានការទទួលស្គាល់ពី ស្មាត។ គ្រឹះស្ថានចំនួន ៣ បានឆ្លើយតប និងបានយល់ព្រមរួមចំណែកក្នុងគម្រោងស្រាវជ្រាវនេះ ដោយបានអនុញ្ញាតឲ្យសម្ភាស

ជាមួយបុគ្គលិករបស់ខ្លួន។ គ្រឹះស្ថានក្រៅពីនេះ មិនបានឆ្លើយតប ឬក៏មិនយល់ព្រម។ លើសពីនេះក្រុមស្រាវជ្រាវបានប្រើប្រាស់ទំនាក់ទំនងខ្លួនឯងផ្ទាល់ ដើម្បីរៀបចំសម្ភាសបុគ្គលិក គ.ម.ហ ជាច្រើន។ សរុបមកកិច្ចសម្ភាសចំនួន ៣៤ បានធ្វើជាមួយនឹងបុគ្គលិកនៃគ្រឹះស្ថានហិរញ្ញវត្ថុចំនួន ៥។ ភាគច្រើននៃការសម្ភាសនោះបានធ្វើជាមួយនឹងមន្ត្រីឥណទាន (N=18) និងប្រធានសាខា (N=15) ទោះជាយ៉ាងណាក៏ដោយ យើងក៏បានសន្ទនាជាមួយនឹងនាយកប្រតិបត្តិម្នាក់ផងដែរ។ ដោយសារវិស័យមីក្រូហិរញ្ញវត្ថុមានបុគ្គលិកភាគច្រើនជាបុរស សម្រាប់ការស្រាវជ្រាវនេះបុគ្គលិកនៃ គ.ម.ហ ទាំងអស់ដែលយើងបានសម្ភាសសុទ្ធតែជាបុរស លើកលែងតែម្នាក់ជាស្ត្រី។

បន្ថែមលើនេះទៀត ក្រុមស្រាវជ្រាវបានសម្ភាសជាមួយកូនបំណុលមីក្រូហិរញ្ញវត្ថុបច្ចុប្បន្នចំនួន ១១៩នាក់។ ភាគច្រើននៃកូនបំណុលដែលយើងបានសម្ភាសនេះ គឺជាស្ត្រី (សូមមើលឧបសម្ព័ន្ធ ១ បន្ថែម)។ គម្រោងស្រាវជ្រាវនេះ ក៏បានសម្ភាសផងដែរជាមួយនឹងអ្នកដែលនាបច្ចុប្បន្នមិនមានជាប់ឥណទាននៃគ្រឹះស្ថានផ្លូវការ ចំនួន ១៧នាក់។ ធ្វើដូច្នេះយើងអាចយល់បានជាទូទៅចំពោះភាពខុសគ្នារវាងវិធីដោះស្រាយរបស់គ្រួសារកូនបំណុល និងគ្រួសារដែលបានដោះបំណុល ប៉ុន្តែគ្រួសារទាំងពីរប្រភេទនេះសុទ្ធតែមានចំណូលធ្លាក់ចុះដោយសារជំងឺរាតត្បាតកូវីដ ១៩។

កូនបំណុលទាំងនេះបានជ្រើសរើសទៅតាមវិស័យនៃការងាររបស់គាត់ ហើយបានយកតែអ្នកដែលបានធ្វើការក្នុងវិស័យរោងចក្រផលិតសម្លៀកបំពាក់ ទេសចរណ៍ កម្មករចំណាកស្រុក និង/ឬ កសិកម្មសម្រាប់នាំចេញ នៅពេលមុនកូវីដ ១៩។ នៅក្នុងចំណោមកូនបំណុលដែលបានសម្ភាសយើងក៏បានប្រឹងប្រែងធ្វើយ៉ាងណាឲ្យមានតំណាង នៃសកម្មភាពមុខរបរចម្រុះផ្សេងៗគ្នា។ គោលបំណងដែលយើងបានសម្ភាស គឺមានទាំងគ្រួសារចំណាកស្រុកក្រៅប្រទេស និងក្នុងប្រទេស កម្មកររោងចក្រ កសិករដាំពោត/ដំឡូងមី/ស្រូវ ដែលមានដីជាកម្មសិទ្ធិ កសិករដែលជាម្ចាស់ដីផង និងធ្វើការយកប្រាក់ឈ្នួលផង កសិករដែលធ្វើការយកប្រាក់ឈ្នួល អ្នកលក់វត្ថុអនុស្សាវរីយ៍ អ្នកបើកបរទុកទុក មគ្គុទ្ទេសទេសចរណ៍ ព្រមទាំងបុគ្គលិកសណ្ឋាគារ និងភោជនីយដ្ឋាន។ មុននឹងសម្ភាសក្រុមស្រាវជ្រាវបានជ្រើសរើសយកគ្រួសារដែលកំពុងជាប់ឥណទានជាមួយខាងធនាគារ ឬខាងមីក្រូហិរញ្ញវត្ថុ ប៉ុន្តែ យើងមិនទាន់បានដឹងនៅឡើយទេថា តើគ្រួសារកូនបំណុលនោះកំពុងត្រដាបត្រដួសរកប្រាក់សងគេឬយ៉ាងណា។

ក្រុមស្រាវជ្រាវបំពាក់ជាប់ជាមួយនូវឧបករណ៍ការពារកូវីដ ១៩ ហើយស្នើឲ្យអ្នកចូលរួមទាំងអស់រក្សាគម្លាតសង្គមនៅពេលសម្ភាស (សូមមើលរូបថត១)។ ក្រុមស្រាវជ្រាវមានគ្នាបួននាក់៖ ប្រធានក្រុមស្រាវជ្រាវម្នាក់ អ្នកស្រាវជ្រាវឯករាជ្យម្នាក់ និងជំនួយការស្រាវជ្រាវពីរនាក់។ ម្នាក់ៗទទួលបានការបណ្តុះបណ្តាល និងការណែនាំពីរបៀបសម្ភាសពីប្រធានក្រុមស្រាវជ្រាវ។ រួមជាមួយគ្នាផងដែរ ប្រធានក្រុមស្រាវជ្រាវ ក៏បានពន្យល់យ៉ាងក្បោះក្បាយ អំពីគោលបំណង និងកម្រងសំណួរនៃការស្រាវជ្រាវនេះដល់សមាជិកក្រុមស្រាវជ្រាវនីមួយៗ។ ក្រៅពីទទួលបានការបណ្តុះបណ្តាលដោយផ្ទាល់មាត់ ប្រធានក្រុមស្រាវជ្រាវក៏បានបង្ហាត់បង្ហាញពីរបៀបសម្ភាសដោយជាក់ស្តែងផងដែរ ដោយការធ្វើបទសម្ភសឲ្យសមាជិកក្រុមស្រាវជ្រាវមើល។ ជាដំបូងកម្រងសំណួរត្រូវបានសម្ភាសសាកល្បង បន្ទាប់មកយើងបានកែរបៀបការសួរខ្លះៗដោយប្រើគ្រាមភាសាមកជំនួស ការធ្វើបែបនេះគឺដើម្បីឲ្យអ្នកចូលរួមផ្តល់ព័ត៌មានងាយយល់។ លើសពីនេះទៅទៀត ក្រុមស្រាវជ្រាវគឺត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំងឲ្យចាប់យកប្រធានបទដែលលេចឡើងថ្មីៗ ដែលយើងយល់ថា មានសារៈសំខាន់។ កិច្ចសម្ភាសទាំងអស់បានធ្វើប្រតិចារឹក បកប្រែ និងវិភាគរកប្រធានបទចម្បង និងប្រធានបទអនុ។ សេចក្តីដកស្រង់ និងករណីសិក្សា បានរើសយកមកធ្វើជាតំណាង គឺឆ្លុះបញ្ចាំងនូវបទពិសោធន៍ទូទៅរបស់អ្នកចូលរួមសម្ភាសបានជួបប្រទះ។ លើសពីនេះទៀតរបាយការណ៍នេះ បានពិភាក្សាពីករណីមួយចំនួនដែលមិនមែនជាបទពិសោធន៍ទូទៅ ប៉ុន្តែមានលក្ខណៈសំខាន់ធ្វើឲ្យយើងស្វែងយល់ពីបញ្ហាចំរុះដែលកូនបំណុលឥណទានជួបប្រទះ។ យើងនឹងកត់សម្គាល់នៅពេលដែលយើងពិភាក្សាពីករណីមិនប្រក្រតីនេះ។ ដើម្បីរក្សាការសម្ងាត់ និងអត្តសញ្ញាណឲ្យអ្នកចូលរួមផ្តល់ព័ត៌មានរបស់យើង ឈ្មោះរបស់អ្នកដែលផ្តល់ព័ត៌មាន និងឈ្មោះរបស់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវបានដាក់ជាឈ្មោះក្លែងថ្មី ឬនឹងមិនត្រូវបានបញ្ចេញ។



*(រូបថត ១: កំពុងសម្ភាសនៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឆ្នាំ២០២០។ រូបថតដោយ ណូ អាស៊ីម)*



*(រូបថត ២: កំពង់ចម្លង ខេត្តកំពង់ឆ្នាំង ឆ្នាំ២០២០។ រូបថតដោយ វេះ ផាស៊ី)*

# IV. របកគំហើញ

## ផ្នែកទី ១. ផលប៉ះពាល់សេដ្ឋកិច្ច និងសង្គមនៃកូវីដ ១៩ មកលើកូនបំណុល

ជំងឺរាតត្បាតកូវីដ ១៩ បានប៉ះពាល់ដល់កូនបំណុលក្នុងលក្ខណៈខុសៗគ្នា ទៅតាមមុខរបរផ្សេងៗរបស់ពួកគាត់។ អ្នកខ្លះបាត់បង់ការងារទាំងស្រុង ខណៈដែលអ្នកខ្លះទៀតមានចំណូលធ្លាក់ចុះ ឬផ្អាកការងារបណ្ដោះអាសន្ន ដោយសារមានការកែប្រែបុគ្គលិក និង/ឬ រាំងស្ទះខ្សែសង្វាក់ផ្គត់ផ្គង់។ ជំពូកនេះចង្អុលបង្ហាញពីរបៀបដែលប្រាក់ចំណូលរបស់កូនបំណុលបានប៉ះពាល់ដោយសារជំងឺរាតត្បាតកូវីដ ១៩ នៅក្នុងវិស័យសំខាន់ៗចំនួន ៤ ដែលបានលើកមកសិក្សា ៖ ការផលិតសម្លៀកបំពាក់ ទេសចរណ៍ ការធ្វើចំណាកស្រុកក្រៅប្រទេស និងកសិកម្ម។ នៅក្នុងវិស័យកសិកម្ម របាយការណ៍នេះ ផ្ដោតទៅលើកសិករដែលដាំដំណាំបម្រើការនាំចេញ (ជាពិសេស ដូចជាស្រូវ ពោត និងដំឡូងមី)។

### ១.១. ការផលិតសម្លៀកបំពាក់

យោងតាមការព្យាកររបស់ធនាគារពិភពលោកនៅឆ្នាំ២០២០ វិស័យផលិតសម្លៀកបំពាក់ និងស្បែកជើងនៅកម្ពុជាបានផ្ដល់ការងារចំនួន ៩៤១.០០០ ភាគច្រើនទៅដល់ស្ត្រី ដែលមកពីតំបន់ជនបទជិតៗរោងចក្រនោះ។ ជាសរុប វិស័យនេះគឺជាអ្នកផ្ដល់ការងារក្នុងប្រព័ន្ធបានច្រើនជាងគេបំផុតនៅក្នុងសេដ្ឋកិច្ចទាំងមូល ហើយយោងតាមធនាគារពិភពលោក វិស័យនេះសម្រេចបានប្រហែល ១៧% នៃកំណើនពិតនៃផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ២០១៩។[40] តាំងពីជំងឺរាតត្បាតកូវីដ ១៩ ចាប់ផ្ដើមមកកម្មករផលិតសម្លៀកបំពាក់ជិត ១០០.០០០ នាក់បានបាត់បង់ការងារ[41] ស្មើនឹងប្រហែល ១០% នៃការងារទាំងអស់ក្នុងវិស័យនេះ។ មានការព្យាករថាចាប់ពីខែមករា ដល់ខែតុលា ២០២០ ការផលិតសម្លៀកបំពាក់សម្រាប់បម្រើការនាំចេញនឹងធ្លាក់ចុះអស់ ៩%។[42]

ជំងឺរាតត្បាតកូវីដ ១៩ បានប៉ះពាល់វិស័យនេះក្នុងកត្តាសំខាន់ៗមួយចំនួន។ ទោះជាយ៉ាងណាក៏ដោយ សូម្បីតែនៅមុនកូវីដ ១៩ វិស័យនេះមានអស្ថិរភាពខ្លាំងរួចទៅហើយ ដោយសារមានការដកចេញនៃរបបពាណិជ្ជកម្មអ្វីៗទាំងអស់លើកលែងតែអាវុធ (អ៊ីប៊ីអេ) ដែលជារបៀបផ្ដល់សម្បទានពាណិជ្ជកម្មដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយសហភាពអឺរ៉ុប (អ៊ីយូ)។[43] អស្ថិរភាពទាំងនេះបានប៉ះពាល់រួចទៅហើយដល់វិស័យនេះ ដែលបានធ្វើឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការព្រួយបារម្ភ។ ឧទាហរណ៍ ប្រធានសាខាជាច្រើនដែលយើងបានសន្ទនាជាមួយ បានលើកឡើងនូវការព្រួយបារម្ភចំពោះការដកចេញ អ៊ីប៊ីអេ ដោយសារអតិថិជនរបស់ពួកគេគឺជាកម្មកររោងចក្រ បើមិនដូច្នោះទេ ក៏ជាអាជីវករដែលពាក់ព័ន្ធផ្ទាល់ជាមួយកម្មករ។ ប្រធានសាខាមួយរូបបានលើកឡើងថា "យើងក៏កំពុងជួបបញ្ហា អ៊ីប៊ីអេ នេះដែរ យើងមិនប្រាកដថា រោងចក្រណាខ្លះនឹងនៅ ហើយរោងចក្រណាខ្លះនឹងទៅនោះទេ។"[44] ដោយសារមានភាពមិនប្រាកដប្រជា និងអស្ថិរភាពបែបនេះនៅក្នុងវិស័យផលិតសម្លៀកបំពាក់ ដែលប៉ះពាល់ដោយសារកត្តាពីរ ការដកចេញអ៊ីប៊ីអេផង និងជំងឺរាតត្បាតកូវីដ ១៩ ផង។ ការសម្ភាសជាមួយនឹងភាគីខាងគ្រឹះស្ថានហិរញ្ញវត្ថុ និងកូនបំណុលបានបង្ហាញថា

---

[40] World Bank, 2020

[41] IndustriAll Global Union 2020.

[42] SoK 2020.

[43] EBA ជាសម្បទានមិនយកពន្ធ និងកូតា ជាឯកតោភាគីចំពោះរាល់ទំនិញនាំចេញ លើកលែងតែអាវុធ និងគ្រឿងផ្ទុះ (សូមមើលបន្ថែមតាមរយៈ https://ec.europa.eu/trade/policy/countries-and-regions/countries/cambodia/. ការដក EBA បានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការរំលោភជាប្រព័ន្ធទៅលើគោលការណ៍សំខាន់ៗនៃកតិកាសញ្ញាអន្តរជាតិស្ដីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ពាក់ព័ន្ធនឹងការចូលរួមក្នុងនយោបាយ សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការប្រមូលផ្ដុំ នៅក្នុងប្រទេសកម្ពុជា។ ដំណើរការដក EBA បានចាប់ផ្ដើមនៅខែកុម្ភៈ ឆ្នាំ២០១៩ ហើយនៅប្រហែលជាខែកុម្ភៈ ឆ្នាំ២០២០ ការដក EBA បានដកចេញរួចហើយត្រង់ផ្នែកខ្លះ។

[44] FI ID:11.

ក្នុងពេលជំងឺរាតត្បាតកូវីដ ១៩ មានគ្រឹះស្ថានហិរញ្ញវត្ថុធំៗមួយចំនួនតូចបានផ្អាកផ្តល់ឥណទានដល់កម្មករផលិតសម្លៀកបំពាក់ បើមិនដូច្នោះទេបានបញ្ឈប់ផ្តល់តែម្តង ក្នុងនោះមានទាំងបញ្ឈប់ការទទួលយកប្រាក់ឈ្នួលក្នុងវិស័យនេះមកធ្វើការវាយតម្លៃសមត្ថភាពសងបំណុល។ បើដូច្នេះក៏ដោយ កម្មករក្នុងវិស័យផលិតសម្លៀកបំពាក់ជាច្រើននាក់មានជាប់បំណុលខ្លួនឯង ឬជួយសងបំណុលសមាជិកគ្រួសារនៅតំបន់ជនបទ។

កិច្ចសម្ភាសរបស់យើងជាមួយកម្មករក្នុងវិស័យផលិតសម្លៀកបំពាក់ ភាគច្រើនមកពីខេត្តជិតៗរាជធានីភ្នំពេញ។ ភាគច្រើននៃកម្មករដែលបានសម្ភាសក្នុងគម្រោងនេះ បានផ្ញើប្រាក់ទៅផ្ទះជាទៀងទាត់ ហើយក្នុងករណីភាគច្រើន ប្រាក់ផ្ញើទៅផ្ទះទាំងនោះជាចម្បងគឺសម្រាប់សងបំណុល។ ក្នុងករណីខ្លះ កម្មករផលិតសម្លៀកបំពាក់ផ្ញើលុយទៅផ្ទះសម្រាប់សងបំណុលខ្លួនឯងផ្ទាល់ ប៉ុន្តែក្នុងករណីខ្លះគឺសម្រាប់សងបំណុលរបស់ឪពុកម្តាយ។

ល្បឿននៃជំងឺកូវីដ ១៩ បានប៉ះពាល់ដល់សេដ្ឋកិច្ចជាសកល បង្កជាការលំបាកធ្ងន់ធ្ងរដល់កម្មកររោងចក្រផលិតសម្លៀកបំពាក់ក្នុងលក្ខណៈដូចជា លែងមានការងារបន្ថែមម៉ោង ការផ្អាកបណ្តោះអាសន្ន ការបញ្ឈប់ការងារជាអចិន្ត្រៃយ៍ និងបិទរោងចក្រ។ ក្នុងចំណោមកិច្ចសម្ភាសចំនួន ២៣ ដែលយើងបានធ្វើជាមួយកម្មករផលិតសម្លៀកបំពាក់ ក្នុងនោះមានកម្មការនីត្រូវបញ្ឈប់ការងារចំនួន ២ នាក់[45] ប៉ុន្តែមានកម្មករភាគច្រើនបានបាត់បង់ការងារបន្ថែមម៉ោង ឬ រោងចក្របានបិទទ្វារក្នុងរយៈពេលយ៉ាងតិចមួយខែ។

ការបាត់បង់ការងារបន្ថែមម៉ោងជាបញ្ហាធ្ងន់ធ្ងរសម្រាប់កម្មករ ដែលមានបំណុលត្រូវសង ពីព្រោះវាត្រូវថយចុះចំណូលអស់ប្រហែល ១/៣ (សូមមើលគំនូសតាង ៤)។ អ្នកចូលរួមផ្តល់បទសម្ភាសបានជួបប្រទះបញ្ហាប្រហាក់ប្រហែលគ្នាក្នុងករណីបាត់បង់ប្រាក់ចំណូលរបស់ខ្លួនមួយភាគធំ៖

*"ចាប់តាំងពីជំងឺរាតត្បាតកូវីដ ១៩ បានចាប់ផ្តើម ខ្ញុំមិនមានការងារបន្ថែមម៉ោងទេ។ ឥឡូវខ្ញុំចេញពីធ្វើការនៅម៉ោង ៤ល្ងាចរាល់ថ្ងៃ។ ដូច្នេះខ្ញុំរកបានប្រាក់ខែគោលចំនួន ១៩៣ ដុល្លារ មិនមែន ២៩០ ដុល្លារក្នុងមួយខែដូចមុននោះទេ។"*
***- កម្មកររោងចក្រស្បែកជើង អាយុ ៤៧ឆ្នាំ***

*"ចាប់តាំងពីពេលមានជំងឺរាតត្បាតកូវីដ១៩ ប្រាក់ខែខ្ញុំបានថយចុះអស់ចន្លោះពី ៨០ទៅ ៩០ ដុល្លារក្នុងមួយខែ។"*[46]
***- កម្មកររោងចក្រផលិតសម្លៀកបំពាក់ អាយុ ១៩ឆ្នាំ***

*"កាលពីមុន ពេលខ្ញុំធ្វើការបន្ថែមម៉ោង ខ្ញុំទទួលបានជាង ៣០០ ដុល្លារក្នុងមួយខែ។ ប៉ុន្តែ ឥឡូវនេះខ្ញុំបានតែ ២០០ដុល្លារ ពីព្រោះរោងចក្រមិនមានការងារបន្ថែមម៉ោង។"*[47]
***- កម្មកររោងចក្រផលិតកាបូប អាយុ ២១ឆ្នាំ***

ការបាត់បង់ប្រាក់ចំណូលធ្វើឲ្យបុគ្គលជាច្រើនត្រូវចាត់ចែងលើកដាក់ការចំណាយសម្រាប់ថ្លៃជួលផ្ទះ អាហារ ចំណាយផ្ទាល់ខ្លួន ផ្គត់ផ្គង់គ្រួសារនៅផ្ទះ និងសងបំណុល (សូមមើលគំនូសតាង៤)។ កម្មការនីរោងចក្រផលិតកាបូបអាយុ ២៥ឆ្នាំ ម្នាក់ លើកឡើងថា ប្រាក់ខែគោលរបស់គាត់បាន ១៩៣ ដុល្លារសហរដ្ឋអាមេរិក ប៉ុន្តែ ពេលខ្លះនៅពេលដែលកូវីដ ១៩ ចាប់ផ្តើម គាត់ទទួលបានមិនដល់ ១០០ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយខែ ពីព្រោះប្រាក់ឈ្នួលរបស់គាត់ត្រូវបានកាត់បន្ថយដោយសាររោងចក្របានបិទម្តង ៧ថ្ងៃ ១០ថ្ងៃ ឬ ១៤ថ្ងៃក៏មាន។ ប៉ុន្តែ ការចំណាយរបស់គាត់នៅរក្សាដដែល។ "ខ្ញុំនៅតែត្រូវបង់ថ្លៃបន្ទប់ ៣៥ដុល្លារ ថ្លៃភ្លើង ១៧.០០០ រៀល និងថ្លៃទឹក ២០.០០០ រៀល។"[48] បន្ថែមពីលើនោះ គាត់ត្រូវផ្ញើរប្រាក់ទៅឲ្យឪពុកម្តាយចាស់ៗ និងកូនៗគាត់

[45] សូមកត់សម្គាល់ថា មានកម្មករតែពីរនាក់ប៉ុណ្ណោះដែលត្រូវបានបញ្ឈប់ពីការងារនៅក្នុងការសិក្សាស្រាវជ្រាវនេះ ពីព្រោះកម្មករដែលបានបញ្ឈប់ភាគច្រើនបានត្រឡប់រួចទៅហើយ ទៅស្រុកកំណើតដែលនៅពាសពេញប្រទេសកម្ពុជា។ កត្តានេះបញ្ជាក់ថា សំណាករបស់យើងអាចនឹងវាយតម្លៃទាបចំពោះផលប៉ះពាល់អវិជ្ជានៃកូវីដ ១៩ ទៅលើកម្មករវិស័យផលិតសម្លៀកបំពាក់ទាំងមូល។

[46] Participant ID:50.

[47] Participant ID:59.

[48] Participant.

នៅផ្ទះ ហើយមានកាតព្វកិច្ចសងបំណុលមីក្រូហិរញ្ញវត្ថុចំនួន ១១០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។ លើសពីនេះ ក្នុងពេលជំងឺរាតត្បាតកូវីដ ១៩ ប្ដីគាត់បានជាប់នៅប្រទេសម៉ាឡេស៊ី អស់មួយរយៈពេលខ្លី ហើយថៅកែរបស់ប្ដីគាត់មិនបង់ប្រាក់ប្រចាំឆ្នាំឲ្យប្ដីគាត់ទៀត។ នៅខែមេសា ឆ្នាំ ២០២០ ប្ដីរបស់គាត់បានមកដល់ផ្ទះវិញ។ ដោយសារប្ដីគាត់មានជំនាញដេរ ប្ដីគាត់ក៏បានចូលធ្វើការជាមួយគាត់នៅរាជធានីភ្នំពេញ។ ទោះជាយ៉ាងណាក៏ដោយ គាត់និយាយថាប្ដីគាត់ ប្រើពេលអស់ពីរបីខែទើបរកការងារបាន ដោយសាររោងចក្រមួយចំនួនបដិសេធប្ដីគាត់ដោយមូលហេតុគាត់ជាបុរស។ ចុងបញ្ចប់ នៅខែសីហា ឆ្នាំ២០២០ រោងចក្រមួយបានទទួលប្ដីគាត់ឲ្យធ្វើការ ក្នុងករណីប្ដីគាត់យល់ព្រមធ្វើការនៅពេលណាដែលគេត្រូវការ ជាទូទៅមួយសប្ដាហ៍បានមួយថ្ងៃ ឬពីរថ្ងៃ។ ដោយមិនមានជម្រើសផ្សេង ប្ដីគាត់បានទទួលយកការងារនោះ ហើយទទួលបាន ៧ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃដែលគាត់ធ្វើការ។ ករណីនេះបង្ហាញថា ការកាត់ចោលការងារបន្ថែមម៉ោង និងការខ្វះខាតចំណូលបន្ថែមជារឿយៗ មានន័យថា កម្មករផលិតសម្លៀកបំពាក់ត្រូវតែជ្រើសរើសរវាងចំណាយទៅលើតម្រូវការជាមូលដ្ឋានរបស់ខ្លួន ឬត្រូវយកទៅសងបំណុល។

## គំនូសតាង ៤: ការបាត់បង់ប្រាក់ចំណូលក្នុងវិស័យផលិតសម្លៀកបំពាក់




*ប្រភព: គំនិតរបស់អ្នកនិពន្ធ។ រចនារូបភាពដោយ Gcreatives*

*n= 23*[49]

បញ្ហាប្រឈមទាំងនេះ នៅមានបន្ត ទោះបីជារដ្ឋាភិបាលបានប្រឹងប្រែងឧបត្ថម្ភអ្នកដែលធ្វើការនៅក្នុងវិស័យផលិតសម្លៀកបំពាក់ក៏ដោយ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២០ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (ក.ប) បានចេញសេចក្ដីណែនាំថាកម្មករនៅក្នុងវិស័យវាយនភណ្ឌផលិតសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដែលកិច្ចសន្យាបានផ្អាក មានសិទ្ធិដាក់ពាក្យសុំការឧបត្ថម្ភជាសាច់ប្រាក់។ ពីដំបូងគោលនយោបាយនេះសរសេរថា រោងចក្រនានាត្រូវទទួលខុសត្រូវបង់ឲ្យកម្មករ ៤០% នៃប្រាក់ឈ្នួលអប្បបរិមាហើយ រដ្ឋាភិបាលនឹងបន្ថែមជូន ២០% នៃប្រាក់ឈ្នួលនោះប្រសិនបើកម្មករណាបានចូលរៀនវគ្គបណ្ដុះបណ្ដាលជំនាញទន់។[50] [51] ផ្ទុយមកវិញ ក្រោយមក ក.ប បានកែប្រែគោលនយោបាយ ដោយបែងចែកក្រុមកម្មករដែលបានផ្អាកការងារ ហើយដែលមានសិទ្ធិសុំការឧបត្ថម្ភសាច់ប្រាក់ទៅជាបីក្រុម៖ ១) កម្មករដែលបានផ្អាកពីការងារមួយសប្ដាហ៍ទៅ ដប់ថ្ងៃ ទទួលបាន ១៥ដុល្លារ

---

[49] ក្រាបនេះបានគណនាចេញមកពីកិច្ចសម្ភាសចំនួន ២៣ ជាមួយកម្មកររោងចក្រផលិតសម្លៀកបំពាក់។

[50] MOLVT Announcement 2020.

[51] វិសាលភាពនៃការស្រាវជ្រាវនេះ មិនបានគ្របដណ្ដប់ទៅលើការស្វែងយល់បន្ថែម ចំពោះអ្វីដែលបានកើតឡើងដល់គោលនយោបាយមុនៗ។

សហរដ្ឋអាមេរិក ២) កម្មករដែលបានផ្អាកពីការងារពីដប់មួយ ទៅម្ភៃថ្ងៃ ទទួលបាន ៣០ ដុល្លារសហរដ្ឋអាមេរិក ៣) កម្មករដែលបានផ្អាកពីការងារចាប់ពីម្ភៃមួយដល់សាមសិបថ្ងៃ ទទួលបាន ៤០ ដុល្លារសហរដ្ឋអាមេរិក។ របបឧបត្ថម្ភនៃគោលនយោបាយនេះស៊ីសង្វាក់ជាមួយនឹងទិន្នន័យរបស់យើង។ យើងបានសន្ទនាជាមួយនឹងបុគ្គលជាច្រើន ដែលបានទទួលការឧបត្ថម្ភពីកម្មវិធីទាំងនេះ។ ឧទាហរណ៍ កម្មការនីរោងចក្រកាបូប អាយុ ២៥ឆ្នាំ ម្នាក់ បានត្រឡប់ទៅស្រុកកំណើតរបស់គាត់ ដើម្បីជួយឪពុកម្ដាយធ្វើស្រែចម្ការ ក្រោយពីពេលរោងចក្រដែលគាត់ធ្វើការបានបិទអស់រយៈពេលមួយខែ។ គាត់លើកឡើងថា "ពេលដែលរោងចក្របានបិទទ្វារអស់រយៈពេលមួយខែ រោងចក្របានឲ្យខ្ញុំ ៣០ ដុល្លារសហរដ្ឋអាមេរិក ហើយរដ្ឋាភិបាលបានឲ្យខ្ញុំ ៤០ ដុល្លារសហរដ្ឋអាមេរិក។"[52] [53] ទម្រង់នៃការឧបត្ថម្ភសាច់ប្រាក់ប្រភេទនេះជួយដល់តែកម្មករផ្អាកណាដែលមានកិច្ចសន្យា ប៉ុន្តែកម្មករដែលកិច្ចសន្យាបានបញ្ចប់មិនបានទទួលការឧបត្ថម្ភនោះទេ។ កម្មករដែលបានបញ្ចប់ពីការងារចំនួន ២នាក់ ដែលយើងបានសន្ទនាជាមួយបានប្រាប់ថា ពួកគាត់មិនបានទទួលការឧបត្ថម្ភសាច់ប្រាក់ពីរោងចក្រ ហើយក៏មិនបានទទួលពីរដ្ឋាភិបាលដែរ។ កម្មករទាំងពីររូបនេះលើកឡើងថាពួកគាត់ត្រូវបញ្ឈប់ដោយសារកិច្ចសន្យារបស់ពួកគាត់បានដល់ពេលបញ្ចប់។ ករណីនេះជាសក្ខីភាពបង្ហាញថា ចាប់តាំងពីមានជំងឺរាតត្បាតកូវីដ ១៩ មក បណ្ដារោងចក្រកាន់តែច្រើនឡើង បានងាកទៅជួលកម្មករកិច្ចសន្យាខ្លីសម្រាប់រយៈពេលបីខែ ឬប្រាំមួយខែ។ ធ្វើដូច្នេះនិយោជកមានអំណាចច្រើនក្នុងការបញ្ឈប់កម្មករនិយោជិក ដោយមិនចាំបាច់ទទួលខុសត្រូវខាងហរិញ្ញវត្ថុដែលត្រូវបំពេញ។ ប្រហាក់ប្រហែលគ្នានេះដែរ នៅពេលរោងចក្របិទទ្វារជាបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍ កម្មករនយោជិតដែលកិច្ចសន្យាបានដល់ទីបញ្ចប់ នឹងមិនបានទទួលអត្ថប្រយោជន៍អ្វីឡើយ។ ការអនុវត្តបែបនេះ និងផលវិបាករបស់វាមានបរិយាយរួចហើយនៅក្នុងឯកសារផ្សេងៗទៀត។[54]

## ១.២. ទេសចរណ៍

ខុសពីវិស័យផលិតសម្លៀកបំពាក់ វិស័យទេសចរណ៍នៅកម្ពុជាមានស្ថិរភាព និងកំណើនរយៈពេលវែងរហូតដល់ពេលមានកូវីដ ១៩។ មុនពេលមានជំងឺរាតត្បាតកូវីដ ១៩ វិស័យទេសចរណ៍បានផ្ដល់ការងារផ្ទាល់ប្រហែលចំនួន ៦២០.០០០ ហើយតំណាងឲ្យ ១៨,៧% នៃកំណើនពិតនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៩។[55] លទ្ធផលស្រាវជ្រាវរបស់យើងរកឃើញថា ដោយសារអ្នកដែលពឹងផ្អែកទៅលើវិស័យទេសចរណ៍កន្លងមកមានស្ថិរភាពប្រាក់ចំណូល អ្នកទាំងនោះភាគច្រើនបានប្រើឥណទានមីក្រូហិរញ្ញវត្ថុ និងឥណទានផ្លូវការ យកទៅវិនិយោគក្នុងវិស័យអចលនទ្រព្យ ដូចជាដី និងផ្ទះ។

វិស័យទេសចរណ៍ជាវិស័យដែលរងការប៉ះពាល់ពីជំងឺកូវីដ ១៩ ធ្ងន់ធ្ងរជាងគេនៅក្នុងរយៈពេលខ្លី និងមធ្យមដោយសារវិស័យទេសចរណ៍នៅលើសកលលោកទំនងជានឹងមិនងើបឡើងវិញដូចដើមទេ រហូតដល់ពេលមានវ៉ាក់សាំងទូទាំងសកលលោក។ នៅក្នុងខែមីនា ឆ្នាំ២០២០ ប្រទេសកម្ពុជាសម្រេចផ្អាកអ្នកទេសចរអន្តរជាតិដែលចូលតាមរយៈការធ្វើទិដ្ឋការនៅពេលមកដល់ ហើយមកទល់ពេលនេះមិនទាន់មានសញ្ញាណាថានឹងបន្ធូរបន្ថយការត្រួតពិនិត្យនៅតាមព្រំដែន ដែលឃាត់ទេសចរបរទេសមិនឲ្យចូលមកកម្ពុជា។ ក្រោយពីមានព្រឹត្តិការណ៍ឆ្លងតាមសហគមន៍ "៣ វិច្ឆិកា"[56] និង "២៨ វិច្ឆិកា"[57] កម្ពុជាបានចាត់វិធានការតឹងរ៉ឹងបន្ថែមចំពោះជនបរទេសដែលមកកាន់ប្រទេសកម្ពុជា ដោយបានកែប្រែពីការដាក់ចត្តាឡីស័ករយៈពេលពីរសប្ដាហ៍ដោយខ្លួនឯង ទៅជាចត្តាឡីស័កដែលរដ្ឋត្រូវត្រួតពិនិត្យសម្រាប់គ្រប់អ្នកធ្វើដំណើរចូលមក។

---

52 Participant ID:46.

53 ទាក់ប្រាក់ ៤០ ដុល្លារសហរដ្ឋអាមេរិក គឺស្របគ្នាទៅនឹងគោលនយោបាយចុងក្រោយរបស់រដ្ឋាភិបាលដែលឧបត្ថម្ភសាច់ប្រាក់ដោយសារគាត់ត្រូវបានផ្អាកពីការងារចំនួន ៣០ថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ ទឹកប្រាក់ ៣០ ដុល្លារសហរដ្ឋអាមេរិក គឺអ្វីដែលគាត់ទទួលបានពីរោងចក្រ ប៉ុន្តែវិធីគណនាឃើញទឹកប្រាក់ ៣០ដុល្លារសហរដ្ឋអាមេរិកនេះ មិនមានភាពច្បាស់លាស់ទេ ហើយវិសាលភាពនៃការស្រាវជ្រាវនេះមិនគ្របដណ្ដប់ទៅលើការស្វែងយល់ពីបញ្ហានេះទេ។

54 សូមមើល Human Rights Watch 2015; OXFAM 2019.

55 World Bank 2020.

56 ព្រឹត្តិការណ៍ ៣ វិច្ឆិកា គឺជាករណីឆ្លងមកពីរដ្ឋមន្ត្រីពាណិជ្ជកម្មហុងហ្គារី ដែលមកទស្សនៈកិច្ចកម្ពុជា ក្រោយមកធ្វើតេស្តឃើញវិជ្ជមានកូវីដ ១៩ ខណៈដែលគាត់បន្តទៅទស្សនកិច្ចនៅប្រទេសថៃ។

57 ព្រឹត្តិការណ៍ ២៨ វិច្ឆិកា គឺជាករណីទី១ ដែលរកឃើញការនៅក្នុងសហគមន៍។ ព្រឹត្តិការណ៍នេះបានផ្ដើមមកពីភរិយារបស់មន្ត្រីជាន់ខ្ពស់ម្នាក់ដែលតេស្តរកឃើញវិជ្ជមានកូវីដ ១៩។ ជាបន្តមកទៀតមានការបិទផ្សារអ៊ីអនដ៏ល្បីជាបណ្ដោះអាសន្ន ដោយបានដឹងថា អ្នកជំងឺនោះបានមកផ្សារអ៊ីអនកាលពីមួយអាទិត្យមុននោះ។





*(រូបថត ៣៖ ផ្លូវផាប់ស្ទ្រីត (ខាងលើ) ផ្លូវក្នុងផ្សារ (ខាងក្រោម) ក្រុងសៀមរាប ខេត្តសៀមរាប ឆ្នាំ២០២០។ រូបថតដោយ  ផេះ ផាស៊ី)*



ការមកដល់ពីក្រៅប្រទេសធ្លាក់ចុះយ៉ាងគំហុក បានប្រែក្លាយក្រុងសៀមរាប (សូមមើលរូបថត ២) ដែលថ្មីៗកន្លងទៅបានទាក់ទាញភ្ញៀវទេសចរអន្តរជាតិរាប់លាននាក់ក្នុងមួយឆ្នាំ។ ដោយសារវិស័យទេសចរជាក្បាលម៉ាស៊ីនចម្បងនៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងខេត្តនេះ ទាំងនៅក្នុងក្រុង និងទាំងនៅតំបន់ជុំវិញ បានរងការប៉ះពាល់ខ្លាំងដោយសារជំងឺរាតត្បាតនេះ។

នៅក្នុងវិស័យទេសចរណ៍មានអ្នកដែលប្រកបធុរកិច្ចដោយខ្លួនឯង និងអ្នកដែលជាបុគ្គលិកនៃធុរកិច្ចផ្សេងៗ ដូចជាសណ្ឋាគារ និងភោជនីយដ្ឋាន ។ដោយសារគ្មានអ្នកទេសចរអន្តរជាតិ ក្រុមទាំងពីរនេះ បានរងការប៉ះពាល់ធ្ងន់ធ្ងរ។ ភាគច្រើននៃអ្នកដែលធ្វើការដោយខ្លួនឯង ដែលបានពឹងលើអ្នកទេសចរ មានដូចជាអ្នកបើកបរទុកទុក និងអ្នកលក់វត្ថុអនុស្សាវរីយ៍។ អ្នកបើកបរទុកទុក និងអ្នកលក់វត្ថុអនុស្សាវរីយ៍ដែលយើងបានសន្ទនាជាមួយ បានពណ៌នាធ្ងន់ៗអំពីការបាត់បង់ប្រាក់ចំណូល ដោយលើកឡើងថា ពួកគាត់បានបាត់បង់ប្រាក់ចំណូលមួយភាគធំមែនទែន។ ក្នុងករណីជាច្រើនអ្នកទាំងនេះបានកត់សម្គាល់ថា ការបាត់បង់មានរហូតទៅដល់ ៩០%។ ខណៈដែលការប៉ាន់ប្រមាណនេះមិនប្រាកដថា ត្រឹមត្រូវ ដោយសារការបាត់បង់ជាក់ស្តែងអាចខ្ពស់ជាង ឬទាបជាង ៩០% (សូមមើលតារាង ១) វាក៏បង្ហាញបានពីសភាពធ្ងន់ធ្ងរដែលបុគ្គលទាំងនេះយល់ឃើញចំពោះការបាត់បង់ប្រាក់ចំណូលរបស់ខ្លួន។ អ្នកដែលជាបុគ្គលិករបស់ធុរកិច្ចនានា បានរងផលប៉ះពាល់សេដ្ឋកិច្ចក្នុងលក្ខណៈផ្សេងទៀត។ អ្នកខ្លះបាត់បង់ប្រាក់ចំណូល ១០០% នៅក្នុងវិស័យនេះ។ ខណៈដែលអ្នកខ្លះទៀតបានទទួលប្រាក់ឈ្នួលក្នុងកម្រិតណាមួយ (ចាប់ពី ៤០% ទៅដល់ ៧០%) នៃប្រាក់ឈ្នួលរបស់គេមុនកូវីដ ១៩។ នៅក្នុងការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានដែលបានជួបប្រទះបទពិសោធន៍ផ្សេងៗគ្នា មានការរៀបរាប់ចំពោះការបាត់បង់ក្នុងកម្រិតប្រហាក់ប្រហែលគ្នា។

## តារាង. ១: ការបាត់បង់ប្រាក់ចំណូលក្នុងវិស័យទេសចរណ៍

| អត្តសញ្ញា | មុនពេល កូវីដ ១៩ | ក្នុងពេល កូវីដ ១៩ | អាយុ | ភេទ | មុខរបរ | ចំនួនប្រាក់កម្ចី (ដុល្លារ សហរដ្ឋអាមេរិក) | ការរៀបចំ ឥណទាន ឡើងវិញ |
|---|---|---|---|---|---|---|---|
| ២៥ | ៣០-៤០ ដុល្លារ សហរដ្ឋអាមេរិក/ថ្ងៃ | ២,៥ ដុល្លារ សហរដ្ឋអាមេរិក/ថ្ងៃ | ៣០ | ប្រុស | អ្នកបើក បរទុកទុក | ៦.០០០ | បាទ/ចាស |
| ១១៦ | ១០០ដុល្លារ សហរដ្ឋអាមេរិក នៃតម្លៃទំនិញ/ថ្ងៃ | គ្រប់គ្រាន់សម្រាប់ ម្ហូបអាហារ/ថ្ងៃ | ៤០ | ស្រី | អ្នកលក់ វត្ថុអនុស្សាវរីយ៍ | ៩.០០០ | មិនបានស្នើសុំ |
| ២ | ៣៥០ ដុល្លារ សហរដ្ឋអាមេរិក/ខែ | គ្មានការងារធ្វើ | ២២ | ស្រី | ចុងភៅ ភោជនីយដ្ឋាន | ២.៥០០ | ភ័យខ្លាចមិនហ៊ាន ទាក់ទងទៅ គ្រឹះស្ថានហិរញ្ញវត្ថុ |
| ១៦ | ១.៣០០ ដុល្លារ សហរដ្ឋអាមេរិក/ខែ | ១០ ដុល្លារ សហរដ្ឋអាមេរិក/ថ្ងៃ | ៣៤ | ប្រុស | មគ្គុទ្ទេស ទេសចរណ៍/ បុគ្គលិកសណ្ឋាគារ | ៣.០០០ | បាទ/ចាស |

*ប្រភព: រៀបចំដោយអ្នកនិពន្ធ*

ផ្ទុយពីអ្នកធ្វើការក្នុងវិស័យផលិតសម្លៀកបំពាក់ ការឧបត្ថម្ភសាច់ប្រាក់របស់រដ្ឋាភិបាលចំពោះកម្មករក្នុងវិស័យទេសចរណ៍ ដែលបានបញ្ឈប់ពីក្រុមហ៊ុនដែលមានចុះបញ្ជីការ គឺទទួលបាន ៤០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ សម្រាប់រយៈពេលពីរខែ។[58] ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមអ្នកដែលយើងបានសម្ភាស ហើយដែលបានធ្វើការក្នុងវិស័យផ្លូវការ (ឧទាហរណ៍ មគ្គុទ្ទេសទេសចរណ៍ ឬអ្នកធ្វើការនៅសណ្ឋាគារ) មិនមានអ្នកណាទទួលបានការឧបត្ថម្ភជាសាច់ប្រាក់ទេ ទាំងពីក្រុមហ៊ុន ទាំងពីរដ្ឋាភិបាល។ ការធ្លាក់ចុះយ៉ាងគំហុកនូវប្រាក់ចំណូលអស់រយៈពេលរាប់ខែបែបនេះ មានន័យថា អ្នកធ្វើការក្នុងវិស័យទេសចរណ៍បានរងការប៉ះពាល់ធ្ងន់ធ្ងរពីជំងឺរាតត្បាតកូវីដ ១៩។ ចំពោះអ្នកជាប់បំណុល ហើយគ្មានប្រាក់សន្សំ ឬគ្មានជំនួយហិរញ្ញវត្ថុពីសាច់ញាតិដែលធូរធារ ការសងបំណុលប្រហែលជាមិនអាចធ្វើទៅបានឡើយ។

## ១.៣ កម្មករចំណាកស្រុកក្រៅប្រទេស

មានកម្មករកម្ពុជានៅបរទេសប្រមាណជា ១,២ លាននាក់ ដែលបានផ្ញើប្រាក់មកផ្ទះ ២ពាន់លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ។[59] ប្រទេសគោលដៅចំណាកស្រុកធំជាងគេគឺប្រទេសថៃ បន្ទាប់មកគឺកូរ៉េខាងត្បូង។ មុនជំងឺរាតត្បាតកូវីដ ១៩ កម្មករចំណាកស្រុកក្រៅប្រទេស ជារឿយៗជួបបញ្ហាជាច្រើន រួមមានទាំងការ ទទួលបាននូវឯកសារនានា ការងារមិនបានប្រាក់ឈ្នួល និងការបំពាននៅក្នុងប្រទេសដែលខ្លួនធ្វើការ។ កម្មករចំណាកស្រុកក្រៅប្រទេសជារឿយៗក៏ពឹងលើឥណទានផ្លូវការ យកមកចំណាយលើការធ្វើចំណាកស្រុក និង/ឬទទួលបានឯកសារផ្សេងៗ។[60] លើសពីនេះទៀត កម្មករចំណាកស្រុកក៏ខ្ចីប្រាក់មកពីគ្រឹះស្ថានហិរញ្ញវត្ថុយកទៅធ្វើផ្ទះ ឬវិនិយោគ ឬចាយលើតម្រូវការជាមូលដ្ឋានផ្សេងៗ។[61] ក្នុងចុងឆ្នាំ២០២០ ការជំរឿនមួយក្នុងចំណោមគ្រួសារកម្មករចំណាកស្រុក និងកម្មករដែលបានត្រឡប់មកវិញ (N=1054) ដែលធ្វើដោយភ្នាក់ងារចម្រុះរបស់អង្គការសហប្រជាជាតិរកឃើញថា ៣០,៥% នៃគ្រួសារដែលបានសម្ភាស បានជាប់បំណុលធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលជាមធ្យមគ្រួសារមួយជាប់បំណុលដល់ទៅ ១.៥០០ ដុល្លារសហរដ្ឋអាមេរិក។[62] ការសិក្សាស្រាវជ្រាវមួយចំនួន ក៏បានអះអាងផងដែរថា ការជាប់បំណុលវ័ណ្ឌកជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុ បានជំរុញឲ្យមានការធ្វើចំណាកស្រុកដោយរងសម្ពាធ។[63] ផ្អែកលើកិច្ចសម្ភាសដែលយើងបានធ្វើជាមួយគ្រួសារកម្មករចំណាកស្រុក និងកម្មករដែលបានត្រឡប់មកវិញ (n=32) យើងរកឃើញថា កម្មករចំណាកស្រុកក្រៅប្រទេសទាំងមាន និងទាំងគ្មានជាប់បំណុល មានផែនការធ្វើចំណាកស្រុក ឬបានធ្វើចំណាកស្រុកសាជាថ្មីរួចគឺទៅតាមផ្លូវក្រៅផ្លូវការ ឬផ្លូវកាត់ បើទោះជាព្រំដែនបានបិទហើយក៏ដោយ។ យើងបានជួបកម្មករមួយចំនួនតូចដែលយកឥណទានមកជួសជុលផ្ទះឬទិញដី ក្រោយពីពួកគាត់គិតថា ចំណូលពីចំណាកស្រុកក្រៅប្រទេសមានស្ថិរភាព។ ដោយមិនគិតពីមូលហេតុនៃការប្រើប្រាស់ឥណទាន ឬការធ្វើចំណាកស្រុក គ្រួសារមានសមាជិកធ្វើចំណាកស្រុកតែងតែពឹងលើប្រាក់ផ្ញើមកផ្ទះដើម្បីសងបំណុល។[64] អាស្រ័យហេតុនេះ វាជាកត្តាសំខាន់ខ្លាំងណាស់ ដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវផ្តល់យន្តការគាំពារផ្សេងៗដែលអាចជួយដល់គ្រួសាររងសម្ពាធបំណុល ធ្វើយ៉ាងណាឲ្យគ្រួសារទាំងនោះកុំធ្វើចំណាកស្រុករកការងារពេលរងសម្ពាធ។ ការព្រួយបារម្ភសំខាន់ជាងគេ គឺថាកាលណាគ្រួសារធ្វើចំណាកស្រុកពេលរងសម្ពាធ គ្រួសារនោះងាយនឹងរងគ្រោះពីការកេងប្រវ័ញ្ចកំលាំងពលកម្ម ពីព្រោះថា គ្រួសាររងសម្ពាធអាចនឹងទទួលការងារណាក៏ដោយឲ្យតែគេផ្តល់ឲ្យពួកគាត់។

[58] The Asian Foundation 2020.

[59] Mom 2020.

[60] IOM 2019; Bylander 2020.

[61] Bylander 2014.

[62] IOM & UNFPA 2020.

[63] ជំរឿនឆ្នាំ ២០១៦ ដោយអង្គការ IOM បានលើកឡើងថា ៤១% នៃកម្មករចំណាកស្រុកនៅក្នុងខេត្តចំនួន ១០ ដែលបានត្រឡប់ថ្មីៗនេះ បានឲ្យដឹងថា បញ្ហាបំណុលហិរញ្ញវត្ថុ គឺជាមូលហេតុធំនាំឲ្យពួកគេធ្វើចំណាកស្រុកកាលពីដំបូង (Dickson and Koeing 2016). សូមមើលផងដែរ Bylander 2014; Bylander 2015; MFC and Good Return 2017; Green and Estes 2018; IOM 2019; LICADHO 2020.

[64] OECD 2017; IOM 2019.

មកទល់នឹងខែមិថុនា ឆ្នាំ២០២០ IOM បានរាយការណ៍ថា កម្មករចំណាកស្រុកកម្ពុជាជាង ១១៥.០០០ បានត្រឡប់មកពីប្រទេសថៃ។[65] ក្រោយពីបានសន្ទនាជាមួយគ្រួសារកម្មករចំណាកស្រុក និងសាមីខ្លួនដែលបានត្រឡប់មកវិញ យើងរកឃើញថា កម្មករចំណាកស្រុកទទួលការប៉ះពាល់ អាស្រ័យទៅតាមប្រភេទចំណាកស្រុកដែលបានធ្វើ។ តទៅនេះ យើងនឹងពណ៌នាអ្វីដែលកម្មករចំណាកស្រុកបីក្រុមផ្សេងៗគ្នា បានជួបប្រទះ៖ កម្មករចំណាកស្រុកទៅធ្វើការតាមរដូវ ក្នុងរយៈពេលខ្លីៗនៅប្រទេសថៃតាមខេត្តជាប់ព្រំដែន កម្មករដែលធ្វើចំណាកស្រុកតាមផ្លូវការតាមរយៈអនុស្សារណៈយោគយល់ផ្លូវការរបស់ភ្នាក់ងារជ្រើសរើសកម្លាំងពលកម្ម ព្រមទាំងកម្មករដែលពីដំបូងចំណាកស្រុកក្រៅផ្លូវការហើយក្រោយមកអ្នកខ្លះបានទទួលឯកសារ តាមរយៈកម្មវិធីផ្ទៀងផ្ទាត់សញ្ជាតិរបស់ប្រទេសថៃ។

ក្រុមទី១ ជាពលករតាមរដូវ ដែលជាទូទៅរស់នៅតាមព្រំដែនកម្ពុជាថៃ ហើយបានធ្វើការនៅប្រទេសថៃយកប្រាក់មកបំពេញជីវភាព។ ពួកគាត់ប៉ះពាល់ខ្លាំង ដោយសារការបិទច្រកព្រំដែន ព្រោះវាកាត់ផ្តាច់ទម្លាប់ចំណាកស្រុក ដែលពួកគាត់ធ្វើតាមរដូវ។ ពួកគាត់ធ្វើការយកប្រាក់ឈ្នួលប្រចាំថ្ងៃនៅប្រទេសថៃ នៅរដូវដែលមានការងារ ហើយប្រកបរបរផ្សេងៗនៅក្នុងប្រទេសកម្ពុជាក្នុងរដូវផ្សេងៗទៀតនៃឆ្នាំនីមួយៗ។ ពួកគាត់ឆ្លងដែនទៅធ្វើការក្នុងចម្ការផ្លែឈើ ឬដំណាំឧស្សាហកម្មផ្សេងៗ ដូចជាដំឡូងមី និងអំពៅ។ នៅក្នុងប្រទេសកម្ពុជាពួកគាត់ធ្វើស្រែចម្ការខ្លួនឯង ឬធ្វើឲ្យអ្នកដទៃ។ ជាទូទៅពួកគាត់ចូលចិត្តធ្វើការនៅខាងប្រទេសថៃជាងដោយសារវាផ្តល់ប្រាក់ឈ្នួលខ្ពស់ជាង និងការងារទៀងទាត់ជាង។ ឧទាហរណ៍ កម្មករតាមរដូវម្នាក់ដែលយើងបានសន្ទនា **បងភាព**[66] តែងតែធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃនៅរដូវដែលមានការងារ។ ចាប់តាំងពីខែឧសភាដល់ខែកញ្ញា គាត់បកសារម៉ាវឲ្យរោងចក្រសារម៉ាវកំប៉ុងនៅខេត្តចន្ទបុរី។ ក្នុងរយៈពេល ៥ ខែ គាត់និងស្វាមី តែងតែសន្សំបានដល់ទៅ ៥០.០០០ បាត (១.៥៦០ ដុល្លារសហរដ្ឋអាមេរិក) ពីខែតុលាដល់ខែធ្នូ គាត់ និងគ្រួសារតែងតែឆ្លងដែនរាល់ថ្ងៃទៅធ្វើការនៅចម្ការមៀន ហើយពីរនាក់ប្តីប្រពន្ធរកបាន ៨០០ បាត (២៥ ដុល្លារសហរដ្ឋអាមេរិក) សម្រាប់ការងារបេះផ្លែឈើក្នុងមួយថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារច្រកព្រំដែនបានបិទដោយសារកូវីដ ១៩ ទម្លាប់ចំណាកស្រុកនេះបានត្រូវកាត់ផ្តាច់។ ការកាត់ផ្តាច់របៀបនេះធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់គាត់មានការលំបាកក្នុងការសងបំណុលមីក្រូហិរញ្ញវត្ថុផង ហើយត្រូវចំណាយប្រចាំថ្ងៃផង។ ទោះជាការឧបត្ថម្ភជាសាច់ប្រាក់របស់រដ្ឋាភិបាលតាមរយៈកម្មវិធីបណ្ណក្រីក្រ ធ្វើឲ្យគ្រួសារនេះអាចសងបំណុលគ្រប់ក៏ដោយ ក៏គ្រួសារគាត់នៅតែលំបាកនឹងរកអង្ករច្រកឆ្នាំង។ ដំណើររឿងរបស់ **បងភាព** បង្ហាញឲ្យឃើញនូវបញ្ហាប្រឈមរបស់ពលករចំណាកស្រុកក្រៅប្រទេសប្រចាំថ្ងៃ និងប្រចាំរដូវដែលជីវភាពបានធ្លាក់ចុះដោយសារការបិទព្រំដែន។ ក្នុងករណីជាច្រើនពលករដូចនេះបានទទួលការឧបត្ថម្ភសាច់ប្រាក់ពីរដ្ឋាភិបាល ហើយប្រាក់នេះត្រូវបានយកទៅសងបំណុលមីក្រូហិរញ្ញវត្ថុ។

លើសពីនេះ ជំងឺរាតត្បាតកូវីដ ១៩ ធ្វើឲ្យមានការប្រកួតប្រជែងកាន់តែខ្លាំងក្នុងចំណោមកម្មករចំណាកស្រុកតាមរដូវ ដែលរកការងារនៅខាងទឹកដីកម្ពុជា។ ចាប់តាំងពីមានការបិទព្រំដែនកាលពីចុងខែមីនា កម្មករចំណាកស្រុកតាមរដូវជាច្រើននាក់ ដែលធ្លាប់តែឆ្លងព្រំដែនទៅប្រទេសថៃក្នុងរដូវប្រមូលផល និងរដូវដាំដុះ បច្ចុប្បន្នបែរជាកំពុងប្រកួតប្រជែងរកការងារយកប្រាក់ឈ្នួលប្រចាំថ្ងៃនៅក្នុងស្រុក។ ប្រការនេះបានធ្វើឲ្យមានអតិរេកខាងការផ្គត់ផ្គង់កម្លាំងពលកម្មនៅភាគពាយព្យនៃកម្ពុជា ដោយហេតុនេះហើយបានជាប្រាក់ឈ្នួលជាមធ្យមនាបច្ចុប្បន្នទាបជាងពេលមុនមានជំងឺរាតត្បាតកូវីដ ១៩។ កម្មករចំណាកស្រុកតាមរដូវម្នាក់អាយុ ៤៥ឆ្នាំបានឲ្យដឹងថា “មុនពេលជំងឺរាតត្បាតកូវីដ ១៩ បើយើងដកស្មៅតាមចម្ការយើងទទួលបានប្រាក់ ២៥.០០០រៀល (៦,២៥ដុល្លារ

[65] IOM & UNFPA 2020.
[66] Participant ID:65.

សហរដ្ឋអាមេរិក) ក្នុងមួយថ្ងៃ។ បច្ចុប្បន្ន យើងអាចរកបានតែ ២០.០០០ រៀល (៥ ដុល្លារសហរដ្ឋអាមេរិក) តែប៉ុណ្ណោះក្នុងមួយថ្ងៃ ហើយការងារមានកំណត់ថែមទៀត ដោយសារមនុស្សជាច្រើនកំពុងរកការងារធ្វើ។"[67] ចំពោះការយល់ឃើញដូចគ្នានេះទៅលើលំហូរចូលនៃកម្មករក្នុងតំបន់នេះដើម្បីរកការងារ ក៏បានបញ្ជាក់ផងដែរពីម្ចាស់ចម្ការដំឡូងមី ដែលតែងតែជួលកម្មករមកជួយដាំ និងដកដំឡូងជារៀងរាល់ឆ្នាំ។ "ទើបតែឆ្នាំនេះទេ ពីមុនមិនសូវមានមនុស្សមករកការងារច្រើនដូចអច្ចេះទេ។ ពីមុនពិបាក ខ្លាំងណាស់ក្នុងការរកមនុស្សមកដកដំឡូង។"[68]




*(រូបថត ៤: ឯកសារចំណាកស្រុកប្រចាំរដូវ - ប័ណ្ណព្រំដែនពណ៌ខៀវ និងប័ណ្ណ ប្រចាំថ្ងៃ - ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឆ្នាំ២០២០។ រូបថតដោយ ផេះ ផាសុី)*

[67] Participant ID:69.
[68] Participant ID:72.

កម្មករដែលធ្វើចំណាកស្រុកតាមផ្លូវការ ពោលគឺអ្នកដែលចំណាកស្រុកតាមរយៈភ្នាក់ងារជ្រើសរើសកម្លាំងពលកម្ម ដែលបានចុះបញ្ជី ក៏បានជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងកូវីដ ១៩ ក្នុងលក្ខណៈផ្សេងទៀត។ បុគ្គលទាំងនេះសុទ្ធតែចំណាកស្រុកតាមច្រកផ្លូវការ ដែលមានភ្នាក់ងារគ្រប់គ្រង និងមានការងារដាក់ឲ្យជាមួយនឹងនិយោជកជាក់លាក់។ គ្រួសារចំណាកស្រុក ឬសាមីខ្លួនដែលបានត្រឡប់មកវិញភាគច្រើន ដែលយើងបានសម្ភាស បានឲ្យដឹងថា សមាជិកគ្រួសារ ឬបើមិនដូច្នោះទេសាមីខ្លួនតែម្តងធ្វើចំណាកស្រុកទៅធ្វើការតាមរោងចក្រក្នុងនោះមានដូចជា អ្នកធ្វើការខាងផលិតម្ហូបអាហារ (រោងចក្រសាច់មាន់ និងត្រីខកំប៉ុង) និងរោងចក្រផលិត (សម្លៀកបំពាក់ ស្រោមដៃ គ្រឿងបន្លាស់រថយន្ត វីស)។ កម្មករចំណាកស្រុកទាំងនេះមានកិច្ចសន្យាខ្លី ដែលអាចបន្តការងារសម្រាប់រយៈពេលដល់ទៅ ៤ឆ្នាំ។ បន្ទាប់មកកម្មករនិយោជិតត្រូវតែចរចាជាមួយនិយោជក។ កម្មករនិយោជិតប្រភេទនេះមានការការពារបានល្អជាងក្រុមដែលបានលើកឡើងមុននេះ ពីព្រោះពួកគេមានកិច្ចសន្យាតាមផ្លូវការ ហើយបានធ្វើចំណាកស្រុកតាមច្រកស្របច្បាប់។ តាមទ្រឹស្តី កម្មករនិយោជិតទាំងនេះគួរតែទទួលបានការការពារក្នុងពេលមានវិបត្តិជំងឺរាតត្បាតកូវីដ ១៩ ល្អប្រសើរជាងក្រុមពីរផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ ការជាក់ស្តែងមានលក្ខណៈស្មុគស្មាញច្រើន។ កម្មករខ្លះដែលយើងបានសម្ភាស ទទួលបានអត្ថប្រយោជន៍ក្នុងពេលរោងចក្របិទបណ្តោះអាសន្ន ប៉ុន្តែកម្មករខ្លះទៀតមិនបានទទួល។ ករណីសិក្សាចំនួនពីរ បានបង្ហាញនូវការការពារដែលមានលក្ខណៈខុសប្លែកពីគ្នានេះ។

*__អ៊ី ធា__[69] ដែលខ្លួនគាត់ផ្ទាល់ធ្លាប់បានធ្វើចំណាកស្រុកទៅធ្វើការសំណង់ ហើយបច្ចុប្បន្នកូនៗធ្វើជាកម្មករចំណាកស្រុកដែរ បានពណ៌នាថា កូនស្រីគាត់ម្នាក់បានធ្វើចំណាកស្រុកតាមច្រកផ្លូវការទៅធ្វើការនៅរោងចក្រផលិតស្រោមដៃនៅប៉ែកខាងត្បូងប្រទេសថៃ។ តាមសម្តីរបស់ __អ៊ី ធា__ ការងារកូនស្រីគាត់មិនបានប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺរាតត្បាតកូវីដ ១៩ ទេ។ ការងារកូនស្រីគាត់បានផ្អាកអស់ពីរសប្តាហ៍ក្នុងខែមេសា ប៉ុន្តែ កូនស្រីគាត់នៅទទួលបានប្រាក់ខែដដែលដោយមិនមានកាត់ទេ។ លើសពីនេះទៀត កូនស្រីគាត់ក៏ទទួលបានប្រាក់បន្ថែម ៤.០០០ បាត ក្នុងមួយខែ ជាសាច់ប្រាក់ឧបត្ថម្ភ ហៅថា "លុយកូវីដ" ដែល __អ៊ី ធា__ យល់ថារដ្ឋាភិបាលថៃជាអ្នកផ្តល់ឲ្យ។ ដោយបានទទួលប្រាក់កូនស្រីគាត់ផ្ញើមកផ្ទះរាល់ខែ __អ៊ី ធា__ មិនមានការលំបាកក្នុងការសងបំណុលមីក្រូហិរញ្ញវត្ថុរបស់គ្រួសារគាត់ទេ។*

ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពដែលបានធ្វើចំណាកស្រុកតាមផ្លូវការ មិនប្រាកដថា ទទួលបានការការពារល្អជាងគេក្នុងគ្រប់ករណីនោះទេ។

*ប្តីរបស់ __សុជាតា__[70] បានធ្វើចំណាកស្រុកតាមរយៈភ្នាក់ងារជ្រើសរើសកម្លាំងពលកម្ម ដែលចុះបញ្ជីស្របច្បាប់ ទៅធ្វើការក្នុងរោងចក្រត្រីខកំប៉ុង។ __សុជាតា__ និយាយថា ម្ចាស់រោងចក្រហៅប្តីគាត់ទៅធ្វើការតែនៅពេលដែលមានការបញ្ជាទិញប៉ុណ្ណោះ។ បើខាងរោងចក្រមិនបានទទួលបញ្ជាទិញទេ ប្តីគាត់មិនមានការងារធ្វើទេ។ ចាប់តាំងពីជំងឺរាតត្បាតកូវីដ ១៩ ចាប់ផ្តើម ប្តីគាត់បានធ្វើការជាមធ្យមតែបីថ្ងៃក្នុងមួយសប្តាហ៍។ ការប្រែប្រួលនេះ ធ្វើឲ្យប្តីគាត់លំបាកក្នុងជីវភាពរស់នៅក្នុងប្រទេសថៃ ហើយធ្វើឲ្យគាត់មិនមានលុយផ្ញើមកផ្ទះ ដើម្បីសងបំណុលខាងមីក្រូហិរញ្ញវត្ថុទេ។*[71]

ការអនុវត្តខុសគ្នាមកលើកូនស្រីរបស់ **អ៊ី ធា** និងប្តីរបស់ **សុជាតា** បានបង្ហាញឲ្យឃើញការខ្វះចន្លោះដែលមានជាក់ស្តែងក្នុងការការពារកម្មករចំណាកស្រុកតាមផ្លូវការទៅធ្វើការនៅប្រទេសថៃ។ មិនមានការធានាណាមួយថា ស្ថានភាពចំណាកស្រុកតាមផ្លូវការនឹងនាំឲ្យមានការការពារកម្លាំងពលកម្មបានគ្រប់គ្រាន់នោះឡើយ។[72]

---

[69] Participant ID:21.

[70] Participant ID:107.

[71] ក្រុមស្រាវជ្រាវទាំងឡាយមិនបានស្វែងយកល់អំពីបំណុលដែលពាក់ព័ន្ធនឹងការជ្រើសរើសកម្លាំងពលកម្មនោះទេ។

[72] សូមមើល Bylander 2019; ILO and IOM 2017 (the risks and rewards study).

ក្រុមចុងក្រោយ ដែលជាកម្មករចំណាកស្រុករយៈពេលវែងទៅធ្វើការតាមបណ្តាខេត្តឆ្ងាយពីព្រំដែននៅក្នុងប្រទេសថៃ ក៏បានជួបប្រទះនូវបញ្ហាប្រឈមកូវីដ ១៩ ផងដែរ។ ហើយកម្មករជាច្រើនត្រូវបានបញ្ឈប់ពីការងារ ហើយបង្ខំចិត្តត្រឡប់មកផ្ទះ។ ជាពិសេសបញ្ហាប្រឈមនេះកើតមានចំពោះកម្មករធ្វើការក្នុងវិស័យសំណង់។ នេះជាវិស័យចម្បងមួយផ្តល់ការងារនៅតាមទីជនបទនៃខេត្តសៀមរាបដែលយើងបានធ្វើសម្ភាស។ នៅក្នុងសហគមន៍នេះមានប្រវត្តិមានកម្មករទៅធ្វើការនៅប្រទេសថៃយូរមកហើយ ហើយថែមទាំងមានស្គាល់បណ្តាញច្រើនក្នុងចំណោមកម្មករចំណាកស្រុក។[73] ខណៈដែលកម្មករទាំងនេះ ភាគច្រើនទៅប្រទេសថៃពីដំបូងតាមរយៈច្រកក្រៅផ្លូវការ ឬផ្លូវកាត់ ក្រោយមកកម្មករជាច្រើនបានបំពេញលក្ខខណ្ឌស្របច្បាប់តាមរយៈកម្មវិធីផ្ទៀងផ្ទាត់សញ្ជាតិ[74] ដែលបានធ្វើពីចុងឆ្នាំ២០១៧ ដល់ពាក់កណ្តាលឆ្នាំ២០១៨។ ប៉ុន្តែ ទោះបីជាកម្មករទាំងនេះជារឿយៗមានលក្ខណៈស្របច្បាប់នៅក្នុងប្រទេសថៃក៏ដោយ ក៏កម្មករជាច្រើនត្រូវបាត់បង់ការងារនៅពេលដែលរដ្ឋាភិបាលថៃបិទការដ្ឋានសំណង់ជាច្រើន ក្នុងពេលមានជំងឺរាតត្បាតកូវីដ ១៩។ កម្មករខ្លះបានត្រឡប់មកផ្ទះ ហើយខ្លះទៀតនៅប្រទេសថៃដដែល ទាំងអត់មានការងារធ្វើដោយបារម្ភថា គេនឹងមិនអាចត្រឡប់ទៅប្រទេសថៃវិញបានទេបើគេទៅផ្ទះ។ បញ្ហាបំណុលដើរតួនាទីសំខាន់ធ្វើឲ្យមានការសម្រេចបែបនេះ។ ប្អូនស្រីរបស់កម្មករចំណាកស្រុកម្នាក់បាននិយាយថា “ពួកគាត់ [សាច់ញាតិរបស់គាត់] មិនហ៊ានត្រឡប់មកផ្ទះទេ ពីព្រោះពួកគាត់ត្រូវតែធ្វើការយកលុយមកសងធនាគារ / គ.ម.ហ។ គាត់លឺគេថាបើពួកគាត់មកលេងផ្ទះ ពួកគាត់នឹងមិនអាចត្រឡប់ទៅវិញបានទេ។ ដូច្នេះពួកគាត់នឹងមិនអាចសងបំណុលបានទេ។ អច្ចឹង ពួកគាត់ក៏សម្រេចបន្តនៅប្រទេសថៃ។”[75]

សូមបញ្ជាក់ថា កម្មករចំណាកស្រុករយៈពេលវែងមិនទាំងអស់គ្នាទេ ដែលបានទទួលការប៉ះពាល់ដោយអវិជ្ជមានដោយជំងឺរាតត្បាតកូវីដ ១៩។ កម្មករដែលកំពុងធ្វើការនៅខេត្តតូចៗជាមួយនឹងក្រុមការងារតូចៗនៅការដ្ឋានសំណង់តាមមូលដ្ឋាន អាចធ្វើការជាបន្ត។ ប៉ុន្តែ គ្រួសារដែលមានសមាជិករស់នៅដាច់ពីគ្នា មានការលំបាកមិនអាចមកជួបជុំបាន ក្នុងករណីជាច្រើន។ ក្នុងអំឡុងពេលដែលយើងធ្វើការសម្ភាស កម្មករជាច្រើនកំពុងរង់ចាំគេបើកច្រកព្រំដែនវិញ ទើបពួកគេអាចត្រឡប់ទៅធ្វើការវិញតាមច្រកស្របច្បាប់។ ប៉ុន្តែសមាជិកគ្រួសារផ្សេងទៀត បានត្រឡប់ទៅប្រទេសថៃវិញរួចទៅហើយតាមច្រកក្រៅផ្លូវការ។ ក្នុងពេលដែលយើងចុះទៅសួរសុខទុក្ខ កម្មករមួយចំនួនតូចដែលបានត្រឡប់មកផ្ទះ ហើយដែលយើងបានសម្ភាសកាលពីលើកមុននោះ បានត្រឡប់ទៅប្រទេសថៃវិញរួចហើយទោះបីជាព្រំដែននៅតែបិទជាផ្លូវការក៏ដោយ។

## ១.៤. កសិករដាំស្រូវ/ពោត/ដំឡូងមី

ទោះបីជាការបិទព្រំដែនមិនបានប៉ះពាល់ដល់ការនាំចេញស្រូវ ពោត និងដំឡូងមី ក៏ដោយ ក៏កសិកម្មដែលបម្រើការនាំចេញនៅមានហានិភ័យម៉្យាងនៅក្នុងវិស័យនេះផ្ទាល់។ កសិករដែលយើងបានសន្ទនាជាមួយ កត់សម្គាល់ថា នៅមុនជំងឺរាតត្បាតកូវីដ ១៩ ចាប់ផ្តើម ជារឿយៗពួកគេបានជួបបញ្ហាបរិស្ថាន ដូចជាទឹកភ្លៀងមិនគ្រប់គ្រាន់ ឬមានទឹកជំនន់។ ក្នុងករណីទាំងពីរ ផលដំណាំសុទ្ធតែបានជួបហានិភ័យដូចគ្នា។ ការប្រឈមទាំងនេះក៏មានលើកឡើងផងដែរនៅពេលយើងចុះស្រាវជ្រាវ ដែលនៅពេលនោះប្រជាជនរស់នៅតាមវាលទំនាបទន្លេសាបជួបបញ្ហាទឹកឡើងតិចពេក រីឯខេត្តផ្សេងៗបែរជាមានទឹកជំនន់ឡើងខ្លាំងទៅវិញ (សូមមើលរូបថត ៣)។ អាកាសធាតុមិនទៀងទាត់បែបនេះ គឺជាបញ្ហាប្រឈមចំពោះកសិករដែលត្រូវព្យាករពេលណាគួរចាប់ដាំដំណាំ ហើយពេលណាគួរប្រមូលផល។ បញ្ហាមួយទៀតដែលកសិករបានលើកឡើង គឺមានសត្វចង្រៃច្រើនពេក ហើយក៏មានកើតសត្វចង្រៃប្រភេទថ្មីៗទៀត។ ទោះជាយ៉ាងណាក៏ដោយបញ្ហានេះហាក់ដូចជាកសិករអាចគ្រប់គ្រងបាន ដោយសារមានថ្នាំសម្លាប់សត្វចង្រៃ និងសត្វល្អិតច្រើនប្រភេទ។ ថ្នាំសម្លាប់សត្វល្អិតទាំងនេះធ្វើឲ្យចំណាយនៃការប្រកបកសិកម្មកើនឡើង ហើយកសិករក៏មានការលំបាកដើម្បីទាញយកប្រាក់ចំណេញ។

---

73 សូមមើល Bylander 2015.

74 ដំណើរការនេះជាផ្នែកមួយនៃកិច្ចប្រឹងប្រែងធ្វើឲ្យស្របច្បាប់ចំពោះកម្មករចំណាកស្រុក ដែលមិនមានឯកសារ ដែលមកពីប្រទេសចំនួនបី គឺកម្ពុជា ភូមា និងឡាវ។

75 Participant ID:3.



*(រូបថត ៥: យុវជនមួយក្រុម កំពុងរកចាប់ត្រីនាពេលទឹកជំនន់ក្នុងស្រុកបវេល ខេត្តបាត់ដំបង ឆ្នាំ២០២០។ រូបថតដោយ វេះ ផាសុី)*

កសិករភាគច្រើនពឹងផ្អែកលើឥណទានដើម្បីធ្វើកសិកម្មដូចជាទិញជី ថ្នាំពុល ថ្នាំពៅ និងសម្រាប់ចំណាយជួលគ្រឿងចក្រ។ នៅពេលដែលកសិករលក់ផលិតផលមិនបានតាមតម្លៃដែលបានគិតទុក ឬផលទទួលបានទាបជាងការរំពឹងទុក វាជាកត្តាបង្កឲ្យមានបញ្ហាហិរញ្ញវត្ថុ ដែលតម្រូវឲ្យពួកគាត់ត្រូវជ្រើសរើសក្នុងចំណោមជម្រើសមានអាហារហូបគ្រប់គ្រាន់ពេញមួយឆ្នាំ ឬត្រូវយកទៅសងបំណុល។ អ្នកដែលធ្លាក់ក្នុងការលំបាកច្រើនឆ្នាំជាប់ៗគ្នា បំណុលកាន់តែកើនឡើង (សូមមើលគំនូសតាង ៥)។ ករណីសិក្សាចំនួនពីរខាងក្រោមនេះ យើងលើកមកដើម្បីបង្ហាញពីហានិភ័យពាក់ព័ន្ធនឹងការធ្វើកសិកម្ម។

*__បុប្ផា__[76] រៀបការនៅក្នុងឆ្នាំ២០១០។ នៅក្នុងឆ្នាំនោះ គាត់ និងប្តីគាត់បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាលើកទី១ មានចំនួន ២៥០ ដុល្លារសហរដ្ឋអាមេរិក យកមកជួសជុលផ្ទះ។ បន្ទាប់មកប្តីប្រពន្ធនេះឃើញអ្នកជិតខាងទទួលបានចំណូលល្អពីការដាំសណ្តែកបាយនៅម្តុំវាលទំនាបទន្លេសាប។ ប្តីប្រពន្ធថ្មីថ្មោងនេះមានការរំភើបចិត្ត ហើយក៏បានសម្រេចជួលដី ៤ ហិកតាមកដាំសណ្តែកបាយដែរ។ ថ្លៃឈ្នួលដីមានចំនួន ៥០០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយហិកតាក្នុងមួយឆ្នាំ។ ប្តីប្រពន្ធនេះសម្រេចខ្ចី ១.៥០០ ដុល្លារសហរដ្ឋអាមេរិកពីគ្រឹះស្ថានហិរញ្ញវត្ថុយកសម្រាប់ជាដើមទុនធ្វើកសិកម្ម។ ទោះជាយ៉ាងណាក៏ដោយ ដំណាំកសិកម្មមិនធានាថាទទួលបានប្រាក់ចំណូលឲ្យពួកគាត់បានរស់នៅគ្រប់គ្រាន់នោះទេ ដោយសារកត្តាមួយចំនួនដូចជា ការកើនឡើងនៃសត្វចង្រៃ ព្យុះ និងទឹកមានតិចពេក។ ចំនួនទឹកប្រាក់នៃឥណទានចេះតែកើនឡើងពីវគ្គកម្ចីមួយលើកវគ្គកម្ចីមួយទៀត ដោយសារប្តីប្រពន្ធត្រូវការលុយយកទៅសងឥណទានលើកមុនផង និងយកមកទ្រទ្រង់ជីវភាពផង។ នៅក្នុងឆ្នាំ២០១៦ ប្តីប្រពន្ធក៏សម្រេចឈប់ធ្វើកសិកម្ម ប៉ុន្តែមកដល់ពេលនោះបំណុលបានកើនឡើងទៅដល់ ៤.៥០០ ដុល្លារសហរដ្ឋអាមេរិក ពីគ្រឹះស្ថានហិរញ្ញវត្ថុតែមួយ (សូមមើលគំនូសតាង ៥)។ តាំងពីពេលនោះមក គ្រួសាររបស់ បុប្ផា ពឹងទៅលើប្តីដែលធ្វើការងារសំណង់ប្រចាំថ្ងៃនៅ ក្នុងមូលដ្ឋានដែលទទួលបានប្រាក់ឈ្នួលពី ១០ ទៅ ១២,៥ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃ។ ក្នុងអំឡុងពេលដែលយើងធ្វើការសម្ភាសឥណទានដែលត្រូវសងសរុបនៅសល់ចំនួនប្រហែល ២.៨០០ ដុល្លារសហរដ្ឋអាមេរិក។ បន្ទាប់ពីការបរាជ័យក្នុងការដាំសណ្តែកបាយដើម្បីកែប្រែ និងលើកកម្ពស់ជីវភាពគ្រួសារ ប្តីប្រពន្ធនេះបានសន្យាចំពោះខ្លួនឯងថា ពួកគាត់នឹងលែងខ្ចីឥណទានធំៗពីគ្រឹះស្ថានហិរញ្ញវត្ថុណាទៀតហើយ។ ក្រៅពីបរាជ័យក្នុងការដាំសណ្តែកនេះ ប្តីប្រពន្ធក៏បានខ្ចីប្រាក់ក្រៅផ្លូវការដែលត្រូវបង់ការដល់ទៅ ៣០% ក្នុងមួយខែ ដើម្បីយកទៅសងឥណទានដែលបានខ្ចីជាផ្លូវការនៅឯគ្រឹះស្ថានហិរញ្ញវត្ថុ។ នៅចុងបញ្ចប់នៃវគ្គខ្ចីនីមួយៗ ពួកគាត់ត្រូវខ្ចីប្រាក់ក្រៅផ្លូវការទៅសងគ្រឹះស្ថានហិរញ្ញវត្ថុ ហើយបន្ទាប់មកក៏យកឥណទានវគ្គថ្មីទៀតពីគ្រឹះស្ថានហិរញ្ញវត្ថុដដែល ដោយយកប្រាក់កម្ចីមួយចំនួនធំនេះទៅសងប្រាក់ខ្ចីក្រៅផ្លូវការ។ រួចហើយយកប្រាក់នៅសល់ទៅទិញជី ថ្នាំពុលថ្នាំពៅ និងសម្រាប់ចំណាយទៅលើការភ្ជួររាស់ និងទ្រទ្រង់ជីវភាពប្រចាំថ្ងៃក្នុងគ្រួសារ។ វិធីងាយស្រួលបំផុតដើម្បីប្រមើលមើលឃើញចំពោះការកើនឡើងនៃចំនួនឥណទានគ្រួសាររបស់គាត់ គឺប្រៀបដូចជាយើងវេញអំបោះពីមួយជុំទៅមួយជុំ ជុំអំបោះកាន់តែធំទៅៗ ដូចគ្នានឹងបំណុលកើនឡើងពីវគ្គខ្ចីមួយទៅវគ្គខ្ចីមួយទៀតអញ្ចឹងដែរ (សូមមើលគំនូសតាង ៥)។*

**គំនូសតាង ៥: វដ្តឥណទានរបស់ បុប្ផា ក្នុងគ្រឹះស្ថានហិរញ្ញវត្ថុមួយ**




*ប្រភព: គំនិតរបស់អ្នកនិពន្ធ។ រចនារូបភាពដោយ Gcreatives*

[76] Participant ID:84.

*ដូចគ្នានេះដែរ ពេលដែល **ពូធឿន** និង **មីងម៉ៅ** ចាប់ខ្ចីលុយពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកាលពីឆ្នាំ ២០១៤ ឥណទានដំបូងរបស់គាត់គឺយកមកទិញត្រាក់ទ័រភ្ជួរដីរបស់គាត់ ១៥ ហិកតា។ ពីរបីឆ្នាំក្រោយមក (ពូធឿន មិនចាំថាពេលណាប្រាកដ) ផលពោត និងដំឡូងមីរបស់គាត់ខូច ដោយសាររាំងស្ងួត។ ចាប់ពីពេលនោះមកបានចាប់ផ្តើមខ្វះទឹកភ្លៀងចំនួនបីឆ្នាំ ដែលធ្វើឲ្យគ្រួសារគាត់បានចាប់ផ្តើមលំបាកសងបំណុល។ ដោយសារការខាតបង់ជាប់ៗគ្នា ប្តីប្រពន្ធនេះសម្រេចលក់ត្រាក់ទ័រចេញ។ ទោះជាបានលក់ត្រាក់ទ័រហើយនៅតែសងបំណុលមិនគ្រប់ ដូច្នេះគួកគាត់ក៏លក់ដី១០ហិកតាយកមកសងទៀត។ នៅពេលដែលយើងធ្វើការសម្ភាសគ្រួសារវ័យកណ្តាលនេះកំពុងតែកាប់ដំឡូងមីដែលមិនទាន់ដល់ពេលប្រមូលផល ប៉ុន្តែត្រូវប្រមូលមុនពីរបីខែពីព្រោះគ្រួសារគាត់ត្រូវការលុយដើម្បីសងបំណុលខាងមីក្រូហិរញ្ញវត្ថុ។ ក្រុមស្រាវជ្រាវរបស់យើងបានសួរពូធឿនអំពីហានិភ័យធ្ងន់ធ្ងរក្នុងវិស័យកសិកម្មដោយបានប្រើពាក្យខ្មែរថា **ភ័យ**។ គាត់ឆ្លើយដោយលេងសើចថា "ការ**ភ័យ**ខ្លាចជាងគេ គឺខ្លាចថ្ងៃដល់កំណត់សងបំណុល ពីព្រោះខ្ញុំត្រូវសងបំណុលមួយហើយមួយទៀត។" បន្ទាប់ពីនិយាយហើយ គាត់សើចតិចៗ។ សាច់រឿងនេះឆ្លុះបញ្ចាំងការពិតដែលមានចំពោះកូនបំណុលដែលលំបាកសង ពោលគឺអារម្មណ៍**ភ័យ**។ មកទល់ពេលនេះប្តីប្រពន្ធគាត់នៅតែលំបាកដដែលក្នុងការសងបំណុលប្រចាំខែ។*[77]

ករណីសិក្សាទាំងនេះ បំភ្លឺឲ្យឃើញហានិភ័យពាក់ព័ន្ធការធ្វើកសិកម្ម ព្រមទាំងលទ្ធភាពនឹងរងសម្ពាធបំណុលដែលមានចំពោះការយកឥណទានមកធ្វើកសិកម្ម។ ខ្លឹមសារទាំងនោះ បានចងក្រងល្អិតល្អន់ដោយការស្រាវជ្រាវមុនៗ នៅក្នុងបរិបទកម្ពុជា។ តាមពិតរបាយការណ៍ចុងក្រោយបំផុតស្តីពីការជំពាក់បំណុលវ័ណ្ឌក ដែលវិស័យហិរញ្ញវត្ថុបានចាត់ចែងធ្វើការស្រាវជ្រាវ កត់សម្គាល់ថា កូនបំណុលជិតពាក់កណ្តាល (៤៩%) ទទួលបានផលដំណាំតិចជាងការរំពឹងទុក ហើយភាគរយប្រហែលគ្នានេះ (៤៧%) បានរងនូវតម្លៃផលដំណាំធ្លាក់ចុះខ្លាំង។[78] ប្រហែលកត្តានេះហើយដែលនាំឲ្យរបាយការណ៍នោះ ក៏លើកឡើងផងដែរថា កូនបំណុលដែលយកប្រាក់ឥណទានមកធ្វើកសិកម្ម ច្រើនតែត្រូវប្រើវិធីទប់ទល់ណាមួយទៀតទើបអាចសងបំណុលទាន់ពេល។[79]

## គំនូសតាង ៦: ប្រតិទិននៃការដាំដំណាំស្រូវ/ពោត/ដំឡូងមី នៅកម្ពុជា




*ប្រភព: គំនិតរបស់អ្នកនិពន្ធ។ រចនារូបភាពដោយ Gcreatives*

---

77 Participant ID:77.
78 MFC and Good Return 2017.
79 MFC and Good Return 2017.

ទោះជាជំងឺរាតត្បាតកូវីដ ១៩ មិនបានប៉ះពាល់ខ្លាំងដល់វិស័យកសិកម្មដោយផ្ទាល់ក៏ដោយ ក៏វាបានបង្កើនភាពងាយរងគ្រោះ ដោយបានធ្វើឲ្យកសិករលំបាកក្នុងការរកការងារដែលបានប្រាក់ឈ្នួលប្រចាំថ្ងៃ ក្រៅពីរដូវធ្វើកសិកម្ម ដោយសារ (ដូចបានរៀបរាប់ខាងលើ) មិនអាចធ្វើចំណាកស្រុកទៅប្រទេសជិតខាង ថែមទាំងមានអតិរេកការផ្គត់ផ្គង់កម្លាំងពលកម្មនៅក្នុងស្រុក។ កសិករភាគច្រើនបានប្រើវិធីដែលហៅថា បណ្តាក់លុយ ដែលកសិករខ្ចីប្រាក់ក្នុងរដូវដាំដុះ ហើយសងដើមមកវិញនៅរដូវប្រមូលផល (សូមមើលគំនូសតាង ៦)។ ដូច្នេះ មានន័យថា អ្នកដែលដាំដំណាំសម្រាប់លក់ ក៏ធ្វើសកម្មភាពផ្សេងៗទៀតដែរ ដើម្បីរកចំណូលមកបង្គ្រប់ការចំណាយប្រចាំថ្ងៃ។ ហើយនេះជាការពិត ជាពិសេសសម្រាប់អ្នកដែលមានដីកម្មសិទ្ធិ ២ហិកតា ឬតិចជាង ២ហិកតា។ ដោយសារកសិករកម្ពុជាច្រើនតែដាំដំណាំសម្រាប់លក់ដែលមានតម្លៃបន្ថែមតិច ដូចជាពោត ដំឡូងមី និងស្រូវ ប្រាក់ចំណូលពីដី ២ ហិកតា គឺមិនគ្រប់គ្រាន់សម្រាប់គ្រួសារដែលមានគ្នា៤នាក់នោះទេ។

ដើម្បីជីវភាព សមាជិកគ្រួសារត្រូវប្រកបរបបផ្សេងៗរកចំណូលនៅក្នុងសហគមន៍ ឬធ្វើចំណាកស្រុកទៅទីក្រុង ឬប្រទេសជិតខាង ក្រៅពីរដូវដាំដុះ។ ឧទាហរណ៍ ជារឿយៗអ្នកដែលរស់នៅជិតព្រំដែន ធ្វើចំណាកស្រុកទៅប្រទេសថៃ ដើម្បីធ្វើការយក



*(រូបថត ៦: កំពុងកាប់ដំឡូងមី ដែលប្រមូលមុនរដូវ នៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឆ្នាំ២០២០។ រូបថតដោយ វេះ ផាស៊ី)*

ប្រាក់ឈ្នួលក្រៅពីរដូវដាំដុះ។ ទោះជាយ៉ាងណាក៏ដោយ ពេលព្រំដែនបានបិទ ឱកាសទាំងនេះក៏មិនមានដែរ។ ជាទូទៅប្រាក់ដែលរកលែងបាននេះច្រើនតែធ្លាប់យកទៅចំណាយប្រចាំថ្ងៃ និងសងការប្រាក់ប្រចាំខែចំពោះបំណុលផ្សេងៗ។ កសិករដែលធ្វើការយកប្រាក់ឈ្នួល អាយុ ៣១ឆ្នាំនិយាយថា “នៅពេលមិនមានជំងឺកូវីដ ១៩ ផ្ទុះឡើងទេនោះ ខ្ញុំធ្វើការឲ្យគេបានប្រាក់ឈ្នួលខ្លះ ហើយប្ដីខ្ញុំធ្វើចំណាកស្រុកទៅប្រទេសថៃប្រចាំថ្ងៃ។ ដូច្នេះទើបយើងអាចសងការប្រាក់គ្រប់ចំនួន។ ពួកខ្ញុំមានការលំបាកនៅក្នុងពេលមានជំងឺកូវីដ។”[80] ដូចគ្នានេះដែរ បុរសជាប្រធានសាខា គ.ម.ហ ម្នាក់ បានលើកឡើងថា នៅក្នុងពេលគាត់ទៅផ្ទះអតិថិជន មុនកូវីដ ១៩ អតិថិជនរបស់គាត់មានការងារធ្វើក្រៅពីរដូវដាំដុះ នៅក្នុងការដ្ឋានសំណង់នៅប្រទេសកម្ពុជា ឬធ្វើចំណាកនៅរដូវដែលមានការងារធ្វើនៅប្រទេសថៃ។ ទោះជាយ៉ាងណាក៏ដោយចាប់តាំងពីកូវីដកើតឡើងមក គាត់មានប្រសាសន៍ថា អតិថិជន និងកូនៗអតិថិជនរបស់គាត់មិនមានការងារធ្វើទេ។[81] ដោយសារមិនមានឱកាសរកចំណូលឲ្យបានពីច្រើនមុខរបរផ្សេងៗគ្នាទេនោះ គ្រួសារនានាងាយនឹងរងគ្រោះជាខ្លាំង ការរងគ្រោះនេះកាន់តែប្រាកដថែមទៀត ករណីដែលពួកគេក៏មានជាប់បំណុលគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការដែរនោះ។



*(រូបថត ៧: ដំណាំស្រូវ, ដំឡូងមី, ពោត, សណ្ដែកបាយ, នៅខេត្តកំពង់ឆ្នាំង និងខេត្តបាត់ដំបង ឆ្នាំ២០២០។ រូបថតដោយ វេះ ផាស៊ី)*

[80] Participant ID:64.
[81] FI ID:11.

## ១.៥. ភាពងាយរងគ្រោះក្នុងជីវភាពរស់នៅពាក់ព័ន្ធនឹងវិស័យនីមួយៗ មុនកូវីដ ១៩

ក្នុងចំណោមវិស័យទាំង៤ ដែលយើងបានសិក្សាមានហានិភ័យពីមុនមកក្នុងលក្ខណៈខុសៗគ្នា។ ពីមុនមានកូវីដ ១៩ កម្មករផលិតសម្លៀកបំពាក់មានស្ថិរភាពការងារមិននឹងនរ ហើយមិនអាចរំពឹងទុកជាមុនបានដោយសារមានការដក អ៊ីប៊ីអេ និងមានការអនុវត្តកិច្ចសន្យាការងាររយៈពេលខ្លី។ នៅក្នុងវិស័យកសិកម្មវិញ កសិករបានជួបការប្រែប្រួលអាកាសធាតុ ថ្លៃផលដំណាំឡើងចុះធ្វើឲ្យពួកគាត់លំបាករកចំណូលឲ្យបាននឹងនរ និងគ្រប់គ្រាន់។ កម្មករចំណាកស្រុកបានស្ថិតនៅដោយឡែកពីគេ ហើយត្រូវបានកេងប្រវ័ញ្ចជាច្រើនទសវត្សរ៍ ហើយទោះជាប៉ុន្មានឆ្នាំចុងក្រោយកម្មករទាំងនេះ បានទទួលការការពារចំពោះការងារបានច្រើនជាងមុនក៏ដោយ ក៏កម្មករជាច្រើននៅតែមិនបានទទួល ហើយងាយនឹងរងការបំពាន។ វិស័យទេសចរណ៍ជាទូទៅមានស្ថានភាពនឹងនរជាងគេ ក៏ប៉ុន្តែ អ្នកបើកបរ មគ្គុទ្ទេសទេសចរណ៍ កម្មករនិយោជិតជាច្រើន មិនមានមុខរបរណាផ្សេងក្រៅពីវិស័យនេះឡើយ បង្កឲ្យងាយនឹងមានការប៉ះពាល់ជាលក្ខណៈទូទៅក្នុងវិស័យតែម្តង ដោយសារកូវីដ ១៩។

នៅក្នុងបណ្តាវិស័យទាំងនេះគ្រួសារភាគច្រើនយកឥណទាន៖ មកធ្វើវិនិយោគ ចំណាយប្រចាំថ្ងៃ ជួសជុលផ្ទះ ថែទាំសុខភាព[82] និងបង់ថ្លៃសាលា។ បញ្ហាបំណុលខ្ពស់ក្នុងគ្រួសារទូទាំងប្រទេស ការប៉ះពាល់នៃជំងឺរាតត្បាតជាសកលធ្ងន់ធ្ងរ និងមិនធ្លាប់មានពីមុនមក ព្រមទាំងជីវភាពដែលងាយរងគ្រោះពីមុនមក ជាកត្តារួមដែលធ្វើឲ្យមានអស្ថិរភាពសេដ្ឋកិច្ចធ្ងន់ធ្ងរ។ គ្រួសារជាច្រើនកំពុងលំបាកបំពេញតម្រូវការផង និងបង្គ្រប់សងបំណុលផង។ លើសពីនេះទៀត ជំងឺកូវីដ ១៩ បានរឹតត្បិតមិនឲ្យគ្រួសារនានាមានវិធីណាច្រើនយកមកឆ្លើយតបនឹងបញ្ហាទាំងនេះ ដោយសារទម្រង់នៃការរកចំណូលផ្សេងៗ និងការឆ្លើយតប លែងមានដូចពីមុន។ នៅក្នុងជំពូកបន្ទាប់ យើងស្វែងយល់អំពីវិធីផ្សេងៗដែលគ្រួសារកំពុងប្រើទប់ទល់នឹងការបាត់បង់ចំណូល៖ តាមរយៈការបង្វែរគោលដៅនៃធនធាន និង/ឬ ចាប់យករបរថ្មី ព្រមទាំងតាមរយៈវិធីទប់ទល់ផ្សេងៗទៀត។

# ផ្នែកទី ២. ការកែប្រែមុខរបរទប់ទល់នៅនឹងការធ្លាក់ចុះប្រាក់ចំណូល

នៅក្នុងផ្នែក១ របាយការណ៍នេះបានបង្ហាញវិធីដែលគ្រួសារពាក់ព័ន្ធនឹងការផលិតសម្លៀកបំពាក់ ធ្វើចំណាកស្រុកក្រៅប្រទេស វិស័យទេសចរណ៍ និងកសិកម្មបម្រើការនាំចេញ បានជួបប្រទះការបាត់បង់ចំណូលដោយសារវិបត្តិកូវីដ ១៩។ ផ្នែកនោះក៏បានពន្យល់វិធីដែលកូវីដ ១៩ កាត់បន្ថយសមត្ថភាពនៃគ្រួសារនានា ក្នុងការរកប្រាក់ចំណូលឲ្យបានច្រើនមុខ ដែលជាបន្ទុកបន្ថែមទៀតសម្រាប់គ្រួសារដែលមានអស្ថិរភាពក្នុងមុខរបរតាំងពីមុនមក។ ផ្នែកនេះ នឹងពិភាក្សាពីការប្រែប្រួលមុខរបរដើម្បីឆ្លើយតបនឹងការបាត់បង់ចំណូលដោយឆ្លើយនឹងសំណួរ “តើបុគ្គលទាំងឡាយធ្វើអ្វីនៅពេលដែលគេបាត់បង់ប្រាក់ចំណូល”? ឈរលើទិន្នន័យមានវិធីឆ្លើយតបពីរសំខាន់ទាក់ទងទៅនឹងការបាត់បង់ប្រាក់ចំណូល៖ ១) ការកែប្រែជីវភាពក្នុងករណីចាប់យកមុខរបរថ្មី ២) រកការងារប្រចាំថ្ងៃ ឬបន្ថែមសកម្មភាព ក្នុងករណីមិនផ្លាស់ប្តូរមុខរបរ។ វិធីសាស្ត្រឆ្លើយតបទាំងនេះបានប្រើទាំងគ្រួសារដែលមានឥណទានត្រូវសងផង និងមិនមានឥណទានត្រូវសងផង ប៉ុន្តែគ្រួសារដែលរងសម្ពាធបំណុល ជារឿងៗ មានតម្រូវផ្នែកហិរញ្ញវត្ថុខ្លាំងជាង ដោយសារពួកគាត់ត្រូវចំណាយមិនត្រឹមតែទ្រទ្រង់គ្រួសារប៉ុណ្ណោះទេ ក៏ប៉ុន្តែ ក៏ត្រូវសងបំណុលផងដែរ។ ផ្នែកខាងក្រោមរៀបរាប់នូវវិធីទប់ទល់ផ្សេងៗទៀតដែលគ្រួសារនានាប្រើ។

[82] Ir Por et al 2019.

## ២.១. ការកែប្រែជីវភាព: វិធីប្រើសម្រាប់គ្រួសារដែលមានមុខរបរច្រើនមុខ

ការប្រកបរបរច្រើនមុខសម្រាប់ទ្រទ្រង់ជីវភាពមានសារៈសំខាន់ ដើម្បីឆ្លើយតបដោយប្រសិទ្ធភាព ទៅនឹងស្ថានភាពឡើងចុះសេដ្ឋកិច្ច ឧទាហរណ៍ដូចជាក្នុងករណីជំងឺរាតត្បាតកូវីដ ១៩ នេះ។ ចំពោះគ្រួសារដែលមាន ច្រើនមុខរបរតាំងតែពីមុនកូវីដ វិធីឆ្លើយតបដែលប្រើជាទូទៅជាងគេក្នុងការទប់ទល់នឹងប្រាក់ចំណូលធ្លាក់ចុះ គឺដកយកធនធានទៅប្រើក្នុងរបរណាដែលប៉ះពាល់តិចជាងគេ ដោយសារកូវីដ ១៩។ ឧទាហរណ៍ កម្មការនីផលិតសម្លៀកបំពាក់ម្នាក់ឈ្មោះ **ស្រីនាង**[83] បានធ្វើការក្នុងរោងចក្រតែមួយអស់រយៈពេលបីឆ្នាំ។ គាត់ត្រូវបានបញ្ឈប់ពីការងារប្រហែលជានៅខែឧសភា ឆ្នាំ២០២០ ហើយមិនបានទទួលអត្ថប្រយោជន៍អ្វីនោះឡើយ។ ដោយសារថា គាត់មានកិច្ចសន្យារយៈពេលខ្លី។[84] ទោះជាយ៉ាងណាក៏ដោយ នៅមុនកូវីដ គាត់បានយកប្រាក់សន្សំពីការងាររោងចក្រទៅទិញបានតូបពីរនៅផ្សារមួយជិតៗនោះ ដែលគាត់យកទៅបើកហាងកែសម្ផស្ស។ ហាងនេះគាត់ចំណាយអស់ ៦.០០០ ដុល្លារសហរដ្ឋអាមេរិក។ ពីមុន គាត់ធ្វើការនៅរោងចក្រនៅថ្ងៃធ្វើការ នៅចុងសប្តាហ៍ និងល្ងាចៗគាត់ធ្វើការនៅហាងកែសម្ផស្សរបស់គាត់។ ដោយសារតែគាត់បានបាត់បង់ការងាររោងចក្រ គាត់សម្រេចធ្វើការនៅហាងរបស់គាត់ទាំងស្រុងតែម្តង។ នៅពេលដែលយើងធ្វើសម្ភាស មុខរបររបស់គាត់ដូចជាកំពុងដំណើរការល្អ ហើយគាត់មានអតិថិជនជាប្រចាំ។

កម្មករផ្សេងៗទៀតជាច្រើន ដែលយើងបានសន្ទនាក៏មានដំណើររឿងប្រហាក់ប្រហែលគ្នាដែរ ចំពោះការយកធនធានទៅប្រើក្នុងរបរថ្មី។ ឧទាហរណ៍ **សម្ភស្ស**[85] និងប្តីគាត់ធ្លាប់ទៅធ្វើការជាអ្នកចាប់ទឹកកក និងរត់ម្ហូបនៅតាមពិធីអាពាហ៍ពិពាហ៍ ដោយរកបានពី១០ ទៅ ១៥ ដុល្លារសហរដ្ឋអាមេរិកក្នុងកម្មពិធីមង្គលការមួយ។ ប៉ុន្តែចាប់តាំងពីកូវីដកើតឡើង មិនសូវមានការរៀបចំអាពាហ៍ពិពាហ៍ទេ ហើយប្តីប្រពន្ធនេះមិនបានទទួលចំណូលដូចរាល់ដងឡើយ។ សរុបមកពួកគាត់បានយកកម្លាំងកាយទៅប្រើក្នុងការងារដែលពីមុនជារបរបន្ថែមចំណូលតិចតួចប៉ុណ្ណោះសម្រាប់ពួកគាត់៖ ដូចជា ចាក់កន្ត្រក (សម្រាប់សម្ភស្ស) និងការងារសំណង់ (សម្រាប់ប្តីគាត់)។ របរទាំងនេះឥឡូវបានក្លាយជាប្រភពចំណូលចម្បងរបស់គាត់ទៅវិញ។ **សម្ភស្ស** ចាក់កន្ត្រកបានពីរក្នុងមួយថ្ងៃ ហើយកន្ត្រកមួយអាចលក់បានប្រហែល ១,២៥ ដុល្លារសហរដ្ឋអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ តម្លៃនេះគឺទាបជាងតម្លៃធម្មតាមុនពេលកូវីដ ហើយមានបញ្ហាខ្លះៗពាក់ព័ន្ធនឹងការផ្គត់ផ្គង់វត្ថុធាតុដើមយកមកប្រើ។ **សម្ភស្ស** បានប្រាប់ឲ្យដឹងថា អ្នកភូមិរបស់នាងជាច្រើននាក់បានចាប់យកការចាក់កន្ត្រកធ្វើជាមុខចំណូលចម្បង ហើយឥឡូវនៅតំបន់នោះមានការខ្វះខាតវល្លិ៍ល្ពាក់។ កត្តានេះបានជំរុញឲ្យអ្នកភូមិទៅជួលឡាន ដើម្បីរកវល្លិ៍ល្ពាក់នៅខេត្តជិតខាងដែលធ្វើឲ្យចំណាយនៃការធ្វើកន្ត្រកកើនឡើង។

នៅក្នុងករណីរបស់ **ស្រីនាង** និង **សម្ភស្ស** គ្រួសារមួយមានវិធីច្រើនរកប្រាក់ចំណូល ហើយអាចផ្លាស់ប្តូរពេលវេលា និងធនធានយកទៅប្រើបានឆាប់រហ័សក្នុងមុខរបរថ្មី ដែលនៅអាចធ្វើបានក្នុងរយៈពេលមានកូវីដ ១៩។ ចំពោះកូនបំណុលខ្លះដូចជា **ស្រីនាង** នេះ អាជីវកម្មបែបនោះឃើញថា បានទទួលជោគជ័យគ្រាន់បើ។ ចំពោះអ្នកផ្សេងទៀត ដូច **សម្ភស្ស** ផ្លាស់ប្តូរទៅមុខរបរថ្មីគ្រាន់តែទទួលបានប្រាក់សម្រាប់ការចំណាយជាមូលដ្ឋានប៉ុណ្ណោះ។

83 Participant ID:47.
84 កិច្ចសន្យារបស់គាត់បានបន្តរៀងរាល់ ៦ ខែ។
85 Participant ID:130.

## ២.២. មុខរបរថ្មី៖ ការឆ្លើយតបដោយគ្រួសារដែលមានប្រាក់ចំណូលក្នុងវិស័យតែមួយ

សម្រាប់អ្នកដែលមានប្រាក់ចំណូលពីវិស័យតែមួយ វិធីសាស្ត្រដែលច្រើនប្រើជាងគេ គឺមានដូចជា ទៅធ្វើការរកប្រាក់ឈ្នួលប្រចាំថ្ងៃក្នុងវិស័យ ផ្សេងៗទៀតដូចជា វិស័យសំណង់ ឬកសិកម្ម ឬក៏ប្រកបមុខរបរថ្មីតែម្តង។ ការប្រកបមុខរបរថ្មីជាទូទៅត្រូវបានចាត់ទុកថា ជាវិធីដែលមានហានិភ័យខ្ពស់ អាស្រ័យហេតុនេះហើយបានជាអ្នកដែលយើងបានសន្ទនាជាមួយ ភាគច្រើនងាកទៅចាប់យកការងារប្រាក់ឈ្នួលប្រចាំថ្ងៃជាបណ្តោះអាសន្ន ដោយចាត់ទុកថាជាជម្រើសងាយស្រួល និងមិនសូវមានហានិភ័យខ្ពស់។ ជាប្រវត្តិកន្លងមក វិស័យសំណង់ និងកសិកម្មធ្លាប់តែមានសមត្ថភាពផ្តល់ការងារបណ្តោះអាសន្ន ឬទៅតាមរដូវ សម្រាប់អ្នកដែលបាត់បង់ប្រាក់ចំណូល។ ប៉ុន្តែដើម្បីអាចរកការងារបានធ្វើក្នុងពេលមិនសូវមានការងារបែបនេះ តម្រូវឲ្យមានខ្សែរយៈច្រើន។ លើសពីនេះ ក្នុងករណីភាគច្រើន ប្រភេទការងារដែលមានក្នុងវិស័យនេះគឺមានលក្ខណៈប្រើកម្លាំងច្រើន មិនទៀងទាត់ ហើយមិនសូវបានថ្លៃ។ លើសពីនេះការងារប្រចាំថ្ងៃមិនមានការគ្រប់គ្រងជាផ្លូវការ ធ្វើឲ្យមានការកេងប្រាក់ឈ្នួលអាចធ្វើទៅបាន។ កត្តានេះជំរុញឲ្យមានការព្រួយបារម្ភខ្លាំងក្នុងអំឡុងពេលមានកូវីដ។ តាមពិតការស្រាវជ្រាវរបស់យើងបានជួបករណីកម្មករជាច្រើនក្នុងវិស័យសំណង់ដែលមិនបានទទួលប្រាក់ឈ្នួលសម្រាប់ការងារដែលពួកគេបានធ្វើ។ ស្ត្រីម្នាក់ដែលធ្វើការនៅក្នុងហាងលក់វត្ថុអនុស្សាវរីយ៍តូចមួយរបស់ខ្លួនឯងផ្ទាល់បាននិយាយប្រាប់ថា “ពីមុន ប្តីរបស់ខ្ញុំធ្វើការជាមគ្គុទ្ទេសទេចរណ៍ ប៉ុន្តែដោយសារមិនមានអ្នកទេសចរមកទេនោះគាត់បានទៅធ្វើការសំណង់ជាបណ្តោះអាសន្ន។ ប៉ុន្តែគាត់ត្រូវបានមេកាបោក។”[86] ការព្រួយបារម្ភបែបនេះក៏បានលើកឡើងដោយបុគ្គលិក គ.ម.ហ ផងដែរ។ បុគ្គលិកផ្នែកឥណទាន និងប្រធានសាខាជាច្រើន ដែលមានអតិថិជនរបស់ខ្លួនពឹងផ្អែកទៅលើការងារសំណង់ជាចម្បងនោះ ក៏បានសម្តែងការព្រួយបារម្ភប្រហាក់ប្រហែលគ្នាដែរ ព្រមទាំងបានពន្យល់បន្ថែមថា ឆ្នាំនេះ អតិថិជនរបស់ពួកគេជាច្រើននាក់ត្រូវបានមេកាបោក (មិនបានទទួលប្រាក់ឈ្នួល)។ យោងតាមការសម្ភាសជាមួយគ្រួសារផ្សេងៗ និងជាមួយតំណាងស្ថាប័នហិរញ្ញវត្ថុ ហានិភ័យដោយសារការកេងប្រាក់ឈ្នួលនេះគឺទាបជាងប្រសិនជាប្រៀបធៀបទៅកាលមុនពេលមានកូវីដ ១៩។

ការងារកសិកម្មដែលធ្វើយកប្រាក់ឈ្នួលប្រចាំថ្ងៃ ច្រើនតែធ្វើបានតាមរដូវ ហើយភាគច្រើនមានតែក្នុងពេលប្រមូលផល។ ពោត និងដំឡូងមី ជាប្រភេទដំណាំត្រូវការប្រើកម្លាំងពលកម្មច្រើន នាពេលប្រមូលផលដំណាំទាំងពីរអាចផ្តល់ការងារមួយចំនួនដែរដល់គ្រួសារដែលមានចំណូលទាប។ ជាទូទៅ ពោតតែងតែប្រមូលផល ពីរដងក្នុងមួយឆ្នាំ ចំណែកឯ ដំឡូងមីប្រមូលផល មួយដងក្នុងមួយឆ្នាំ (សូមមើលគំនូសតាង ៦)។ ប្រភេទការងារដែលបានប្រាក់ឈ្នួលប្រចាំថ្ងៃនេះ ជាវិធីឆាប់រហ័សមួយក្នុងការរកប្រាក់មកប៉ះប៉ូវប្រាក់ចំណូលដែលបាត់បង់ ហើយវាក៏មិនត្រូវការជំនាញថ្មីដែរ។ នៅពេលដែលយើងធ្វើការសម្ភាស អ្នកផ្តល់សម្ភាសដែលធ្លាប់ធ្វើជាកម្មករចំណាកស្រុកទៅប្រទេសថៃ ហើយដែលមិនអាចត្រឡប់ទៅវិញបាន ក៏មានផែនការចង់ធ្វើចំណាកស្រុកទៅភាគបស្ចិមនៃប្រទេសកម្ពុជា ដើម្បីរកការងារដូចជាកាច់ពោត និងដកដំឡូង។

នៅពេលដែលមិនមានការងារក្នុងវិស័យសំណង់ ឬកសិកម្ម ឬក៏មិនមានប្រាក់ចំណូលគ្រប់គ្រាន់ គ្រួសារផ្សេងៗងាកទៅធ្វើអ្វីក៏ធ្វើឲ្យតែពួកគាត់អាចធ្វើបាន ដើម្បីរកប្រាក់មកប៉ះប៉ូវការបាត់បង់ប្រាក់ចំណូលនេះ។ ឧទាហរណ៍ ភាគច្រើននៃអ្នកដែលយើងបានសម្ភាស ដែលជាគ្រួសារមានចំណូលទាប រស់នៅតាមជិតព្រំដែនកម្ពុជាថៃ រើសខ្យងព្រៃ បេះត្រួយអំពិល ឬរើសពោតដែលគេកាច់សល់។ ពលករចំណាកស្រុកតាមរដូវអាយុ ៤០ឆ្នាំ ម្នាក់បាននិយាយថា “រាល់ថ្ងៃប្តីខ្ញុំទៅរើសពោតដែលគេកាច់សល់។”[87] កម្មករ

[86] Participant ID:118.
[87] Participant ID:65.

ចំណាកស្រុកម្នាក់ទៀតដែលបានត្រឡប់មកវិញហើយ បានបន្ថែមថា សមាជិកគ្រួសារគាត់ដើររើសខ្យងនៅក្នុងព្រៃ ហើយរកបានបីទៅបួនគីឡូក្រាមក្នុងមួយថ្ងៃ ដោយលក់បានមួយគីឡូក្រាមថ្លៃ ២៧០០ រៀល (សូមមើលរូបថត ៨)។[88]



*(រូបថត ៨: ខ្យងដែលគ្រួសារចំណាកស្រុករើសមកពីព្រៃ នៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឆ្នាំ២០២០។ រូបថតដោយ វេះ ផាស៊ី)*

អ្នកខ្លះដែលបានផ្តល់បទសម្ភាសចាប់ផ្តើមមុខរបរថ្មីទាំងស្រុងតែម្តងនៅពេលមានកូវីដ ១៩។ នៅក្នុងករណីភាគច្រើន ការប្រកបរបរថ្មីនេះផ្អែកទៅលើជំនាញចាស់ៗ ដូចជាលក់ដូរ កាត់ដេរ ឬចិញ្ចឹមសត្វ។ មុខរបររកចំណូលថ្មីៗដែលយើងរកឃើញក្នុងការស្រាវជ្រាវនេះរួមមាន៖ ការធ្វើកសិកម្ម (ចិញ្ចឹមត្រី កង្កែប និងមាន់) លក់ផលិតផលតម្រូវតាមអ្នកមូលដ្ឋាន និងបើកអាជីវកម្មតូចៗ។ ត្រង់ចំណុចនេះ យើងលើកយកករណីសិក្សាចំនួន ៣ ដើម្បីឆ្លុះបញ្ចាំងឲ្យឃើញពីរបៀបដែលគ្រួសារទាំងឡាយដែលបានប៉ះពាល់ដោយសារកូវីដ ងាកទៅចាប់យកមុខរបរថ្មី ដើម្បីបំពេញតម្រូវការជីវភាព។

88 Participant ID:69.

*__ធារ៉ា__[89] ជាបុរសម្នាក់អាយុ២៩ឆ្នាំ។ គាត់បានរៀបការ និងមានកូនស្រីម្នាក់អាយុ២ឆ្នាំ។ នៅពេលសម្ភាស ប្រពន្ធរបស់គាត់មានផ្ទៃពោះ ហើយនឹងឆ្លងទន្លេ ក្នុងរយៈពេលពីរបីខែទៀត។ មុនពេលមានកូវីដ ១៩ គាត់បើកបរទុកទុកនៅពេលយប់ ហើយដឹកជញ្ជូនទឹកសុទ្ធនៅពេលថ្ងៃ។ តាំងពីកើតមានជំងឺរាតត្បាតមក គាត់មិនអាចបើកបររកប្រាក់បានដូចមុនទេ ធ្វើឲ្យគ្រួសារគាត់ជួបការលំបាកខាងហិរញ្ញវត្ថុ។ ដើម្បីបំពេញការខ្វះខាតចំណូលដែលបាត់បង់មកពីការមិនបានបើកបរទុកទុក គាត់បានសម្រេចទិញមេមាន់១០០ក្បាលមកចិញ្ចឹម។ ទោះជាយ៉ាងណាក៏ដោយមាន់ដែលគាត់ទើបតែទិញមកថ្មីភាគច្រើនកើតមានជំងឺ ហើយបានងាប់។ ដើម្បីបំពេញគាត់បានទិញមាន់២០ក្បាលថែមទៀត។*

*__នាថ__[90] ជាស្ត្រីម្នាក់មានអាយុជិត៣០ឆ្នាំ។ គាត់បានរៀបការ និងមានកូនស្រី២នាក់។ គាត់បើកតូបមួយនៅផ្សាររាត្រីក្នុងមូលដ្ឋានរបស់គាត់ដោយមានលក់កន្ត្រក និងឧបករណ៍សិប្បកម្មផ្សេងៗទៀត។ __នាថ__ និយាយថា មុនកូវីដ គាត់លក់វត្ថុសិប្បកម្មដែលលក់ដាច់សម្រាប់អ្នកទេសចរអន្តរជាតិ។ ដោយសារមិនមានសង្ឃឹមថា អ្នកទេសចរអន្តរជាតិមកទៀតទេក្នុងពេលឆាប់ៗនោះ គាត់ក៏ដាក់ផលិតផលថ្មីនៅក្នុងហាងដដែលរបស់គាត់ជំនួសវិញសំដៅរកអតិថិជនក្នុងស្រុក។ ក្នុងរយៈពេលពីរបីសប្តាហ៍ក្រោយពីបានបើកតូបនេះ អាជីវកម្មថ្មីនេះបានដំណើរការល្អ ប៉ុន្តែមកដល់ពេលដែលបានសម្ភាសនេះ គាត់និយាយថា មានអ្នកលក់កាន់តែច្រើនហើយដែលធ្វើដូចគាត់ ដែលធ្វើឲ្យមានការទាញយកអតិថិជនខ្លះពីអាជីវកម្មរបស់គាត់។*

*ស្ត្រីម្នាក់ឈ្មោះ __នារី__[91] អាយុ ៣២ឆ្នាំ។ គាត់បានរៀបការហើយមានកូនពីរនាក់។ គាត់បានទៅធ្វើការក្នុងវិស័យផលិតសម្លៀកបំពាក់ធ្វើឈប់ៗអស់រយៈពេលជាង១០ឆ្នាំ ខណៈដែលជាមួយគ្នានោះគាត់ក៏ ធ្វើស្រែផងដែរ។ ក្នុងពេលថ្មីៗនេះគាត់បានធ្វើការនៅរោងចក្រមានកិច្ចសន្យារយៈពេលខ្លី ហើយនៅចុងខែមីនា ឆ្នាំ២០២០ គេប្រាប់ថា កិច្ចសន្យាគាត់មិនត្រូវបន្តទេ។ គាត់មិនបានទទួលអត្ថប្រយោជន៍ ហើយក៏មិនបានទទួលការឧបត្ថម្ភជាសាច់ប្រាក់អ្វីក្រៅពីប្រាក់ខែ និងប្រាក់អតីតភាពឡើយ។ ក្នុងខែកក្កដា ឆ្នាំ២០២០ ប្រធានរបស់គាត់ហៅគាត់ទៅធ្វើការវិញ ប៉ុន្តែគាត់មិនទៅទេ ព្រោះខ្លាចបញ្ឈប់ម្តងទៀតដោយសារស្ថានភាពកូវីដមិនទៀងទាត់។ ប្តីរបស់គាត់បានធ្វើការដូរចុះឡើងរវាងការងារសំណង់រកប្រាក់ឈ្នួលប្រចាំថ្ងៃ និងការធ្វើស្រែ។ ក្រោយពីនារីបានបោះបង់ចោលឱកាសការងាររបស់គាត់ ប្តី ប្រពន្ធនេះសម្រេចត្រឡប់ទៅស្រុកកំណើតហើយបើកហាងកាត់ដេរមួយ។ ធ្វើដូច្នេះបានដោយសារពួកគេទាំងពីរពឹងលើជំនាញដែលនារីបានរៀនក្នុងវគ្គកាត់ដេររៀងរាលល្ងាចៗបន្ទាប់ពីចេញពីធ្វើការនៅរាជធានីភ្នំពេញ។*

[89] Participant ID: 25.
[90] Participant ID:121.
[91] Participant ID:80.

ករណីសិក្សាទាំងបីនេះក៏បានឆ្លុះបញ្ចាំងផងដែរ នូវតួនាទីគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងការជួយដល់ការងាកទៅចាប់យកមុខរបរថ្មី។ ម្នាក់ៗក្នុងចំណោមបុគ្គលទាំងបីនាក់ដែលបានរៀបរាប់ខាងលើនេះ នាពេលបច្ចុប្បន្ន គឺជាកូនបំណុលខាងមីក្រូហិរញ្ញវត្ថុ ហើយម្នាក់ៗជាប់បំណុលដែលពួកគេលំបាកនឹងសងដោយសារមានការបាត់បង់ចំណូល។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីនីមួយៗ កូនបំណុលសុទ្ធតែបានទៅពឹងខាងគ្រឹះស្ថានហិរញ្ញវត្ថុ ឲ្យជួយតម្រង់ទិសចំពោះការចាប់យកមុខរបរថ្មី។ ឧទាហរណ៍ **នាថ** ជាអ្នកលក់នៅផ្សាររាត្រី បានជាប់បំណុលនៅគ្រឹះស្ថានហិរញ្ញវត្ថុចំនួន ២ សរុបជាទឹកប្រាក់ចំនួនប្រហែល ៧.០០០ ដុល្លារសហរដ្ឋអាមេរិក។ ដើម្បីដាក់ទំនិញថ្មីចូលក្នុងតូបរបស់គាត់ គាត់បានខ្ចីប្រាក់បន្ថែម ហើយប្រើទុនថ្មីនេះទៅទិញផលិតផលថ្មីសម្រាប់ទីផ្សារក្នុងស្រុក។ ចំពោះ **នារី** ការបើកហាងកាត់ដេររបស់គាត់ត្រូវការឥណទានច្រើនដើម្បីចំណាយ។ មុននឹងបើកហាង គាត់បានប្រើប្រាក់ដែលខ្ចីមកពីសាច់ញាតិ ពីមីងរបស់គាត់យកមកបង់ផ្តាច់បំណុលចាស់ ដែលមាននៅ គ.ម.ហ (ប្រហែល៨៥០ដុល្លារសហរដ្ឋអាមេរិក) ហើយ បន្ទាប់មកបានស្នើសុំកម្ចីថ្មីចំនួន ៣.០០០ ដុល្លារសហរដ្ឋអាមេរិក។ គាត់ត្រូវបានបដិសេធចំពោះពាក្យសុំលើកទីមួយ ប៉ុន្តែនៅគ្រឹះស្ថានថ្មីមួយទៀត ការសុំលើកទីពីររបស់គាត់បានទទួលជោគជ័យ។ ក្នុងករណីទាំងពីរនេះ មានន័យថា បំណុលថ្មីមកពីគ្រឹះស្ថានហិរញ្ញវត្ថុបានជួយឲ្យចាប់យកបាននូវមុខរបរថ្មី។ ជំហានទាំងនេះ មិនទាន់អាចពន្យល់អ្វីបានប្រាកដប្រជានៅឡើយទេ៖ ករណីមុខរបរថ្មីបានជោគជ័យហើយបំណុលទាំងនេះអាចសងបានដោយគ្មានការលំបាក វាបង្ហាញថា ឥណទានថ្មីដែលផ្តល់ទៅកូនបំណុលដែលមានប្រាក់ចំណូលធ្លាក់ចុះ អាចជួយពួកគាត់ឲ្យឆ្លងអន្តរកាល ហើយចាប់យកបាននូវមុខរបរថ្មី។ ផ្ទុយមកវិញ ករណី មុខរបរថ្មីរកចំណូលមិនបាន ឬនៅអស្ថិរភាពដដែល នោះឥណទានថ្មីៗនឹងនាំឲ្យកាន់តែងាយរងគ្រោះឡើងៗចំពោះកូនបំណុលវាអាចបង្កើនបន្ទុកបំណុល។ នៅក្នុងកាលៈទេសៈដែលមានឱកាសតិចហើយការប្រែប្រួលលឿន វាជាការសមហេតុផល ដែលត្រូវព្រួយបារម្ភចំពោះអ្វីដែលអាចកើតឡើង គឺករណីរបរថ្មីរកមិនបានចំណូល។ នៅពេលយើងចុះទៅធ្វើការក្រោយមកទៀត **នារី** ដែលជាកម្មករផលិតសម្លៀកបំពាក់ដែលត្រូវបានបញ្ឈប់ពីការងារ រកប្រាក់បានជាមធ្យម ៥ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃ ដែលគាត់ថា បានគ្រប់គ្រាន់សម្រាប់តែថ្លៃហូបចុក។ ដូច្នេះ គ្រួសារនេះសន្សំប្រាក់ដែលប្តីរកបានពីការងារសំណង់ក្នុងមូលដ្ឋានជារៀងរាល់ថ្ងៃ យកទៅសងបំណុលខាងមីក្រូហិរញ្ញវត្ថុជារៀងរាល់ខែ។

នៅក្នុងករណីទីបី **ធារ៉ា** បានទទួលអនុគ្រោះពីខាងស្ថាប័នហិរញ្ញវត្ថុ ចំពោះបំណុលរបស់គាត់បានមួយចំណែក។ **ធារ៉ា** បានយកឥណទានផ្លូវការកាលពីមុនកូវីដ ហើយបានស្នើរៀបចំឥណទានឡើងវិញ។ គាត់បានទទួលការយល់ព្រមចំពោះប្រាក់ត្រូវបង់សងប្រចាំខែទាបជាងមុន ធ្វើឲ្យបន្ទុកសងបំណុលប្រចាំខែបានធូរស្រាលបន្តិច ហើយបានធ្វើឲ្យគាត់បង្វែរធនធានបានច្រើនទៅដល់អាជីវកម្មថ្មីរបស់គាត់។ យើងនឹងពិភាក្សាករណីមួយចំនួនទៀតនៅក្នុងផ្នែក ៤ ពាក់ព័ន្ធនឹងការរៀបចំឥណទានឡើងវិញ និងផលវិបាករបស់វា។

## ផ្នែកទី ៣: វិធីសងបំណុលរបស់គ្រួសារដែលរងសម្ពាធបំណុល

ស្ទើរគ្រប់គ្រួសារទាំងអស់ដែលយើងបានសន្ទនាជាមួយ បានព្យាយាមផ្លាស់ប្តូរ ឬចាប់យកមុខរបរថ្មី ប៉ុន្តែគ្រួសារទាំងនោះក៏បានប្រើវិធីបន្ថែមផ្សេងៗថែមទៀតដែរ ដើម្បីយកមកទប់ទល់នឹងការសងបំណុល។ ជាទូទៅ ជាការចាំបាច់ត្រូវធ្វើបែបនេះ កាលណាគ្រួសារជាប់បំណុលកំពុងស្ថិតនៅក្នុងអន្តរកាលស្វែងរកមុខរបរថ្មី ឬក្នុងករណីសកម្មភាពរកចំណូលថ្មីនោះមិនបានចំណេញគ្រប់គ្រាន់។

ផ្អែកលើការសម្ភាសរបស់យើង យើងកំណត់បាននូវវិធីសំខាន់ៗចំនួនបី ដែលគ្រួសារទាំងឡាយបានប្រើក្នុងករណីមានសម្ពាធបំណុលផង និងបាត់បង់ចំណូលផង៖ ១) កាត់បន្ថយម្ហូបអាហារក្នុងគ្រួសារ និង/ឬ ចាយប្រាក់សន្សំ ២) បង្វិលលុយ ៣) ប្រើវិធីចុងក្រោយ ក្នុងនោះរួមមានលក់ដី និងជម្រើសដែលទ័លច្រកបំផុត។ ត្រង់ចំណុចនេះ យើងក៏បានលើកឡើងអំពីវិធីចរចាជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ ដែលកូនបំណុលក៏យល់ថា ជាវិធីចុងក្រោយដែលត្រូវធ្វើដែរ។ ករណីនេះ វាជាការពិត ជាពិសេសចំពោះគ្រួសារដែលមានចំណូលទាប។ នៅក្នុងតារាង ២ (ខាងក្រោម) យើងពិពណ៌នាវិធីទាំងនេះបន្ថែមទៀត តាមលំដាប់ដែលកូនបំណុលជាទូទៅលើកឡើងថា ជាវិធីដែលគាត់ចង់បានជាងគេ។

## តារាង ២: វិធីទូទៅសម្រាប់សងបំណុល ចំពោះគ្រួសាររងសម្ពាធបំណុល

| លំដាប់ | វិធីទប់ទល់ |
|---|---|
| វិធីចម្បង | . កាត់បន្ថយម្ហូបអាហារក្នុងគ្រួសារ<br>. ប្រើប្រាក់សន្សំ / លក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងសត្វ<br>. ខ្ចីប្រាក់ក្នុងចំណោមសាច់ញាតិ ដោយមិនមានការប្រាក់ |
| វិធីទីពីរ | . ផ្លាស់ប្តូរឥណទានដែលយកមកពីម្ចាស់បំណុលផ្លូវការ / ក្រៅផ្លូវការ ដែលមានការប្រាក់ |
| វិធីចុងក្រោយ | . ចរចាជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ<br>. លក់ទ្រព្យសកម្ម ដូចជាដី<br>. ដកកូនៗពីសាលា<br>. ធ្វើចំណាកស្រុកដោយសារការរងសម្ពាធ<br>. ប្រើកម្លាំងពលកម្មកុមារ |

*ប្រភព: រៀបចំដោយអ្នកនិពន្ធ*

យើងគួរកត់សម្គាល់ថា លទ្ធផលដែលយើងរកឃើញមានលក្ខណៈស្របទៅនឹងការរកឃើញក្នុងការស្រាវជ្រាវថ្មីៗ ដែលបានធ្វើពាក់ព័ន្ធនឹងការជំពាក់បំណុលវ័ណ្ឌក ទាំងលក្ខណៈកូនបំណុលប្រើវិធីពេលរងសម្ពាធបំណុល ទាំងការយល់ឃើញចំពោះការប្រើវិធីផ្សេងៗគ្នា។[92] ដូចដែលតារាង ២ បានបង្ហាញ ជាទូទៅគ្រួសារផ្សេងៗបានកាត់បន្ថយតម្រូវការក្នុងគ្រួសារ ជាជម្រើសដំបូង បន្ទាប់មកខ្ចីប្រាក់ពី (ដោយអត់មានការប្រាក់) មិត្តភក្តិ និងសាច់ញាតិ លក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងសត្វចិញ្ចឹម មុននឹងប្រើវិធីដែលមិនសូវចង់ប្រើ ដូចជាយកបំណុលបន្ថែមពីម្ចាស់បំណុលផ្លូវការ / មិនផ្លូវការ (ដោយមានការប្រាក់) លក់ទ្រព្យសកម្ម ធ្វើចំណាកស្រុកដែលមានហានិភ័យខ្ពស់ដកកូនៗចេញពីសាលា ឬឲ្យកូនទៅធ្វើការ។ ការសិក្សាអំពីស្ថានភាពជំពាក់បំណុលវ័ណ្ឌកចំនួនពីរ នៅឆ្នាំ២០១៣ និងនៅឆ្នាំ២០១៧ ដែលវិស័យនេះបានធ្វើ ក៏បានកត់សម្គាល់នូវលំនាំប្រហាក់ប្រហែលគ្នានេះដែរ។ អ្វីដែលការស្រាវជ្រាវរបស់យើងរកឃើញថ្មីនោះគឺ កូនបំណុលចាត់ទុកថាការចរចាជាមួយគ្រឹះស្ថានហិរញ្ញវត្ថុទុកជាជម្រើសចុងក្រោយ ដែលត្រូវធ្វើក្រោយពេលដែលវិធីផ្សេងៗបានបរាជ័យ គឺមិនប្រើក្នុងដំណាក់កាលមុនគេទេ។ នេះជាកត្តាបង្ហាញឲ្យឃើញនូវផលវិបាកនៃវិធីដែលគ្រឹះស្ថានហិរញ្ញវត្ថុផ្សព្វផ្សាយនូវការយល់ដឹងពីយន្តការដែលមានសម្រាប់ជួយការពារដល់គ្រួសារដែលរងសម្ពាធបំណុល ហើយនិងប្រសិទ្ធភាពនៃយន្តការទាំងនេះក្នុងការឆ្លើយតបចំពោះការរងសម្ពាធបំណុល។

[92] សូមមើល Liv 2013; MFC and Good Return 2017.

ទោះបីជាវិធីទប់ទល់ទាំងអស់ខាងលើនេះអាចនឹងជួយឲ្យកូនបំណុលដោះស្រាយបញ្ហាបានមួយរយៈខ្លីក៏ដោយ ក៏ប៉ុន្តែវិធីទាំងអស់នេះសុទ្ធតែអាចផ្តល់ផលវិបាកអវិជ្ជមានក្នុងរយៈពេលមធ្យម និងរយៈពេលវែង។ ការប្រើប្រាក់ដែលបានសន្សំ និងការលក់សត្វចិញ្ចឹម ជាឧទាហរណ៍ បង្កើននូវភាពងាយរងគ្រោះនៅពេលខាងមុខ ដោយសារ គ្រួសារទាំងឡាយខ្វះខាតធនធានក្នុងពេលជួបវិបត្តិនាអនាគត។ ដូចគ្នានេះដែរ ការបង្ខំចិត្តកាត់បន្ថយម្ហូបអាហារដោយសារចំណូលធ្លាក់ចុះ អាចបណ្តាលឲ្យមានកង្វះអាហារូបត្ថម្ភធ្លាមៗជាពិសេសក្នុងករណីគ្រួសារមានចំណូលទាប ដែលសមាជិកគ្រួសារម្នាក់ៗបានហូបស្ទើរតែមិនគ្រប់កម្រិតអប្បបរិមានៃអាហារូបត្ថម្ភ ដែលត្រូវហូបក្នុងមួយថ្ងៃក្នុងពេលធម្មតា ហើយអាចប៉ះពាល់ធ្ងន់ធ្ងរដល់សុខមាលភាពនៃសមាជិកគ្រួសារ។[93] ការខ្ចីលុយពីមិត្តភក្តិ និងគ្រួសារអាចធ្វើឲ្យប៉ះពាល់ទំនាក់ទំនងនៅក្នុងគ្រួសារ ហើយធ្វើឲ្យលែងសល់ប្រាក់សន្សំនៅក្នុងគ្រួសារវណ្ណៈកណ្តាល និងវណ្ណៈកណ្តាលទាប ដែលបង្កើននូវភាពងាយរងគ្រោះរបស់គ្រួសារទាំងនោះ។ វិធីសាស្ត្រដែលមិនចង់ធ្វើជាងគេ ក៏មានផលវិបាកអវិជ្ជមានផងដែរ។ ការយកឥណទានថែមទៀត នៅចុងបញ្ចប់នឹងបង្កើនការរងសម្ពាធ ហើយការលក់ទ្រព្យសម្បត្តិ ការធ្វើចំណាកស្រុកដោយសាររងសម្ពាធ ព្រមទាំងការដកកូនៗចេញពីសាលា នឹងផ្តល់ផលវិបាកអវិជ្ជមានក្នុងរយៈពេលវែង។ គោលដៅរបស់ភាគីទាំងអស់ គួរតែកំណត់ចៀសវាងនូវផលវិបាកទាំងនេះ។ នៅក្នុងផ្នែកបន្តបន្ទាប់ យើងនឹងពណ៌នាបន្ថែមអំពីវិធីសាស្ត្រជាទូទៅដែលបានប្រើប្រាស់ក្នុងការទប់ទល់បញ្ហាបាត់បង់ចំណូល និងការសងបំណុល នៅក្នុងចំណោមអ្នកដែលយើងបានសម្ភាស។

## ៣.១. ការកាត់បន្ថយម្ហូបអាហារនៅក្នុងគ្រួសារ និងការចាយវាយប្រាក់សន្សំ

គ្រួសារជាប់បំណុលជាច្រើនបានសងបំណុលរបស់ខ្លួនជាធម្មតា បើទោះជាមានការបាត់បង់ប្រាក់ចំណូលក៏ដោយ។ ជារឿយៗវិធីសាស្ត្រដំបូងដែលគ្រួសារនានាយកមកប្រើ ដើម្បីធ្វើដូច្នេះទៅបាន គឺត្រូវកាត់បន្ថយម្ហូបអាហារនៅក្នុងគ្រួសារ។[94] អ្នកដែលយើងបានសម្ភាសជាទូទៅបាននិយាយដូច្នេះ ហើយវាក៏ជាការពិតដែរ ជាពិសេសចំពោះគ្រួសារមានប្រាក់ចំណូលទាប។ អ្នកដែលយើងបានសម្ភាសនៅក្នុងវិស័យផ្សេងៗ បានលើកឡើងនូវបទពិសោធន៍ប្រហាក់ប្រហែលគ្នា៖

*“កូនៗរបស់ខ្ញុំបានផ្ញើលុយមកសងគ្រឹះស្ថានហិរញ្ញវត្ថុ។ ខ្ញុំយកវាទៅសងបំណុល ទោះបីជាខ្ញុំមិនមានលុយគ្រប់សម្រាប់ម្ហូបអាហារក៏ដោយ។ ប៉ុន្តែមិនអីទេ ទោះបីជាយើងមិនមានអាហារគ្រប់គ្រាន់ហូបក៏ដោយ។”* [95]

***- សមាជិកគ្រួសារនៃកម្មករចំណាកស្រុក***

*“កន្លងមកមិនមានបញ្ហាក្នុងការសងបំណុលទេ។ យើងបានប្រឹងប្រែងធានាថាយើងមានលុយគ្រប់យកទៅសងបំណុលរាល់ខែ ទោះបីជាពេលខ្លះយើងមិនបានហូបឆ្អាញ់ក៏ដោយ។ យើងមិនចង់មានឈ្មោះមិនល្អ... វាពិតជាលំបាកមែនហើយ ប៉ុន្តែរឿងហ្នឹងវាត្រូវតែអញ្ចឹង។”* [96]

***- កម្មករចំណាកស្រុកតាមរដូវ***

*“ខ្ញុំអាចសងគេបានធម្មតា ប៉ុន្តែខ្ញុំត្រូវតែយកមួយផ្នែកធំពីប្រាក់ចំណូលរបស់គ្រួសារទៅសងបំណុល ដូច្នេះខ្ញុំសល់លុយតិចតួចសម្រាប់បំពេញតម្រូវការផ្សេងៗក្នុងគ្រួសារ។”* [97]

***- កម្មកររោងចក្រផលិតកាបូប***

[93] សូមមើល Seng 2018 ចំពោះការកាត់បន្ថយម្ហូបអាហារ និងកង្វះអាហារូបត្ថម្ភដែលពាក់ព័ន្ធនឹងបញ្ហាបំណុល។

[94] See Seng 2018.

[95] Participant ID:94.

[96] Participant ID:66.

[97] Participant ID:54.

វិធីជាទូទៅមួយទៀតដែលបណ្តាគ្រួសារនានា តែងប្រើយកទៅដោះបំណុលនាបច្ចុប្បន្ននេះគឺ ដកយកមកពីប្រាក់សន្សំ ឬ លក់សត្វចិញ្ចឹម ឬទ្រព្យសម្បត្តិមានតម្លៃផ្សេងៗ។ ឧទាហរណ៍ស្ត្រីអ្នកលក់វត្ថុអនុស្សាវរីយ៍ម្នាក់ ដែលប្តីគាត់រត់ទុកទុកបានលើកឡើងថា ដើម្បីយកប្រាក់ទៅសងបំណុល គាត់បានលក់គ្រឿងអលង្ការមាសរបស់គាត់ ហើយដកខ្លះចេញមកពីប្រាក់សន្សំ។ ពួកគេជំពាក់បំណុល ២៥០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ ហើយបាននិយាយថា ក្នុងពេលមានកូវីដ ៣ខែ ដំបូង ពួកគាត់បានលក់មាសអស់ប្រហែល ៥ជី (គិតជាទឹកប្រាក់ប្រហែល ៨០០ ដុល្លារសហរដ្ឋអាមេរិក) ដើម្បីយកមកទប់ការចំណាយក្នុងការរស់នៅ និងសងបំណុល។[98] ស្ត្រីម្នាក់ទៀត ដែលធ្វើការនៅក្នុងវិស័យកសិកម្ម បានឲ្យដឹងថា គាត់បានលក់គោបួនក្បាលយកមកសងបំណុលប្រចាំខែឲ្យខាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។[99] ស្ត្រីម្នាក់ទៀតដែរដែលជាអ្នកលក់វត្ថុអនុស្សាវរីយ៍ ហើយដែលជាម្ចាស់ហាងច្រើនកន្លែង ហើយជាប់បំណុលធនាគារមួយអស់ប្រហែល ១២០.០០០ ដុល្លារសហរដ្ឋអាមេរិក បានលក់ឡានគាត់ ៣៣.០០០ ដុល្លារសហរដ្ឋអាមេរិក ដែលទើបតែទិញបានពីរខែប៉ុណ្ណោះ មុនពេលកើតមានវិបត្តិជំងឺកូវីដ ១៩ ក្នុងតម្លៃ ៤៣.០០០ ដុល្លារសហរដ្ឋអាមេរិក ដើម្បីសងបំណុលបានរលូន។ លុយបានមកពីលក់ឡាន អនុញ្ញាតឲ្យគ្រួសារនេះសងបំណុលបានរយៈពេល ៧ខែ ដោយសារគាត់ត្រូវសងធនាគារប្រហែល ៣.០០០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។[100]

## ៣.២. ការបង្វិលលុយ

អ្នកដែលរងសម្ពាធបំណុល ក៏មានទម្លាប់តែងតែពឹងផ្អែកលើការបង្វិលលុយផងដែរ។ *ការបង្វិលលុយ* មានន័យថា គ្រួសារជាប់បំណុលខ្ចីប្រាក់យកទៅសងគេ ទោះជាតាមរយៈគ្រឹះស្ថានផ្លូវការ ឬមិនផ្លូវការក្តី។ ការធ្វើរបៀបនេះត្រូវបានអ្នកស្រាវជ្រាវខ្លះសរសេរទុកជាឯកសារពីមុនមករួចហើយក្នុងបរិបទការផ្តល់ប្រាក់កម្ចីផ្សេងៗទៀត។[101]

នៅក្នុងការចុះស្រាវជ្រាវ *ការបង្វិលលុយ* នេះ បានលើកយកមកនិយាយជាញឹកញាប់ ទាំងអ្នកជាកូនបំណុល ទាំងអ្នកតំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ជាការពិតណាស់ អ្វីដែលគ្រួសាររងសម្ពាធបំណុលចាប់ផ្តើមធ្វើមុនគេគឺ រកប្រាក់កម្ចីណាដែលមិនមានការប្រាក់ ជាទូទៅតែងតែខ្ចីពី ឪពុកម្តាយ កូនៗ ឬក៏ពីបងប្អូនបង្កើត។ ជារឿយៗ កម្ចីទាំងនេះមានទំហំធំៗដែរ ហើយខណៈដែលក្នុងករណីខ្លះពួកគាត់ប្រើសម្រាប់ចំណាយទូទៅក្នុងគ្រួសារ ពួកគាត់ក៏ប្រើផងដែរជាញឹកញាប់យកទៅសងគ្រឹះស្ថានហិរញ្ញវត្ថុ។

កម្មការនីចំណាកស្រុកម្នាក់បានពន្យល់ថា ចាប់តាំងពីកូវីដ ១៩ ចាប់ផ្តើម គាត់បានខ្ចីលុយម្តាយគាត់ក្នុងចន្លោះពី ៥០.០០០ បាត [១.៥៦២,៥ ដុល្លារសហរដ្ឋអាមេរិក] ទៅ ៦០.០០០ បាត [១.៨៧៥ ដុល្លារសហរដ្ឋអាមេរិក] ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ និងទ្រទ្រង់ការចំណាយប្រចាំថ្ងៃរបស់គាត់។[102] ប្រពន្ធរបស់កម្មករចំណាកស្រុកម្នាក់ ដែលជាម្ចាស់តូបចាបហួយមួយនៅផ្ទះរួម ក៏បានទូរសព្ទទៅខ្ចីប្រាក់ពីសាច់ញាតិជិតដិតរបស់នាង។[103] កម្មកររោងចក្រម្នាក់និយាយថា “នៅពេលដែលរោងចក្របានបិទអស់រយៈពេលមួយខែ ខ្ញុំបានខ្ចីលុយ [៦០០ ដុល្លារសហរដ្ឋអាមេរិក] ពីមីង និងពូខ្ញុំយកមកជួយម្តាយឪពុកខ្ញុំ និងយកទៅសងធនាគារ។”[104] អ្នករត់ទុកទុកម្នាក់ដែលជាប់បំណុលគ្រឹះស្ថានហិរញ្ញវត្ថុក្នុងចំនួនទឹកប្រាក់ប្រហែល ៩.០០០ ដុល្លារសហរដ្ឋអាមេរិក បានប្រាប់យើងថា គាត់បានខ្ចីលុយ ១.០០០ ដុល្លារសហរដ្ឋអាមេរិកពីបងប្អូនបង្កើតគាត់ ហើយ ១.០០០ ដុល្លារសហរដ្ឋអាមេរិកទៀតពីម្តាយក្មេកគាត់ដើម្បីសងប្រាក់ទៅខាងស្ថាប័នហិរញ្ញវត្ថុ។[105]

---

98 Participant ID:116.
99 Participant ID:102.
100 Participant ID:123.
101 See Rankin 2002.
102 Participant ID:96.
103 Participant ID:107.
104 Participant ID:46.
105 Participant ID:24.

នៅពេលដែលគ្រួសារទាំងឡាយបានប្រើប្រាស់អស់ធនធានដែលមានក្នុងចំណោមសាច់ញាតិខ្លួនឯងរួចហើយ និង/ឬ ក្នុងករណីដែលវិធីទប់ទល់ដំបូងៗបានប្រើអស់លទ្ធភាពហើយ គ្រួសារដែលរងសម្ពាធបំណុលជារឿយៗ ក៏ចាប់ផ្តើមខ្ចីលុយ ដែលមានការប្រាក់ ដើម្បីយកទៅសងបំណុល។ ទម្រង់នៃការខ្ចីលុយពីកន្លែងមួយទៅសងកន្លែងមួយទៀតរបៀបនេះ គឺជាវិធីសាស្ត្រទប់ទល់ដែលពួកគាត់មិនសូវចង់ធ្វើ។ យោងតាមអ្នករត់ទុកទុកម្នាក់និយាយថា តាំងពីមានកូវីដ ១៩ មក គាត់បានខ្ចីប្រាក់ពីម្តាយគាត់ ឪពុកម្តាយក្មេក និងពីអ្នកចងការឯកជនចំនួនពីរនាក់ផ្សេងទៀត។[106] ប្រហាក់ប្រហែលគ្នានេះដែរ ស្ត្រីកសិករដាំស្រូវ វ័យ ៦៥ឆ្នាំម្នាក់បានប្រាប់យើងថា ចាប់តាំងពីកូនស្រី និងកូនប្រសាររបស់គាត់ផ្ញើប្រាក់មកមិនគ្រប់យកទៅសងបំណុលដែលគាត់បានខ្ចីពីខាង គ.ម.ហ គាត់ក៏បានខ្ចីប្រាក់ ៥០.០០០ បាត ពីអ្នកភូមិ ចំនួនបីនាក់ខុសៗគ្នានៅក្នុងអត្រាការប្រាក់ ៥%ក្នុងមួយខែ។[107]

ការបង្វិលលុយ ជាពិសេសករណីកម្ចីមានការប្រាក់ គឺជាអ្វីដែលកូនបំណុលមិនចង់ធ្វើ។ ពីព្រោះការធ្វើបែបនេះអាចឲ្យពួកគាត់ធ្លាក់ក្នុង ស្ថានភាពហិរញ្ញវត្ថុតានតឹងឡើងៗ។ ទោះជាយ៉ាងណាក៏ដោយ ការបង្វិលលុយក្នុងរយៈពេលខ្លីមិនត្រឹមតែត្រូវបានប្រើជាទូទៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការយល់ឃើញយ៉ាងទូលាយថា មិនសូវមានបញ្ហាធ្ងន់ធ្ងរដូចលក់ដី ឬទ្រព្យសកម្មសំខាន់ៗនោះទេ។ ក្នុងទសវត្សរ៍កន្លងទៅគ្រឹះស្ថានហិរញ្ញវត្ថុខ្លះក៏បានគាំទ្រទៅដល់ការប្រើវិធីបង្វិលលុយនេះដែរ ដោយអនុញ្ញាតឲ្យសងប្រាក់មុនពេលកំណត់ ដើម្បីធ្វើបុនហិរញ្ញប្បទានដល់កូនបំណុលដែលកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ។ នៅក្នុងករណីបែបនេះកូនបំណុលសងផ្តាច់មុនកាលកំណត់ ហើយបន្ទាប់មកត្រូវយកឥណទានថ្មីធំជាងមុនពីម្ចាស់បំណុលដដែល។ យោងតាមការលើកឡើងនៅក្នុងរបាយការណ៍ស្រាវជ្រាវស្តីអំពីការជំពាក់បំណុលវ័ណ្ឌកដែលបានធ្វើនាពេលថ្មីៗនេះ ការអនុវត្តរបៀបនេះគឺជារឿងធម្មតានៅក្នុងវិស័យនេះ។[108]

## ៣.៣. វិធីសាស្ត្រទប់ទល់ចុងក្រោយ

ពេលដែលវិធីសាស្ត្រទប់ទល់ទីមួយ និងទីពីរ បរាជ័យ កូនបំណុលនៅសល់តែជម្រើសមួយដែលយើងហៅថា ជម្រើស "ចុងក្រោយ"៖ ជាជម្រើសដែលគ្រោះថ្នាក់បំផុត។ វិធីទាំងនេះរាប់បញ្ចូលទាំងការចំណាកស្រុកទាន់ហន់ បញ្ឈប់កូនៗពីការសិក្សា និង/ឬឲ្យកូនៗទៅធ្វើការ លក់ដីដែលបានដាក់ជាទ្រពធានា ឬស្ថានភាពអសាធនីយ (default)។ អ្នកដែលយើងបានសន្ទនាជាមួយជាច្រើននាក់បានលើកឡើងពីហានិភ័យទាំងនេះ។ ឧទាហរណ៍ កម្មកររោងចក្រកាត់ដេរម្នាក់ ដែលបានធ្លាក់ចំណូលដោយសារជំងឺកូវីដ ១៩ បាននិយាយថា "ប្រសិនខ្ញុំមិនអាចរកលុយសងប្រាក់ទៅធនាគារ ខ្ញុំបានឮឪពុកខ្ញុំថា គាត់ប្រហែលជាត្រូវលក់ស្រែ [ដែលបានដាក់ជាទ្រព្យធានា] ដើម្បីយកទៅសងធនាគារ។"[109] អ្នករត់ទុកទុកម្នាក់ដែលយើងបានសន្ទនាជាមួយ បានពិចារណាចង់លក់ទុកទុកបើគាត់នៅតែជួបបញ្ហារកប្រាក់មិនបាន។[110] បុរសជាកសិករដាំដំឡូងមី/ពោត បានឲ្យដឹងថា គាត់កំពុងពិចារណាចង់លក់ដីមួយកន្លែងយកទៅព្យាបាលជំងឺប្រពន្ធគាត់ និងសងខាងគ្រឹះស្ថានហិរញ្ញវត្ថុប្រសិនបើព្រំដែននៅតែបន្តបិទបែបនេះ។[111]

តាំងពីនៅមុនពេលកូវីដ ១៩ មកម្លេះអង្គហេតុដែលថា ពេលខ្លះកូនបំណុលត្រូវបង្ខំចិត្តប្រើវិធីសាស្ត្រទប់ទល់ចុងក្រោយទាំងនេះ ត្រូវបានគេចងក្រងរួចហើយ។[112] ស្រដៀងគ្នានេះដែរ អ្នកចូលរួមផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវនេះមួយចំនួនតូច បានប្រាប់ដល់យើងថា ការរងសម្ពាធបំណុលដែលបានបណ្តាលឲ្យពួកគាត់ជួបប្រទះលទ្ធផលដែលពួកគាត់មិនចង់បានដូច្នេះគឺមាន តាំងតែពីមុនពេលកូវីដ ១៩ មកម្លេះ។ ឧទាហរណ៍ ប្អូនស្រីម្នាក់ដែលបានចូលរួមផ្តល់ព័ត៌មានបានកត់សម្គាល់ថា កាលពីច្រើនឆ្នាំកន្លងទៅគាត់បង្ខំចិត្តត្រូវឈប់រៀន ហើយធ្វើចំណាកស្រុកទៅធ្វើការក្នុងវិស័យផលិតសម្លៀកបំពាក់ ដោយសារតែគ្រួសារជំពាក់បំណុលគេ។ ប្អូនស្រីបាននិយាយថា "ខ្ញុំឈប់រៀននៅថ្នាក់ទី ១០ ដោយសារនៅពេលនោះគ្រួសារខ្ញុំមិនមានលុយគ្រប់ឲ្យខ្ញុំទៅរៀន និងបង់សងបំណុលខាង គ.ម.ហ។"[113]

---

[106] Participant ID:13.

[107] Participant ID:1

[108] MFC and Good Return 2017.

[109] Participant ID:50.

[110] Participant ID:24.

[111] Participant ID:74.

[112] Bylander 2015a; Bylander 2015b; MFC and Good Return 2017; Green and Estes 2018; Natarajan et al 2020; Green and Bylander ចេញនៅពេលខាងមុខ.

[113] Participant ID:59.

ប្រធានសាខាមួយចំនួនក៏បានដឹងឮអំពីករណីទាំងនេះដែរ។ ប្រធានសាខាគ្រឹះស្ថានហិរញ្ញវត្ថុមួយបានប្រាប់យើងថា "យើងបានប្រាប់ពួកគាត់រួចហើយថា បើគាត់ខ្ចីលុយច្រើនពេក ហើយមិនអាចសងវិញបាន ផលប៉ះពាល់នឹងមានចំពោះកូនៗពួកគាត់។ ដូចជាកូនៗគាត់នឹងអាចឈប់រៀន ហើយការធ្វើចំណាកស្រុកទាន់ហាន់នឹងកើតមានឡើង។ នេះជាសារមួយដែលយើងផ្តល់ឲ្យអតិថិជនរបស់យើង។"[114]

ការសិក្សារបស់យើងមិនបានរកឃើញករណីច្រើនទេដែលកូនបំណុលបានប្រើវិធីសាស្រ្តទប់ទល់ចុងក្រោយទាំងនោះប្រហែលមួយផ្នែកគឺដោយសារយើងពិបាកនឹងរកជួបពួកគាត់។ ហេតុផលទីពីរគឺ អាចមកពី ការរៀបចំឥណទានឡើងវិញនាពេលកន្លងទៅ (នឹងរៀបរាប់បន្ថែមនៅផ្នែកបន្ទាប់) ដែលបានជួយសម្រាលដល់ កូនបំណុលមួយចំនួនក្នុងការចាប់យកវិធីសាស្រ្តចុងក្រោយ។

នៅក្នុងការស្រាវជ្រាវរបស់យើង លទ្ធផលដែលយើងរកឃើញគួរឲ្យភ្ញាក់ផ្អើលមួយនោះគឺ កូនបំណុលទៅចរចារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះ ជាជម្រើសចុងក្រោយ។ មុននឹងខ្លួនប្រើវិធីទីមួយ ឬទីពីរ កូនបំណុលរងសម្ពាធមួយចំនួនបានទំនាក់ទំនងដោយមានផែនការ និងដោយសកម្មជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុ ប៉ុន្តែករណីនេះកើតមានឡើងដោយកម្រ។ ផ្ទុយមកវិញ កូនបំណុលដែលយើងបានសន្ទនាជាមួយ បែរជាលើកឡើងពីការភ័យខ្លាចមិននិយាយរឿងលំបាកសងបំណុលជាមួយមន្រ្តីឥណទានរបស់ខ្លួនម្យ៉ាងដោយសារពួកគាត់មានការអៀនខ្មាស ឬម្យ៉ាងទៀតដោយសារពួកគាត់ខ្លាចប៉ះពាល់ចំពោះប្រវត្តិឥណទានរបស់ខ្លួន។ នេះរាប់បញ្ចូលទាំងបុគ្គលទាំងឡាយដែលបានដឹងអំពីគោលនយោបាយរៀបចំឥណទានឡើងវិញ និងលទ្ធភាពដែលអាចស្នើបាននូវការរៀបចំឥណទានឡើងវិញ។ ម្ចាស់ហាងគ្រឿងទេសវ័យ ៤១ ឆ្នាំម្នាក់បានឲ្យដឹងថា "តាមពិតខ្ញុំចង់ប្រាប់រាល់ស្ថាប័នហិរញ្ញវត្ថុទាំងអស់ថា ទោះបីជាខ្ញុំបានសងទាន់ពេលរាល់ខែក៏ដោយ ខ្ញុំពិតជាកំពុងជួបការលំបាកខ្លាំង។ ប៉ុន្តែខ្ញុំខ្លាចថា ស្ថាប័នហិរញ្ញវត្ថុនោះលែងឲ្យខ្ញុំខ្ចីទៀត បើខ្ញុំបង្កបញ្ហា។"[115] ការភ័យខ្លាចនេះមិនមែនអត់ហេតុផលនោះទេ។ អ្នកចូលរួមផ្តល់ព័ត៌មានម្នាក់ទៀតនិយាយថា "មន្រ្តីឥណទានបានប្រាប់ខ្ញុំថា បើខ្ញុំមិនបានសងទៀងទាត់តាមកាលកំណត់ ពួកគេនឹងឈប់ឲ្យខ្ញុំខ្ចីលើកក្រោយ។"[116] ចុងភៅម្នាក់ដែលបានបញ្ឈប់ពីការងារនិយាយថា "ខ្ញុំស្គាល់អ្នកខ្លះដែលបានស្នើសុំពន្យារពេល ប៉ុន្តែសំណើពួកគាត់បានត្រូវបដិសេធ។ ពេលខ្ញុំឃើញដូច្នេះ ខ្ញុំមិនមានការជឿជាក់ក្នុងការស្នើសុំទៀតទេ។ ខ្ញុំខ្លាចថានឹងបានចម្លើយដូចគ្នា។ នោះវានឹងធ្វើឲ្យខ្ញុំខ្មាសគេ។"[117] ម្នាក់ទៀតក៏បានបន្ថែមថា "ខ្ញុំមិនដែលបានទៅសុំគេទេ ពីព្រោះគ្រប់គ្នាបានប្រាប់ខ្ញុំថា កុំទៅរវល់ ពីព្រោះពួកគេមិនមែនគ្រឹះស្ថានរដ្ឋនោះទេពួកគេគឺគ្រឹះស្ថានឯកជន។"[118]

ការព្រួយបារម្ភទាំងនេះមានន័យថា អ្នកដែលជាក់ស្តែងបានទៅជួបខាងគ្រឹះស្ថានហិរញ្ញវត្ថុ ជារឿយៗពិតជាទៅជាវិធីចុងក្រោយ បន្ទាប់ពីបានប្រើអស់ជម្រើសផ្សេងៗ ដែលក្នុងនោះជម្រើសខ្លះអាចនឹងបានបង្កើននូវហានិភ័យសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងសម្រាប់កូនបំណុល (ដូចជាការយកឥណទានថ្មីទៀត)។ នៅក្នុងស្ថានភាពដែលមានការលំបាកសងបំណុល កូនបំណុលជារឿយៗមិនមានអារម្មណ៍ល្អក្នុងការទំនាក់ទំនងទៅជួបមន្រ្តីឥណទានណាទេ រហូតដល់ពេលដែលហួសឆ្ងាយពីពេលដែលពួកគាត់កំពុងត្រូវការជំនួយ ដោយសារពួកគាត់បារម្ភថា វាអាចប៉ះពាល់ដល់ប្រវត្តិឥណទានរបស់ខ្លួន ហើយក៏ដូចជាប៉ះពាល់ដល់ការទទួលបានឥណទាននាពេលអនាគត។ ចំណុចនេះជាកន្លែងដែលគ្រឹះស្ថានហិរញ្ញវត្ថុអាចលូកដៃចូល និងលើកទឹកចិត្តឲ្យកូនបំណុលដែលកំពុងលំបាក ចេញមកនិយាយជាមួយបុគ្គលិកគ្រឹះស្ថានហិរញ្ញវត្ថុ ព្រមទាំងទំនាក់ទំនងឲ្យបានច្បាស់លាស់ទៅដល់អតិថិជនដែលកំពុងលំបាកថា ការធ្វើដូច្នោះមិនបានប៉ះពាល់ដល់ប្រវត្តិឥណទានឡើយឬលទ្ធភាពទទួលបានឥណទាននាអនាគតនោះទេ។ នៅក្នុងផ្នែកបន្ទាប់នេះ យើងនឹងពណ៌នាការឆ្លើយតបផ្សេងៗ ដែលគ្រឹះស្ថានហិរញ្ញវត្ថុបានផ្តល់ឲ្យដល់អតិថិជនរបស់ខ្លួនក្នុងអំឡុងពេលមានកូវីដ ១៩ ហើយនរណាខ្លះបានទទួលការឆ្លើយតបទាំងនោះ។

---

[114] FI ID:8.

[115] Participant ID:107.

[116] Participant ID:98.

[117] Participant ID:2.

[118] Participant ID:20.

# ផ្នែកទី ៤: ការឆ្លើយតបរបស់គ្រឹះស្ថានហិរញ្ញវត្ថុចំពោះវិបត្តិកូវីដ ១៩

## ៤.១. យន្តការនានាមុនកូវីដ ១៩

យោងតាមតំណាងស្ថាប័នហិរញ្ញវត្ថុដែលយើងបានសន្ទនាជាមួយ ពេលមុនកូវីដ ១៩ បណ្តាភាគីខាងវិស័យហិរញ្ញវត្ថុមានយុទ្ធសាស្ត្រតែក្នុងចំនួនតូចមានកំណត់ ក្នុងការជួយដល់គ្រួសារដែលរងសម្ពាធបំណុល។ ទីមួយ ភាគីទាំងនោះអាចធ្វើបុនហិរញ្ញប្បទានក្នុងគ្រឹះស្ថានដដែល (ពោលគឺបន្តផ្តល់ប្រាក់កម្ចីបន្ថែម) ដែលអនុវត្តន៍ក្នុងករណីកូនបំណុលបានទទួលប្រាក់បន្ថែមយកទៅសងបំណុលចាស់ ដែលផ្តល់ដោយគ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុដដែល។ ទោះជាយ៉ាងណាក៏ដោយ ខណៈដែលការផ្តល់ប្រាក់បន្ថែមនេះជាវិធីមួយដែលកូនបំណុលបានប្រើក្នុងការឆ្លើយតបនឹងការរងសម្ពាធក៏ដោយ ប៉ុន្តែការធ្វើរបៀបនេះមានការទិតៀនដោយសារបានធ្វើឲ្យគ្រួសារកាន់តែជាប់បំណុលធំឡើងៗ ហើយជាទូទៅ តាមទស្សនៈកិច្ចគាំពារអតិថិជនយល់ថា ទង្វើនេះជាការអនុវត្តមួយដែលមានបញ្ហា។ នៅក្នុងឆ្នាំ២០១៧ ទិន្នន័យផ្លូវការរបស់ការិយាល័យឥណទានកម្ពុជាបានបង្ហាញថា ៥០% នៃប្រាក់កម្ចីទាំងអស់ដែលបានផ្តល់ គឺសម្រាប់បុនហិរញ្ញប្បទាន "ដោយមាន ២៥% ធ្វើបុនហិរញ្ញប្បទានមុនពេលបំណុលចាស់ដល់កំណត់ ហើយ ៣០% បានធ្វើបុនហិរញ្ញប្បទានក្នុងចំនួនស្មើនឹង ១៣០% នៃប្រាក់កម្ចីចាស់។"[119] ការព្រួយបារម្ភពីការប្រើប្រាស់បុនហិរញ្ញប្បទាន មានចែងនៅក្នុងសេចក្តីណែនាំស្តីពីការផ្តល់ឥណទាន ដែលបានដាក់ចេញ និងត្រួតពិនិត្យដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (ស.ម.ហ.ក) និងដោយធនាគារជាតិកម្ពុជា (ធ.ជ.ក) នៅក្នុងប្រកាស[120] ស្តីអំពីចំណាត់ថ្នាក់ហានិភ័យឥណទាន (មាត្រា ៣៥)។

លើសពីនេះទៀត នៅក្នុងករណីពិសេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុលុបចោលបំណុលនោះទាំងស្រុងតែម្តង ឬក៏ផ្តល់កម្ចីសង្គ្រោះបន្ទាន់ (សូមមើលតារាង ៣) ការលុបបំណុលត្រូវបានប្រើនៅក្នុងករណីបុគ្គលិកមិនអាចទាក់ទង កូនបំណុល និងអ្នកធានាបាន ប៉ុន្តែកម្ចីសង្គ្រោះបន្ទាន់នោះជាទូទៅប្រើក្នុងករណីមានគ្រោះថ្នាក់ផ្ទាល់ខ្លួន ជំងឺ ឬគ្រោះធម្មជាតិ ហើយកម្រមានប្រើណាស់បើប្រៀបធៀបនឹងការផ្តល់បុនហិរញ្ញប្បទានក្នុងរង្វង់គ្រឹះស្ថានដដែល។

### តារាង ៣: យន្តការនានាសម្រាប់គ្រួសាររងសម្ពាធបំណុល

| ភាពញឹកញាប់ ក្នុងការអនុវត្ត | មុនពេលកូវីដ ១៩ | ក្នុងពេលកូវីដ ១៩ | ភាពញឹកញាប់ ក្នុងការអនុវត្ត |
|---|---|---|---|
| ជាទូទៅ | . ការធ្វើបុនហិរញ្ញប្បទាន/ការផ្តល់ប្រាក់កម្ចីបន្ថែម នៅក្នុងគ្រឹះស្ថានដដែល | . ការធ្វើបុនហិរញ្ញប្បទាន/ការផ្តល់ប្រាក់កម្ចីបន្ថែមនៅក្នុងគ្រឹះស្ថានដដែល<br>. ការសងតែការប្រាក់<br>. កម្ចីសង្គ្រោះបន្ទាន់ | . ការធ្វើបុនហិរញ្ញប្បទាន/ការផ្តល់ប្រាក់កម្ចីបន្ថែមនៅក្នុងគ្រឹះស្ថានដដែល |
| មិនទូទៅ | . ការលុបបំណុលចោល<br>. កម្ចីសង្គ្រោះបន្ទាន់ * | . ការពន្យារពេលទូទាត់សង<br>. ការពន្យារឥណប្រតិទាន<br>. លុបបំណុលចោល | . ការសងតែការប្រាក់<br>. កម្ចីសង្គ្រោះបន្ទាន់<br>. ការលុបបំណុលចោល<br>. ការពន្យារពេលទូទាត់សង<br>. ការពន្យារឥណប្រតិទាន |

*ប្រភព: រៀបចំដោយអ្នកនិពន្ធ*

** កម្ចីសង្គ្រោះបន្ទាន់ ជាធម្មតាគឺប្រើសម្រាប់ពេលមានគ្រោះថ្នាក់ផ្ទាល់ខ្លួន មានជំងឺ និងគ្រោះធម្មជាតិ។*

119 Incofin 2018.

120 ប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអឹមតែរមិន លេខ ធ៧.០១៧.៣៤៤ ប្រក ចេញឆ្នាំ ២០១៧។ Prakas on Credit Risk Grading and Impairment Provisioning - number B7-017-344 Prokor issued in 2017.

## ៤.២. យន្តការក្នុងអំឡុងកូវីដ ១៩

ឆ្លើយតបនឹងវិបត្តិកូវីដ ១៩ ការអនុវត្តបែបថ្មីបានកើតឡើងចំពោះការរៀបចំឥណទានឡើងវិញ។ ជាភាសាខ្មែរ ការអនុវត្តនេះត្រូវប្រើពាក្យនាបច្ចុប្បន្នថា *ការរៀបចំឥណទានឡើងវិញ ឬ ឥណទានសាឡើងវិញ* ( សូមមើលបន្ថែម រូបថត ៩ : “អ្វីទៅគឺជាការរៀបចំឥណទាន [កម្ចី] ឡើងវិញ ?” )។




*(រូបថត ៩: អក្សរខ្មែរសរសេរថា “អ្វីទៅគឺជាការរៀបចំឥណទានឡើងវិញ ?” យកមកពីហ្វេសប៊ុក ខែមិថុនា ឆ្នាំ២០២០ )*

ការរៀបចំឥណទានឡើងវិញតាមរបៀបថ្មីនេះ គឺគោរពតាមដោយផ្ទាល់នូវសំណើដែលរដ្ឋាភិបាលសូមឲ្យបន្ធូរបន្ថយដល់កូនបំណុលដែលរងសម្ពាធដោយសារកូវីដ ១៩។ នៅក្នុងខែមីនា ឆ្នាំ២០២០ នាយករដ្ឋមន្ត្រីកម្ពុជាបានអំពាវនាវគ្រឹះស្ថានហិរញ្ញវត្ថុឲ្យបន្ធូរបន្ថយដល់កូនបំណុល ហើយកុំរឹបអូសយកទ្រព្យធានាពីគ្រួសារដែលរងសម្ពាធបំណុល។ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ក្រោយពីនាយករដ្ឋមន្ត្រីបានស្នើ ធនាគារជាតិនៃកម្ពុជា (ធ.ជ.ក) បានចេញសារាចរណែនាំធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុឲ្យអនុវត្តគោលនយោបាយរៀបចំឥណទានឡើងវិញ ដែលសំដៅបន្ធូរបន្ថយដល់អតិថិជនរបស់ខ្លួនក្នុងពេលបាត់បង់ប្រាក់ចំណូលដោយសារវិបត្តិកូវីដ ១៩។

មកទល់ពេលនេះ យោងតាមសមាគមហិរញ្ញវត្ថុកម្ពុជា (ស.ម.ហ.ក) មានឥណទានសរុបជាទឹកប្រាក់ ១,៣ ពាន់លានដុល្លារសហរដ្ឋអាមេរិកបានកំពុងរៀបចំឡើងវិញ ឬប្រហែល ១៦% នៃឥណទានសរុបដែលត្រូវសងក្នុងឆ្នាំ២០២០។ គិតមកត្រឹមខែ ធ្នូ ឆ្នាំ២០២០ កូនបំណុលសរុបចំនួន ២៧១.១២៧ នាក់ បានទទួលការរៀបចំឥណទានឡើងវិញ ឬប្រហែល ១២% នៃគ្រួសារកូនបំណុលសរុប។ ខែវិច្ឆិកា ឆ្នាំ២០២០ ស.ម.ហ.ក និងសមាគមធនាគារនៅកម្ពុជា (សធក) បានរួមគ្នាអំពាវនាវដល់ ធ.ជ.ក ឲ្យបន្តពេលគោលការណ៍រៀបចំឥណទានឡើងវិញរហូតទៅដល់ពាក់កណ្តាលឆ្នាំ២០២១ ដោយសារផលប៉ះពាល់ខាងសេដ្ឋកិច្ចនៃវិបត្តិកូវីដ ១៩ នៅតែបន្ត ហើយក៏មានការឆ្លើយតបចំពោះវិបត្តិទឹកជំនន់ផងដែរ។[121] ធ.ជ.ក បានអនុញ្ញាតតាមសំណូមពររួចហើយ ដូច្នេះគោលការណ៍រៀបចំឥណទានឡើងវិញនឹងបន្តរហូតដល់ពាក់កណ្តាលឆ្នាំ២០២១។[122]

ធ.ជ.ក បានចេញសារាចរណែនាំដល់បណ្តាគ្រឹះស្ថានហិរញ្ញវត្ថុឲ្យចាត់វិធានការក្នុងចំណោមវិធានការទាំង៩៖ ១) ការកាត់បន្ថយចំនួនប្រាក់ដើមឥណទាន ឬចំនួនដែលត្រូវសងនៅឥណប្រតិទាន ២) ការបន្ថយអត្រាការប្រាក់ទាបជាងលក្ខខណ្ឌនៃកិច្ចសន្យាដើម ៣) ការពន្យារពេលទូទាត់សងប្រាក់ដើម ឬការប្រាក់ ឬការធ្វើមូលធនកម្មការប្រាក់ ៤) ការពន្យារឥណប្រតិទាន ៥) ការបន្ថែម និង/ឬការផ្លាស់ប្តូរ អ្នករួមខ្ចី និង/ឬ អ្នកធានារួមគ្នា (ប្រសិនបើមាន) ៦) ការផ្លាស់ប្តូរពីឥណទានមានការទូទាត់សងតាមការបង់រំលស់ ទៅជាការទូទាត់តែការប្រាក់ហើយទូទាត់សងប្រាក់ដើមទាំងអស់នៅឥណប្រតិទាន ៧) ការលើកលែង ឬបន្ថយទ្រព្យធានា ៨) ការបន្ថយលក្ខខណ្ឌកិច្ចសន្យា ឬ / និង ៩) ការផ្តល់រយៈពេលអនុគ្រោះដោយគ្មានការទូទាត់សង ដែលមានរយៈពេលរហូតដល់ ៦ខែ គិតចាប់ពីថ្ងៃប្រសិទ្ធភាពនៃកិច្ចសន្យាថ្មី។

ធ.ជ.ក បានចេញសារាចរ ៩ ចំណុចនេះ ហើយមានការអនុវត្តជាផ្លូវការកន្លងមកនូវការរៀបចំឥណទានឡើងវិញ ប៉ុន្តែមិនមានកំណត់និយមន័យច្បាស់លាស់ទេ ហើយការណែនាំរបស់ ធ.ជ.ក ក៏មានតិចតួចក្នុងការបញ្ជាក់ថាអ្វីខ្លះពាក់ព័ន្ធ ឬនរណាគួរទទួលបានវិធានការណា ។ ដោយមិនមានការណែនាំនេះ គ្រឹះស្ថានហិរញ្ញវត្ថុកន្លងមកត្រូវតែរកវិធីខ្លួនឯងដើម្បីឆ្លើយតបនឹងវិបត្តិកូវីដ ១៩។ អាស្រ័យហេតុនេះ ការអនុវត្តចំពោះគោលការណ៍រៀបចំឥណទានឡើងវិញ មានលក្ខណៈខុសគ្នាពីគ្រឹះស្ថានមួយទៅគ្រឹះស្ថានមួយ។ ទោះជាយ៉ាងណាក៏ដោយ គ្រឹះស្ថានហិរញ្ញវត្ថុដែលយើងបានសន្ទនាជាមួយ បានកត់សម្គាល់ថា ពួកគេផ្តល់ការរៀបចំឥណទានឡើងវិញដល់អតិថិជនដែលប៉ះពាល់ដោយសារកូវីដ ១៩ ក្នុងទម្រង់សំខាន់ៗដូចខាងក្រោម៖

ក) **ការពន្យារពេលទូទាត់សង៖** កូនបំណុលដែលបានទទួល ការពន្យារពេលទូទាត់សង មិនតម្រូវឲ្យសងអ្វីទាំងអស់ក្នុងរយៈពេលកំណត់មួយ។ ការសងប្រាក់ការ ក្នុងរយៈពេលនេះត្រូវយកទៅដាក់បញ្ចូលជាមួយប្រាក់ដើម ហើយតារាងសម្រាប់សងថ្មីមួយត្រូវចេញនៅពេលផុតកំណត់ ការពន្យារពេលទូទាត់។

ខ) **ការពន្យារឥណប្រតិទាន៖** ដោយមាន ការពន្យារឥណប្រតិទាន រយៈពេលដែលកូនបំណុលត្រូវសងក៏មានរយៈពេលវែង ដូច្នេះចំនួនទឹកប្រាក់ដែលត្រូវសងប្រចាំខែក៏ត្រូវមានចំនួនតិចជាងមុនដល់កម្រិតមួយដែលកូនបំណុលមានសមត្ថភាពសង។

គ) **ការសងតែការប្រាក់៖** កូនបំណុលដែលបានទទួល រយៈពេលអនុគ្រោះ មានជម្រើសសងតែការប្រាក់ក្នុងរយៈពេលកំណត់ណាមួយ។ កត្តានេះធ្វើឲ្យកូនបំណុលបង់ប្រចាំខែតិចជាងមុន ហើយមិនបង់ប្រាក់ដើមក្នុងរយៈពេលអនុគ្រោះនោះ។

យោងទៅតាមកិច្ចសម្ភាសទាំងអស់ដែលយើងបានធ្វើជាមួយនឹងបុគ្គលិកស្ថាប័នហិរញ្ញវត្ថុ (N=34) យើងបានដឹងថា គ្រប់វិធានការនៃការរៀបចំឥណទានឡើងវិញទាំងអស់ (ការសងតែការប្រាក់ ការពន្យារពេលទូទាត់សង និងការពន្យារឥណប្រតិទាន) តម្រូវឲ្យមានការអនុម័តពីទីស្នាក់ការកណ្តាល។ ផ្ទុយមកវិញ ការធ្វើបុនហិរញ្ញប្បទាន មិនតម្រូវឲ្យមានការអនុម័តពីទីស្នាក់ការកណ្តាល

---

[121] White 2020.

[122] ប្រសិទ្ធភាពនៃគោលនយោបាយរៀបចំឥណទានឡើងវិញរហូតដល់ពាក់កណ្តាលឆ្នាំ២០២១ ជាលទ្ធផលនៃសំណូមពររបស់ គ.ម.ហ ស.ធ.ក (សូមមើល Sok 2020).

នោះទេ។ បើយោងតាមបុគ្គលិកគ្រឹះស្ថានហិរញ្ញវត្ថុភាគច្រើនដែលយើងបានសន្ទនាជាមួយ ការធ្វើបុនហិរញ្ញប្បទាន ធ្វើឲ្យគ្រឹះស្ថានហិរញ្ញវត្ថុក៏រកបានប្រាក់ចំណូលខ្លះៗដែរ។ កត្តានេះធ្វើឲ្យយើងយល់បានថា ហេតុអ្វីបានជាកូនបំណុលខ្លះដែលយើងបានសន្ទនាជាមួយ (នឹងពន្យល់បន្ថែមនៅក្នុងផ្នែកបន្ទាប់នេះ) កត់សម្គាល់ថា ដំបូងពួកគាត់ត្រូវបានផ្តល់ជម្រើសឲ្យយកប្រាក់ឥណទានបន្ថែម មិនមែនឲ្យយកការរៀបចំឥណទានឡើងវិញនោះទេ។ លើសពីនេះទៀត លទ្ធផលនៃការស្រាវជ្រាវក៏បានបង្ហាញផងដែរថា បន្ថែមទៅលើការរៀបចំឥណទានឡើងវិញ និងការធ្វើបុនហិរញ្ញប្បទាន បណ្តាគ្រឹះស្ថានហិរញ្ញវត្ថុក៏មានការបន្ធូរបន្ថយចំពោះការសងយឺតយ៉ាវតាមរយៈការកាត់បន្ថយ ឬលើកលែងប្រាក់ពិន័យចំពោះការបង់យឺតតិចជាង ៣០ថ្ងៃ។ គួរកត់សម្គាល់ផងដែរថា គ្រប់ទម្រង់នៃការជួយសង្គ្រោះទាំងនេះកំណត់ថា កូនបំណុលត្រូវតែសងប្រាក់បំណុលទាំងអស់ ដូច្នេះ ការលប់ចោលបំណុលមិនត្រូវបានអនុវត្តនោះឡើយ។ ទោះបីជាគ្រឹះស្ថានហិរញ្ញវត្ថុនានាអាចបន្តលុបចោលបំណុលក៏ដោយ ក៏តាមដែលយើងបានដឹង ពួកគេមិនបានធ្វើដូច្នោះក្នុងលក្ខណៈជាប្រព័ន្ធនោះទេ ក្នុងការឆ្លើយតបនឹងជំងឺកូវីដ ១៩។ មូលហេតុដែលបណ្តាលឲ្យស្ថាប័នហិរញ្ញវត្ថុមិនលុបបំណុលចោលមានខុសៗគ្នា៖ ប្រហែលពួកគេមិនមានចិត្តចង់ធ្វើដូច្នោះ ឬប្រហែលជាពួកគេខ្វះលទ្ធភាព ក្នុងការបំពេញកាតព្វកិច្ចដែលត្រូវយកចិត្តទុកដាក់ធានាថា មានតែកូនបំណុលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប៉ុណ្ណោះទេ ទើបអាចទទួលបានការលុបចោលបំណុល។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវនេះបានបង្ហាញថា មានតម្រូវការខ្លាំងឲ្យអនុវត្តការលុបបំណុលចោលនេះក្នុងលក្ខណៈស៊ីសង្វាក់គ្នា និងជាប្រព័ន្ធ ហើយមិនមានមូលហេតុច្បាស់មកបញ្ជាក់ទេថា ហេតុម្តេចបានជាប្រព័ន្ធនេះមិនត្រូវបានបង្កើតឲ្យមានរួចជាស្រេចតាំងតែនៅពេលមុនកើតវិបត្តិកូវីដ ១៩។

## ៤.៣. ដំណើរការរៀបចំឥណទានឡើងវិញ

ផ្អែកទៅលើកិច្ចសម្ភាសដែលយើងបានធ្វើជាមួយបុគ្គលិកឥណទាន (N=34) ទាំងអស់គ្នាបានរាយការណ៍ថា ការរៀបចំឥណទានឡើងវិញបានផ្តល់ដល់គ្រួសារដែលប៉ះពាល់ដោយកូវីដ ១៩ ហើយត្រូវមានការអនុម័តពីទីស្នាក់ការកណ្តាលនៃគ្រឹះស្ថានហិរញ្ញវត្ថុនោះ។ នៅទីនេះ យើងចង់ពន្យល់ពីដំណើរការរៀបចំឥណទានឡើងវិញ ដោយឈរលើព័ត៌មានដែលយើងប្រមូលបានពីបុគ្គលិកហិរញ្ញវត្ថុចំនួន ៣៤នាក់ ដែលបានសម្ភាស។

ដើម្បីកំណត់ថាគ្រួសារណាទទួលបាន ឬក៏អត់នោះ តំណាងគ្រឹះស្ថានហិរញ្ញវត្ថុបានលើកឡើងថា ពួកគេត្រូវវាយតម្លៃចំពោះផលប៉ះពាល់ដែលមានទៅលើប្រាក់ចំណូល ពោលគឺកំណត់ឲ្យឃើញថា តើប្រាក់ចំណូលកូនបំណុលបានប៉ះពាល់ដោយកូវីដ ១៩ ឬអត់។ ដំណើរការនេះចាប់ផ្តើមដោយមានមន្ត្រីឥណទានធ្វើការស្ទាបស្ទង់អំពីគ្រួសារដែលប៉ះពាល់។ បន្ទាប់ពីរកឃើញគ្រួសារដែលប៉ះពាល់ហើយ មន្ត្រីឥណទានបំពេញទម្រង់មួយសម្រាប់ការរៀបចំឥណទានឡើងវិញក្នុងពេលកូវីដ ១៩។ មន្ត្រីឥណទានដាក់សំណើនេះទៅកាន់ប្រធានសាខា។ ប្រធានសាខាចុះពិនិត្យដល់ផ្ទះផ្ទាល់ ឬចាត់តាំងមន្ត្រីឥណទានជាន់ខ្ពស់ ឬប្រធានផ្នែកឥណទានឲ្យទៅពិនិត្យដល់ផ្ទះជំនួស។ បន្ទាប់ពីខាងសាខាបានពិនិត្យហើយ សំណើត្រូវដាក់ទៅឲ្យខាងទីស្នាក់ការកណ្តាល គ.ម.ហ អនុមតិ។ ដំណើរការនេះប្រើអស់រយៈពេលក្នុងចន្លោះទី៤ថ្ងៃ ដល់មួយខែ អាស្រ័យទៅលើចំនួនករណីតិចឬច្រើនដែលទីស្នាក់ការកណ្តាលបានទទួល។ នៅទីស្នាក់ការកណ្តាល ក្រុមទទួលខុសត្រូវខាងការគ្រប់គ្រងហានិភ័យឥណទាន ធ្វើការវាយតម្លៃលើសំណើនោះ ហើយក៏អនុមតិ ឬក៏បដិសេធសំណើនោះ។

ទោះជាយ៉ាងណាក៏ដោយ ការប្រឹក្សាយោបល់ដែលយើងបានធ្វើជាមួយអ្នកគ្រប់គ្រងជាន់ខ្ពស់របស់ខាងមីក្រូហិរញ្ញវត្ថុបាន បង្ហាញពីដំណើរការមួយផ្សេង។ នៅក្នុងដំណើរការនោះ ពួកគាត់និយាយថា អ្នកណាក៏ដោយដែលមានសមត្ថភាព និងចំណេះដឹង អាចអនុម័តលើពាក្យសុំរៀបចំឥណទានឡើងវិញបាន ទោះបីជានៅកម្រិតសាខា ក៏បានដែរ ហើយមិនចាំបាច់តែនៅកម្រិតទីស្នាក់ការ កណ្តាលនោះទេ។ វាជាកត្តា សារៈសំខាន់ក្នុងការស្វែងយល់ពីមូលហេតុដែលការអនុវត្តនេះអាចធ្វើទៅបានខុសពីវិធានដែលបាន ចែង។ តើមូលហេតុនោះបណ្តាលមកបុគ្គលិកនៅតាមសាខាមិនមានការប្តេជ្ញាចិត្តទទួលខុសត្រូវ និងភាពក្លាហានហ៊ានសម្រេចចិត្ត ឬប្រហែលជាបណ្តាលមកពីមានសមត្ថភាពមិនគ្រប់គ្រាន់ក្នុងការវាយតម្លៃទៅលើករណីសុំរៀបចំឥណទានឡើងវិញ ឬក៏បណ្តាល មកពីកត្តាទាំងអស់នោះសុបគ្នា ឬដោយមូលហេតុអ្វីផ្សេងដោយឡែក? ការយល់ដឹងអំពីដំណើរការនេះនឹងអាចជួយឲ្យឆ្លើយសំណួរ បន្ទាន់មួយគឺ តើដំណើរការនេះអាចសម្រួលបានដោយរបៀបណាសម្រាប់កូនបំណុល។

យើងមិនបានរកឃើញថាមានលក្ខខណ្ឌណាបានចែងច្បាស់ថា កូនបំណុលប្រភេទណាទើបគ្រប់លក្ខណៈទទួលបានការ រៀបចំឥណទានឡើងវិញប្រភេទណានោះទេ ហើយយោងតាមការសម្ភាសរបស់យើងស្តែងឲ្យឃើញថា ការសម្រេចទាំងនេះបានធ្វើ ឡើងទៅតាមករណី ដោយករណី។ នៅពេលដែលយើងសួរថាការរៀបចំឥណទានឡើងវិញប្រភេទណា ដែលគ្រឹះស្ថានហិរញ្ញវត្ថុ ច្រើនអនុម័តចម្លើយគឺថា ការសងតែការប្រាក់ (គឺក្នុងករណី ដែលកូនបំណុលសងតែការប្រាក់ សូមមើលតារាង ៤)។ ផលវិបាកនៃ ការយកវិធានការ ការសងតែការប្រាក់នេះគឺថា បង្កើននូវប្រាក់ដែលត្រូវបង់សរុបចំពោះឥណទានក្នុងរយៈពេលវែង។ ការយល់ឃើញ បែបនេះត្រូវនឹងការយល់ឃើញរបស់កូនបំណុលមួយចំនួនផងដែរ ដោយពួកគាត់យល់ថា ការសងតែការប្រាក់ គឺជាវិធីនាំឲ្យ*"ខាត"*។

## តារាង ៤: ការរៀបចំឥណទានឡើងវិញក្នុងតំណាងគ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗ

| តួនាទី | ខេត្ត | ទីតាំង | ការពន្យារពេលទូទាត់សង | ការពន្យារឥណប្រតិទាន | ការសងតែការប្រាក់ | ចំនួនសរុបការរៀបចំឥណទានឡើងវិញ | ចំនួនកូនបំណុលសរុប |
|---|---|---|---|---|---|---|---|
| ប.ស | កណ្តាល | ទីក្រុង | 0 | 0 | ២៨ | ២៨ | ៩៣៤ |
| ម.ឥ | កណ្តាល | ទីក្រុង | 0 | 0 | ២០ | ២០ | ២០០ |
| ម.ឥ | កណ្តាល | ទីក្រុង | 0 | 0 | ៨ | ៨ | ២៦៣ |
| ប.ស | កណ្តាល | ជនបទ | 0 | 0 | 0 | ២ | ២.០៦៨ |
| ម.ឥ | កណ្តាល | ជនបទ | 0 | 0 | ២០ | ២០ | ៣៧៥ |
| ម.ឥ | កណ្តាល | ជនបទ | 0 | 0 | 0 | 0 | ៣៥៤ |
| ប.ស | បាត់ដំបង | ទីក្រុង | 0 | 0 | ១០០ | 0 | ១.៧៧០ |
| ម.ឥ | បាត់ដំបង | ទីក្រុង | 0 | 0 | ៣០ | ៣០ | ៣២៨ |
| ម.ឥ | បាត់ដំបង | ទីក្រុង | 0 | 0 | ២០ | ២០ | ១៧២ |
| ប.ស | បាត់ដំបង | ជនបទ | 0 | 0 | ៤០ | ៤០ | ២.១០០ |
| ម.ឥ | បាត់ដំបង | ជនបទ | 0 | 0 | ៦ | ៦ | ៣៥០ |
| ម.ឥ | បាត់ដំបង | ជនបទ | 0 | 0 | ៣ | ៣ | ៣៣៥ |
| ប.ស | បាត់ដំបង | ជនបទ | 0 | 0 | ២០ | ២០ | ៧៧០ |
| ប.ស | បាត់ដំបង | ជនបទ | ម.ក* | ម.ក | ភាគច្រើន | ១០០ | ១.២៦០ |
| ប.ស | បន្ទាយមានជ័យ | ទីក្រុង | 0 | 0 | ៣០ | 0 | ១.២០០ |
| ម.ឥ | បន្ទាយមានជ័យ | ទីក្រុង | 0 | 0 | ៥ | ៥ | ២៨២ |
| ម.ឥ | បន្ទាយមានជ័យ | ទីក្រុង | 0 | 0 | 0 | 0 | ១៣៥ |
| ប.ស | សៀមរាប | ទីក្រុង | 0 | 0 | ២៥០ | ២៥០ | ២.១០០ |
| ម.ឥ | សៀមរាប | ទីក្រុង | ម.ក | ម.ក | ម.ក | ៧០ | ៣៦៧ |
| ម.ឥ | សៀមរាប | ទីក្រុង | ម.ក | ម.ក | ភាគច្រើន | ៦០ | ៣២០ |
| ប.ស | សៀមរាប | ទីក្រុង | ៥0 | 0 | ៣៥0 | ៤00 | ១.២00 |
| ប.ស | សៀមរាប | ទីក្រុង | ១00 | 0 | ៩00 | 0 | ៣.៤00 |
| ប.ស | សៀមរាប | ជនបទ | 0 | 0 | ៥៨ | ៥៨ | ២.៤១៤ |
| ម.ឥ | សៀមរាប | ជនបទ | 0 | 0 | ២០ | ២០ | ៤៨២ |
| ប.ស | សៀមរាប | ជនបទ | 0 | 0 | ២០ | 0 | ១.២០០ |
| ប.ស | សៀមរាប | ជនបទ | ២៤ | ១២ | ២០៥ | 0 | ១.៥០០ |
| ម.ឥ | សៀមរាប | ជនបទ | 0 | 0 | ២២ | ២២ | ១១០ |
| ប.ស | កំពង់ឆ្នាំង | ទីក្រុង | 0 | 0 | ១០ | ១០ | ១.២៨០ |
| ម.ឥ | កំពង់ឆ្នាំង | ទីក្រុង | 0 | 0 | ១០ | ១០ | ២៧២ |
| ប.ស | កំពង់ឆ្នាំង | ជនបទ | 0 | 0 | 5 | 0 | ម.ក |

*ប្រភព: រៀបចំដោយអ្នកនិពន្ធ*

* ចំនួនសរុបនៃកូនបំណុលដែលបុគ្គលិកម្នាក់ៗបានផ្តល់
* ការរៀបចំឥណទានឡើងវិញ (ក.ឥ.ឡ)
* មិនអាចកំណត់បាន (ម.ក)
* ប្រធានសាខា (ប.ស)
* មន្ត្រីឥណទាន (ម.ឥ)

លើសពីនេះទៀតនៅក្នុងករណីមួយចំនួនប្រធានសាខា និងបុគ្គលិកឥណទានហាក់ដូចជារើសយកការធ្វើបុនហិរញ្ញប្បទានច្រើនជាងការរៀបចំឥណទានឡើងវិញ ដោយឈរលើការអះអាងដែលពួកគាត់ថា ការរៀបចំឥណទានឡើងវិញ អាចប៉ះពាល់ដល់ប្រវត្តិឥណទានរបស់អតិថិជន។ ប្រធានសាខាម្នាក់បានលើកឡើងថា "នៅពេលដែលខ្ញុំឲ្យយោបល់ដល់អតិថិជន ខ្ញុំត្រូវតែពន្យល់យោបល់នេះដល់ពួកគាត់។ តើពួកគាត់រើសយកជម្រើសណា? បើពួកគាត់ចង់រៀបចំឥណទានសាឡើងវិញ ពួកគាត់អាចរៀបចំបាន។ បើពួកគាត់ចង់ធ្វើបុនហិរញ្ញប្បទាន ពួកគាត់ក៏អាចធ្វើបាន។ ករណីពួកគាត់យកបុនហិរញ្ញប្បទាន ប្រវត្តិឥណទានរបស់ពួកគាត់មិនប៉ះពាល់ក្នុងលក្ខណៈដូចជា ពួកគាត់រៀបចំឥណទានឡើងវិញនោះទេ។"[123] ការលើកឡើងនេះបង្ហាញថា បុគ្គលិកឥណទានអាចកំពុងនឹងរារាំងកូនបំណុលកុំឲ្យយកការរៀបចំឥណទានឡើងវិញ ហើយឲ្យយកបុនហិរញ្ញប្បទានដោយសារណែនាំថា វានឹងប៉ះពាល់ជាអវិជ្ជមានដល់ប្រវត្តិឥណទានរបស់កូនបំណុល ដែលជាអ្វីមិនទាន់បានកំណត់ច្បាស់លាស់នៅឡើយ ហើយដែលជាទង្វើមួយផ្ទុយនឹងការអនុវត្តល្អៗក្នុងពេលឆ្លើយតបទៅនឹងកូវីដ ១៩ នៅក្នុងវិស័យនេះ (នឹងរៀបរាប់បន្ថែមនៅខាងក្រោមទៀត)។[124]

## ៤.៤. ការរៀបចំឥណទានឡើងវិញក្នុងចំណោមអ្នកផ្តល់កិច្ចសម្ភាសរបស់យើង

ក្នុងចំណោមកូនបំណុល ១១៩ នាក់ ដែលយើងបានសន្ទនាជាមួយ មានតែចំនួន២៣នាក់ប៉ុណ្ណោះដែលបានទទួលការរៀបចំឥណទានឡើងវិញ (១៦នាក់បានទទួលការសងតែការប្រាក់ ៦នាក់បានទទួលការពន្យារពេលទូទាត់សង និង ១នាក់បានទទួលការអនុញ្ញាតពីគ្រឹះស្ថានហិរញ្ញវត្ថុឲ្យសងតាមពេល និងទឹកប្រាក់ដែលគាត់អាចបង់បាន។) លើសពីនេះកូនបំណុលចំនួន ១១នាក់ បានទាក់ទងទៅខាងគ្រឹះស្ថានហិរញ្ញវត្ថុ ហើយត្រូវបានបដិសេធដោយផ្ទាល់មាត់ ៖ ៦នាក់ ដោយសារគាត់មិនបានបំពេញគ្រប់លក្ខណៈ ដែលវិស័យតម្រូវ ៥នាក់ ដោយសារ នៅតំបន់របស់ពួកគាត់ជាទូទៅមិនមានការរៀបចំឥណទានឡើងវិញ។ លើសពីនេះទៀត កូនបំណុលចំនួន ៧នាក់ បានទទួលការអនុញ្ញាតឲ្យរៀបចំឥណទានឡើងវិញ (ការសងតែការប្រាក់) ប៉ុន្តែពួកគាត់បដិសេធពីព្រោះពួកគាត់បារម្ភថា វានឹងនាំឲ្យខាត ប្រាក់ទៅវិញ។ ក្នុងចំណោមអ្នកនៅសល់ កូនបំណុល ៣១នាក់ទៀតមិនបានដឹងអំពីគោលនយោបាយអនុញ្ញាតឲ្យរៀបចំឥណទានឡើងវិញនេះទាល់តែសោះ អ្នកក្រៅពីនោះគឺសុទ្ធតែមានលទ្ធភាពបង់ ឬមិនហ៊ានទាក់ទងគ្រឹះស្ថានហិរញ្ញវត្ថុ ដោយខ្លាចប៉ះពាល់ប្រវត្តិឥណទានរបស់ពួកគាត់ និង/ឬខ្លាចខ្មាសគេ។ ការរកឃើញថាមានកូនបំណុលចំនួន ៣១នាក់មិនបានដឹងអំពីគោលការណ៍រៀបចំឥណទានឡើងវិញនោះ គឺស៊ីសង្វាក់ទៅនឹងជំរឿនមួយ (N=997) ដែលបានធ្វើជាមួយសហគ្រាស ខ្នាតមីក្រូ តូច និងមធ្យម ទាំងបានចុះបញ្ជី និងមិនបានចុះបញ្ជីនៅក្នុងវិស័យទេសចរណ៍ធ្វើឡើងនៅខែកក្កដា ឆ្នាំ២០២០ នៅក្នុងតំបន់ចំនួន ៤ នៅប្រទេសកម្ពុជា ហើយរកឃើញថា មានសំណាកអ្នកផ្តល់ចម្លើយចំនួន ៦០% មិនបានដឹងអំពីការរៀបចំឥណទានឡើងវិញរបស់ធនាគារ/ គ.ម.ហ។[125]

ការសម្ភាសរបស់យើងជាមួយកូនបំណុល បានបំភ្លឺខ្លឹមសារជាច្រើនដែលបានលើកឡើងដោយគ្រឹះស្ថានហិរញ្ញវត្ថុ។ ភាគច្រើននៃអ្នកដែលបានទទួលការរៀបចំឥណទានឡើងវិញ បានឆ្លងកាត់ដំណាក់កាលមួយ*ដែលផ្តួចផ្តើមដោយបុគ្គលិកឥណទាន៖* កូនបំណុលត្រូវបានទាក់ទងដោយមន្ត្រីឥណទាន ហើយត្រូវបានគេប្រាប់ថា ពួកគាត់អាចដាក់ពាក្យសុំបាន។ ក្នុងករណីតែមួយចំនួនតូចប៉ុណ្ណោះ ដែលកូនបំណុលបានស្នើសុំដោយខ្លួនឯង ហើយបានទទួលការរៀបចំឥណទាន ដែលស្នើសុំនោះដោយខ្លួនឯងឡើងវិញ។ ដូច្នេះ ទោះជានៅលើក្រដាសមើលទៅឃើញថា កូនបំណុល "ស្នើសុំ" រៀបចំឥណទានឡើងវិញ លើកលែងតែករណីកូនបំណុលនៅក្រុងសៀមរាប ក៏ដោយ ក៏ទិន្នន័យរបស់យើងបង្ហាញថា មន្ត្រីឥណទាន មិនមែនកូនបំណុលនោះទេ ដែលជាអ្នកភាគច្រើនកំណត់ថានរណាមានជម្រើសអាចសុំរៀបចំឥណទានឡើងវិញបាន។ យើងនឹងពិភាក្សាបញ្ហាប្រឈមទាំងនេះថែមទៀតនៅផ្នែកបន្ទាប់។

---

123 FI ID:2.

124 CGAP 2020.

125 The Asia Foundation 2020.

មន្ត្រីឥណទានបានឲ្យដឹងថា ប្រភេទនៃការរៀបចំឥណទានឡើងវិញដែលបានអនុម័តច្រើនជាងគេនោះគឺ ការសងតែការប្រាក់ ហើយទិន្នន័យរបស់យើងក៏បានបង្ហាញដូច្នេះដែរ។ តាមពិត កូនបំណុលភាគច្រើនដែលយើងបានសន្ទនាជាមួយ បានដឹងថាមានជម្រើសនេះតែមួយប៉ុណ្ណោះគឺ ការសងតែការប្រាក់។ នៅក្នុងករណីភាគច្រើន ការពន្យារពេលទូទាត់សង និងការពន្យារឥណប្រតិទាន មិនបានលើកមកនិយាយថាជាជម្រើសដែលអាចធ្វើទៅបាននោះទេ ហើយជម្រើសប្រភេទនេះ មានតែគ្រួសារមួយចំនួនតូចនៅខេត្តសៀមរាបប៉ុណ្ណោះដែលបានដឹងហើយទទួលបាន។ ដោយសារមានគ្រួសារតែមួយចំនួនតូចទទួលបាន ការពន្យារពេលទូទាត់សង ធ្វើឲ្យមានការយល់ឃើញ ជម្រើសនេះខុសៗគ្នាក្នុងចំណោមកូនបំណុល និងម្ចាស់បំណុល។ កូនបំណុលម្នាក់ដែលទទួលបានការពន្យារពេលទូទាត់សង បានពន្យល់ថា នៅពេលដែលពួកគាត់ត្រឡប់ឈានទៅបង់សងបំណុលតាមកាលវិភាគធម្មតាវិញ គ្រឹះស្ថានហិរញ្ញវត្ថុនឹងយកប្រាក់ការសរុបធ្វើជាប្រាក់ដើម។ ទោះជាយ៉ាងណាក៏ដោយ ការយល់ឃើញបែបនេះមិនស៊ីសង្វាក់ជាមួយនឹងអ្វីដែលប្រធានសាខាម្នាក់បានប្រាប់ក្រុមស្រាវជ្រាវយើងនោះទេ ដែលថាមិនមានការគិតការប្រាក់ទៅលើការប្រាក់សរុបនោះទេ។ មិនមានលក្ខណៈច្បាស់លាស់ទេថា ការលើកឡើងមួយណាជាការពិតត្រឹមត្រូវនោះ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តល្អៗរបស់វិស័យហិរញ្ញវត្ថុក្នុងពេលឆ្លើយតបទៅនឹងកូវីដ ១៩ បានកត់សម្គាល់ពីសារៈសំខាន់នៃការមិនគិតការប្រាក់ទៅលើការប្រាក់។[126]

កិច្ចសម្ភាសរបស់យើងជាមួយនឹងកូនបំណុលក៏បានបង្ហាញផ្ទុយពីការអះអាងដែលថា ការរៀបចំឥណទានឡើងវិញ បើកឲ្យមានចំពោះគ្រប់គ្រួសារដែលបានរងការប៉ះពាល់។ កូនបំណុលជាច្រើនដែលយើងបានសន្ទនាជាមួយ ដែលយល់ថាខ្លួនឯងរងការប៉ះពាល់ដែរ បែរជាមិនបានទទួលការរៀបចំឥណទានឡើងវិញ។ កូនបំណុលដែលយើងបានសម្ភាសប្រហែល ១០% បានទទួលការបដិសេធចំពោះការរៀបចំឥណទានឡើងវិញតាមរយៈមន្ត្រីឥណទាន (ម.ឥ) របស់ពួកគេ។ ហេតុផលដែល ម.ឥ បានប្រាប់កូនបំណុលដែលយើងបានសម្ភាស មានដូចជាថា គោលការណ៍នោះមិនមានទេក្នុងតំបន់របស់គេ ឬថា កូនបំណុលទាំងនោះមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដោយសារខុសវិស័យ (កសិកម្ម)។ ទិន្នន័យដែលមាន ២៣ ករណីទទួលបានការរៀបចំឥណទានឡើងវិញ ក៏បង្ហាញផងដែរថា ក្នុងចំណោមពួកគាត់ មានតែ ៥ ករណីប៉ុណ្ណោះ គឺជាអ្នកដែលស្ថិតក្នុងវិស័យកសិកម្ម។ យើងនឹងរៀបរាប់ពីបទពិសោធន៍របស់អ្នកដែលការស្នើសុំរបស់ពួកគាត់ត្រូវបានគេបដិសេធនៅផ្នែកបន្ទាប់។

យើងមិនអាចញែកឲ្យបានច្បាស់នូវលំនាំថាតើនរណាបានទទួលការរៀបចំឥណទានឡើងវិញ ពីព្រោះគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងគ្នា មានលក្ខខណ្ឌតម្រូវផ្សេងៗគ្នា ក្នុងការកំណត់ថាតើអ្នកណាត្រូវទទួលបានការរៀបចំឥណទានឡើងវិញ។ មានគ្រឹះស្ថានខ្លះផ្តល់ការអនុញ្ញាតទៅដល់គ្រួសារណាក៏ដោយដែលមាន សាមីខ្លួន ឬសមាជិកគ្រួសារ បានប៉ះពាល់ធ្ងន់ធ្ងរដោយសារកូវីដ ១៩។ មានគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ផ្តល់ការអនុញ្ញាតតែចំពោះកូនបំណុលណា ដែលស្ថិតនៅក្នុងវិស័យណាមួយក្នុងចំណោមវិស័យទាំងបួន ដែលបានកំណត់ ដូចជា វិស័យផលិតសម្លៀកបំពាក់ ទេសចរណ៍ ការដឹកជញ្ជូន និងសំណង់។ ទោះជាយ៉ាងណាក៏ដោយ ក៏មានករណីអាចទៅរួចផងដែរ ដោយសារមន្ត្រីឥណទានជាអ្នកគ្រប់គ្រងទៅលើដំណើរការមួយភាគធំនៃការដាក់ពាក្យសុំ ធ្វើឲ្យការសម្រេចចិត្តមានលក្ខណៈអត្តនោម័ត្តិចំពោះថាតើនរណាបានបំពេញគ្រប់លក្ខខណ្ឌ។

ទោះបីជាភាគច្រើននៃបុគ្គលិកគ្រឹះស្ថានហិរញ្ញវត្ថុអះអាងថា ការរៀបចំឥណទានឡើងវិញមានអត្ថប្រយោជន៍សម្រាប់អតិថិជនរបស់ខ្លួនក៏ដោយ ប្រការនេះមិនទាន់ច្បាស់នៅឡើយទេ។ ឧទាហរណ៍ ក្នុងចំណោមកូនបំណុលចំនួន ២៣នាក់ ដែលបានទទួលការរៀបចំឥណទានឡើងវិញ ភាគច្រើនទទួលបានជម្រើសបង់តែការប្រាក់ ដែលនៅក្នុងរយៈពេលវែង នឹងអាចបង្កើនចំនួនឥណទានសរុបដែលត្រូវបង់។ ប្រការនេះបានធ្វើឲ្យកើតចេញជាសំណួរមួយថាតើការបង់តម្លៃឥណទានសរុបដែលត្រូវបង់ និងហានិភ័យដែលកើតចេញពីការរៀបចំឥណទានឡើងវិញនេះ បានថ្លឹងថ្លែងបែងចែកសមស្របឬទេ រវាងអ្នកផ្តល់សេវាហិរញ្ញវត្ថុ និងអតិថិជនរបស់ខ្លួន។ សំណួរនេះ នាំយើងទៅដល់ផ្នែកបន្ទាប់ ដែលផ្អែកលើកិច្ចសម្ភាសរបស់យើង យើងបានកំណត់រកឃើញកាលានុវត្តភាពការអនុវត្តនៅមានកម្រិត និងបញ្ហាប្រឈមក្នុងការរៀបចំឥណទានឡើងវិញ។

---

[126] Rhyne et al 2020.

# ផ្នែកទី ៥: ភាពខុសគ្នា ការអនុវត្តនៅមានកម្រិត និងបញ្ហាប្រឈមក្នុងការរៀបចំឥណទានឡើងវិញ

កូនបំណុលដែលយើងបានសន្ទនាជាមួយ ហើយដែលបានទទួលការរៀបចំឥណទានឡើងវិញ មានទស្សនៈខុសៗគ្នាអំពីការរៀបចំនេះ មានទាំងអារម្មណ៍អរគុណ និងអារម្មណ៍មិនពេញចិត្ត។ កូនបំណុលខ្លះយល់ថា វិស័យនេះមិនទាន់បានបំពេញភារកិច្ចគ្រប់គ្រាន់នៅឡើយទេ ហើយខ្លះទៀតមិនទទួលយកឥណទានដែលរៀបចំឡើងវិញនេះទេ ទោះជាខ្លួនកំពុងរងសម្ពាធបំណុលក៏ដោយ។ លើសពីនេះទៀតទិន្នន័យរបស់យើងបានបង្ហាញថា មានបញ្ហាប្រឈមសំខាន់ៗចំនួនបី ដែលកើតឡើងនៅក្នុងការអនុវត្តរៀបចំឥណទានឡើងវិញ៖ ១) នៅមានកម្រិតនៅឡើយនៅក្នុងការចុះទៅដល់គ្រួសារដែលរងសម្ពាធបំណុល នាំឲ្យបុគ្គលិកឥណទានក្លាយជាអ្នកកំណត់យ៉ាងមានប្រសិទ្ធភាព ថាតើអ្នកណាត្រូវដាក់ពាក្យសុំរៀបចំឥណទានឡើងវិញ គឺមិនមែនជាពាក្យសុំមួយដែលនាំមុខដោយកូនបំណុលនោះទេ ២) កូនបំណុលដែលបានប៉ះពាល់ មិនមែនគ្រប់គ្នានោះទេ អាចទទួលការរៀបចំឥណទានឡើងវិញ ដោយសារវាមិនមាននៅគ្រប់តំបន់ ហើយមិនមានចំពោះគ្រប់ប្រភេទគ្រួសារដែលបានប៉ះពាល់នោះទេ ៣) ផលវិបាកនៃការរៀបចំឥណទានឡើងវិញទៅលើ ប្រវត្តិឥណទានរបស់អតិថិជន មិនទាន់បានកំណត់ឲ្យច្បាស់នៅឡើយ ធ្វើឲ្យការអនុវត្ត និងការបកស្រាយ មានលក្ខណៈខុសគ្នា និងស្រពេចស្រពិល។

## ៥.១. ទស្សនៈរបស់កូនបំណុលចំពោះការទទួលបាននូវការរៀបចំឥណទានឡើងវិញ

ការស្រាវជ្រាវរបស់យើង បានកំណត់ឃើញទស្សនៈមួយចំនួន អំពីការរៀបចំឥណទានឡើងវិញរបស់អ្នកដែលបានទទួលវា។ ឧទាហរណ៍ ប្ដីប្រពន្ធកម្មករចំណាកស្រុកទៅធ្វើការប្រចាំថ្ងៃ បានឲ្យដឹងថា ពួកគាត់សម្ដែងការអរគុណជាខ្លាំងដល់ការរៀបចំឥណទានឡើងវិញ។ ពួកគាត់មានអាយុជិត ៦០ឆ្នាំ ហើយបានយកឥណទានពីគ្រឹះស្ថានហិរញ្ញវត្ថុមួយក្នុងចំនួនទឹកប្រាក់ ៧៥០ដុល្លារសហរដ្ឋអាមេរិក យកទៅបង្គ្រប់សង់ផ្ទះតូចមួយ ដែលធ្វើអំពីស័ង្កសី។ ពួកគាត់ពឹងទៅលើការងារដែលឆ្លងទៅធ្វើនៅម្ខាងព្រំដែន យកមកសងបំណុល ហើយនៅពេលដែលព្រំដែនបិទ ក៏មានការលំបាកសម្រាប់ពួកគាត់ ក្នុងការរកប្រាក់ឲ្យបានគ្រប់ យកទៅសងបំណុលឲ្យបានទៀងទាត់។ ដោយសារពួកគាត់មានកាន់ប័ណ្ណក្រីក្រប្រភេទ ១ ពួកគាត់ទទួលបានប្រាក់ ៤០ ដុល្លារសហរដ្ឋអាមេរិកពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់រដ្ឋាភិបាលនេះ ដែលផ្ដល់ដល់គ្រួសារក្រីក្ររាល់ខែ។ ក្រោយពីព្រំដែនបានបិទ គ្រួសារនេះរកលុយមិនគ្រប់សងគេ ដូច្នេះពួកគាត់ក៏ទាក់ទងទៅអ្នកផ្ដល់សេវាហិរញ្ញវត្ថុរបស់ពួកគាត់។ ការស្រាវជ្រាវមិនបានរកឃើញរបៀបដែលគាត់បានដឹងពីដំណើរការរៀបចំឥណទានឡើងវិញនោះទេ។ តាមរយៈទូរសព្ទ បុគ្គលិកនោះក៏បានពន្យល់ពួកគាត់ថា គ្រឹះស្ថានរបស់បុគ្គលិកនោះបានចាប់ផ្ដើមមានគោលការឲ្យបង់តែការប្រាក់ ចំពោះអ្នកណាដែលមានប្រាក់ចំណូលប៉ះពាល់ដោយកូវីដ ១៩។ ដោយបានដឹងព័ត៌មាននេះ ពីរនាក់ប្ដីប្រពន្ធរូបនេះក៏ស្នើសុំ បង់តែការប្រាក់ ចំនួន ៣ ខែ ប៉ុន្តែទទួលបានដល់ទៅ ៦ខែ កាលពីខែឧសភា ឆ្នាំ២០២០។ ការបង់ប្រចាំខែរបស់គាត់បានធ្លាក់ចុះពី ៤០ ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយខែ ទៅត្រឹមតែ ១០ ដុល្លារសហរដ្ឋអាមេរិក។ ទោះបីជាគ្រួសារនេះមានការអរគុណដល់ការរៀបចំឥណទានឡើងវិញនេះក៏ដោយ ក៏ប៉ុន្តែពួកគាត់បានលើកឡើងនូវការព្រួយបារម្ភថា កូវីដ ១៩ នឹងនៅតែមានបន្ត ហើយចំនួនដែលត្រូវបង់សរុបចំពោះឥណទានក្នុងរយៈពេលវែងក៏ចេះតែកើនឡើង។[127]

កម្មការនីរោងចក្រផលិតកាបូបអាយុ ២១ឆ្នាំ ជួយឪពុកម្ដាយរបស់គាត់សងបំណុលមីក្រូហិរញ្ញវត្ថុចំនួនទឹកប្រាក់ ៦.០០០ ដុល្លារសហរដ្ឋអាមេរិក។ ឪពុកម្ដាយរបស់គាត់ឲ្យគាត់ទូរសព្ទទៅមន្ត្រីឥណទានរបស់ពួកគាត់ ដើម្បីពន្យល់ស្ថានភាពរបស់គាត់ ហើយនិងសុំ ការពន្យារពេលទូទាត់សង។ គាត់បានចរចាជាមួយនឹងមន្ត្រីឥណទានម្នាក់ ហើយសំណើរបស់គាត់សុំផ្អាកបង់ប្រាក់ពីរខែ (ខែមេសា និងឧសភា) បានទទួលការអនុញ្ញាត។ គាត់មានការអរគុណដល់រយៈពេលផ្អាកបង់ពីរខែនេះ ដោយសារវាជួយបន្ធូរ

[127] Participant ID:67.

គាត់ពីសម្ពាធនៃបំណុលហិរញ្ញវត្ថុ ក្នុងពេលដែលគាត់អត់មានការងារធ្វើរយៈពេលមួយខែក្នុងខែឧសភា។ នៅពេលដែលបានសម្ភាស នៅក្នុងខែសីហា គាត់មានការងារធ្វើឡើងវិញ ហើយបង់សងជាធម្មតាវិញ ប៉ុន្តែគាត់កំពុងរស់នៅក្នុងការភ័យខ្លាច មិនដឹងថារក លុយបានមកពីណាយកទៅសងបំណុលមីក្រូហិរញ្ញវត្ថុ ក្នុងករណីគាត់ត្រូវបញ្ឈប់ពីការងារ។ គាត់និយាយថា “ខ្ញុំខ្លាចតែត្រូវគេបញ្ឈប់ពីការងារ”។ នៅពេលដែលយើងទូរសព្ទទៅសួរនាំបន្ថែមក្រោយមក គាត់មានអារម្មណ៍នឹងនរជាងមុនចំពោះស្ថានភាពហិរញ្ញវត្ថុរបស់គាត់ដោយសារគាត់មានការងារបន្ថែមម៉ោងវិញ។

កូនបំណុលផ្សេងៗទៀតដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារកូវីដ ១៩ បានទិតៀនខ្លាំងជាង ដោយបានចង្អុលថាវាមិនអាចជួយអ្វីបាននោះទេ កាលណាពួកគាត់នៅតែត្រូវបន្តសងការចំពោះបំណុលបែបនេះនោះ។ ផ្ទុយមកវិញ ពួកគាត់មានអារម្មណ៍ថា ខាត។ ឧទាហរណ៍ **ពូធឿន** ជាអ្នករត់ទុកទុក ដែលនៅផ្ទះជាមួយសាច់ថ្លៃរបស់គាត់នៅខេត្តសៀមរាប។ គាត់មានអាយុ ៤១ឆ្នាំ គាត់បានរៀបការហើយមានកូន ៤នាក់ ចាប់ពីអាយុ ១ឆ្នាំ ដល់ ៨ឆ្នាំ។ សាច់ថ្លៃរបស់គាត់បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៦.០០០ ដុល្លារសហរដ្ឋអាមេរិក ដែលប្រពន្ធរបស់គាត់បានគ្រោងយកទៅបើករកស៊ី។ **ពូធឿន** រំពឹងថា ប្រើទុកទុករកលុយទៅសងបំណុលពេលអាជីវកម្មរបស់ប្រពន្ធគាត់មិនទាន់បានចំណេញ។ មុនពេលកូវីដ ១៩ គាត់ធ្វើការពីម៉ោង ៧ ព្រឹក ដល់ ១១ យប់ ហើយរកបានពី ១០ ទៅ ១២ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃ។ ចាប់តាំងពីមានកូវីដ ១៩ មកមិនមានអតិថិជនទេ។ គាត់ធ្វើការក្នុងរយៈពេលដូចមុន ប៉ុន្តែរកបានជាមធ្យមពី ២,៥ទៅ ៥ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃ។ នេះធ្វើឲ្យមានការលំបាកក្នុងការសងបំណុល។ ក្រោយពីមានការប្រកាសអំពីការរៀបចំឥណទានឡើងវិញ ដោយគាត់បានឃើញតាមរយៈបណ្តាញព័ត៌មានសង្គមមានសារមួយពណ៌នាអំពីដំណើរការនេះ ហើយគាត់ក៏បានសួរនាំអំពីរឿងនេះជាមួយធនាគាររបស់គាត់។ ពីរបីថ្ងៃក្រោយមក នៅក្នុងខែមីនា ២០២០ គាត់បានទទួល រយៈពេលអនុគ្រោះ ចំពោះបំណុលរបស់គាត់។ ការបង់ប្រចាំខែបានធ្លាក់ចុះពី ១៥០ ដុល្លារសហរដ្ឋអាមេរិក ទៅត្រឹមតែ ៥០ ដុល្លារសហរដ្ឋអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងកម្រៃរបស់គាត់បច្ចុប្បន្ន សូម្បីតែធ្វើដូច្នេះហើយ នៅតែមានការលំបាកសងបំណុលទៀត។ គាត់និយាយថា ជម្រើសបែបនេះហាក់ដូចជាមិនមានជម្រើសអច្ចឹង ហើយគាត់ចង់ឲ្យអ្នកផ្តល់ហិរញ្ញវត្ថុរបស់គាត់បើកឲ្យមានការពន្យារពេលទូទាត់សង។ តាមការនិយាយតាមទូរសព្ទ ដែលយើងបានសាកសួរបន្ថែមកាលពីខែតុលា ឆ្នាំ២០២០ ការរៀបចំឥណទានឡើងវិញរបស់គាត់ (បង់តែការប្រាក់) បានបន្តសម្រាប់រយៈពេល៦ខែទៀត។[128]

បន្ថែមលើនេះ ស្ត្រីអ្នកលក់វត្ថុអនុស្សាវរីយ៍ម្នាក់ក៏បានសម្តែងទស្សនៈរបស់គាត់ អំពីគោលការណ៍រៀបចំឥណទានឡើងវិញដែលតម្រូវឲ្យបង់តែប្រាក់ការ ដោយគាត់លើកឡើងថា “បុគ្គលិកគេប្រាប់ថាខ្ញុំអាចស្នើសុំតារាងបង់សងថ្មី។ ខ្ញុំអាចជ្រើសរើសបង់សងក្នុងរយៈពេល ៦ខែ ឬ ១២ ខែក៏បាន។ នៅពេលនោះ ខ្ញុំបានរើសយករយៈពេល ៦ខែ ដោយសង្ឃឹមថា អ្នកទេសចរនឹងត្រឡប់មកវិញ ផ្ទុយមកវិញសព្វថ្ងៃនេះអ្នកទេសចរស្ងាត់ជាងមុន ។” គាត់បន្តថា “ខ្ញុំមិនសប្បាយចិត្តចំពោះជម្រើសហ្នឹងទេ ពីព្រោះវាខាត។”[129] អារម្មណ៍*ខាត* ដោយសារការរៀបចំឥណទានឡើងវិញនេះ (ការខាតបង់បណ្តាលមកពីការបង់តែការប្រាក់) ក៏មានលើកឡើងដូចគ្នាដែរក្នុងចំណោមតំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន។ ប្រធានសាខាម្នាក់លើកឡើងថា “អតិថិជនមិនចង់អូសបន្លាយការរៀបចំឥណទានឡើងវិញនេះទេ ពីព្រោះពួកគាត់មានអារម្មណ៍ថា ខាតពេល និងថវិកា។ នៅពេលដែលយើងបន្តផ្តល់គោលការណ៍បែបនេះ អតិថិជនជាច្រើនទោះជាកំពុងលំបាកក៏ដោយ ក៏គាត់នឹងប្រឹងសងតាមធម្មតា ដោយសារវាបានកាត់បន្ថយប្រាក់ដើម។”[130]

អ្នកប៉ះពាល់ខាងផ្នែកសេដ្ឋកិច្ចដោយសារកូវីដ ១៩ ខ្លះៗទៀតបានបដិសេធមិនទទួលយកជម្រើសបង់តែការប្រាក់នេះ ដោយពួកគាត់បានសម្តែងពីការព្រួយបារម្ភប្រហាក់ប្រហែលគ្នា។ ឧទាហរណ៍ កម្មកររោងចក្រផលិតសម្លៀកបំពាក់វ័យ ៣៣ឆ្នាំ ម្នាក់បានកត់សម្គាល់ថា “ខ្ញុំបានស្នើខាងធនាគារឈប់បង់រយៈពេល ៥ខែ។ ប៉ុន្តែគេបានប្រាប់ខ្ញុំថា ក្នុងករណីនោះចំនួនប្រាក់ការនៅតែត្រូវ

[128] Participant ID:32.
[129] Participant ID:119.
[130] FI ID:17.

បង់ទាំងអស់។ ដឹងដូច្នេះហើយ ខ្ញុំរើសយកការបង់តាមធម្មតា។"[131] មន្ត្រីឥណទាននានាបានឲ្យដឹងថា នេះជាអ្វីដែលកូនបំណុលបានលើកឡើងជាទូទៅ។ មន្ត្រីឥណទានម្នាក់បានកត់សម្គាល់ថា "តាមពិត តាមបទពិសោធន៍កាលពីអំឡុងពេលខែមីនា និងមេសា យើងឃើញថាទោះបីជាបុគ្គលទាំងឡាយបានជួបវិបត្តិក៏ដោយ ប៉ុន្តែអ្នកដែលអាចបង់នៅតែបង់ដដែល។ ពីព្រោះពួកគាត់យល់ថា ឲ្យបង់តែប្រាក់ការអច្ចឹង ក៏មិនអាចជួយអ្វីបាននោះទេ។"[132] ចុងបញ្ចប់មានករណីតិចតួចប៉ុណ្ណោះដែលទទួលយកការរៀបចំឥណទានឡើងវិញ ប៉ុន្តែកូនបំណុលទាំងឡាយនៅតែមិនរំពឹងថា អាចបង់បំណុលបាននៅក្នុងរយៈពេលអនុគ្រោះនេះ។ នៅក្នុងករណីទាំងនេះកូនបំណុលបារម្ភថា នឹងត្រូវតែងាកទៅដើរតាមវិធីដែលពួកគាត់មិនចង់បានក្នុងការយកមកទប់បំណុល។ ឧទាហរណ៍ កូនបំណុលម្នាក់ដែលយើងបានសន្ទនាជាមួយ ហើយដែលជាម្ដាយរបស់កម្មករចំណាកស្រុកម្នាក់ បានឲ្យដឹងថា សូម្បីតែបានរយៈពេលអនុគ្រោះ (ឲ្យបង់តែប្រាក់ការ) ក៏ដោយ ក៏គាត់នៅតែខ្លាចបាត់បង់ដីរបស់គាត់ដែរ។ ចំពោះកូនបំណុលមួយចំនួនគ្មានអ្វីក្រៅពីការលើកលែងភ្លាមៗចំពោះឥណទាននោះទេ ទើបអាចគ្រប់គ្រាន់ដើម្បីចៀសវាងពីការប្រើវិធីទាំងនោះ។ តាមយើងដឹង ការលើកលែងចំពោះបំណុលបែបនោះ មិនទាន់មានខាងវិស័យហិរញ្ញវត្ថុពិចារណានៅឡើយទេ ទោះបីជាចំពោះករណីប៉ះពាល់ដោយសារកូវីដ ១៩ មានលក្ខណធ្ងន់ធ្ងរខ្លាំងក៏ដោយ។

## ៥.២. ការចុះផ្សព្វផ្សាយនៅមានកម្រិត

តាមការពិភាក្សារបស់យើងជាមួយនឹងបុគ្គលិកខាងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់បានប្រាប់យើងថា វាគឺជាចេតនា និងជាយុទ្ធសាស្ត្រដែលមន្ត្រីឥណទានទាំងឡាយ មិនផ្ដល់ព័ត៌មានអំពីគោលការណ៍រៀបចំឥណទានឡើងវិញ ជាមួយគ្រប់អតិថជនរបស់ខ្លួន ដោយសារបុគ្គលិកទាំងនោះបារម្ភថា ធ្វើដូច្នេះ នាំឲ្យមាន "គ្រួសារដែលមិនបានប៉ះពាល់" ឆក់ឱកាសប្រើស្ថានភាពនេះ។ ឧទាហរណ៍ ប្រធានសាខាម្នាក់បានឲ្យដឹងថា "ហ៊ឺ យើងមិនប្រកាសជាសាធារណៈ យើងមិនផ្ដល់វាដល់គ្រប់អតិថិជនរបស់យើង ពីព្រោះយើងគិតថា នឹងមានការខូចខាតផលប្រយោជន៍ខ្លះៗបើយើងធ្វើដូច្នេះ។ វានឹងនាំឲ្យអាចនឹងកើតមានករណីដែលថា បុគ្គលខ្លះដែលនៅមានលទ្ធភាពបង់ បែរជាមកសុំរៀបចំឥណទានឡើងវិញដែរ ក្រោយពីបានឃើញកូនបំណុលផ្សេងទៀតបានសុំ។ ពេលមានស្ថានភាពបែបនេះកើតឡើង វានឹងក្លាយទៅជារីករាលដល់កម្រិតមួយដែលយើងមិនអាចគ្រប់គ្រងបាន។ ដូច្នេះ ព័ត៌មានគួរតែផ្ដល់ទៅតែចំពោះអ្នកដែលបានប៉ះពាល់ប៉ុណ្ណោះ។"[133]

អ្វីដែលយើងបានពិភាក្សាជាមួយនឹងបុគ្គលិកគ្រឹះស្ថានហិរញ្ញវត្ថុទាំងឡាយ (N=34) ស៊ីសង្វាក់ទៅនឹងអ្វីដែលយើងបានសម្ភាសជាមួយកូនបំណុលនានា។ ក្នុងចំណោម ៧៤% (n=88 ករណី) ដែលបានដឹងអំពីគោលការណ៍រៀបចំឥណទានឡើងវិញ ប្រហែល ៩១% (n=80 ករណី) នៃកូនបំណុលទាំងនោះ បានដឹងពីគោលការណ៍នេះតាមរយៈការប្រកាសរបស់រដ្ឋាភិបាល ទំនាក់ទំនងផ្ទាល់ខ្លួន ឬបណ្ដាញសង្គមរបស់កូនបំណុលផ្សេងទៀត ឬភាគីទីបី (សូមមើល រូបថត ៧)។ មានតែ ៩% (n=8 ករណី) បានដឹងពីគោលការណ៍នេះពីមន្ត្រីឥណទានរបស់ខ្លួន។

នេះមានន័យថា គ្រឹះស្ថានហិរញ្ញវត្ថុគ្រប់គ្រងដំណើរការរៀបចំឥណទានឡើងវិញ តាមរយៈការកំណត់នរណាខ្លះដែលត្រូវឲ្យដឹងព័ត៌មាន និងអាចដាក់ពាក្យសុំ។ យោងតាមពាក្យពេចន៍របស់បុគ្គលិកខាងគ្រប់គ្រងនៃគ្រឹះស្ថានហិរញ្ញវត្ថុម្នាក់និយាយថា បុគ្គលិកឥណទាន/បុគ្គលិកខាងបំណុល/អ្នកប្រឹក្សាឥណទាន គឺជា "ភ្នាក់ងារនាំមុខផ្ដល់ការគាំទ្រ" តាមរយៈការកំណត់គ្រួសារណាដែលងាយរងគ្រោះជាងគេ ហើយមានចំណូលធ្លាក់ចុះដោយសារកូវីដ ១៩។ ប្រការនេះបានធ្វើឲ្យយើងមានសំណួរសួរថា តើបុគ្គលិកខាងឥណទានទាំងនោះកំណត់បានដោយរបៀបណាថាគ្រួសារទាំងនេះ "បានទទួលការប៉ះពាល់"? ជាញឹកញាប់បំផុត មន្ត្រីឥណទានបានឲ្យដឹងថា ការបង់យឺតយ៉ាវកំណត់បានជាលក្ខណៈវិនិច្ឆ័យមួយជាចម្បង ក្នុងការធ្វើរកឲ្យឃើញថា គ្រួសារណាខ្លះកំពុងរងសម្ពាធ

[131] Participant ID:43.
[132] FI ID:9.
[133] FI ID:14.

ហើយត្រូវការការរៀបចំឥណទានឡើងវិញ។ បុគ្គលិកឥណទានម្នាក់បានពន្យល់ថា៖ “ចំពោះអ្នកមិនមានលទ្ធភាពបង់ ពួកគាត់នឹងត្រូវបង់យឺត។ នៅពេលដែលពួកគាត់បង់យឺត យើងដែលជា ម.ឥ នឹងទៅជួបពួកគាត់ហើយពិនិត្យមើល។ ពួកគាត់នឹងពន្យល់ហេតុផលដល់យើង [ចំពោះការបង់យឺត]។ បន្ទាប់មកទើបយើងអាចប្រាប់ពីដំណោះស្រាយនានា។”[134]

ខណៈដែលតំណាង គ.ម.ហ មួយចំនួនយល់ថា ការដែលមានបុគ្គលិកផ្សេងៗខាងឥណទានមកគ្រប់គ្រងដំណើរការនឹងអាចជួយចៀសវាងការបន្លំពីខាងអ្នកប្រើប្រាស់ (ពោលគឺ អ្នកដែលមិនត្រូវការការរៀបចំឥណទានឡើងវិញ ក៏មកស្នើសុំដែរ) ការដែលមានមន្ត្រីឥណទានមកគ្រប់គ្រងការចាប់ផ្ដើមដំណើរការរៀបចំឥណទានឡើងវិញ ធ្វើឲ្យមានការព្រួយបារម្ភជាច្រើនដោយសារការកំណត់ថានរណាបាន “ប៉ះពាល់” វាមិនមែនជាកិច្ចការងាយយល់នោះទេ។ ក្នុងករណីជាច្រើន មន្ត្រីឥណទានមិនបានដឹងអំពីព័ត៌មានពិស្ដារនៃប្រភពចំណូលរបស់កូនបំណុលនោះឡើយ របៀបដែលប្រភពចំណូលទាំងនោះបានប្រែប្រួលមកទល់ពេលនោះ ឬអ្វីដែលជាតម្រូវការរបស់កូនបំណុល។ លើសពីនេះទៀត កាលណាមន្ត្រីឥណទានគ្រប់គ្រងដំណើរការពាក្យសុំ នោះវានឹងមានហានិភ័យថាការសម្រេចផ្ដល់ការរៀបចំឥណទានឡើងវិញ នឹងត្រូវផ្អែកទៅលើទំនាក់ទំនងផ្ទាល់ខ្លួន ការលម្អៀងជាអត្តនោម័ត្តិ និង/ឬ ផ្នត់គំនិតដែលបានសន្មតិក្នុងចិត្តជាមុនថានរណាសមនឹងទទួលបានការជួយសង្គ្រោះនេះ។

លើសពីនេះទៀត ផ្អែកទៅលើបទពិសោធន៍ទាំងឡាយរបស់កូនបំណុល យើងកំណត់រកឃើញបញ្ហាប្រឈមយ៉ាងហោចណាស់ចំនួនពីរ ក្នុងការប្រើវិធីបែបនេះ។ ទី១ យោងតាមវិធីឆ្លើយតបទៅនឹងការរងសម្ពាធបំណុល ដែលគ្រួសាររងសម្ពាធទាំងឡាយបានប្រើនោះ បានបង្ហាញយ៉ាងច្បាស់ថា ការរង់ចាំរហូតដល់ពេលបង់យឺត យកមកធ្វើជាសញ្ញាប្រាប់ពីការរងសម្ពាធនោះ គឺជារឿយៗបានហួសពេលទៅហើយ។ ការព្រួយបារម្ភរបៀបនេះក៏បានលើកឡើងផងដែរ ដោយតំណាងគ្រឹះស្ថានហិរញ្ញវត្ថុម្នាក់ក្នុងចំណោម ៣៤នាក់ដែលយើងបានសម្ភាស។ មុនពេលមានការបង់ប្រាក់យឺត កូនបំណុលជាច្រើនបានធ្វើការលះបង់ជាច្រើនរួចទៅហើយ ដោយធ្វើតាមវិធីដែលខ្លួនមិនអាចទទួលយកបាន ហើយដែលអាចបង្កើនភាពងាយរងគ្រោះរបស់ខ្លួន។ ការរង់ចាំរហូតដល់ពេលកូនបំណុលនានាបង់យឺតយ៉ាវ មានន័យថា ឱកាសសម្រាប់គាំពារអតិថិជនប្រាកដជាត្រូវបាត់បង់។ ទី២ ការដាក់ភារកិច្ចឲ្យមន្ត្រីឥណទានជាអ្នកទទួលខុសត្រូវបែងចែកថាគ្រួសារណាកំពុងលំបាក ឬសមនឹងទទួលបានការរៀបចំឥណទានឡើងវិញ ព្រមទាំងគ្មានឧបករណ៍ណែនាំត្រឹមត្រូវ ការបណ្ដុះបណ្ដាល និងវិធីសាស្រ្តផ្សេងៗក្នុងការវាយតម្លៃ នោះវាទំនងនឹងនាំឲ្យមានការវាយតម្លៃ ផ្អែកលើការលម្អៀងអត្តនោម័តិ និងមិនបានគ្រប់គ្រាន់។ ការដាក់បន្ទុកទៅលើមន្ត្រីឥណទាន ធ្វើឲ្យបាក់ទឹកចិត្តក្នុងចំណោមកូនបំណុលលែងចង់ចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃការផ្ដល់ឥណទាន ហើយក៏លែងចង់តស៊ូមតិដើម្បីអ្វីដែលខ្លួនត្រូវការទៀតហើយ។ ធ្វើដូច្នេះក៏អាចធ្វើឲ្យបណ្ដាគ្រឹះស្ថានហិរញ្ញវត្ថុយល់ច្រឡំទៅលើករណីផលប័ត្ររបស់កូនបំណុលខ្លួនផងដែរ។

## ៥.៣. គ្រួសារទាំងឡាយដែលបានប៉ះពាល់ ហើយមិនបានទទួលការរៀបចំឥណទានឡើងវិញ

ក្នុងចំណោម ១១ករណី ដែលទទួលការបដិសេធ បានបញ្ជាក់យ៉ាងច្បាស់ថា គោលការណ៍នានាក្នុងការរៀបចំឥណទានឡើងវិញរបស់គ្រឹះស្ថានហិរញ្ញវត្ថុ មិនបានបែងចែកច្បាស់ថា សមាជិក គ្រួសារណាដែលមានឈ្មោះនៅក្នុងពាក្យសុំឥណទាន និងសមាជិក គ្រួសារដែលជាក់ស្ដែងជាអ្នកបង់ប្រាក់សងបំណុល។ ទោះបីជាអ្នកដែលកំពុងបង់ប្រាក់បំណុលបានប៉ះពាល់ធ្ងន់ធ្ងរដោយកូវីដ ១៩ ក៏ដោយ ពាក្យសុំរបស់គេត្រូវបានបដិសេធដោយសារអ្វីដែលគេហៅថា មុខរបរ “កូនបំណុល” បានពាក់ព័ន្ធទៅនឹងសកម្មភាពកសិកម្មដែលបានចាត់ទុកថា មិនសូវប៉ះពាល់ដោយកូវីដ ១៩ទេ ឬដោយសារពួកគាត់រស់នៅក្នុងភូមិសាស្រ្តដែលមិនមានការរៀបចំឥណទានឡើងវិញ។ មានករណី ៣ ក្នុងចំណោមការបដិសេធផ្ដល់ការរៀបចំឥណទានឡើងវិញយកមកបំភ្លឺចំណុចទាំងនេះ។

134 FI ID:9.

*បុរសវ័យ ២៩ឆ្នាំ ជាអ្នករត់ទុកទុក ឈ្មោះ **សុភក្តិ** បានធ្វើចំណាកស្រុកទៅខេត្តសៀមរាបកាលពី២ឆ្នាំមុន។ គាត់មានកូន២នាក់។ **សុភក្តិ** បានសុំឲ្យ ឪពុកម្ដាយរបស់គាត់ខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជំនួយគាត់។ គាត់នៅមានជាប់បំណុលត្រូវបង់ចំនួន ៦.០០០ ដុល្លារសហរដ្ឋអាមេរិកទៀត។ គាត់ត្រូវបង់ប្រហែល២៥០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។ ពីមុននេះបន្តិច តែនៅក្នុងពេលមានកូវីដដែរ គាត់បានទូរសព្ទទៅខាងមន្ត្រីឥណទានរបស់គាត់ សាកសួរពីលទ្ធភាពសុំសងតែការប្រាក់ ហើយគេប្រាប់គាត់ថា ពេលនោះវានៅថ្មីៗពេក ដូច្នេះសាខានោះមិនទាន់មានគោលការណ៍បែបហ្នឹងទេ។ គេឲ្យគាត់ចាំ ហើយទូរសព្ទទៅពេលក្រោយម្ដងទៀត។ នៅក្នុងខែឧសភា ឆ្នាំ២០២០ គាត់បានទូរសព្ទទៅសួរបញ្ជាក់ម្ដងទៀត ពេលនោះគេប្រាប់គាត់ថា គោលការណ៍ហ្នឹងនៅតែមិនទាន់មានដដែលនៅក្នុងតំបន់របស់ឪពុកម្ដាយគាត់។ សាខានោះផ្ដល់យោបល់ថា ឲ្យគាត់បង់ផ្ដាច់ទាំងអស់តែម្ដងទៅ ដើម្បីគេផ្ដល់ឥណទានថ្មីឲ្យគាត់បានសមស្របនឹងលទ្ធភាពគាត់អាចសងបាន។ ករណីគាត់មិនមានប្រាក់បង់ គេនិយាយថា គេអាចរៀបពាក្យសុំឥណទានថ្មីមួយឲ្យគាត់បាន ប៉ុន្តែគាត់ត្រូវបង់សេវាឲ្យគេប្រហែលជាពីរបីរយដុល្លារសហរដ្ឋអាមេរិក សម្រាប់ការជួយរត់ឯកសារ។ គាត់បដិសេធការផ្ដល់ឲ្យនេះ ហើយងាកទៅខ្ចីលុយពីបងប្អូនគាត់វិញដើម្បីយកមកសងបំណុលនេះ។ ក្នុងពេលដែលយើងបានសន្ទនាគ្នានោះ គាត់បានគិតចង់លក់ទុកទុករបស់គាត់បើស្ថានភាពនៅតែបន្តរបៀបនេះ។[135] គាត់បានឲ្យដឹងថា "ខ្ញុំកំពុងចង់លក់ទុកទុករបស់ខ្ញុំហើយ ប៉ុន្តែគ្មាននរណានឹងទិញនោះទេ ទាល់តែខ្ញុំលក់វាតម្លៃថោក។ ខ្ញុំមិនដឹងធ្វើយ៉ាងមិចនោះទេ មានតែទុកវាតាមដំណើរហើយមើលទៅនោះ។"[136] ឧទាហរណ៍នេះរំលេចឲ្យឃើញពីវិធីដែលគ្រឹះស្ថានហិរញ្ញវត្ថុទាំងឡាយបានផ្ដល់អាទិភាពទៅលើការផ្ដល់បុនហិរញ្ញប្បទាន ឬផ្ដល់ឥណទានថែម ជាងការរៀបចំឥណទានឡើងវិញ។*

*ស្ត្រីម្នាក់ឈ្មោះ **មាលា** បានធ្វើចំណាកស្រុកទៅខេត្តសៀមរាប ហើយបានប្រកបអាជីវកម្មលក់វត្ថុអនុស្សាវរីយ៍អស់រយៈពេល៦ឆ្នាំ។ គាត់បានប្រាប់ក្រុមស្រាវជ្រាវរបស់យើងថា តាំងពីខែកុម្ភៈ ចំណូលរបស់គាត់បានធ្លាក់ចុះ៩០%។ ក្នុងពេលយើងធ្វើការសម្ភាស គាត់បានជួលតូបមួយក្នុងតម្លៃ ៣០០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។ គាត់បាននឹងកំពុងលក់ដូរនៅតូបថ្មីនេះបានរយៈពេលមួយខែ។ កាលពីខែមុនគាត់អាចរកប្រាក់គ្រប់បង់ថ្លៃឈ្នួលតូប។ នៅខែនេះគាត់មិនទាន់ច្បាស់នៅឡើយ ដោយសារពីរសប្ដាហ៍កន្លងទៅគាត់លក់មិនដាច់អ្វីទាំងអស់។ ក្រៅពីត្រូវបង់ ៣០០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ ថ្លៃឈ្នួលតូបហើយនោះ គាត់ក៏ត្រូវបង់ ៣៥០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែទៀតទៅខាងគ្រឹះស្ថានហិរញ្ញវត្ថុ។ បំណុលនោះបានយកនៅក្នុងស្រុកដាច់ស្រយាលមួយនៅក្នុងខេត្តមួយផ្សេងទៀត ដោយម្ដាយរបស់គាត់ជួយយកឲ្យ។ ដោយសារគាត់កំពុងលំបាករកប្រាក់ គ្រួសាររបស់គាត់បានស្នើសុំដោយផ្ទាល់មាត់ សងតែការប្រាក់ ប៉ុន្តែ បុគ្គលិកគ្រឹះស្ថានហិរញ្ញវត្ថុបានប្រាប់គ្រួសាររបស់គាត់ថា គេមិនមានគោលការណ៍បែបនោះទេនៅក្នុងស្រុករបស់ម្ដាយឪពុកគាត់។ គ្រឹះស្ថានហិរញ្ញវត្ថុនោះបានអនុញ្ញាតឲ្យគ្រួសារនេះបង់យឺតពី ១០ ទៅ ២០ ថ្ងៃ តែត្រូវយកកម្រៃមួយដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃសម្រាប់ការបង់យឺត។ ដើម្បីបង្គ្រប់សងឲ្យដូចធម្មតា បច្ចុប្បន្នគាត់បានជាប់បំណុលជាមួយម្ចាស់បំណុលឯកជនជាច្រើននាក់។[137]*

---

[135] Participant ID:24.
[136] Participant ID:24.
[137] Participant ID:125.

*ស្ត្រីម្នាក់វ័យប្រហែល ២៥ឆ្នាំ ឈ្មោះ **កញ្ញា** រស់នៅខេត្តសៀមរាប។ គាត់រកចំណូលបានជាមធ្យម ៣៥០ដុល្លារក្នុងមួយខែពីការងារនៅក្នុងក្រុមហ៊ុនសវនកម្មមួយ។ គាត់និងប្អូនៗបីនាក់ជួយបង់សងបំណុលឪពុកម្តាយនៅឯផ្ទះ ដែលស្ថិតនៅតំបន់ដាច់ស្រយាលមួយនៃខេត្តសៀមរាប។ ប្អូនៗរបស់គាត់ធ្វើការនៅសណ្ឋាគារ និងភោជនីយដ្ឋានមួយ។ តាំងពីកូវីដ ១៩ កើតមក ប្អូនៗទាំងបីនាក់បានបាត់បង់ការងារទាំងអស់។ បន្ទុកនេះបានធ្លាក់មកលើគាត់ទាំងអស់ដោយគាត់បាននិយាយថា "ប្រាក់ខែជាមធ្យមរបស់ខ្ញុំ គឺ (... សើច [138].... ) ៣៥០ ដុល្លារសហរដ្ឋអាមេរិក។ ខ្ញុំបង់ទៅខាងគ្រឹះស្ថានហិរញ្ញវត្ថុប្រហែល ៣០០ដុល្លារសហរដ្ឋអាមេរិក។ ថ្លៃឈ្នួលបន្ទប់របស់ខ្ញុំប្រហែល៦០ដុល្លារសហរដ្ឋអាមេរិក។ ដូច្នេះប្រាក់ខែរបស់ខ្ញុំមិនទាំងគ្រប់ផងសម្រាប់បង់ឥណទាន និងថ្លៃបន្ទប់។" កូនស្រីច្បងរូបនេះបានដឹងពីគោលការណ៍រៀបចំឥណទានឡើងវិញ តាមរយៈការប្រកាសរបស់រដ្ឋាភិបាល នៅកន្លែងការងាររបស់គាត់ និងតាមរយៈបណ្តាញសង្គម។ ដើម្បីបន្ធូរបន្ទុករបស់គាត់ គាត់បានឲ្យម្តាយឪពុករបស់គាត់ស្នើទៅខាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសុំបង់តែការប្រាក់មួយរយៈ រហូតដល់ពេលប្អូនៗគាត់មានការងារធ្វើវិញ។ សំណើនេះត្រូវបានបដិសេធ ហើយពីដំបូងគេប្រាប់ឪពុកម្តាយរបស់គាត់ថា គ្រួសារគាត់មិនបំពេញតាមលក្ខខណ្ឌសម្រាប់ទទួលការរៀបចំឥណទានឡើងវិញទេ ដោយសារឪពុកម្តាយរបស់គាត់ជាកសិករ ហើយគោលបំណងដែលបានសរសេរនៅក្នុងខ្ចីឥណទានដាក់ថា យកទៅបើកអាជីវកម្មខ្នាតតូច។ ក្រោយមកទៀតប្រធានសាខានោះប្រាប់ឪពុកម្តាយគាត់ថា មានការលំបាកក្នុងការដំណើរការឯកសារ ដូច្នេះប្រធានសាខារូបនោះក៏ផ្តល់យោបល់ថា ពួកគាត់ត្រូវខ្ចីលុយដើម្បីសងផ្តាច់ទៅខាងគ្រឹះស្ថានហិរញ្ញវត្ថុនោះ។ ពីរបីថ្ងៃក្រោយពីការសងផ្តាច់នេះ សាខានឹងផ្តល់ឥណទានថ្មីឲ្យវិញ ហើយមានកាលវិភាគបង់ថ្មីមួយដែរ ដែលសមស្របទៅនឹងលទ្ធភាពបង់របស់ពួកគាត់។ គ្រួសារនេះមិនចង់ធ្លាក់ចូលទៅក្នុងការរៀបចំដែលមានហានិភ័យខ្ពស់របៀបនេះទេ ហើយក៏បានសម្រេចបង់ធម្មតា។ បន្ទុកនោះក៏បានធ្លាក់លើស្មារបស់ **កញ្ញា**តែម្នាក់ឯង។ ដើម្បីបង់តាមធម្មតាបាន បង់ថ្លៃឈ្នួលបន្ទប់ និងបង់ថ្លៃចំណាយប្រចាំថ្ងៃរបស់គាត់ **កញ្ញា** ត្រូវខ្ចីលុយពីមិត្តភក្តិប៉ុន្មាននាក់ក្នុងនោះមានទាំងប្រធានរបស់គាត់ផង។ ស្ថានភាពសេដ្ឋកិច្ចរបស់គាត់នឹងនៅតែលំបាកតទៅមុខទៀតរហូតទាល់តែប្អូនៗរបស់គាត់រកការងារបានធ្វើវិញ។*[139]

---

[138] សើច នៅត្រង់នេះ ឆ្លុះបញ្ចាំងមានប្រជាជនកម្ពុជាជាច្រើនជាទូទៅទប់ទល់ជាមួយនឹងការលំបាកផ្សេងៗ របៀបនេះ។

[139] Participant ID:6.

ដូចដែលករណីទាំងនេះបានបញ្ជាក់ ឃើញថាកូនបំណុលយ៉ាងហោចក៏មានមួយចំនួនមិនបានទទួលការរៀបចំឥណទានឡើងវិញទេ ទោះបីជាបានប៉ះពាល់ដោយសារកូវីដ ១៩ យ៉ាងច្បាស់ហើយក៏ដោយ។ នៅក្នុងការស្រាវជ្រាវរបស់យើងការមិនបានទទួលនេះ គឺជាបញ្ហាប្រឈមជាពិសេសមួយសម្រាប់បុគ្គលទាំងឡាយនៅក្នុងស្ថានភាពដូចបានរៀបរាប់ខាងលើ៖ អ្នកដែលបានទទួលឥណទានក្នុងរូបភាពជាឥណទានជំនួស ដែលក្នុងនោះជាចម្បងឥណទានបានប្រើ និងបង់ដោយបុគ្គលម្នាក់ បែរជាដាក់ផ្លូវការក្នុងឈ្មោះបុគ្គលម្នាក់ទៀត។ ឥណទានជំនួសមានអនុវត្តទូទៅច្រើនទូទាំងប្រទេសកម្ពុជា ហើយសូម្បីតែក្នុងករណីឥណទានមិនមែនជំនួសក៏ដោយ (ពោលគឺកូនបំណុលជាអ្នកប្រើ និងក៏ជាអ្នករំពឹងត្រូវសងបំណុល) ក៏បំណុលជាច្រើនបានបង់មកវិញដោយបានប្រាក់មកពីចំណូលច្រើនមុខ មកពីសមាជិកជាច្រើននៃគ្រួសារ។

ខណៈដែលឥណទានជំនួសអាចមានច្រើនរូបភាព តាមទិន្នន័យរបស់យើងវិញបានបង្ហាញថា រូបភាពមួយដែលទូទៅជាងគេនោះ គឺម្ដាយឪពុកបានយកឥណទានជំនួសមុខឲ្យកូនៗដែលមានអាយុពេញវ័យ។ ការអនុវត្តបែបនេះពាក់ព័ន្ធទៅហ្នឹងបែបបទផ្សេងៗនៃកម្មសិទ្ធិដីធ្លីតាមផ្លូវការ។ ដោយសារមីក្រូឥណទានបានកំពុងងាកទៅយកដីធ្លីជាទ្រព្យធានា ឪពុកម្ដាយត្រូវតែយកឥណទានជំនួសមុខឲ្យកូនៗដែលពេញវ័យរបស់គាត់ ពីព្រោះវិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដី ជារឿយៗបានដាក់ឈ្មោះ ឪពុកម្ដាយ ហើយមិនបានដាក់ឈ្មោះកូនៗពេញវ័យរបស់គាត់នោះទេ។ នៅក្នុងករណីខាងលើនេះ ឥណទានជាក់ស្ដែងគឺបានដាក់ឈ្មោះឪពុកម្ដាយដែលភាគច្រើនប្រកបរបរកសិកម្ម ខណៈដែលមុខរបរក្រៅពីកសិកម្មដែលកូនៗប្រកបនោះ បានប្រើយកមកបង់បំណុលជាក់ស្ដែងនោះទៅវិញ។ អាស្រ័យហេតុនេះ ចរិតលក្ខណៈដែលឥណទាននោះបានចុះឈ្មោះ បានប្រើប្រាស់ និងបានបង់សងវិញអាចមើលទៅឃើញផ្សេងនៅលើក្រដាស ហើយវាផ្ទុយពីការពិតនៅក្នុងការអនុវត្ត។ បណ្ដាបុគ្គលិកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាទូទៅបានដឹងយ៉ាងច្បាស់អំពីលក្ខណៈខុសគ្នាបែបនេះ ទោះបីជាលក្ខណៈទាំងនេះមិនបានកត់ត្រាទុកក្នុងឯកសារក៏ដោយ។

ការស្រាវជ្រាវនេះបានរកឃើញនូវកូនបំណុលជំនួសជាច្រើន បានទទួលការរៀបចំឥណទានឡើងវិញ ប៉ុន្តែការយកឥណទានជំនួសក្លាយជាបញ្ហាប្រឈម ក្នុងករណីដែលការរៀបចំឥណទានឡើងវិញនេះមានលក្ខខណ្ឌតម្រូវទៅតាមវិស័យនៃមុខរបរ ភូមិសាស្ត្រ និងចរិតលក្ខណៈរបស់កូនបំណុល ពីព្រោះថា អ្នកដែលខ្ចីជារឿយៗ មិនទទួលខុសត្រូវក្នុងការបង់សងបំណុលនោះទេ។ ឧទាហរណ៍ នៅក្នុងករណីរបស់ **កញ្ញា** ទោះជាប្រាក់ចំណូលរបស់សមាជិកដែលជួយគ្នាសងបំណុលគាត់ កំពុងតែប៉ះពាល់ធ្ងន់ដោយជំងឺកូវីដក៏ដោយ សំណើរបស់ឪពុកម្ដាយគាត់ត្រូវបានបដិសេធដោយសំអាងលើអង្គហេតុថា មុខរបររបស់ម្ដាយឪពុកគាត់មិនបានប៉ះពាល់នោះទេ។ ស្រដៀងគ្នានេះដែរ នៅក្នុងករណីរបស់ **មាលា** ការរៀបចំឥណទានឡើងវិញមិនមានទេនៅក្នុងស្រុកដែលម្ដាយឪពុកគាត់រស់នៅ។ ប្រហែលជាដោយសារគ្រឹះស្ថានហិរញ្ញវត្ថុទាំងឡាយយល់ថា មានកូនបំណុលតិចតួចប៉ុណ្ណោះដែលបានប៉ះពាល់ក្នុងវិស័យសំខាន់ៗ។ ប៉ុន្តែ **មាលា** ដែលរស់នៅខេត្តសៀមរាប ហើយដែលបានប៉ះពាល់យ៉ាងធ្ងន់ដោយសារកូវីដ គឺជាអ្នកដែលត្រូវបង់ប្រាក់ធំជាងគេក្នុងការសងបំណុល។ ក្នុងករណីទាំងឡាយដែលមានលក្ខណៈដូចគ្នានេះ តម្រូវការរបស់កូនបំណុលគឺមិនបានបំពេញលក្ខខណ្ឌតាមការអនុវត្តរបស់គ្រឹះស្ថានហិរញ្ញវត្ថុ។ ករណីជាច្រើនដែលជួបការបដិសេធមិនបានរៀបចំឥណទានឡើងវិញនោះ គឺរូបភាពផ្សេងៗនៃឥណទានជំនួសនេះឯង។

ក្នុងករណីជាច្រើនដែលគ្រឹះស្ថានបានបដិសេធរៀបចំឥណទានឡើងវិញ ដែលយើងបានដឹង ជាញឹកញាប់កូនបំណុលនានាទទួលយកការបដិសេធនេះភ្លាមៗតែម្ដង ហើយមិនបានព្យាយាមចរចាពន្យល់ ឬស្នើអ្វីផ្សេងៗទៀតនោះទេ។ ផ្ទុយមកវិញ អ្នកដែល

យើងបានសន្ទនាជាមួយ ជាញឹកញាប់បំផុតនោះគឺបានលើកឡើងថា បានទូរសព្ទទៅខាងមន្ត្រីឥណទានរបស់ខ្លួន ឬអ្នកប្រឹក្សាឥណទានដើម្បីសាកសួរលទ្ធភាពដែលមានការរៀបចំឥណទានឡើងវិញ។ ករណីដែលគេប្រាប់ពួកគាត់ថា ពួកគាត់មិនបានបំពេញគ្រប់លក្ខខណ្ឌ ឬថាគោលការណ៍នោះមិនមាននៅតំបន់របស់ពួកគាត់ ឬតំបន់របស់ឪពុកម្ដាយពួកគាត់ ពួកគាត់កម្រនឹងសួរនាំបន្ថែម សួរទៅខាងលើបន្តទៀត ឬក៏ចរចាថែមទៀតនោះទេ។ ប្រការនេះបង្ហាញឲ្យឃើញពីលក្ខណៈសំខាន់នៃការប្រើអំណាចបានច្រើនយ៉ាងក្នុងការអនុវត្តជាក់ស្ដែងនៃទំនាក់ទំនងរវាងម្ចាស់ និងកូនបំណុល។ តាមពិតយើងបានជួបប្រទះតែពីរករណីដែលមានកូនបំណុលបានតស៊ូមតិក្នុងករណីរបស់ពួកគាត់ ដោយបានព្យាយាមចរចាជាមួយបណ្ដាគ្រឹះស្ថានហិរញ្ញវត្ថុ។ នៅទំព័រនេះយើងសូមចែករំលែកករណីនេះ (ដែលមិនមែនជាករណីទូទៅទេនៅក្នុងទិន្នន័យរបស់យើង៖ ស្ត្រីម្នាក់ឈ្មោះ **កនិកា**[140] ជាម្ចាស់កម្មសិទ្ធិហាងលក់ខោអាវមួយកន្លែង ហើយគាត់ពណ៌នាអំពីសាច់រឿងរបស់បងស្រីគាត់ ដែលបានរៀបការជាមួយគ្រូបង្រៀនម្នាក់។ ប្ដីប្រពន្ធនេះបានខ្ចីប្រាក់ពីធនាគារមួយដើម្បីយកមកបើកសាលារៀន និងមណ្ឌលថែទាំកុមារមួយកន្លែង។ ដោយសារសាលាគ្រួសារនេះបានបិទ គ្រួសារនេះកំពុងជួបការលំបាកក្នុងការបង់សងធនាគារ។ ពួកគាត់បានចរចាជាមួយធនាគារសុំមិនបង់ ៣ខែ គឺខែមីនា មេសា និងឧសភា ក្រោយពីនោះមកពួកគាត់បានចរចាជាមួយធនាគារសុំបង់តែប្រាក់ដើមរហូតដល់ពេលសាលាពួកគាត់បើកទ្វារវិញ ទើបពួកគាត់បង់ការប្រាក់សរុបនៅពេលដែលពួកគាត់អាចមានលទ្ធភាពបង់បាន។

នៅក្នុងករណីមួយផ្សេងទៀត ស្ត្រីម្នាក់ឈ្មោះ **សារ៉ន** ជាកម្មករចំណាកស្រុកប្រចាំរដូវ និងប្រចាំថ្ងៃ មិនទទួលបានលទ្ធផលដែលគាត់ចង់បាននោះទេ បន្ទាប់ពីគាត់បានចរចាជាមួយគ្រឹះស្ថានហិរញ្ញវត្ថុរួច។ គ្រួសារនេះទទួលការឧបត្ថម្ភជាសាច់ប្រាក់មកពីរដ្ឋាភិបាលតាមរយៈកម្មវិធីផ្ដល់សាច់ប្រាក់មិនអចិន្ត្រៃយ៍។ នៅក្នុងពេលដែលយើងសន្ទនាជាមួយ គ្រួសារនោះបានជាប់បំណុលគ្រឹះស្ថានហិរញ្ញវត្ថុចំនួនពីរ។ មានគ្រឹះស្ថានមួយបានអនុញ្ញាតឲ្យរៀបចំឥណទានឡើងវិញ ឲ្យបង់តែប្រាក់ការសម្រាប់រយៈពេល ៦ ខែ។ ចាប់តាំងពីកូវីដ ១៩ បានកើតមក គ្រួសារនេះអាចបង់បំណុលប្រចាំខែបានដោយសារប្រាក់ដែលពួកគាត់ទទួលបានពីរដ្ឋាភិបាល។ ដោយភ័យខ្លាចថា ព្រំដែននឹងអាចបន្តបិទយូរថែមទៀត គ្រួសារនេះបានទូរសព្ទទៅខាងប្រធានសាខាចំនួនពីរបីលើកដើម្បីសុំបន្តការរៀបចំឥណទានឡើងវិញរបស់ពួកគាត់។ ប៉ុន្តែនៅក្នុងពេលដែលយើងធ្វើការសម្ភាស សំណើនោះត្រូវបានគេធ្វើការបដិសេធ។ គាត់និយាយដោយសើចផងថា "ប្រសិនបើគេ [អ្នកផ្ដល់សេវាហិរញ្ញវត្ថុនានា] មិនពន្យាទេ [ឲ្យបង់តែការប្រាក់] ឲ្យខ្ញុំទេ យើងនឹងត្រូវតែធ្វើចំណាកស្រុក 'ខុសច្បាប់' ឬខ្ញុំត្រូវ លក់ដីហើយមើលទៅនោះ។"[141]

ករណីទាំងពីរនេះរំលេចឲ្យឃើញថា ទោះបីជាក្នុងករណីដែលកូនបំណុលទាំងឡាយមានប្រវត្តិបង្ហាញការបង់ប្រាក់បានទៀងទាត់ ហើយមានស្ថានភាពសេដ្ឋកិច្ចធ្លាក់ចុះពិតប្រាកដក៏ដោយ ក៏ការចរចាទាំងឡាយជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានា មិនប្រាកដថាបានជោគជ័យរហូតនោះទេ។ ភាពជោគជ័យក្នុងការចរចាក៏ពឹងផ្អែកផងដែរទៅលើធនធានសង្គម និងឥទ្ធិពលនយោបាយដែលកូនបំណុលមាន។ ទោះជាយ៉ាងណាក៏ដោយកាលណាគ្រួសារទាំងឡាយបានតស៊ូមតិដោយប្រសិទ្ធភាពដោយខ្លួនឯង ហើយទំនាក់ទំនងឲ្យគ្រឹះស្ថានហិរញ្ញវត្ថុបានយល់ពីតម្រូវការរបស់ខ្លួន នោះវានឹងបង្កើនការយល់ដឹងរបស់វិស័យនោះចំពោះស្ថានភាពកូនបំណុល ហើយអាចនាំឲ្យទទួលបានលទ្ធផលកាន់តែប្រសើរ។ ជាអកុសលករណីឧទាហរណ៍ចុងក្រោយនេះក៏បានបង្ហាញផងដែរថា កូនបំណុលទាំងឡាយដែលមិនបានទទួលការជួយសង្គ្រោះដល់បំណុលតាមជាក់ស្ដែងទេនោះ នឹងមានហានិភ័យដោយភាពងាយរងគ្រោះនឹងកើនឡើងហើយនឹងទទួលផលវិបាកដែលពួកគាត់មិនចង់បាន។

[140] Participant ID:131.
[141] Participant ID:65.

## ៥.៤. ផលវិបាកនៃការរៀបចំឥណទានឡើងវិញទៅលើប្រវត្តិឥណទាន មិនទាន់កំណត់បានច្បាស់លាស់

មិនមានការបញ្ជាក់ច្បាស់លាស់នៅឡើយទេថា ការរៀបចំឥណទានឡើងវិញនោះនឹងប៉ះពាល់ដល់អតិថិជនមីក្រូហិរញ្ញវត្ថុដូចម្តេចពាក់ព័ន្ធនឹងប្រវត្តិឥណទាន និងលទ្ធភាពដែលគាត់អាចទទួលបានឥណទានបាននៅពេលអនាគត។ តំណាងបុគ្គលិកនានាផ្នែកគ្រប់គ្រងជាន់ខ្ពស់ និងប្រធានប្រតិបត្តិនៃ គ.ម.ហ បានបញ្ជាក់យ៉ាងច្បាស់ប្រាប់ក្រុមស្រាវជ្រាវយើងថា ការរៀបចំឥណទានឡើងវិញនឹងមិនប៉ះពាល់ចំពោះពិន្ទុឥណទានរបស់អតិថិជននោះទេ ក៏ប៉ុន្តែ តាមការពិភាក្សារបស់យើងជាមួយមន្ត្រីឥណទានបែរជាបានចោទជាសំណួរ ថាតើប្រការមិនប៉ះពាល់នេះ ពិតជាបានផ្សព្វផ្សាយបញ្ជ្រាបពេញទូទាំងវិស័យទាំងមូលមែនដែរឬទេ។

នៅក្នុងចំណោមតំណាងនានានៃគ្រឹះស្ថានហិរញ្ញវត្ថុដែលយើងបានសន្ទនាជាមួយ ប្រហែលចំនួនពាក់កណ្តាលបានឲ្យដឹងថាពួកគាត់មិនបានដឹង បើមិនដូច្នោះទេ ក៏ដឹងមិនច្បាស់អំពីថាតើការរៀបចំឥណទានឡើងវិញត្រូវប៉ះពាល់ដូចម្តេចខ្លះដល់ប្រវត្តិអតិថិជន ហើយក្រៅពីនេះក៏មានអ្នកដឹងប្រាកដថា ការរៀបចំឥណទានឡើងវិញពិតជាប៉ះពាល់ដោយអវិជ្ជមានដល់ប្រវត្តិឥណទានរបស់អតិថិជន។ សេចក្តីដកស្រង់ទាំង៤ខាងក្រោមនេះបានមកពីបុគ្គលិកគ្រឹះស្ថានហិរញ្ញវត្ថុចំនួន៣ផ្សេងគ្នា បង្ហាញនូវការយល់ឃើញខុសគ្នាឆ្ងាយអំពីលក្ខណៈដែលការរៀបចំឥណទានឡើងវិញប៉ះពាល់ដល់ប្រវត្តិឥណទានរបស់អតិថិជន។

> *"វានឹងមិនប៉ះពាល់ដល់ពិន្ទុឥណទានពួកគាត់ទេ។ វាគ្រាន់តែមានការចំណាំទុកដោយសរសេរថា ឈ្មោះណាមួយបានបាត់បង់ប្រាក់ចំណូល [ក្នុងពេលកូវីដ ១៩] ប៉ុន្តែចំណារនេះនឹងមិនប៉ះពាល់ដល់ពិន្ទុឥណទានពួកគាត់ទេ។ តាមពិតការរៀបចំឥណទានឡើងវិញនេះជួយដល់ពួកគាត់ទៅវិញទេ។ កាលណាពួកគាត់មិនមានលទ្ធភាពបង់ ហើយពួកគាត់មិនបានដាក់ពាក្យសុំឲ្យមានរៀបចំឥណទានឡើងវិញ នោះឥណទានពួកគាត់នឹងរងការប៉ះពាល់។"* [142]

> *"សម្រាប់សាខាខ្ញុំ បើខ្ញុំផ្អែកមើលការិយាល័យឥណទានកម្ពុជា ហើយឃើញថាពួកគាត់ [អ្នកដាក់ពាក្យសុំឥណទាន] កំពុងមានរៀបចំឥណទានឡើងវិញ [ជាមួយគ្រឹះស្ថានផ្សេងៗទៀត] នេះមានន័យថា ពួកគាត់មិនមានលទ្ធភាពបង់ទេ ដូច្នេះខ្ញុំក៏មិនផ្តល់ឥណទានដល់ពួកគាត់ដែរ ។"* [143]

> *"នៅក្នុងប្រព័ន្ធរបស់ការិយាល័យឥណទានកម្ពុជា វានឹងបង្ហាញនូវបច្ចុប្បន្នភាព ដូចជាផលប័ត្រមានហានិភ័យ PAR 30, PAR 60 និង PAR 90 បានរៀបចំរចនាសម្ព័ន្ធឥណទានឡើងវិញរួចហើយ ... ប៉ុន្តែខ្ញុំមិនទាន់ច្បាស់ថាវានឹងប៉ះពាល់ដល់ប្រវត្តិឥណទានរបស់កូនបំណុលទាំងឡាយដោយរបៀបណានោះទេ។ ខ្ញុំមិនច្បាស់ពីបញ្ហានេះទេ។"* [144]

> *"អ៊ី ជាក់ស្តែងយើងពិតជាមិនឲ្យយោបល់ពួកគាត់ឲ្យរៀបចំឥណទានឡើងវិញនោះទេ ពីព្រោះវានឹងអាចប៉ះពាល់ដល់ប្រវត្តិឥណទានរបស់ពួកគាត់។ ដូច្នេះក្នុងករណីភាគច្រើន យើងតែងតែលើកទឹកចិត្តឲ្យពួកគាត់យកប្រាក់បន្ថែមលើឥណទានចាស់។"* [145]

ភាពមិនច្បាស់លាស់ថាតើការរៀបចំឥណទានឡើងវិញនឹងមានផលប៉ះពាល់ឬយ៉ាងណា ទៅលើពិន្ទុឥណទាន ឬលទ្ធភាពខ្ចីប្រាក់នាពេលអនាគត បានបង្កការលំបាកដល់បណ្តាកូនបំណុល ក្នុងការសម្រេចចិត្តដែលឈរលើព័ត៌មានគ្រប់គ្រាន់ ថាតើត្រូវរើសយកដាក់ពាក្យសុំ ត្រូវទទួលយក ឬក៏ត្រូវចៀសវាងការរៀបចំឥណទានឡើងវិញ។ នៅក្នុងករណីខ្លះកូនបំណុលម្នាក់ដែលជាក់ស្តែងត្រូវការរៀបចំឥណទានឡើងវិញ បែរជាត្រូវបាត់បង់ឱកាសនេះទៅវិញ ដោយសារពួកគាត់ព្រួយបារម្ភអំពីផលប៉ះពាល់ទៅដល់លទ្ធភាពនាអនាគតក្នុងការទទួលបានឥណទានថ្មី។ ផ្ទុយមកវិញ លទ្ធភាពមួយដែលអាចទៅរួចដែរគឺថា កូនបំណុលខ្លះប្រហែលជាមានជាប់ចំណុចមិនល្អ ដែលបានកត់ទុកក្នុងប្រវត្តិឥណទានទាំងដែលពួកគាត់មិនបានដឹង ដោយសារតែទាំងការិយាល័យឥណទានកម្ពុជា និងទាំងគ្រឹះស្ថានហិរញ្ញវត្ថុមិនបានកំណត់កន្លងមកនូវគោលការណ៍ច្បាស់លាស់ស្តីអំពីចរិត្តលក្ខណៈដែលការរៀបចំឥណទានឡើងវិញនឹងប៉ះពាល់ដល់ការផ្តល់ឥណទាននាពេលអនាគត នេះធ្វើឲ្យមានការខ្វែងយោបល់គ្នា និងភាពមិនច្បាស់លាស់ ក្នុងចំណោមទាំងបុគ្គលិកគ្រឹះស្ថានហិរញ្ញវត្ថុ និងខាងទាំងកូនបំណុល។

[142] FI ID:30.
[143] FI ID:34.
[144] FI ID:14.
[145] FI ID:13.

# V. វិធីឆ្លើយតបដែលភាគីផ្សេងៗអាចយកទៅអនុវត្តបាន

របាយការណ៍នេះបានកំណត់រកឃើញបញ្ហារចនាសម្ព័ន្ធមួយចំនួន ក្នុងក្របខណ្ឌសំណាកដែលយើងបានសម្ភាសទាំងអស់ ប៉ុន្តែក៏បញ្ជាក់ថា អាចមានបញ្ហាដូចគ្នា ឬប្លែកគ្នាច្រើនជាងនេះទៀត។ ដូច្នេះកត្តាទាំងនេះតម្រូវឲ្យមានកិច្ចសហការគ្នាក្នុងចំណោមភាគីទាំងអស់ ដើម្បីធានាឲ្យបាននូវកិច្ចគាំពារអតិថិជនក្នុងពេលមានវិបត្តិនេះ។ ខាងក្រោមនេះ ពណ៌នាយ៉ាងពិស្តារអំពីមតិយោបល់សម្រាប់ឲ្យភាគី ធ្វើដូចម្តេចទើបអាចចូលរួមបានក្នុងការងើបឡើងវិញនៃសេដ្ឋកិច្ច ជួយកូនបំណុលដែលរងសម្ពាធ ឲ្យចៀសផុតពីអន្លង់នៃបំណុលវ័ណ្ឌក ព្រមទាំងការពារដល់គ្រួសារទាំងឡាយដែលងាយរងគ្រោះ។ អនុសាសន៍ទាំងនេះផ្អែកទៅលើគោលការណ៍ស្តីពីកិច្ចគាំពារអតិថិជន ដែលកំណត់រកឃើញដោយ យុទ្ធនាការរបស់ស្មាត ហើយបានគាំទ្រដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាក៏ដូចជាគោលការណ៍ទូទៅស្តីពីអ្នកផ្តល់សេវាហិរញ្ញវត្ថុ (អេហ្វអេសភី/FSP) របស់ក្រុមប្រឹក្សាយោបល់សម្រាប់ជួយជនក្រីក្រ( ស៊ីជីអេភី/CGAP) ក្នុងការឆ្លើយតបនឹងវិបត្តិកូវីដ ១៩។ ដោយសារគោលការណ៍នេះពាក់ព័ន្ធជាក់លាក់ទៅនឹងបរិបទកូវីដ ១៩ នៅ ទំព័រនេះយើងយកចិត្តទុកដាក់ជាពិសេសលើគោលការណ៍ដែលបាននែនាំដោយ ស៊ីជីអេភី/CGAP។

ជាក់លាក់តែម្តង គឺមានគោលការណ៍ទូទៅចំនួន ៥ ដែលបានពណ៌នាដោយ (ស៊ីជីអេភី) ថាជាមធ្យោបាយសំខាន់ក្នុងកិច្ចគាំអតិថិជននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុក្នុងពេលកូវីដ ១៩ ដែលការស្រាវជ្រាវរបស់យើងយល់ថា ត្រូវយកចិត្តទុកដាក់បន្ថែមទៀតនៅក្នុងបរិបទកម្ពុជាៈ ១) ដាក់តម្រូវការរបស់អតិថិជនដែលមានចំណូលទាបជាអាទិភាព និងជាចំណុចកណ្តាលដែលត្រូវយកចិត្តទុកដាក់ ២) ទំនាក់ទំនងដោយមានផែនការនិងដោយសកម្ម ៣) តាមដានទីផ្សារតាមរយៈទិន្នន័យបណ្តឹងតវ៉ា បណ្តាញសង្គម និងការធ្វើជំរឿនផ្ទាល់ ៤) ផ្តល់ការសង្គ្រោះបែបទូលាយ និងលក្ខណៈងាយស្រួល ៥) ធានាថា អតិថិជនទាំងឡាយដែលបានផ្អាក ឬបានរៀបចំកាលវិភាគបង់ប្រាក់ឡើងវិញដោយសារជំងឺរាតត្បាត មិនមានការពិន័យនៅក្នុងរបាយការណ៍ឥណទាន។[146] អនុសាសន៍របស់យើងផ្តោតទៅលើការអនុវត្តល្អៗទាំងនេះ។ អនុសាសន៍មួយចំនួនរបស់យើងអាចនឹងបានកំពុងអនុវត្តរួចហើយ ដោយសារយើងរំពឹងថា ភាគីទាំងឡាយនៅក្នុងវិស័យនេះ ក៏បានជ្រួតជ្រាបផងដែរ ព្រមទាំងបានចាប់អារម្មណ៍ក្នុងការអនុវត្តតាមប្រការល្អៗទាំងនេះ។

## *ចំពោះភាគីខាងវិស័យហិរញ្ញវត្ថុ*

គោលការណ៍ថ្មីៗស្តីពីការរៀបចំឥណទានឡើងវិញបានផ្តល់លទ្ធភាពឲ្យគ្រឹះស្ថានហិរញ្ញវត្ថុនានា អាចឆ្លើយតបបានឆាប់រហ័សទៅនឹងគ្រួសារដែលបានប៉ះពាល់ដោយជំងឺកូវីដ នៅទូទាំងប្រទេស។ ដោយសារគោលការណ៍នេះទើបតែបានដាក់ចេញថ្មី ការខ្វះចន្លោះរវាងគោលនយោបាយ និងការអនុវត្តជាក់ស្តែង តែងតែមានចៀសមិនផុត។ ការស្រាវជ្រាវក្នុងក្របខណ្ឌនៃការសិក្សានេះ បានបង្ហាញឲ្យឃើញនូវចំណុចខ្វះខាតជាគន្លឹះជាច្រើន ដែលគ្រឹះស្ថានហិរញ្ញវត្ថុទាំងឡាយ គួរយកទៅបំពេញដើម្បីកែលម្អគោលនយោបាយនាពេលអនាគត។

**ទីមួយ ជម្រើសទាំងអស់នៃការរៀបចំឥណទានឡើងវិញ គួរតែត្រូវផ្តល់ជូនទៅដល់គ្រប់គ្រួសារទាំងអស់ដែលរងការប៉ះពាល់។** ខណៈដែលគោលការណ៍នេះមាននៅលើក្រដាស នាបច្ចុប្បន្នការអនុវត្តជាក់ស្តែងមិនទាន់បានគ្រប់ជ្រុងនៅឡើយទេ។ វាជាកត្តាសំខាន់បផុតដែលអ្នកគ្រប់គ្រងនានានៃគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវធានាឲ្យបានថា បុគ្គលិកដែលចុះធ្វើការតាមមូលដ្ឋានបង្ហាញ

[146] Rhyne et al 2020.

យន្តការនេះដល់គ្រប់គ្រួសារទាំងអស់ដែលបានប៉ះពាល់ដោយវិបត្តិកូវីដ ១៩ ហើយធានាថា គោលនការណ៍នានាពិតជាត្រូវបានអនុវត្តដោយល្អិតល្អន់ ដោយរលូន និងដោយយុត្តិធម៌។ កាលណាគ្រួសារដែលប៉ះពាល់ដែលត្រូវការរៀបចំឥណទានឡើងវិញ បែរជាមិនមានឱកាសទទួលបានការរៀបចំឥណទានឡើងវិញ នោះវានាំឲ្យមានការប្រើវិធីសាស្ត្រទប់ទល់ ដូចជាការធ្វើចំណាកស្រុកទាន់ហាន់ ការកាត់បន្ថយចំណាយប្រចាំថ្ងៃ ដកកូនៗចេញពីសាលា (ឬកូនៗសម្រេចឈប់រៀនដោយខ្លួនឯង) ព្រមទាំងការលក់ទ្រព្យសកម្ម មានទាំងដីធ្លីជាដើម។ នេះជាកត្តាសំខាន់ខ្លាំងណាស់ ដែលគ្រួសារទាំងអស់ដែលត្រូវការការគាំពារ ទទួលបានការគាំពារដោយស្វ័យប្រវត្តិចំពោះរាល់សំណើ ដោយមិនគិតពីថាតើមុខរបររបស់ពួកគាត់បានប៉ះពាល់ដោយផ្ទាល់ដោយវិបត្តិនេះ ឬយ៉ាងណានោះទេ។ យន្តការឆ្លើយតបនេះរាប់បញ្ចូលផងដែរទាំងការផ្តល់ការរៀបចំឥណទានឡើងវិញទៅដល់បណ្តាគ្រួសារ ដែលប្រាក់បង់សងបានមកពីបុគ្គលដែលប៉ះពាល់ ទោះបីជាមុខរបររបស់អ្នកខ្ចីនោះមិនបានប៉ះពាល់ផ្ទាល់ក៏ដោយ (ពោលគឺ កូនបំណុលដែលខ្ចីជំនួសគេ)។ ការរៀបចំឥណទានឡើងវិញគឺជាធាតុសំខាន់នៃកិច្ចគាំពារអតិថិជននៅក្នុងដំណាក់កាលដែលមានវិបត្តិ។ ជាការពិតណាស់ យើងយល់ថាការរៀបចំឥណទានឡើងវិញ គួរតែបើកឲ្យមានចំពោះបណ្តាគ្រួសារដែលរងសម្ពាធទោះបីជាក្រោយពេលវិបត្តិកូវីដ ១៩ បានចប់ហើយក៏ដោយ។ នាបច្ចុប្បន្ន មានការលើកទឹកចិត្តតិចតួចណាស់ក្នុងការធានាឲ្យបានថា បណ្តាគ្រឹះស្ថានហិរញ្ញវត្ថុនឹងមិនផ្តល់ឥណទានណាដែលអាចបណ្តាលឲ្យឈានទៅរកបំណុលដែលងាយរងសម្ពាធ។ ការដាក់លក្ខខណ្ឌជាប្រព័ន្ធតម្រូវឲ្យអ្នកផ្តល់ឥណទាននានាបើកឲ្យមានការរៀបចំឥណទានឡើងវិញ ក្នុងករណីដែលកូនបំណុលជួបប្រទះការការលំបាកដែលបណ្តាលមកពីកត្តាខាងក្រៅ គឺអាចនឹងលើកទឹកចិត្តដល់ភាគីទាំងឡាយក្នុងវិស័យហិរញ្ញវត្ថុ ក្នុងការផ្តល់ឥណទានដែលប្រកបដោយការទទួលខុសត្រូវខ្ពស់។

**ទីពីរ ការរៀបចំឥណទានឡើងវិញនាពេលអនាគត គួរតែផ្តល់ឱកាសឲ្យទាំងមន្ត្រីឥណទាន និងទាំងកូនបំណុលចូលរួមក្នុងដំណើរនៃគោលការណ៍នេះ។** គោលការណ៍នេះនឹងត្រូវតែតម្រូវឲ្យបុគ្គលិក ដែលចុះធ្វើការត្រូវតែពន្យល់ផ្ទាល់មាត់ដល់គ្រួសារកូនបំណុលនូវបណ្តាយន្តការដែលមានស្រាប់ ដើម្បីឲ្យគ្រួសារទាំងឡាយយកទៅសម្រេចដោះស្រាយសម្ពាធបំណុលរបស់ពួកគាត់។ ព័ត៌មានអំពីយន្តការទាំងនេះគួរតែផ្តល់ឲ្យតាំងពីពេលដែលដាក់ពាក្យសុំឥណទានមកម្លេះ និង/ ឬ ដោយភាគីទាំងឡាយក្នុងវិស័យហិរញ្ញវត្ថុ រដ្ឋាភិបាល និងភាគីផ្សេងៗទៀតដែលពាក់ព័ន្ធ គួរផ្សព្វផ្សាយយន្តការទាំងនេះឲ្យបានទូលំទូលាយផងដែរ។ ការផ្លាស់ប្តូរទម្រង់គោលការណ៍ឥណទានឡើងវិញ ពីបុគ្គលិកឥណទានជាអ្នកផ្តើមដឹកនាំ ទៅឲ្យមានកូនបំណុលជាអ្នកផ្តើមដឹកនាំផងដែរ ការធ្វើបែបនេះយើងសង្ឃឹមថា យើងនឹងអាចកំណត់បានឆាប់រហ័សនូវបណ្តាហានិភ័យទាំងឡាយដែលកូនបំណុលជួបប្រទះ ហើយអាចជួយឲ្យពួកគាត់ចៀសវាងការប្រើវិធីសាស្ត្រទប់ទល់ដែលបង្កើនភាពងាយរងគ្រោះដល់កូនបំណុល។

**ទីបី ពង្រឹងយន្តការទាំងឡាយដែលអនុញ្ញាតឲ្យកូនបំណុលអាចចូលរួមប្រើបណ្តឹងតវ៉ា ក៏មានសារៈសំខាន់ខ្លាំងផងដែរ។** ប្រកាសលេខ ធ៧.០១៧.២៩៩ ប្រ.ក.[147] ដើរតួនាទីជាសេចក្តីណែនាំឲ្យគ្រឹះស្ថានហិរញ្ញវត្ថុបង្កើតឡើងនូវយន្តការនានាសម្រាប់អតិថិជនប្តឹងតវ៉ា។ យោងតាមប្រកាសនេះ ដំបូងអ្នកប្រើប្រាស់ត្រូវដាក់ពាក្យបណ្តឹងទៅអ្នកផ្តល់សេវាហិរញ្ញវត្ថុរបស់ពួកគាត់។ ហើយប្រសិនបើអ្នកប្រើប្រាស់មិនពេញចិត្តនឹងការសម្រេចរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុរបស់ខ្លួន ទើបពួកគាត់ 'អាច' ស្នើសុំអន្តរាគមន៍ពី ធ.ជ.ក។ លើសពីនេះទៀត ធ.ជ.ក បានដាក់ឲ្យដំណើរការនូវប្រព័ន្ធឆ្លើយតបភ្លាមៗតាមទូរសព្ទ ចំពោះបណ្តឹង និងដំណោះស្រាយទូទាំងប្រទេស ហើយមានប្រព័ន្ធ ៥ខ្សែ នៅទីស្នាក់ការកណ្តាល ធ.ជ.ក នៅរាជធានីភ្នំពេញ និង២១ខ្សែ នៅតាមសាខាតាមខេត្ត។ មកទល់ពេលនេះក្រុមការងារប្រព័ន្ធឆ្លើយតបឆាប់រហ័សនេះបានទទួលបណ្តឹងតវ៉ាចំនួន ៧២០ករណី។[148] ការស្រាវជ្រាវនេះមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីយល់បានយន្តការបណ្តឹងតវ៉ានៃបណ្តាគ្រឹះស្ថានហិរញ្ញវត្ថុ និងប្រព័ន្ធឆ្លើយតបឆាប់រហ័សនៃ ធ.ជ.ក នេះបានដំណើរការដូចម្តេចនៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយក្នុងចំណោមគ្រួសាររងសម្ពាធបំណុលដែលស្ថិតនៅក្នុងក្របខណ្ឌនៃ

[147] ប្រកាស លេខ ធ៧.០១៧.២៩៩ ប្រក ស្តីពីការដោះស្រាយបណ្តឹងអតិថិជន ចេញដោយ ធជក ឆ្នាំ២០១៧។
[148] NBC 2020.

ការស្រាវជ្រាវនេះ គ្មាននរណាម្នាក់លើកឡើងថា បានដឹងពីយន្តការបណ្តឹងតវ៉ានៃបណ្តាគ្រឹះស្ថានហិរញ្ញវត្ថុ ឬពីប្រព័ន្ធឆ្លើយតបឆាប់រហ័សនៃ ធ.ជ.ក ទេ។ បណ្តាគ្រឹះស្ថានហិរញ្ញវត្ថុអាចចូលរួមក្នុងការពង្រឹងយន្តការបណ្តឹងតវ៉ាបាន តាមរយៈការផ្សព្វផ្សាយយន្តការបណ្តឹងតវ៉ារបស់ខ្លួនឯង ព្រមទាំងប្រព័ន្ធឆ្លើយតបឆាប់រហ័សចំពោះបណ្តឹងតវ៉ារបស់ ធ.ជ.ក ឲ្យបានជ្រួតជ្រាបដល់អតិថិជនទាំងឡាយរបស់ខ្លួន ឲ្យបានឆាប់ គឺតាំងតែពីពេលអតិថិជនដាក់ពាក្យសុំឥណទានមកម្លេះ។ សកម្មភាពបែបនេះ អាចចូលរួមកែលម្អការបើកឱកាសឲ្យមានការប្រើប្រាស់យន្តការបណ្តឹងតវ៉ាសម្រាប់គ្រួសារជាប់បំណុល។ ឱកាសក្នុងការប្រើប្រាស់យន្តការបណ្តឹងតវ៉ា នឹងផ្តល់លទ្ធភាពឲ្យគ្រួសារជាប់បំណុល អាចរាយការណ៍បាននូវទង្វើអយុត្តិធម៌របស់បណ្តាគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ។ ជាលទ្ធផល វានឹងចូលរួមក្នុងការកសាងវប្បធម៌នៃការទទួលខុសត្រូវ។

**ទីបួន បណ្តាគ្រឹះស្ថានហិរញ្ញវត្ថុ និង ធ.ជ.ក គួរតែផ្សព្វផ្សាយឲ្យបានច្បាស់ថា ការរៀបចំឥណទានឡើងវិញនឹងមិនប៉ះពាល់ដល់ប្រវត្តិឥណទាន ឬលទ្ធភាពនៃការទទួលឥណទាននាពេលអនាគតនោះទេ។** ខាងតំណាងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនបានប្រាប់យើងថា មានការប្រឹងប្រែងច្រើនក្នុងការធានាថា ការរៀបចំឥណទានឡើងវិញ នឹងមិនប៉ះពាល់ដល់ពិន្ទុឥណទានរបស់អតិថិជននោះទេ ហើយក៏មិនប៉ះពាល់ដល់លទ្ធភាពទទួលឥណទាននាពេលអនាគតដែរ។ ព័ត៌មានបែបនេះ គួរតែផ្សព្វផ្សាយទៅដល់ទាំងបុគ្គលិកមូលដ្ឋាន និងទាំងកូនបំណុលក្នុងលក្ខណៈជាគោលការណ៍តែមួយ ដែលគាំទ្រដោយ ធ.ជ.ក។

**ចុងក្រោយ អង្គភាពឯករាជ្យមួយគួរត្រូវបង្កើតឡើង ដើម្បីអនុវត្តន៍ និងវាយតម្លៃ ទៅលើចំណេះដឹងហិរញ្ញវត្ថុ។** ថវិកាក្នុងការគាំទ្រកម្មវិធីចំណេះដឹងហិរញ្ញវត្ថុ គួរតែបានចូលរួមភាគច្រើនមកពីបណ្តាគ្រឹះស្ថានហិរញ្ញវត្ថុ ផ្អែកលើការទទួលខុសត្រូវសង្គមរបស់ខ្លួន (សូមមើលបន្ថែមត្រង់កម្មវិធីសិក្សាដែលយើងបានផ្តល់អនុសាសន៍នៅផ្នែក ‘ភាគីដៃគូអភិវឌ្ឍន៍‘)។

## *ចំពោះក្រសួង និងអង្គភាពពាក់ព័ន្ធនានា នៃរាជរដ្ឋាភិបាលកម្ពុជា៖*

**ទីមួយ ភាគីទាំងឡាយនៃរាជរដ្ឋាភិបាល គួរពិចារណាដាក់ គោលការណ៍ស្តីពីកិច្ចគាំពារអតិថិជន (គ.ក.អ) បច្ចុប្បន្នឲ្យក្លាយទៅជាច្បាប់ ហើយដាក់ឲ្យមានពិន័យចំពោះគ្រឹះស្ថានទាំងឡាយណាដែលមិនអនុវត្តតាម គ.ក.អ។** មកទល់បច្ចុប្បន្ននេះ ស.ម.ហ.ក និងធ.ជ.ក បានអនុវត្ត និងតាមដានយ៉ាងសកម្មនូវ គ.ក.អ ទោះជាយ៉ាងណាក៏ដោយ គ.ក.អ គឺមិនចងកាតព្វកិច្ចផ្លូវច្បាប់ ហើយការអនុវត្តត្រូវគ្រប់គ្រងដោយខ្លួនឯង។ បុគ្គលទាំងឡាយដែលនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុបានបង្ហាញថា របៀបគ្រប់គ្រងខ្លួនឯងនេះស្តែងឲ្យឃើញថា ពុំមានប្រសិទ្ធភាពទេក្នុងការការពារកូនបំណុល[149] ហើយអាចនឹងបណ្តាលឲ្យមានវិបត្តិផ្សេងៗក្នុងវិស័យឥណទាន។[150] នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ ធ.ជ.ក បានដាក់គោលដៅពង្រីកបទដ្ឋានគតិយុត្ត ដោយចង់ពង្រីកគោលការណ៍ស្តីពីកិច្ចគាំពារអតិថិជនទៅក្នុងបទប្បញ្ញត្តិដែលមានស្រាប់។[151] នៅចុងឆ្នាំ២០១៩ រដ្ឋាភិបាលកម្ពុជាបានអនុម័ត និងប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពី កិច្ចគាំពារអតិថិជន លេខ នស/រកម/១១១៩/០១៦។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់នេះមិនមានវិសាលភាពលើសេវាហិរញ្ញវត្ថុពាក់ព័ន្ធនឹងអ្នកផ្តល់សេវាមិនមែនជាធនាគារ។ ចំណុច ១៤ នៃមាត្រា ៤ ចែងថា “សេវា មានន័យថា សិទ្ធិទាំងឡាយណា អត្ថប្រយោជន៍ អាទិភាព ការជួយសម្រួល ឬផ្តល់ឲ្យក្រោមប្រភេទកិច្ចសន្យាដូចតទៅ លើកលែងតែសេវាហិរញ្ញវត្ថុដែលមិនមែនជារបស់ធនាគារ។” អាស្រ័យហេតុនេះ របាយការណ៍នេះ សូមលើកទឹកចិត្តដល់រដ្ឋាភិបាលឲ្យរកវិធីផ្សេងៗ ដើម្បីដាក់ គ.ក.អ ទៅជាលក្ខខណ្ឌមួយតម្រូវឲ្យបំពេញដោយបណ្តាអ្នកផ្តល់សេវាហិរញ្ញវត្ថុទាំងអស់។ គួរត្រូវមានសេចក្តីណែនាំឲ្យបានច្បាស់ផងដែរ ស្តីពី គ.ក.អ ថាតើត្រូវអនុវត្តដូចម្តេចខ្លះ។ បន្ថែមទៅលើលក្ខខណ្ឌរបស់

[149] Rozas 2020.

[150] សូមមើល Afonso, Forcella, and Guérin 2016.

[151] NBC 2016.

គ.ក.អ គោលការណ៍នេះគួរតែផ្តល់ផងដែរដល់កូនបំណុល នូវសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដែលតម្រូវឲ្យប្តឹងទៅតុលាការចំពោះអ្នកផ្តល់សេវាហិរញ្ញវត្ថុទាំងឡាយណាដែលបានប្រព្រឹត្តិខុសច្បាប់ដោយមិនគិតថា អ្នកផ្តល់សេវានោះស្ថិតក្នុងស្ថានភាពផ្លូវការ ឬក្រៅផ្លូវការនោះទេ។

**ទីពីរ ធ.ជ.ក អាចពិចារណាបង្កើតមណ្ឌលទិន្នន័យស្តីអំពីការផ្តល់ឥណទាននៅតាមមូលដ្ឋាន ដែលបើកឲ្យសាធារណជនប្រើប្រាស់បាន ដើម្បីជួយកូនបំណុលសម្រេចយកមួយណាក្នុងចំណោមអ្នកផ្តល់សេវាហិរញ្ញវត្ថុទាំងឡាយ។** នេះគឺជាយន្តការមួយពីរបៀបអនុវត្តគោលការណ៍ស្តីពីកិច្ចគាំពារអតិថិជន ពោលគឺរបៀបដែលមានលក្ខណៈតម្លាភាព។ ឧទាហរណ៍ ធ.ជ.ក អាចគាំទ្រឲ្យមានប្រព័ន្ធអនឡាញជាភាសាខ្មែរ និងអង់គ្លេសដោយដាក់ចូលបញ្ជីគ្រឹះស្ថានហិរញ្ញវត្ថុទាំងឡាយ ដែលបានចុះនៅ ធ.ជ.ក។ ការរាយការណ៍ទៅមណ្ឌលទិន្នន័យនេះត្រូវដាក់ជាកាតព្វកិច្ចជាកំហិត ហើយព័ត៌មានអាចរាប់បញ្ចូលទាំងទិន្នន័យដូចជា អត្រាការប្រាក់ជាមធ្យម និងកម្រិតឡើងចុះនៃអត្រាការប្រាក់ កម្រិតមធ្យម ឬកម្រិតឡើងចុះនៃការយកកម្រៃសេវា និងលក្ខខណ្ឌនៃឥណទាន និងការប្តេជ្ញាចិត្តដែលបានសរសេរពាក់ព័ន្ធនឹងគោលការណ៍ស្តីពីកិច្ចគាំពារអតិថិជន។ ព័ត៌មាននេះអាចប្រើប្រាស់បានដោយសាធារណជន។ ប្រការនេះអាចបង្កើនការអនុវត្តដោយតម្លាភាពនៅក្នុងវិស័យហិរញ្ញវត្ថុ ហើយកូនបំណុលអាចជ្រើសរើសយកអ្នកផ្តល់សេវាហិរញ្ញវត្ថុណាដែលសមស្របនឹងតម្រូវការរបស់ខ្លួន។ មណ្ឌលទិន្នន័យនេះអាចពង្រឹងសិទ្ធិរបស់អ្នកប្រើប្រាស់តាមរយៈការដឹង និងការវាយតម្លៃក្នុងចំណោមអ្នកផ្តល់សេវាទាំងឡាយ។ ប្រព័ន្ធនេះក៏ផ្តល់ផងដែរ ដល់អ្នកផ្តល់សេវាហិរញ្ញវត្ថុតូចៗនូវឱកាសអាចផ្សព្វផ្សាយជាសាធារណៈនូវឈ្មោះរបស់ពួកគេ។

**ចុងបញ្ចប់ អង្គភាពពាក់ព័ន្ធគួរពិចារណាបង្កើតច្បាប់ស្តីពី ក្ស័យធនជាបុគ្គល ដែលអាចសង្គ្រោះបំណុលករណីធ្ងន់ធ្ងរជាពិសេសចំពោះគ្រួសារមានប្រាក់ចំណូលទាប។** ច្បាប់ស្តីពីក្ស័យធនជាបុគ្គលដែលច្បាស់លាស់ ហើយអាចប្រើប្រាស់បាន អាចធ្វើឲ្យមានការអនុវត្តកិច្ចគាំពារអតិថិជនបានល្អ ពីព្រោះវាមិនលើកទឹកចិត្តដល់ការផ្តល់ឥណទានណាដែលមានហានិភ័យខ្ពស់។ ជាជំហានដំបូង ដោយសំអាងលើច្បាប់ស្តីពីក្ស័យធនឆ្នាំ២០០៧ រដ្ឋាភិបាលអាចចេញសេចក្តីណែនាំបែងចែកឲ្យបានច្បាស់ការអនុវត្តច្បាប់ក្ស័យធនចំពោះធុរកិច្ច និងច្បាប់ក្ស័យធនជាបុគ្គល ចំពោះបុគ្គលទាំងឡាយ។ ទីពីរ ដំណើរការទាំងនោះត្រូវសម្រួល ហើយផ្សព្វផ្សាយឲ្យបានទូលំទូលាយថែមទៀត ជាពិសេស ទៅដល់គ្រួសារដែលងាយរងគ្រោះ។ នាបច្ចុប្បន្ន ច្បាប់ស្តីពីក្ស័យធនដែលមានស្រាប់មិនសូវមានសាធារណជនអាចប្រើប្រាស់បានទេ ដោយសារវាមានលក្ខណៈស្មុគស្មាញ ខ្វះខាត និងមាននីតិវិធីមិនប្រាកដប្រជា។[152]

## *ចំពោះដៃគូអភិវឌ្ឍន៍៖*

នៅក្នុងកម្រិតម៉ាក្រូ របាយការណ៍ទាំងឡាយដែលបានធ្វើពីមុនមក បានអំពាវនាវ ឲ្យដៃគូអភិវឌ្ឍន៍ ដែលប្រតិបត្តិការជាម្ចាស់ភាគហ៊ុនមីក្រូហិរញ្ញវត្ថុ ឬជាអ្នកផ្តល់ថវិកាដែរនោះ ឲ្យពង្រឹងកិច្ចគាំពារអតិថិជន តាមរយៈការដាក់លក្ខខណ្ឌឲ្យបំពេញពេលស្នើសុំឥណទាន ឬតាមដានការវិនិយោគជាក់ស្តែង តាមរយៈមធ្យោបាយឯករាជ្យមិនពាក់ព័ន្ធនឹងគ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះ។[153] អ្នកខាងក្រៅឧទាហរណ៍ អង្គការឃ្លាំមើលសិទ្ធិមនុស្ស សំអាងលើគោលការណ៍ណែនាំស្តីអំពីធុរកិច្ច និងសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងក្របខណ្ឌចិរភាពនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានអំពាវនាវឲ្យសាជីវកម្មនេះ ដែលស្ថិតនៅក្នុងក្រុមធនាគារពិភពលោកឲ្យដាក់សម្ពាធទៅលើដៃគូរបស់ខ្លួនឲ្យអនុលោមតាមក្របខណ្ឌខាងលើ ដោយដាក់ដំឡើង “ប្រព័ន្ធដែលពិនិត្យបានម៉ត់ចត់ចំពោះ

[152] Ly Tayseng 2020.
[153] សូមមើល LICHADO 2019; CGAP 2020.

តម្លាភាព ការទទួលខុសត្រូវ និងផ្តល់ដំណោះស្រាយដល់ផលវិបាក ដែលគម្រោងអាចនឹងបង្កឡើង។"[154] លើសពីការអំពាវនាវឲ្យធ្វើសកម្មភាពខាងលើនេះ របាយការណ៍នេះនឹងផ្តល់យោបល់ផ្តោតទៅលើកម្រិតមីក្រូ។ នៅប្រទេសកម្ពុជា បណ្តាដៃគូអភិវឌ្ឍន៍បានធ្វើការរួចហើយដោយផ្ទាល់ជាមួយនឹងកូនបំណុលមីក្រូហិរញ្ញវត្ថុនៅក្នុងរូបភាពជាច្រើន ហើយអាចនឹងបានចូលរួមការពារកូនបំណុលតាមរយៈកម្មវិធីគោលដៅ។

**ទីមួយ ដៃគូអភិវឌ្ឍន៍គួរផ្តល់ថវិកាដល់គម្រោងចំណេះដឹងហិរញ្ញវត្ថុដែលមានលក្ខណៈនវានុវត្តន៍ ហើយដែលផ្តល់ចំណេះដឹងបានលើសពីចំណេះដឹងហិរញ្ញវត្ថុតាមទម្លាប់ ព្រមទាំងទទួលស្គាល់តម្រូវការឲ្យមានការអប់រំផ្តោតដោយផ្ទាល់ទៅលើកិច្ចគាំពារអតិថិជន។** ការស្រាវជ្រាវកន្លងមកបានបង្ហាញថា ការខ្វះខាតចំណេះដឹងហិរញ្ញវត្ថុ "ដែលបានឲ្យនិយមន័យជាទូទៅ" មិនបានបង្កើនហានិភ័យនៃការជំពាក់បំណុលវ័ណ្ឌកនោះទេ[155] ប៉ុន្តែវាក៏ជាក់ច្បាស់ណាស់ថា អតិថិជននៃមីក្រូហិរញ្ញវត្ថុ នឹងទទួលបានប្រយោជន៍ពីការអប់រំហិរញ្ញវត្ថុ ដែលផ្តោតទៅលើកូនបំណុល ដើម្បីជួយពួកគាត់ឲ្យយល់ផលិតផល និងសេវាដែលមានច្រើនប្រភេទ ហើយពង្រីកកាន់តែធំក្នុងគ្រឹះស្ថានហិរញ្ញវត្ថុ។ ការអប់រំហិរញ្ញវត្ថុប្រភេទនោះអាចផ្តោតទៅលើជំនាញនានា ដូចជាការចៀសផុតពីបំណុលការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវរបស់គ្រឹះស្ថានហិរញ្ញវត្ថុ (រួមមានទាំង គ.ក.អ) ជំនាញចរចាជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ និងសិទ្ធិរបស់កូនបំណុល។ វាជាកត្តាសំខាន់បំផុត ដែលកម្មវិធីទាំងនេះត្រូវធ្វើឡើងដោយភាគីមកពីក្រៅវិស័យហិរញ្ញវត្ថុ ដោយសារកម្មវិធីចំណេះដឹងហិរញ្ញវត្ថុ ដែលដាក់ចេញដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានបង្ហាញរួចហើយថា បានយកការបណ្តុះបណ្តាលទាំងនេះទៅសម្រេចគោលដៅខ្លួនឯងនៅក្នុងលក្ខណៈមិនប្រាកដថា បានបម្រើប្រយោជន៍ឲ្យកូនបំណុលនោះទេ។[156]

**ជាការជួយបំពេញដល់មណ្ឌលទិន្នន័យនោះ ដៃគូអភិវឌ្ឍន៍ អាចបង្កើតវេទិកាឯករាជមួយ ដែលផ្តល់ឱកាសឲ្យអ្នកប្រើប្រាស់ឥណទានឆ្លើយឆ្លងយោបល់ដែលអ្នកប្រើប្រាស់អាចចែករំលែកបទពិសោធន៍របស់ខ្លួន ជាមួយនឹងអ្នកផ្តល់សេវាហិរញ្ញវត្ថុ។** លទ្ធភាពមួយដែលយើងផ្តល់អនុសាសន៍នោះគឺ ត្រូវមានប្រព័ន្ធទិន្នន័យតាមបច្ចេកវិទ្យាព័ត៌មានមួយជាភាសាខ្មែរ។ ប្រព័ន្ធបែបនេះគួរមានប្រព័ន្ធត្រួតពិនិត្យផ្សេងៗធានាឲ្យបានគុណភាព និងភាពអាចទុកចិត្តបាននៃមតិឆ្លើយឆ្លង និងការចែករំលែកបទពិសោធន៍របស់អតិថិជន។ អ្នកបង្កើតវេទិកាសាធារណៈជាលក្ខណអនឡាញបែបនេះ ត្រូវគិតថាតើត្រូវលើកទឹកចិត្តដល់អ្នកប្រើប្រាស់ដោយរបៀបណា ដោយដឹងថាប្រជាជនកម្ពុជាមួយចំនួននូវមិនទាន់ចេះប្រើបច្ចេកវិទ្យាព័ត៌មាននៅឡើយទេ។ កត្តានេះមានសក្តានុពលដើរតួជាយន្តការមួយក្នុងការសម្រេចឲ្យបានតម្លាភាព និងការទទួលខុសត្រូវ។

---

[154] Human Rights Watch 2020.

[155] របាយការណ៍ថ្មីៗស្តីពីការជំពាក់វ័ណ្ឌក បានរកឃើញថា កូនបំណុលដែលចេះដឹងខាងហិរញ្ញវត្ថុ តាមជាក់ស្តែងមានលទ្ធភាពកាន់តែខ្ពស់មិនបានបង់សងឥណទានទាន់ពេល មានន័យថាចំណេះដឹងខាងហិរញ្ញវត្ថុមិនបានជួយការពារចៀសផុតពីការរងសម្ពាធបំណុលនោះទេ (MFC and Good Return 2017)។ ការសិក្សាផ្សេងៗទៀតនៅក្នុងតំបន់បានរកឃើញនូវចំណុចខ្វែងគ្នាប្រហាក់ប្រហែលនេះដែរ (Frolich et al 2015; ILO 2015)។ លើសពីនេះទៀត ការវិភាគបែបវិទ្យាសាស្ត្រទ្រង់ទ្រាយធំមួយចំនួន បង្ហាញថា ឥរិយាបទនៃបំណុលមិនទាក់ទងនឹងការអប់រំផ្នែកហិរញ្ញវត្ថុទេ (Kaiser and Menkhoff 2017; Miller et al 2014).

[156] សូមមើល Bylander and Res 2020.

# ឧបសម្ព័ន្ធ១. បញ្ជីអ្នកចូលរួមផ្តល់ព័ត៌មាន

| លេខសម្គាល់អ្នកចូលរួមផ្តល់ព័ត៌មាន | ភេទ | អាយុ | មុខរបរ | ចំនួនកម្ចី (ដុល្លារសហរដ្ឋអាមេរិក) | ទំនាក់ទំនងទៅនឹងកូនបំណុល | ការរៀបចំឥណទានឡើងវិញ |
|---|---|---|---|---|---|---|
| ១ | ស្រី | ៦៦ | កសិករដាំស្រូវ | ១៥.០០០ | ជំនួស | ចាស |
| ២ | ស្រី | ២២ | ចុងភៅ | ២.៥០០ | ផ្ទាល់ខ្លួន | មិនបានដឹង |
| ៣ | ស្រី | ៤៨ | មេផ្ទះ | មិនបានបញ្ជាក់[157] | បង/ប្អូនស្រី | មិនបានដឹង |
| ១២ | ប្រុស | ៤១ | អ្នករត់ទុកទុក | ១.៦០០ | ផ្ទាល់ខ្លួន | បាទ |
| ១៣ | ប្រុស | ២៩ | អ្នករត់ទុកទុក | ៥.០០០ | ផ្ទាល់ខ្លួន | បាទ |
| ១៦ | ប្រុស | ៣៤ | មគ្គុទ្ទេសទេសចរណ៍ | ៣.០០០ | ផ្ទាល់ខ្លួន | បាន -សងតែការប្រាក់ |
| ២០ | ស្រី | ៣១ | កម្មករចំណាកស្រុកតាមផ្លូវការ | ៣.៧៥០ | ផ្ទាល់ខ្លួន | មិនមាន |
| ២១ | ស្រី | ៤០ | កសិករដាំស្រូវ | ៤.០០០ | ផ្ទាល់ខ្លួន | នៅអាចបង់ប្រាក់បាន |
| ២៤ | | | | | | |
| ២៥ | ប្រុស | ៣០ | អ្នករត់ទុកទុក | ៦.០០០ | ផ្ទាល់ខ្លួន | គ្រឹះស្ថានហិរញ្ញវត្ថុបដិសេធ |
| ២៧ | ស្រី | ២២ | ជំនួយការគ្រូបង្រៀន | មិនបានបញ្ជាក់ | មិនមាន | មិនមាន |
| ២៦ | ប្រុស | ២៥ | មគ្គុទ្ទេសទេសចរណ៍ | ៧.៥០០ | សហកូនបំណុល | បដិសេធ គ្រឹះស្ថានហិរញ្ញវត្ថុ |
| ២៨ | ស្រី | ២១ | ជំនួយការផ្នែកលក់ | ៣០.០០០ | សហកូនបំណុល | នៅអាចបង់ប្រាក់បាន |
| ៣៥ | ស្រី | ៤០ | អ្នកលក់ម្ហូបអាហារ | ២.៤០០ | ផ្ទាល់ខ្លួន | បដិសេធ គ្រឹះស្ថានហិរញ្ញវត្ថុ |
| ៤៣ | ស្រី | ៣៣ | កម្មកររោងចក្រ | ២.០០០ | ផ្ទាល់ខ្លួន | បដិសេធ គ្រឹះស្ថានហិរញ្ញវត្ថុ |
| ៤៤ | ស្រី | ១៨ | កម្មកររោងចក្រផលិតសម្លៀកបំពាក់ | ២០.០០០ | កូនស្រី | មិនបានដឹង |
| ៤៥ | ស្រី | ៤៧ | កម្មកររោងចក្រផលិតស្បែកជើង | ២.០០០ | ផ្ទាល់ខ្លួន | មិនបានស្នើសុំ |
| ៤៦ | ស្រី | ២៥ | កម្មកររោងចក្រផលិតកាបូប | ២.០០០ | ផ្ទាល់ខ្លួន | មិនបានស្នើសុំ |
| ៤៧ | ស្រី | ២៧ | កម្មកររោងចក្រផលិតសម្លៀកបំពាក់ដែលត្រូវបញ្ឈប់ពីការងារ | ១.០០០ (គ្មាន) | ផ្ទាល់ខ្លួន | មិនមាន |
| ៥០ | ស្រី | ១៩ | កម្មកររោងចក្រផលិតសម្លៀកបំពាក់ | ៤.០០០ | កូនស្រី | គ្រឹះស្ថានហិរញ្ញវត្ថុបដិសេធ |
| ៥៤ | ស្រី | ២៨ | កម្មកររោងចក្រផលិតកាបូប | ១.៥០០ | ផ្ទាល់ខ្លួន | មិនបានដឹង |
| ៥៩ | ស្រី | ២១ | កម្មកររោងចក្រផលិតកាបូប | ១០.០០០ | កូនស្រី | ចាស |
| ៦២ | ប្រុស និងស្រី | ២២/២៤ | កសិករជាម្ចាស់កម្មសិទ្ធិដីធ្លីដែលធ្វើយកប្រាក់ឈ្នួល | ២១.២៥០ | ផ្ទាល់ខ្លួន | នៅអាចបង់ប្រាក់បាន |
| ៦៣ | ប្រុស | មិនបានបញ្ជាក់ | កសិករជាម្ចាស់ដី | ២០.០០០ | ផ្ទាល់ខ្លួន | នៅអាចបង់ប្រាក់បាន |
| ៦៤ | ប្រុស និងស្រី | ៣១/៣៥ | កសិករជាម្ចាស់កម្មសិទ្ធិដីធ្លីដែលធ្វើយកប្រាក់ឈ្នួល | ៥.០០០ | ផ្ទាល់ខ្លួន | មិនមាន |

[157] ND = Not Identify

| លេខសម្គាល់អ្នកចូលរួមផ្តល់ព័ត៌មាន | ភេទ | អាយុ | មុខរបរ | ចំនួនកម្ចី (ដុល្លារសហរដ្ឋអាមេរិក) | ទំនាក់ទំនងទៅនឹងកូនបំណុល | ការរៀបចំឥណទានឡើងវិញ |
|---|---|---|---|---|---|---|
| ៦៥ | ស្រី | ៤០ | កម្មករចំណាកស្រុកតាមរដូវ | ១.០០០ | ផ្ទាល់ខ្លួន | នៅអាចបង់ប្រាក់បាន |
| ៦៦ | ស្រី | ២៨ | កម្មករចំណាកស្រុកតាមរដូវ | ៦២៥ | ផ្ទាល់ខ្លួន | នៅអាចបង់ប្រាក់បាន |
| ៦៧ | ប្រុស | ៥៩ | កម្មករចំណាកស្រុកតាមរដូវ | ៧៥០ | ផ្ទាល់ខ្លួន | បាទ |
| ៦៨ | ប្រុស និងស្រី | ៥៧/៦៤ | កសិករធ្វើការយកប្រាក់ឈ្នួល | ៣.១២៥ | ផ្ទាល់ខ្លួន | មិនមាន |
| ៦៩ | ស្រី | ៤៥ | កម្មករចំណាកស្រុកតាមរដូវ | ៥.០០០ | ផ្ទាល់ខ្លួន | ចាស-សងតែការប្រាក់ |
| ៧២ | ស្រី | ៣៧ | កសិករជាម្ចាស់កម្មសិទ្ធិដីធ្លី ដែលធ្វើយកប្រាក់ឈ្នួល | ៦.២៥០ | ផ្ទាល់ខ្លួន | មិនបានទទួលការប៉ះពាល់[158] |
| ៧៧ | ប្រុស | មិនបានបញ្ជាក់ | កសិករម្ចាស់ដី | មិនបានបញ្ជាក់ | ផ្ទាល់ខ្លួន | មិនបានដឹង |
| ៨០ | ស្រី | ៣២ | កម្មកររោងចក្រផលិតសម្លៀកបំពាក់ ដែលត្រូវបញ្ឈប់ពីការងារ | ៣.០០០ | ផ្ទាល់ខ្លួន | កម្ចីថ្មី |
| ៨៤ | ស្រី | ៣១ | អតីតកសិករធ្វើការយកប្រាក់ឈ្នួល | ៤.៥០០ | ផ្ទាល់ខ្លួន | មិនបានដឹង |
| ៩៤ | ស្រី | មិនបានបញ្ជាក់ | កសិករដាំស្រូវ | ៥.០០០ | ផ្ទាល់ខ្លួន | មិនបានស្នើសុំ |
| ៩៦ | ស្រី | ២៥ | កម្មករចំណាកស្រុក | ២០.០០០ | ផ្ទាល់ខ្លួន | គ្រឹះស្ថានហិរញ្ញវត្ថុបដិសេធ |
| ៩៨ | ប្រុស និងស្រី | មិនបានបញ្ជាក់ | កសិករដាំស្រូវ | ៥.០០០ | ផ្ទាល់ខ្លួន | មិនមាន |
| ៩៩ | ប្រុស | ៦៣ | កសិករដាំស្រូវ | ២.៥០០ | ផ្ទាល់ខ្លួន | នៅអាចបង់ប្រាក់បាន |
| ១០១ | ស្រី | ៦១ | កសិករដាំស្រូវ | ៧.០០០ | ចំណាកស្រុក | នៅអាចបង់ប្រាក់បាន |
| ១០២ | ស្រី | ២៧ | កម្មករសំណង់ | ៥.០០០ | ផ្ទាល់ខ្លួន | មិនមាន |
| ១០៣ | ស្រី | ៦១ | កសិករដាំស្រូវ | ១.០០០ | ផ្ទាល់ខ្លួន | នៅអាចបង់ប្រាក់បាន |
| ១០៤ | ស្រី | ៥៥ | កសិករដាំស្រូវ | ៦.០០០ | ផ្ទាល់ខ្លួន | មិនមាន |
| ១០៦ | ប្រុស | ៦៥ | កសិករដាំស្រូវ | ២.៥០០ | ផ្ទាល់ខ្លួន | នៅអាចបង់ប្រាក់បាន |
| ១០៧ | ស្រី | ៤១ | ម្ចាស់ហាងលក់គ្រឿងទេស | ៧.៥០០ | ផ្ទាល់ខ្លួន | មិនមាន |
| ១១៦ | ស្រី | ៤០ | អ្នកលក់វត្ថុអនុស្សាវរីយ៍ | ៩.០០០ | ផ្ទាល់ខ្លួន | មិនបានស្នើសុំ |
| ១១៧ | ស្រី | ៥០ | អ្នកលក់វត្ថុអនុស្សាវរីយ៍ | ៧៥០ | ផ្ទាល់ខ្លួន | ចាស |
| ១១៨ | ស្រី | ៣០ | អ្នកលក់វត្ថុអនុស្សាវរីយ៍ | ៥.០០០ | ផ្ទាល់ខ្លួន | ចាស |
| ១១៩ | ស្រី | មិនបានបញ្ជាក់ | អ្នកលក់វត្ថុអនុស្សាវរីយ៍ | ៨.០០០ | ផ្ទាល់ខ្លួន | ចាស |
| ១២១ | ស្រី | មិនបានបញ្ជាក់ | អ្នកលក់វត្ថុអនុស្សាវរីយ៍ | មិនបានបញ្ជាក់ | ផ្ទាល់ខ្លួន | ចាស |
| ១៣០ | ស្រី | ២២ | អ្នកបម្រើសេវាកម្ម | មិនមែនកូនបំណុល | មិនមាន | មិនមាន |
| ១៣១ | ស្រី | ជិត៣០ | អ្នកលក់ខោអាវ | មិនបានបញ្ជាក់ | ផ្ទាល់ខ្លួន | ចាស |

158 គ្រួសារនោះបានបង់សងរួចហើយនូវការប្រាក់មុនមួយឆ្នាំ។

## ឧទសម្ព័ន្ធ ២. គន្ធនិទ្ទេស

Afonso, J. S., Morvant-Roux, S., Guérin, I., and Forcella, D. (2016) ‘Doing good by doing well? Microfinance, self-regulation and borrowers’ over-indebtedness in the Dominican Republic’, *Journal of International Development* (29), p919–935. DOI: 10.1002/jid.3244.

Asian Development Bank. (2020). *Updated Assessment of the Potential Economic Impact of COVID-19* [Online]. Available at: https://www.adb.org/publications/updated-assessment-economic-impact-covid-19 (Accessed: 20 June 2020).

Bateman, M. (2019) ‘The next Domino to Fall?’ in Bateman, M., Blankenburg, S., and Kozul-Wright, R. (ed.) *The Rise and Fall of Global Microcredit.* London: Routledge, pp.166-193.

Bylander, M. (2020) ‘Destination Debts: Local and Translocal Loans in the Migrant Experience’, *Geoforum,* article in press. DOI: 10.1016/j.geoforum.2020.06.015.

Bylander, M., and Res, P. (2020) ‘“If You Fall, Stand Up Again”: The Moral Nature of Financial Literacy in the Global South’, *Development & Change*, 52(1), p26–53. DOI: 10.1111/dech.12627.

Bylander, M. (2019) ‘Is Regular Migration Safer Migration? Insights from Thailand’, Journal on *Migration and Human Security*, 7(1), p1-18. DOI: 10.1177/2331502418821855.

Bylander, M. (2017) ‘Micro saturated: The promises and pitfalls of microcredit as a development solution’ in Brickell, K., and Springer, S. (ed.) *The handbook of contemporary Cambodia*. Abingdon: Routledge, pp.64-75.

Bylander, M. (2015a) ‘Credit as coping: Rethinking microcredit in the Cambodian context’, *Oxford Development Studies*, 43 (4), p533–553. DOI: 10.1080/13600818.2015.1064880.

Bylander, M. (2015b) ‘Depending on the sky: Environmental distress, migration and coping in rural Cambodia’, *International Migration*, 53(5), p135–147. DOI: 10.1111/imig.12087.

Bylander, M. (2014) ‘Borrowing across borders: Migration and microcredit in rural Cambodia’, *Development and Change*, 45(2), p284–307. DOI: /10.1111/dech.12080.

Center for Financial Inclusion. (2019). *Land seizures and reported abuses in Cambodia: CFI responds*. [Online]. Available at: https://www.centerforfinancialinclusion.org/land-seizures-and-reported-abuses-in-cambodia-the-center-for-financial-inclusion-responds (Accessed 15 January 2021).

CGAP. (2020). *Microfinance and COVID-19: Principles for regulator response. Insights for Inclusive Finance* [Online]. Available at: https://www.cgap.org/research/covid-19-briefing/microfinance-and-covid-19-principles-regulatory-response (Accessed: 20 December 2020).

CMA. (2014). *Annual Report* [Online]. Available at: https://cma-network.org/about-us/annual-report/ (Accessed: 20 June 2020).

Davel, G. (2013). *Regulatory Options to Curb Debt Stress*. Focus Note 83. Washington, D.C.: CGAP.

Dickson, B., and Koenig, A. (2016). *Assessment report: profile of returned Cambodian migrant workers. International Organization for Migration* [Online]. Phnom Penh: International Organization for Migration Available at: https://iomx.iom.int/resources/human-trafficking-general/reports/assessment-report-profile-returned-cambodian-migrant (Accessed: 20 December 2020).

Economist Intelligence Unit. (2019). *Global Microscope 2019: the enabling environment for financial inclusion* [Online]. New York: NY. Available at: https://www.centerforfinancialinclusion.org/global-microscope-2019 (Accessed: 20 February 2021).

Evers, S. (2019). *Promoting responsible lending in Cambodia* [Online]. Available at: https://triplejump.eu/2019/08/29/promoting-responsible-lending-cambodia/ (Accessed: 20 February 2021).

Froelich, M., Kemper, N. Poppe, R., Breda, V., and Richter, P. (2015) 'Microfinance and Risk Management: Impact Evaluation of a Financial Education Programme, AMK Cambodia, Microfinance for Work', *Working paper*, (68). Geneva: ILO.

Gonzalez, A. and Javoy, E. (2011). *Microfinance and the role of policies and procedures in saturated markets and during periods of fast growth* [Online]. Available at: https://www.findevgateway.org/paper/2011/09/microfinance-and-role-policies-and-procedures-saturated-markets-and-during-periods (Accessed 26 June 2020).

Gonzalez, A. (2010). *Is Microfinance Growing Too Fast?* Washington, DC: Microfinance Information Exchange.

Green, W. N, and Bylander M. (Forthcoming) 'The Exclusionary Power of Microfinance: Over-indebtedness and Land Dispossession in Cambodia', *Sociology of Development* forthcoming.

Green, W. N. (2019) 'From Rice Fields to Financial Assets: Valuing Land for Microfinance in Cambodia', Royal Geographical Society, 44(4), p749-762. DOI: 10.1111/tran.12310.

Green, W. N. (2020) 'Financial landscapes of agrarian change in Cambodia', *Geoforum.* Article in Press. DOI:10.1016/j.geoforum.2020.02.001.

Green, W. N, and Estes, J. (2018) 'Precarious Debt: Microfinance Subjects and Intergenerational Dependency in Cambodia', *Antipode*, 51(1), p129–147. DOI: 10.1111/anti.12413.

Human Rights Watch. (2020). *World Bank: investigate Cambodia's micro-loans on coerced land sales linked to predatory lending* [Online]. Available at: https://www.hrw.org/news/2020/12/14/world-bank-investigate-cambodias-micro-loans# (Accessed: 20 January 2021).

Human Rights Watch. (2015). *'Work fast or get out' Labour Rights Abuses in Cambodia's Garment Industry* [Online]. Available at: https://www.hrw.org/reports/cambodia0315_brochure_web.pdf (Accessed: 20 January 2021).

ILO. (2015). *Enhancing the Impact of Microfinance: Evidence from an Action Research Programme* [Online]. ILO: Geneva. Available at: www.ilo.org/wcmsp5/groups/public/---ed_emp/--- emp_ent/documents/publication/wcms_344847.pdf (Accessed: 20 June 2020).

IndustriAll Global Union. (2020). *Cambodian garment workers need supports from brands* [Online]. Available at: http://www.industriall-union.org/cambodian-garment-workers-need-support-from-brands (Accessed: 15 November 2020).

International Monetary Fund. (2012, 2020). *World Economic Outlook reports* [Online]. Available at: https://www.imf.org/en/Publications/WEO#:~:text=The%20global%20economy%20is%20projected%20to%20grow%20at%203.5%20percent,point%20below%20last%20October's%20projections (Accessed: 30 January 2021).

Incofin. (2018). *Incofin spearheads pioneering self-regulatory initiative to prevent over-indebtedness in Cambodia* [Online]. Available at: http://www.incofin.com/incofin-spearheads-pioneering-self-regulatory-initiative-to-prevent-over-indebtedness-in-cambodia/ (Accessed: 5 February 2021).

IOM & UNFPA. (2020). *Rapid Assessment of Social and Health Impact of Covid-19 on Returning Migrant Workers in Cambodia* [Online]. Available at: https://cambodia.unfpa.org/sites/default/files/pub-pdf/irl_kh_final_report_rmw_rapid_assessment2020_0.pdf (Accessed: 20 January 2021).

IOM. (2019). *Debt and the Migrant Experience: Insights from Southeast Asia. Bangkok*: International Organization for Migration.

Ir Por, BJ., Asante, AD., Liverani, M., Jan, S., Chhim, S., and Wiseman, V. (2019) 'Exploring the determinants of distress health financing in Cambodia', *Health Policy and Planning* (34), pi26-i37. Doi:10.1093/heapol/czz006.

Kaiser, T., and Menkhoff, L. (2017) 'Does Financial Education Impact Financial Literacy and Financial Behavior, and if so, When?', *Discussion Paper* (1562). Berlin: German Institute for Economic Research.

Karim, L. (2011). *Microfinance and its discontents: women in debt in Bangladesh*. Minnesota: The University of Minnesota Press.

Krauss, A., Lontzek, L., Meyer, J., and Frommelt, M. (2012). *Lack of access or crowded markets? Toward a better understanding of microfinance market penetration*. Available at: https://www.findevgateway.org/paper/2012/08/lack-access-or-crowded-markets-towards-better-understanding-microfinance-market (Accessed: 26 March 2021).

LICADHO. (2020). *Driven out: One village's experience with MFIs and Cross-border migration*. Available at: https://www.licadho-cambodia.org/reports.php?perm=229 (Accessed: 26 March 2021).

LICADHO, and Sahmakum Teang Tnaut. (2019). *Collateral Damage: Land loss and abuses in Cambodia's microfinance sector.* Available at: https://www.licadho-cambodia.org/reports.php?perm=228 (Accessed: 26 March 2021).

Liv, D. (2013). *Study of the drivers of over-indebtedness of microfinance borrowers in Cambodia. An in-depth investigation of saturated areas* [Online]. Available at: https://www.accessdev.org/wp-content/uploads/2017/07/1037-1006-FILE. pdf (Accessed: 20 June 2020).

Ly, T. (2020) 'Bankruptcy Law: role, inefficiencies and social drama', *Phnom Penh Post*, 25 May [Online]. Available at: https://www.phnompenhpost.com/opinion/bankruptcy-law-role-inefficiencies-and-social-drama (Accessed: 8 March 2021).

Mader, P. (2015). *The political economy of microfinance: financialising poverty*. Hampshire: Palgrave Macmillan.

MFC, and Good Return. (2017). *Over-indebtedness Study Cambodia II: Final Report*. Phnom Penh: Microfinance Center and Good Return (unpublished).

MIMOSA. 2020. *Cambodia country report* [Online]. Available at Mimosaindex.org (Accessed: 10 March 2021).

Miller, M., Reichelstein, J., Salas, C., Zia, B. (2014) 'Can You Help Someone Become Financially Capable? A Meta-analysis of the Literature', *Oxford University Press on behalf of the World Bank* [Online]. Available at: https://openknowledge.worldbank.org/handle/10986/26000 (Accessed: 27 March 2021).

Ministry of Labour and Vocational Trainings. (2020). *Announcement section* [Online]. Available at: http://www.mlvt.gov.kh/index.php?option=com_k2&view=itemlist&layout=category&task=category&id=52&Itemid=214&lang=en (Accessed: 20 December 2020).

Mom, K. (2020) 'Number of migrant workers sent abroad drops by 80 percent', *Khmer Times*, 20 February [Online]. Available at: https://www.khmertimeskh.com/50692896/number-of-migrant-workers-sent-abroad-drops-by-80-percent/ (Accessed: 20 December 2020).

Natarajan, N., Parsons, L., and Brickell, K. (2019) 'Debt-Bonded Brick Kiln Workers and Their Intent to Return: Towards a Labour Geography of Smallholder Farming Persistence in Cambodia', *Antipode* 51(5), p1581-1599. DOI: 10.1111/anti.12564.

NBC. (2009). *2009 Annual Report* [Online]. Available at: https://www.nbc.org.kh/download_files/publication/annual_rep_eng/Annual%20Report%202009%20Eng.pdf (Accessed: 26 March 2021).

NBC. (2018). *2018* Annual Report [Online]. Available at: https://www.nbc.org.kh/download_files/publication/annual_rep_kh/annual_report_2018_kh.pdf (Accessed: 26 March 2021).

NBC. (2020). *Semi Annual Report* [Online]. Available at: https://www.nbc.org.kh/download_files/publication/annual_rep_kh/Semi%20Annual%20Report%202020%20KH.pdf (Accessed: 26 March 2021).

NBC. (2016). *Financial sector development strategy 2016-2025* [Online]. Available at: https://www.nbc.org.kh/download_files/publication/blueprints_eng/Financial-Sector-Development-Strategy-2016-2025-English.pdf (Accessed: 20 December 2020).

Nov, S. (2020) 'Nine working groups to keep tabs on Siem Reap 38-road project', *Phnom Penh Post*, 15 December [Online]. Available at: https://www.phnompenhpost.com/national/nine-working-groups-keep-tabs-siem-reap-38-road-project (Accessed: 27 March 2021).

OECD/Cambodia Development Resource Institute. (2017). *Interrelations between Public Policies, Migration and Development in Cambodia*. OECD Development Pathways. Paris: OECD.

Ovesen, J., and Trankell, I-B. (2014) 'Symbiosis of Microcredit and Private Moneylending in Cambodia', *The Asia Pacific Journal of Anthropology*, 15(2), p178–96. DOI: 10.1080/14442213.2014.894116.

Oxfam. (2019). *Social protection for most marginalized informal workers. Oxfam* [Online]. Available at: https://cambodia.oxfam.org/latest/policy-paper/garment-worker-groups (Accessed: 27 March 2021).

Pimhidzai, O., Tong, K., Anantavrasilpa, R., Popovic, A., Mel, S., Sanchez M., Miguel E. (2019). *Microfinance and Household Welfare. Cambodia policy note*. Washington, D.C.: World Bank Group.

Rakin. K N. (2002), 'Social capital, microfinance, and the politics of development', *Feminist Economics*, 8(1), p1-24. Doi:10.1080/13545700210125167.

Rozas, D. (2020). *Can Self-regulation protect microfinance clients?* [Online]. Available at: https://www.cgap.org/blog/can-self-regulation-protect-microfinance-clients (Accessed: 27 March 2021).

Rhyne, E. (2020) 'Consumer Protection and Borrower Risks as Economies Reopen', *CGAP* [Online]. Available at: https://www.cgap.org/research/covid-19-briefing/consumer-protection-and-covid-19-borrower-risks-economies-reopen (Accessed: 27 March 2021).

Seng, Kimty. (2018) 'Revisiting Microcredit's Poverty-Reducing Promise: Evidence from Cambodia: Microcredit's Poverty-Reducing Promise', *Journal of International Development*, 30(4), p615-642. DOI: 10.1002/jid.3336.

SoK, C. (2020) 'Kingdom's garment-related exports down by 9 percent from January to October', *Khmer Times*, 16 December [Online]. Available at: https://www.khmertimeskh.com/50793527/kingdoms-garment-related-exports-down-9-percent-january-to-october/?p=793527 (Accessed: 27 March 2021).

Sok, C. (2020) 'Banks and FI loan restructuring extended to until mid-2021', *Khmer Times*, 23 November [Online]. Available at: https://www.khmertimeskh.com/50785076/banks-and-fi-loan-restructuring-extended-until-mid-2021/ (Accessed: 27 March 2021).

The Asia Foundation. (2020) 'Enduring the pandemic: rapid survey in the impact of COVID-19 on MSMES in the tourism sector and households in Cambodia', *The Asia Foundation* [Online]. Available at: https://asiafoundation.org/wp-content/uploads/2021/01/Cambodia_Enduring-the-Pandemic_RAPID-SURVEY-ON-THE-IMPACT-OF-COVID-19-ON-MSMES-IN-THE-TOURISM-SECTOR-AND-HOUSEHOLDS-IN-CAMBODIA_EN.pdf (Accessed: 27 March 2021).

White, H. (2020) 'MFIs call on NBC to extend loan restructuring into next year', *Khmer Times*, 20 November [Online]. Available at: https://www.khmertimeskh.com/50784701/mfis-call-on-nbc-to-extend-loan-restructuring-into-next-year/.

World Bank. (2020) 'Cambodia Economic Update: Cambodia in the Time of COVID-19- Special Focus: Teacher Accountability and Student Learning Outcomes' *World Bank* [Online]. Available at: http://documents1.worldbank.org/curated/en/165091590723843418/pdf/Cambodia-Economic-Update-Cambodia-in-the-Time-of-COVID-19-Special-Focus-Teacher-Accountability-and-Student-Learning-Outcomes.pdf (Accessed: 27 March 2021).

World Health Organization. (2020). The first 100 days of the COVID-19 response: past investments in health security system pay off, and learning lessons for future. *World Health Organization* [Online]. Available at: https://www.who.int/cambodia/news/feature-stories/detail/the-first-100-days-of-the-covid-19-response-past-investments-in-health-security-system-pay-off-and-learning-lessons-for-the-future?fbclid=IwAR0R30FmRNVk6YF6EIxYVzGab6BqDoFKRaapJYMzzfhEAwA4Ev9T6J0nUfo (Accessed: 27 March 2021).

៣៦ ពន្លឺបញ្ញាគោលនយោបាយ

Australian Aid

PONLOK CHOMNES

The Asia Foundation